រៀបរៀងដោយ ជួរ គារី

# ការតែងនិពន្ធ

## Writing Skills













.........ប្រលោមលោក

...........ប្រវត្តិសាស្ត្រ

.....អក្សរសាស្ត្រ

...កំរងលិខិត

.....ឯកសារ

បណ្ណាគារ អង្គរ

រៀបរៀងដោយ ជួរ គារី

# ការតែងនិពន្ធ
# Writing Skills

បោះពុម្ពផ្សាយ
ដោយ បណ្ណាគារ អង្គរ
២០០៦

# ការតែងនិពន្ធ
# Writing Skills

រៀបរៀងដោយ ជួរ គារី

រក្សាសិទ្ធិ

**បណ្ណាគារ អង្គរ**

ISBN-10 : 99950-59-35-5
ISBN-13 : 978-99950-59-35-4

**2006**

# មាតិកា


| ចំណងជើង | ទំព័រ |
|---|---|
| មាតិកា | ក |
| អារម្ភកថា | ង |
| ការតែងនិពន្ធ | ១ |
| សេចក្ដីផ្ដើម | ១ |
| ១-ការនិយាយស្ដី | ២ |
| ២-ការសរសេរលិខិត | ២ |
| ៣-ការសរសេរលិខិតរដ្ឋបាលផ្សេងៗ | ៣ |
| ៤-ការសរសេរអត្ថបទខ្លី ឬ វែង | ៣ |
| I-របៀបសរសេរអត្ថបទផ្សេងៗ | ៤ |
| ១-កំណត់ហេតុ | ៤ |
| ២-របាយការណ៍ | ៨ |
| ៣-សុន្ទរកថា | ១១ |
| ៤-អារម្ភកថា | ១៤ |
| ៥-និវេទនកថា | ១៦ |
| ៦-អំពីញត្តិ | ១៧ |

៧-អំពីអត្ថបទស៊ីជម្រៅ ១៩
៧.១-វិចារណកថា ១៩
៧.២-បរិយាយថ្ងៃនេះ ២១
៧.៣-ទស្សនៈឡប់ៗ ២១
៧.៤-យោបល់អាចារ្យធំ ២២
៧.៥-ទស្សនៈចៅតាខ្វែក ២២
៧.៦-ទស្សនៈអាឡេវ ២២
៧.៧-អត្ថាធិប្បាយថ្ងៃនេះ ២៣
K ការបង្កើតទស្សនៈ ២៥
K អំពីគោលដៅ ២៦
K គំនិតផ្តួចផ្តើមគម្រោងសរសេរ ២៨
K ផ្ទៀងផ្ទាត់ឡើងវិញ ២៩
៨-សង្កថា ៣២
៩-បាឋកថា ៣២
១០-ចំណាប់អារម្មណ៍ ៣៣
១១-វិយោគកថា ៣៤
II-អំពីការនិពន្ធរឿង ៣៥

១-អ្វីទៅការនិពន្ធ ? ៣៥
២-គោលបំណងអ្នកនិពន្ធ ៣៦
៣-មធ្យោបាយដើម្បីក្លាយជាអ្នកនិពន្ធ ៣៧
៤-គំនិតសំខាន់ៗដើម្បីសរសេររឿង ៤០
៥-របៀបខ្លះៗនៅពេលតាក់តែងរឿង ៤១
III-ការនិពន្ធរឿងប្រលោមលោក ៤២
១-និយមន័យប្រលោមលោក ៤២
២-ទិដ្ឋភាពសំខាន់ៗដែលត្រូវមាននៅក្នុងប្រលោមលោក ៤៤
២.១-អត្ថន័យ (ទិដ្ឋភាពបញ្ហារឿង) ៤៤
២.២-អត្ថរូប ៤៦
២.៣-អត្ថរស ៤៨
៣-ការណែនាំខ្លះៗដើម្បីតែងរឿងប្រលោមលោក ៤៩
៣.១-ការរំលេចផ្ទៃរឿងឱ្យមានសោភ័ណភាព ៤៩
៣.២-ការលាក់សាច់រឿង ៤៩
៣.៣-ការកំណត់ចរិតតួ ៥១
៣.៤-ចង្វាក់ ៥២
៣.៥-បរិយាការណ៍ ៥៣

៤-ប្រភេទរឿងខ្លី ៥៥ ៤.១-
រឿងប្រលោមលោកមាន៣ខ្នាត ៥៤ ៤.២-
វិធីសរសេររឿងខ្លី ៥៥ ៤.៣-
ការកំណត់ប្រធានបទ ៥៨
IV-អំពីការសរសេរសំបុត្រ និងលិខិតផ្សេងៗ ៦០ ១-
របៀបសរសេរសំបុត្រផ្ទាល់ខ្លួន ៦០
២-សេចក្ដីណែនាំខ្លះៗ ៦៤
៣-លិខិតមានទម្រង់ផ្ទាល់ខ្លួនដែលបម្រើក្នុងអង្គភាពរដ្ឋបាល ៦៦ ៤-
អំពីលិខិតរដ្ឋបាល ៧០ ៥-
ដីកាបញ្ជូន ៧៩
ឧបសម្ព័ន្ធទី១ ៨១
ឧបសម្ព័ន្ធទី២ ១០១
ឧបសម្ព័ន្ធទី៣ ១១៥
ឧបសម្ព័ន្ធទី៤ ១២១
ឧបសម្ព័ន្ធទី៥ ១៤៣
ឧបសម្ព័ន្ធទី៦ ១៥៥
សុភាសិតបារាំង ១៦៥
ឯកសារពិគ្រោះ ១៦៦

# អារម្ភកថា

ការនិពន្ធរឿងប្រលោមលោកក្តី ឬ ការនិពន្ធជាអត្ថបទផ្សេងៗក្តី ក៏ត្រូវមានក្បួនខ្នាត មានរបៀបរបបសរសេរឱ្យបានត្រឹមត្រូវទាំងអស់ ទោះបីជាអ្នកសរសេរម្នាក់ៗមានគំនិតផ្សេងគ្នា ដោយមិនអាចចាប់បង្ខំថា ត្រូវសរសេរយ៉ាងនេះ ឬយ៉ាងនោះក៏ដោយ ក៏ទម្រង់នៃការសរសេរអត្ថបទនីមួយៗ ត្រូវមានក្រឹត្យក្រម បែបផែនដោយឡែកៗពីគ្នាដែរ។

សៀវភៅដែលលោកអ្នកកំពុងតែអាននេះ គឺស្នាដៃមួយដែលអ្នករៀបរៀងខិតខំសិក្សាស្រាវជ្រាវប្រមែប្រមូលស្នាដៃរៀមច្បងជំនាន់មុន ផ្សំនឹងចំណេះដឹងដែលធ្លាប់បានសិក្សាកន្លងមក រួមជាមួយនឹងបទពិសោធន៍ដ៏ស្តួចស្តើងដែលមាន មកចងក្រងបានជា **"ការតែងនិពន្ធ"** នេះ។ ការណ៍ដែលយើងខិតខំចងក្រងសៀវភៅនេះឱ្យលេចចេញជារូបរាង ក៏ព្រោះតែមើលឃើញពីការលំបាករបស់សិស្ស និស្សិត និងអ្នកសិក្សារបស់យើងមួយចំនួនខ្វះខាតនូវឯកសារស្តីពីរបៀបនិពន្ធនេះ។ អ្នកខ្លះចង់សិក្សាស្រាវជ្រាវពីមុខវិជ្ជានេះ មិនដឹងទៅសិក្សាស្រាវជ្រាវនៅឯណា ? ពីព្រោះឯកសាររបស់រៀមច្បងយើងដែលមានពីមុនៗ បានបាត់បង់ស្ទើរតែអស់ទៅហើយ ធ្វើឱ្យ

អ្នកសិក្សាជួបការលំបាកក្នុងការសិក្សាស្រាវជ្រាវ។ មើលឃើញពីកង្វះខាតនេះ ខ្ញុំបានទៅសមាគមអ្នកនិពន្ធខ្មែរស្វែងរកជួបនឹងរៀមច្បងរបស់យើងម្នាក់ គឺលោក **យូ បូ** ដើម្បីរកឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងការនិពន្ធ មកបំពេញបន្ថែមក្នុងការរៀបរៀងនេះ។ លោក **យូ បូ** ថាលោកគ្មានឯកសារចងក្រងទេ ពីព្រោះឯកសារពីជំនាន់មុនបានបាត់បង់អស់ទៅហើយ មាននៅតែក្នុងខ្លួន ក្នុងខួរក្បាលរបស់លោកទេ ប្រសិនបើជារូបខ្ញុំចង់បានឯកសារទាំងនេះ ទាល់តែខ្ញុំចំណាយពេលមកអង្គុយស្តាប់លោកបង្រៀនរាល់៧ល្ងាច(រយៈពេល១ម៉ោងកន្លះ)ជាមួយសិក្ខាកាមដែលរូបលោកកំពុងតែបង្រៀន។ ដើម្បីបានចំណេះមកបំពេញក្នុងការរៀបរៀងរបស់ខ្លួន ខ្ញុំក៏បានចំណាយពេលជិត ៣ខែ (គឺចាប់ពីពាក់កណ្តាលខែមីនា រហូតដល់ចុងខែឧសភា ឆ្នាំ២០០៦) មកសិក្សាបន្ថែមក្រោមការបង្ហាត់បង្រៀនរបស់រៀមច្បង **យូ បូ** តែម្តងទៅ។ (ក្នុងរយៈពេលសិក្សានោះ យើងបានជួបអ្នកស្រី **ម៉ៅ សំ ណាង** និងអ្នកស្រី **ពាន់ ភួងបុប្ផា** មួយពេលម្នាក់ដែរ ដែលខាងសមាគមអ្នកនិពន្ធខ្មែរអញ្ជើញមក ដើម្បីឱ្យអ្នកស្រីយកបទពិសោធន៍ដែលអ្នកស្រីមានបង្ហាញជូនសិក្ខាកាម)។

ក្រោយពេលសិក្សាចប់ពីសមាគមអ្នកនិពន្ធខ្មែរភ្លាម រូបខ្ញុំចាប់ផ្តើមរៀបរៀងវាយបញ្ចូលក្នុងកុំព្យូទ័រ ជាមួយអត្ថបទដែលមានស្រាប់បានជាង ១០០ទំព័រក្នុងរយៈពេលដ៏ខ្លី ដើម្បីបម្រើតម្រូវការរបស់មិត្តអ្នកសិក្សា។ នៅពេលចងក្រងរួចភ្លាម ខ្ញុំក៏យកអត្ថបទនេះទៅជួបលោក យូ បូ ដែលជាគ្រូដើម ដើម្បីឱ្យលោកជួយពិនិត្យ កែសម្រួលពាក្យពេចន៍ឃ្លាឃ្លោង និងបន្ថែមបន្ថយសេចក្តីដែលខ្វះខាតឱ្យបានសព្វគ្រប់។

ការរៀបរៀងនៅក្នុងសៀវភៅនេះ មានចែកជា៤ ផ្នែកធំៗ។ នៅក្នុងផ្នែកទី១ រៀបរាប់បង្ហាញពីរបៀបសរសេរមានដូចជា កំណត់ហេតុ , របាយការណ៍, សុន្ទរកថា, អារម្ភកថា, វិចារណកថា, សង្កថា, បាឋកថា, និងចំណាប់អារម្មណ៍ ជាដើម ដោយលើកយកម្តងមួយៗមកបង្ហាញពីរបៀបសរសេរ តើត្រូវសរសេរយ៉ាងដូចម្តេច សរសេរបែបណាខ្លះ ? គឺយើងមានបង្ហាញជូនពីពេលវេលាប្រើប្រាស់ និងរបៀបសរសេរនៃអត្ថបទនីមួយៗ។

ផ្នែកទី២ និងទី៣ បង្ហាញពីការបង្កើតគំនិតដើម្បីសរសេររឿងប្រលោមលោកដោយមានវិធីតែង និងបែបបទនៃការតែងជាដើម។

នៅផ្នែកទី៤ និយាយអំពីសំបុត្រ និងលិខិតផ្សេងៗ ដែលបង្ហាញ

អំពីការសរសេរសំបុត្រផ្ទាល់ខ្លួនពីកូនផ្ញើទៅឪពុកម្តាយ និងពីឪពុកម្តាយផ្ញើទៅឱ្យកូន។ បង្ហាញពីរបៀបសរសេរលិខិតមានទម្រង់ផ្ទាល់ខ្លួន (លិខិតរបស់សាមីជន ដែលជាអ្នករាជការ) និងលិខិតរដ្ឋបាលមួយចំនួន ដើម្បីឱ្យអ្នកសិក្សាបានយល់ដឹងពីរបៀបរបបប្រើប្រាស់ និងសរសេរលិខិត ដែលមានទាក់ទងនឹងអង្គភាពរដ្ឋយ៉ាងដូចម្តេច ? ទាក់ទងជាមួយនឹងឪពុកម្តាយរបស់ខ្លួនយ៉ាងដូចម្តេច? ។ ជាទូទៅរាល់លិខិតស្នាមផ្សេងៗ មានទាំងកំណត់ហេតុជាដើម គេមិនចាត់ចូលទៅក្នុងការតែងនិពន្ធទេ ព្រោះរាល់លិខិតស្នាមនានា វាមានគំរូស្រាប់តាមទម្រង់ដោយឡែកៗរបស់វា។ ការណ៍ដែលអ្នករៀបរៀងលើកយកមកបង្ហាញនាពេលនេះ ព្រោះយល់ថា រាល់ការសរសេរលិខិតស្នាមទាំងអស់ អ្នកសរសេរក៏ត្រូវចេះតាក់តែងឃ្លាឃ្លោងឱ្យបានត្រឹមត្រូវ ស្វះស្វែងរកពាក្យពេចន៍មកផ្សំផ្សំឱ្យបានពីរោះ ហើយគួរសម សមស្របទៅតាម តួនាទី ឋានៈ ពេលវេលា និងកាលៈទេសៈនោះម្យ៉ាង ហើយម្យ៉ាងវិញទៀតក៏ដើម្បីជាចំណេះដឹងបន្ថែមដល់មិត្តអ្នកអានផងដែរ។

ចំណែកឯនៅផ្នែកបន្ទាប់នៃអត្ថបទទាំងនេះ យើងមានបន្ថែមនូវឧបសម្ព័ន្ធខ្លះៗ ដែលទាក់ទងជាមួយនឹងអត្ថបទខាងលើ ដើម្បីធ្វើជាគំរូ ឬ

ជាឧទាហរណ៍ដើម្បីងាយស្រួលដល់មិត្តអ្នកអានក្នុងការសិក្សា។

អ្នករៀបរៀងសង្ឃឹមថា សៀវភៅនេះអាចជាចំណែកដ៏តូចមួយ ដែលអាចជួយដល់មិត្តអ្នកសិក្សាទាំងឡាយ ស្វែងយល់ពីរបៀបសរសេរអត្ថបទមួយចំនួនបានល្អប្រសើរ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏យល់ថា សៀវភៅនេះពិតជានៅមានចំណុចខ្វះខាតច្រើនទៀត ដែលត្រូវបំពេញនិងកែតម្រូវ។

ដូច្នេះ ស្នើសុំឱ្យរៀមច្បង និងប្រិយមិត្តអ្នកអាន អ្នកសិក្សា មេត្តាជួយរិះគន់កែលម្អឱ្យបានច្រើនជាទីបំផុត ដើម្បីយើងខ្ញុំនឹងធ្វើការកែលម្អឈានទៅរកសេចក្តីរីកចម្រើនជាបន្តទៀត សម្រាប់ការសិក្សារបស់ខ្លួនយើង និងកូនចៅយើងទាំងអស់គ្នាទៅថ្ងៃក្រោយឱ្យកាន់តែល្អប្រសើរ និងកាន់តែសុក្រឹតជាងពេលនេះ។

អ្នករៀបរៀង

ជួរ គារី

ទូរស័ព្ទ ៖ ០១១ ២៥២១៦១

" យើងគ្រប់គ្នាគួរតែចេះសរសេរ ចេះប្រមូលចងក្រងនូវរឿងរ៉ាវផ្សេងៗដែលខ្លួនបានដឹងនិងចេះចាំដើម្បីទុកជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយបានសិក្សានិងស្រាវជ្រាវបន្ត ។ ប្រសិនបើយើងមិននាំគ្នាសរសេរ និងចងក្រងទេ នោះកូនចៅរបស់យើងជំនាន់ក្រោយពិតជាគ្មានអ្វីសិក្សាស្រាវជ្រាវហើយគ្មាន គំនិតតុបតែងបន្តឱ្យបានល្អខ្ពង់ខ្ពស់ជាង យើងទេ" ។

# ការតែងនិពន្ធ

(Writing skills)

**សេចក្តីផ្តើម :**

នៅក្នុងជីវភាពរស់នៅរបស់មនុស្ស តែងតែមានការទាក់ទងគ្នាទៅវិញទៅមកជាប្រចាំ។ ដើមឡើយ រាល់ការប្រាស្រ័យទាក់ទងគ្នា ស្តែងឡើងតាមរយៈការនិយាយស្តី, ការនិយាយរឿងនិទាន និងរឿងព្រេងជាដើម។ លុះមកដល់សម័យកាលក្រោយមក មានការសរសេរសំបុត្រឆ្លងឆ្លើយ, តាមរយៈការសរសេរជាសេចក្តីនានានៅក្នុងលិខិតរដ្ឋបាលផ្សេងៗច្រើនអនេក។ម្យ៉ាងទៀតក្រៅពីការទាក់ទងគ្នាតាមរយៈវិធីខាងលើ គេនៅមានធ្វើការកត់ត្រានូវរឿងរ៉ាវផ្សេងៗ ដូចជារឿងរ៉ាវប្រវត្តិសាស្ត្រ, និពន្ធប្រលោមលោក...។ល។ ចំពោះសិស្ស-និស្សិត ពួកគេសរសេរជាកំណាព្យ តែងសេចក្តី ជាដើម។

អ្វីៗដែលបានរៀបរាប់មកនេះ សុទ្ធតែមានរបៀបសរសេរទៅតាមបែបបទរបស់វាផ្សេងៗគ្នា ដែលយើងគួរតែចេះពីរបៀបទាំងនេះ។

## ១-ការនិយាយស្ដី :

នៅក្នុងសង្គមយើង មានរបៀបនិយាយច្រើនបែបច្រើនយ៉ាងដូចជារបៀបនិយាយជាមួយនឹងមនុស្សចាស់, មនុស្សក្មេង, មនុស្សប្រុស-ស្រី, ជាមួយនឹងមន្ត្រីតូច-ធំ, ព្រះសង្ឃ, រាជវង្សានុវង្ស, ព្រះមហាក្សត្រ, លោកគ្រូ-អ្នកគ្រូ... ។ល។ សុទ្ធតែមានរបៀបរបបនិយាយផ្សេងៗពីគ្នាទៅតាម វ័យ ឋានៈ ភេទ ឬតាមខ្សែស្រឡាយ ញាតិ ទាបខ្ពស់ ឆ្ងាយជិត ដូចជាពូមាមីង អ៊ំ តា យាយ ក្មួយជាដើម។ រាល់ការនិយាយ មនុស្សម្នាក់ៗក៏ត្រូវចេះរៀបឃ្លារៀបប្រយោគឱ្យបានត្រឹមត្រូវ ដូចដែលចាស់ៗតែងពោលថា " *ដើរឱ្យមានបី ស្រដីឱ្យមានក្បួន* "[១] "*និយាយឱ្យស្គាល់ចាស់ស្គាល់ទុំ* ", ឬ " *និយាយមានវគ្គមានស្នើ* "...។

## ២-ការសរសេរលិខិត :

នៅពេលយើងធ្វើដំណើរទៅឆ្ងាយពីក្រុមគ្រួសារ មានរយៈពេលយូរ ឬឆាប់ ដើម្បីឱ្យគ្រួសារបានដឹងពីដំណឹងរបស់យើង យើងត្រូវសរសេរសំបុត្រឆ្លើយឆ្លងគ្នា ដើម្បីបានដឹងសុខទុក្ខគ្នាទៅវិញទៅមក។ គេអាចសរសេរផ្ញើទៅឪពុក-ម្ដាយ បងប្អូន មិត្ត ភក្តិ មីងមា គូសង្សារជាដើម។ រាល់ការសរសេរលិខិតនេះក៏

[១] អ្នកខ្លះនិយាយថា " ដើរឱ្យមានបី ស្រដីឱ្យមានបួន " ។

តម្រូវឱ្យយើងចេះពីរបៀបសរសេរដែរ។ ថ្វីបើបច្ចុប្បន្ននេះ វិទ្យាសាស្ត្រជឿនលឿនមានប្រើរហូតដល់ ទូរស័ព្ទ ទូរសារ ហ្វាក់ អ៊ីមែល អ៊ិនធើណែត ដើម្បីទាក់ទងគ្នាជាដើមក្តី ក៏យើងត្រូវតែចេះសរសេរលិខិតដែរ។

**៣-ការសរសេរលិខិតរដ្ឋបាលផ្សេងៗ :**

នៅក្នុងអង្គភាព ក្រសួង មន្ទីរនីមួយៗ សុទ្ធតែត្រូវការប្រើប្រាស់លិខិតរដ្ឋបាលផ្សេងៗ មានច្រើនបែបច្រើនសណ្ឋានរាប់មិនអស់។ រាល់សេចក្តីនៅក្នុងលិខិតនីមួយៗ មានបែបបទខុសៗគ្នាទៅតាមប្រភេទនៃលិខិត ថ្វីដ្បិតតែរាល់លិខិតរដ្ឋបាលទាំងនោះ មានបែបបទគំរូឯកភាពគ្នានូវចំណុចខ្លះក៏ដោយ ក៏ត្រូវតែទាមទារឱ្យចេះពីការរៀបរៀង តាក់តែងសេចក្តី ពាក្យពេចន៍ ឃ្លោងឃ្លាប្រយោគឱ្យបានត្រឹមត្រូវ សមស្របតាម ពេលវេលាក្នុងការប្រើប្រាស់លិខិតនោះដែរ។

**៤-ការសរសេរអត្ថបទខ្លី ឬ វែង :**

ការសរសេរអត្ថបទទាំងឡាយ ដូចជាសរសេរ វិចារណកថា, អារម្ភកថា, សុន្ទរកថា, រឿងរ៉ាវប្រវត្តិសាស្ត្រ, ប្រលោមលោក ជាដើម ក៏ត្រូវមានរបៀបមានវិធីក្នុងការសរសេរ ផ្សេងៗគ្នាដែរ។

សរុបមក រាល់ពាក្យសម្ដី ការសរសេរ រៀបរៀងពាក្យពេចន៍ ឃ្លោងឃ្លា ប្រយោគត្រឹមត្រូវឱ្យគេឯងស្ដាប់បាន យល់បាននេះហើយ ដែលយើងហៅថា ការចេះ និពន្ធ នោះ។

## I- របៀបសរសេរអត្ថបទផ្សេងៗ :

### ១-កំណត់ហេតុ[២] :

កំណត់ហេតុជាលិខិតស្នាមមួយ សម្រាប់ទុកជាឯកសារប្រគល់ភារកិច្ចឱ្យអង្គភាព ឬ សាមីជន ឬ ឯកជនណាម្នាក់មានការពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានក្នុងការអនុវត្ត។ កំណត់ហេតុ មានច្រើន ដូចជា :

-កំណត់ហេតុប្រជុំការងារ ឬ អង្គប្រជុំណាមួយ

-កំណត់ហេតុផ្ទេរភារកិច្ច

-កំណត់ហេតុស្ដីពីការប្រគល់ -ទទួលទំនិញ

-កំណត់ហេតុប្រគល់សំណុំលិខិត ឬ ឯកសារ

-កំណត់ហេតុស្ដីពីការឆែកឆេរផ្ទះ

-កំណត់ហេតុស្ដីពីការចាប់ ឬ ឃាត់ទំនិញ ខុសច្បាប់

[២] សូមមើល ឡេង លឹមគុង : "ការងារការិយាល័យ " ១៩៩៧ ទំព័រ៣៧។

-កំណត់ហេតុស្តីពីបទល្មើសចរាចរគ្រោះថ្នាក់ចរាចរ ។ល។

កំណត់ហេតុគេអាចសរសេរជាអក្សរទាំងអស់ សូម្បីថ្ងៃ ខែ ឆ្នាំ ចំនួនតួលេខ ជាដើម ។

**ឧទាហរណ៍គំរូទី ១ :**

## កំណត់ហេតុ

ឆ្នាំពីរពាន់ប្រាំមួយ ខែមករា ថ្ងៃទីប្រាំពីរ វេលាម៉ោងប្រាំបី នៅ.....មានបើកអង្គប្រជុំមួយ ស្តីពី...ក្រោមការដឹកនាំរបស់.....។

សមាសភាពចូលរួម :

ឯកឧត្តម......................មុខងារ......មកពីអង្គភាព......ជាប្រធានអង្គប្រជុំ។

-..................................................................

-..................................................................

របៀបវារៈអង្គប្រជុំ :

-..................................................................

ជាកិច្ចចាប់ផ្តើមលោក......ជាប្រធានអង្គប្រជុំ..........................................
...................។

ការតែងនិពន្ធ

.........................................................................................................

.........................................................................................................។

លេខាកត់ត្រា

បានឃើញ និង ឯកភាព | ហត្ថលេខា

ប្រធានអង្គប្រជុំ | នាមឈ្មោះ

នាមឈ្មោះ

**ឧទាហរណ៍គំរូទី ២ :**

## កំណត់ហេតុ
## ស្តីពី
## កិច្ចប្រជុំការងារ

ឆ្នាំពីរពាន់ប្រាំមួយ ខែមិថុនា ថ្ងៃទីដប់ប្រាំ វេលាម៉ោងប្រាំបី នៅ....មានបើកសម័យប្រជុំមួយស្តីអំពី ... ស្ថិតក្រោមអធិបតីភាព (ឬស្ថិតក្រោមការដឹកនាំនៃលោក ...) នៃលោក ... ដើម្បីពិភាក្សាលើបញ្ហា ...។

<u>សមាសភាពចូលរួមមាន</u> :

លោក.... មុខងារ.... មកពីអង្គភាព......ប្រធានអង្គប្រជុំ

លោក.....មុខងារ....មកពីអង្គភាព.......សមាជិក

លោកស្រី....មុខងារ...មកពីអង្គភាព....សមាជិក

កញ្ញា..... មុខងារ....មកពីអង្គភាព.... សមាជិក

<u>អវត្តមាន</u> :

លោក.... មូលហេតុ........។

ជាកិច្ចចាប់ផ្តើមលោក....ជាប្រធានអង្គប្រជុំបានបើកអង្គប្រជុំ....។

លោក....មានមតិថា............................................................................................
.......................។

កញ្ញា......មានមតិថា..........................................................................................
.......................។

លោកស្រី....មានមតិថា...........................................។

ដោយពុំមានបញ្ហាអ្វីទៀតទេ លោកប្រធានអង្គប្រជុំបានសម្រេចយកមតិ...។ រួចហើយ មានមតិផ្តាំផ្ញើឬបានធ្វើការបូកសរុប :

-.................................................................................................................
...................................................................................................................។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ថ្ងៃ ខែឆ្នាំ ដូចខាងលើ។

លេខាកត់ត្រា (ឬលេខាអង្គប្រជុំ)

បានឃើញ និងឯកភាព[៣] ហត្ថលេខា

(ឬ បានឃើញ និងយល់ព្រម) នាមឈ្មោះ

ប្រធានអង្គប្រជុំ

ហត្ថលេខា

នាមឈ្មោះ និងត្រា

**២-របាយការណ៍ :**

របាយការណ៍ជាការសរសេររៀបរាប់ រាយការណ៍ពីសកម្មភាពការងារប្រចាំថ្ងៃ ខែ ឆ្នាំ និងបញ្ជាក់ពីទិសដៅទៅឆ្នាំខាងមុខទៀត ឬ ព្រឹត្តិការណ៍អ្វីមួយដែលកើតឡើង។ គេធ្វើរបាយការណ៍ ដោយដកស្រង់យកតែខ្លឹមសារសំខាន់ៗចេញពីហេតុការណ៍ណាមួយ ឬ ពីអង្គប្រជុំណាមួយដែលអ្នកធ្វើរបាយការណ៍រៀបរៀងឃ្លាប្រយោគធ្វើយ៉ាងណាឱ្យគេយល់ ដោយមិនចាំបាច់សរសេរលម្អិតគ្រប់ចំណុច ដូចជាកំណត់ហេតុទេ។ ចំពោះការសរសេរតួលេខ ឬ ការសរសេរថ្ងៃខែ ឆ្នាំ គេសរសេរជាលេខ មិនសរសេរជាអក្សរដូចក្នុងកំណត់ហេតុទេ។

---

[៣] យកល្អពេលកត់ត្រារួច មុននឹងយកឱ្យប្រធានអង្គប្រជុំចុះហត្ថលេខា អ្នកកត់ត្រាគប្បីឱ្យសាមីខ្លួនអ្នកមានមតិក្នុងអង្គប្រជុំ គេពិនិត្យពាក្យសម្ដីរបស់គេសិន រួចសឹមឱ្យប្រធានលោកចុះហត្ថលេខា។

ឧទាហរណ៍គំរូ ១ :　　　　ព្រះរាជាណាចក្រកម្ពុជា

ក្រសួង............　　　　ជាតិ សាសនា ព្រះមហាក្សត្រ

លេខ...............　　　　........

**របាយការណ៍**

**បូកសរុបការងារក្រសួង( ឬ អង្គភាព... )**

**សម្រាប់ឆ្នាំ២០០៦ និងទិសដៅឆ្នាំ២០០៧**

-..................................................................................................

..........................................................................................។

.............................................................................................។

.............................................................................................។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ......ឆ្នាំ......

រដ្ឋមន្ត្រីក្រសួង

ហត្ថលេខា

កន្លែងទទួល　　　　　　　　នាមឈ្មោះ និងត្រា

-.....................

-......................

ឧទាហរណ៍គំរូ ២ : ព្រះរាជាណាចក្រកម្ពុជា

ក្រសួង............ ជាតិ សាសនា ព្រះមហាក្សត្រ

លេខ............... .......

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦

## របាយការណ៍

–............... ........................

## គោរពជូន

..............................

កម្មវត្ថុ : ................................................... ។

ស្តីពី..................................................................................... ។

–.......................................................................................................

................................................ ។

–........................................................................ ។

ហត្ថលេខា

ចម្លងជូន នាមឈ្មោះ និងត្រា

–....................................

–....................................

**៣- សុន្ទរកថា :** (Le discours)

**ក-និយមន័យ :**

សុន្ទរកថាគេអាចចាត់ជាផ្នែកឧបទេសអក្សរសិល្ប៍ [៤] មួយផ្នែកដែលអ្នកនិពន្ធ ជាពិសេសអ្នកដឹកនាំ, ប្រមុខរដ្ឋ, នាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី, អធិបតីនៃអង្គប្រជុំនានា ។ល ។ តែងឡើងពីបញ្ហាអ្វីមួយ សម្រាប់អាន ឬ ថ្លែងនៅក្នុងពិធីដែលខ្លួនធ្វើជាអធិបតី ឬ ក្នុងនាមខ្លួនជាម្ចាស់កម្មវិធី នៅចំពោះមុខភ្ញៀវ និងប្រជាពលរដ្ឋ ។

**ខ-លក្ខណៈសុន្ទរកថា :**

សុន្ទរកថាពុំមែនជាអត្ថបទធម្មតាទេ ។ ទោះបីថ្លែងនៅក្នុងពិធីសម្ពោធន៍, ពិធីបញ្ចប់ការងារ, ពិធីជប់លៀង សន្និបាត ។ល ។ អ្នកថ្លែងតែងតែបញ្ចូលនូវគំនិតសំខាន់ៗមួយចំនួនឱ្យត្រូវនឹងប្រធានបទ ដែលជាគោលដៅ និងទិសដៅរបស់អង្គពិធីនីមួយៗ ។ ជាទូទៅអ្នកថ្លែងអាចបញ្ចូលនូវលទ្ធផល ជាស្នាដៃរបស់

---

[៤] ឧបទេសអក្សរសិល្ប៍ ជាកម្រងអត្ថបទមួយផ្នែក រៀបរៀងឡើងសម្រាប់ជាគោលអប់រំទូន្មានប្រៀនប្រដៅទៅតាមបែបចរិយាសាស្ត្រ និង សីលធម៌ ។ វាពុំមែនជាច្បាប់ដាច់ខាតទេ ប៉ុន្តែជាការទូន្មានប្រៀនប្រដៅឱ្យជនានុជនធ្វើការពិចារណា ( អាចធ្វើតាមក៏បាន ឬមិនធ្វើតាមក៏បាន) ។

អង្គភាពខ្លួន ឬ ស្នាដៃខ្លួនដែលបានធ្វើកន្លងមកឱ្យជាប់ទាក់ទងនឹងកម្មវិធីនោះ អាចជា របាយការណ៍, ស្ថិតិ, ជាព័ត៌មានសំខាន់ៗផ្សេងទៀត ឬ អាចជាកម្រង មេរៀនសង្ខេបណាមួយដែលមានជាប់ទាក់ទងទៅនឹងគោលបំណង និង ទិសដៅ នៃពិធីនោះ។

បញ្ចូលគំនិតណែនាំ ឬ ដឹកនាំសកម្មភាពថ្មីៗ ដើម្បីអនុវត្តបន្តទៀតបាន ជោគជ័យ និងបញ្ចូលគំនិតអប់រំកសាងប្រៀនប្រដៅផ្សេងៗ។

(សូមមើលឧបសម្ព័ន្ធទី ១)

**គ-ប្រភេទសុន្ទរកថា :**

សុន្ទរកថាមានច្រើនប្រភេទប្លែកៗគ្នា ដូចជា :

-សុន្ទរកថាសម្ពោធនានា,

-សុន្ទរកថាបើក ឬ បិទពិធីនានា,

-សុន្ទរកថានយោបាយ

-សុន្ទរកថារៀបរាប់ផ្សេងៗ អំពីសមិទ្ធ ឬ ពីបញ្ហានានា,

-សុន្ទរកថាបែបសាសនា។

**ឃ-តើអ្នកត្រូវធ្វើយ៉ាងណាដើម្បីឱ្យសុន្ទរកថាល្អ ?**

ដើម្បីធ្វើសុន្ទរកថាមួយបានល្អ អ្នកសរសេរត្រូវ ៖

-ដឹងពីប្រធានបទដែលអ្នកបម្រុងនឹងថ្លែង ថាតើជាពិធីអ្វី ? បិទវគ្គបណ្ដុះបណ្ដាលសិស្ស ឬ ជាពិធីសម្ពោធន៍សាលា ឬ ពិធីសម្ពោធន៍អាគារស្រាវជ្រាវ អ្វីមួយ ?។

កាលណាយើងដឹងពីប្រធានបទនៃពិធីនីមួយៗ យើងត្រូវយល់ដឹងពីគោលបំណងនៃសមិទ្ធផលដែលបណ្ដាលឱ្យកើតជាពិធីនោះឡើង។ រួចហើយកំណត់ទិសដៅក្នុងការសរសេរសុន្ទរកថា។ អ្នកនិយាយបញ្ចុះបញ្ចូលគេ ឬ អប់រំគេឱ្យស្របនឹងទិសដៅដែលបានលើកឡើង។

-ក្នុងការសរសេរអ្នកត្រូវដឹងថា យើងសរសេរឱ្យអ្នកណាស្ដាប់ ? យើងត្រូវកំណត់មុខសញ្ញាអ្នកស្ដាប់ តើពួកគេអាចយល់ពីទិសដៅរបស់យើងកម្រិតណា ?

-ដឹងពីកម្មវិធីនៃពិធីនោះ តើគេឱ្យអ្នកនិយាយបានប៉ុន្មាននាទី ? គឺត្រូវសរសេរមានកម្រិត។ តើយើងនិយាយតែម្នាក់យើង ឬ មានគេនិយាយដែរ ? តើគេនិយាយមុន ឬ យើងនិយាយមុន ? គេនិយាយអំពីអ្វី ? យើងត្រូវនិយាយ

អំពីអ្វី ?ត្រង់នេះគឺអ្នកសរសេរត្រូវសរសេរឱ្យទាក់សេចក្តីគ្នាពីសុន្ទរកថាទី១ ទៅសុន្ទរកថាទី២ ឬ សុន្ទរកថាទី ២ ត្រូវទាក់ទៅនឹងសុន្ទរកថាទី១វិញ។

-កំណត់ចំណុចសំខាន់មួយចំនួន ដើម្បីលើកយកមកដាក់ក្នុងសុន្ទរកថារបស់យើង។

-ឃ្លោងឃ្លានៃសុន្ទរកថាត្រូវឱ្យទាក់ចិត្តអ្នកស្តាប់។

-មានសេចក្តីបញ្ចប់នៃសុន្ទរកថា មុននឹងបញ្ចប់ត្រូវលើកពីចំណុចដែលអ្នកចង់បាន។ អាចជាសេចក្តីថ្លែងការណ៍មួយ ដែលធ្វើឱ្យគេរំភើបនៅក្នុងនោះអ្នកអំពាវនាវឱ្យគេធ្វើសកម្មភាពទស្សន៍ទាយពីអនាគត ធ្វើសេចក្តីប្រកាសមួយនិយាយលម្អិតមតិដំបូងរបស់អ្នក និងសង្ខេបគោលដៅសំខាន់ៗ។

**៤- អារម្ភកថា :**

ក-អ្វីទៅជាអារម្ភកថា ?

អារម្ភ + កថា

អារម្ភ = ការប្រារព្ធ ការតាំងផ្តើម ឬ ផ្តួចផ្តើម, ការរៀបរបដំណើរចាប់ផ្តើមការ, ចាប់ធ្វើការ។

កថា = ពាក្យ, សម្តី, ពំនោល, ការសំដែង, រឿង។

ដូច្នេះអារម្ភកថា គឺជា ពាក្យប្រារព្ធ, ពាក្យផ្ដើម, ពាក្យនាំមុខ ។

តើពាក្យនាំមុខ ពាក្យផ្ដើមពីអ្វី ?

អារម្ភកថា ជាពាក្យនាំមុខ ជាពាក្យផ្ដើម សេចក្ដីបញ្ជាក់ ឬ ជាពាក្យឃោសនាឱ្យគេអានខ្លឹមសារទាំងឡាយនៅក្នុងសៀវភៅរបស់យើង ។ គេសរសេរអារម្ភកថានៅពីខាងដើមទំព័រនៃសៀវភៅនីមួយៗ គឺជាការសរសេររៀបរាប់ពីការតាំងផ្ដើម ដែលនាំឱ្យដល់ការសរសេរសៀវភៅនេះ ។ អ្នកអាចរៀបរាប់ពីការលំបាក ការងាយស្រួល រៀបរាប់ពីមូលហេតុដែលអ្នកធ្វើសៀវភៅនេះឡើងមានគោលបំណងអ្វី ? ផលប្រយោជន៍នៃសៀវភៅ ពីកង្វះខាត ឬ សំណូមពរឱ្យគេជួយកែលម្អជាដើម ។ គេអាចដាក់ចំណងជើងផ្សេងៗខុសពី" **អារម្ភកថា** " នេះក៏បានដែរ ទៅតាមចំណង់ចំណូលចិត្តរបស់អ្នកនិពន្ធ ឬ ទៅតាមការនិពន្ធសៀវភៅប្រសិនបើសៀវភៅនោះអ្នកនិពន្ធចង់ឱ្យអ្នកជំនាញដ៏ល្បីល្បាញណាម្នាក់ ឬអ្នកធំមានមុខមាត់ខ្ពង់ខ្ពស់ណាម្នាក់មានចំណារបញ្ចេញយោបល់នៅលើសៀវភៅរបស់ខ្លួន ប៉ុន្តែរាល់ខ្លឹមសារនៃអត្ថបទទាំងនោះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងអារម្ភកថាដែរ ដូចជា : " *លំនាំដើម ពាក្យប្រារព្ធ, ពាក្យនាំមុខ, បុព្វកថា, ចំណាប់អារម្មណ៍, និវេទនកថា* " ជាដើម ។

នៅក្នុងសៀវភៅមួយក្បាល គេអាចសរសេរជា បុព្វកថាផង ចំណាប់អារម្មណ៍ផង និងអារម្ភកថាផង ប៉ុន្តែគេអាចឱ្យ " **បុព្វកថា** " ទៅលោកជាធំណាម្នាក់ដែលលោកបានយកចិត្តទុកដាក់ចំពោះសៀវភៅនោះយ៉ាងខ្លាំងក្លា ឬ លោកជាអ្នករួមចំណែកទទួលខុសត្រូវលើសៀវភៅនោះដែរ គឺលោកសរសេរឱ្យជាមតិយោបល់ទៅលើខ្លឹមសារ សារៈប្រយោជន៍របស់សៀវភៅនោះ។ បន្ទាប់មកអាចមាន "**ចំណាប់អារម្មណ៍**" ឬជា "**ពាក្យប្រារព្ធ**" ក៏បាន ឱ្យទៅលោកអ្នកទទួលខុសត្រូវណាម្នាក់ ដែលលោកជាប្រធានគណៈកម្មការត្រួតពិនិត្យមើលការខុសត្រូវលើការនិពន្ធនោះ។

ជាចុងក្រោយ "**អារម្ភកថា** " គឺលោកជាអ្នកនិពន្ធ ឬជា និពន្ធនាយកនៃសៀវភៅនោះ( ការលើកនេះសំដៅលើសៀវភៅដែលមានក្រុមអ្នកនិពន្ធច្រើនមានអ្នកទទួលខុសត្រូវលើសៀវភៅនោះច្រើនគ្នា ជាទូទៅ ជាប្រភេទសៀវភៅថ្នាក់ជាតិប្រើប្រាស់ជាផ្លូវការ ដូចជា វចនានុក្រមខ្មែរ ឬ វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរជាដើម) ។ ចំពោះសៀវភៅធម្មតាដែលមានអ្នកនិពន្ធតែម្នាក់ឯង ឬពីរនាក់ក្តី គេច្រើនសរសេរ " **អារម្ភកថា** " តែម្តង ឬ អាចឱ្យអស់លោកអ្នក

ជំនាញ ឬ លោកធំណាម្នាក់មានចំណារ ឬ ធ្វើចំណាប់អារម្មណ៍ក៏បាន គឺទៅតាមចំណូលចិត្តរបស់អ្នកនិពន្ធចង់បាន។ ( សូមមើលឧបសម្ព័ន្ធទី២ )

**៥-និវេទនកថា :**

និវេទនកថា គឺជាពាក្យជូនដំណឹង, ឱ្យដំណឹង, ប្រាប់ដំណឹងពីកិច្ចការឬពីស្ថានការណ៍ផ្សេងៗដែលគួរឱ្យយល់។ គេសរសេរនិវេទនកថានៅពីខាងដើមទំព័រនៃសៀវភៅបន្ទាប់ពីអារម្ភកថា ដែលជាទូទៅគេអាចនិយាយពីកង្វះខាតផ្សេងៗក្នុងការធ្វើសៀវភៅ ធ្វើវចនានុក្រម ដូចជា ការខ្វះមេពាក្យ, ការអធិប្បាយ និងការរៀបរៀងនៅមានភ្លាំងភ្លាត់ខ្លះៗ។ យើងហើយអាចនិយាយប្រាប់គេឱ្យដឹងថាអ្នកណាខ្លះ ដែលបានជួយធ្វើជួយឱ្យយោបល់ និងប្រាប់ពីផលប្រយោជន៍នៃសៀវភៅនោះផង។ ការពិត និវេទនកថា ក៏ជាអារម្ភកថាដែរ។ (សូមមើល *និវេទនកថា* របស់វចនានុក្រមខ្មែរ ដែលបញ្ចូលនៅក្នុងឧបសម្ព័ន្ធទី២នៃសៀវភៅនេះ) ។

**៦-អំពីញត្តិ :**

នៅក្នុងវចនានុក្រមខ្មែរត្រង់ទំព័រ២៩១ *ញត្តិ* គឺជានាមសព្ទ ជាពាក្យបាលី, សំស្រ្កឹតជា" ជ្ញាប្តិ "មានន័យថា " វាចាដែលភិក្ខុរូបណាមួយសូត្រប្រកាស

ឱ្យជំនុំសង្ឃដឹង គឺសម្ដីដែលភិក្ខុសូត្រផ្សៀងជំនុំសង្ឃក្នុងការធ្វើសង្ឃកម្មដែលមានបង្គាប់ថាត្រូវឱ្យផ្សៀងជំនុំសង្ឃ ដែលមកប្រជុំក្នុងទីនោះជាមុនទើបធ្វើបាន ដើម្បីឱ្យដឹងថា សង្ឃកម្មនោះត្រឹមត្រូវតាមវិន័យហើយ ឬ មានទាស់ខុសដោយហេតុណាមួយ (ពាក្យសម្រាប់ប្រើក្នុងវិន័យខាងព្រះពុទ្ធសាសនា)។ *ញត្តិ* សព្ទនេះមកពី ញា (ដឹង, យល់, ស្គាល់)ផ្សំនឹង តិ-បច្ច័យជា ញាតិ, សម្រេចរូបមកទៀតជា ញត្តិ (សម្ដីប្រកាសយោបល់ឱ្យគេដឹង)។ ប្រើជាសាធារណៈក៏បាន, មាន២យ៉ាងគឺ ញត្តិស្រប, ញត្តិជំទាស់ ឬ ហៅថា ញត្តិយល់ស្រប, ញត្តិយល់ទាស់ វិញក៏បាន។ តាមទម្លាប់ពីបុរាណ គេតែងអានពាក្យ **ញត្តិ** នេះថា **ញាត់** ចំពោះសង្ឃកម្មផ្សេងៗ មានពិធីបំបួសកុលបុត្រជាភិក្ខុ និងកឋិនជាដើម។ សូត្រញត្តិនាគ ឬ ញត្តិនាគ (សូត្រញាត់នាគ ឬ ញាត់នាគ) សូត្រញត្តិក្នុងពិធីបំបួសកុលបុត្រដែលសន្មតនាមថានាគឱ្យទៅជា ភិក្ខុ, ញត្តិកឋិន (ញាត់កៈឋិន)សូត្រញត្តិ ក្នុងកិច្ចកឋិន។ល។"

បច្ចុប្បន្ន *ញត្តិ* សំដៅទៅលើលិខិតដែលគេសរសេរសម្ដែងនូវសញ្ចេតនាប្រកបដោយវិចារណញ្ញាណ បញ្ជាក់ពីការគាំទ្រនូវអ្វីដែលគេពេញចិត្ត ឬ ប្រឆាំងនឹងអ្វីៗ ដែលគេមិនពេញចិត្ត ឬក៏ទាមទារអ្វីៗ ដែលគេចង់បាន។ល។

របៀបសរសេរ *ញត្តិ* ៖ នៅក្បាលលិខិតត្រូវសរសេរថា ៖ "ញត្តិគាំទ្រ...", "ញត្តិប្រឆាំង..." ឬ "ញត្តិទាមទារ..."។ បន្ទាប់មកត្រូវបង្ហាញពីហេតុ ឬ បង្ហាញពីទស្សនៈ និងយោបល់របស់ខ្លួនដែលបានយល់ឃើញចំពោះរឿងណាមួយដែលបានកើតឡើង។ នៅចុងបញ្ចប់នៃញត្តិនីមួយៗត្រូវដាក់ថា ចម្លងជូនដល់ស្ថាប័នណាខ្លះដែលពាក់ព័ន្ធនឹងអ្វីដែលយើងទាមទារ ឬ យើងចង់បាន។ បន្ទាប់មកត្រូវមានចុះហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកគាំទ្រញត្តិនោះគ្រប់ៗគ្នា។

**៧-អំពីអត្ថបទស៊ីជម្រៅ ៖** (article de fond)

អត្ថបទស៊ីជម្រៅ គឺជាអត្ថបទទាំងឡាយណាដែល អ្នកនិពន្ធ (ឬ អ្នកសរសេរ) លើកយកបញ្ហាអសកម្មពីគ្រប់មុំនៃសង្គមបច្ចុប្បន្នមកធ្វើជាប្រធានបទរបស់ខ្លួន ដោយធ្វើការវិភាគ ត្រិះរិះ ពិចារណា ស្វែងរកហេតុផល ត្រូវឬខុស ក្នុងគោលបំណងអប់រំ ណែនាំ បង្ហាញផ្លូវដល់អ្នកដែលកំពុងតែអនុវត្តខុសឆ្គងទាំងឡាយឱ្យគេភ្ញាក់ខ្លួនហ៊ានកែប្រែនូវកំហុសឆ្គងទាំងឡាយដែលខ្លួនកំពុងធ្វើ ឈានទៅរកភាពត្រឹមត្រូវ រីកចម្រើនឡើងវិញ។ គេច្រើនសរសេរ អត្ថបទស៊ីជម្រៅ

ចុះនៅតាមទំព័រសារព័ត៌មាននានា ដែលភាគច្រើនជាទស្សនៈនយោបាយរបស់សារព័ត៌មានមួយ ។

អត្ថបទស៊ីជម្រៅមាន : វិចារណកថា, បរិយាយថ្ងៃនេះ, អត្ថាធិប្បាយថ្ងៃនេះ, មតិមួយ, ទស្សនៈឡប់ៗ, ទស្សនៈចៅតាខ្វែក, ទស្សនៈអាឡេវ, យោបល់អាចារ្យធំជាដើម ។ល ។

**៧-១ វិចារណកថា :**

វិចារណកថាគឺជា ពាក្យសម្ដីប្រកបដោយហេតុគួរត្រិះរិះ, ការថ្លែងបរិយាយពីហេតុការណ៍ដែលគួរពិចារណាឱ្យល្អិតល្អន់ ។ គេសរសេរវិចារណកថាច្រើនតែនៅលើទំព័រសារព័ត៌មាន គឺគេសរសេរវិភាគទៅលើរឿងរ៉ាវអ្វីៗ ដែលកើតមានឡើងនាពេលបច្ចុប្បន្ន ឬ ឆ្លុះបញ្ចាំងរឿងរ៉ាវពីអតីតកាលដែលវាមានជាប់ទាក់ទងទៅនឹងសកម្មភាពបច្ចុប្បន្ន ។ ប្រសិនបើគេសរសេរពីបញ្ហានយោបាយ គេច្រើនវែកញែកទៅតាមនិន្នាការរបស់កាសែតនីមួយៗដែលប្រកាន់យក (របបកុម្មុយនីស្ត, របបសេរី, លទ្ធិប្រជាធិបតេយ្យ ឬ របបផ្ដាច់ការ) ។ល ។ គឺជាអត្ថបទបង្ហាញពីឥរិយាបថ ឬពីទស្សនៈរបស់អង្គការសារព័ត៌មានមួយតែ

ប៉ុណ្ណោះ វាពុំមែនជាគំនិត ឬ យោបល់របស់អ្នកសរសេរសារព័ត៌មានម្នាក់ណា នោះទេ។ ដូច្នេះអត្ថបទ "**វិចារណកថា**" គេមិនដាក់ឈ្មោះរបស់អ្នកនិពន្ធទេ។

ជាទូទៅ ដើម្បីសរសេរវិចារណកថា គេច្រើនផ្តោតទៅលើប្រធានបទណាមួយ ដែលគេបានចាប់អារម្មណ៍ ហើយប្រធានបទនោះមានជាប់ទាក់ទងទៅនឹងបញ្ហានយោបាយជាតិ និងអន្តរជាតិ, បញ្ហាសេដ្ឋកិច្ច, សីលធម៌, ប្រពៃណី, វប្បធម៌, ចរិយាធម៌, សង្គមសាស្ត្រ, ទស្សនះវិជ្ជា, ចិត្តសាស្ត្រ, បច្ចេកវិទ្យា ឬការដឹកនាំប្រទេសជាដើម។ គេអាចលើកយកប្រធានបទណាមួយដែលមានជាប់ទាក់ទងទៅនឹងបញ្ហាសង្គមនាពេលបច្ចុប្បន្ន ដែលជាព្រឹត្តិការណ៍គួរឱ្យចាប់អារម្មណ៍មកធ្វើការត្រិះរិះ ពិចារណារកហេតុរកផល ត្រូវឬខុស ល្អឬអាក្រក់ ចំណេញ ឬខាត ដោយមានឱ្យឧទាហរណ៍ជាក់ស្តែងក្នុងសង្គម ជាទ្រឹស្តីអ្នកប្រាជ្ញណាមួយ ជាទ្រឹស្តីវិទ្យាសាស្ត្រ ឬ ជាក្បួនច្បាប់ណាមួយមកបង្ហាញ។

បន្ទាប់មកធ្វើសេចក្តីសន្និដ្ឋានមួយទៅលើការបរិយាយវែកញែកនោះរួចហើយ គេក៏បញ្ចេញយោបល់ ឬ ទស្សនះផ្ទាល់ខ្លួន ថាគួរធ្វើយ៉ាងនេះធ្វើយ៉ាងនោះ ដើម្បីស្វែងរកសេចក្តីចម្រើនដល់ប្រជាជន ប្រទេសជាតិ ដល់ក្រុមណាមួយ ឬ ដល់សហគមន៍ណាមួយ ។ល។

៧.២-បរិយាយថ្ងៃនេះ :

បរិយាយថ្ងៃនេះ សរសេរអំពីអ្វីដែលកើតឡើងក្នុងសង្គម មាននយោបាយ, សេដ្ឋកិច្ច, វប្បធម៌, ប្រពៃណី...។ល។ ជារឿងរ៉ាវដែលគួរចាប់អារម្មណ៍ វាមិនមែនជារឿងបុគ្គលទេ គឺជារឿងជាតិ។ វាជាអត្ថបទបញ្ចេញនូវទស្សនៈយោបល់ គេច្រើនសរសេរជាទម្រង់រាយរ៉ាប់រៀបរាប់អំពីគោលជំហរស៊ីជម្រៅរបស់ក្រុមអ្នកនិពន្ធសារព័ត៌មាន ដែលបានឯកភាពគ្នា។ គឺគេរៀបរាប់ពីគោលគំនិតរបស់ព្រឹត្តិការណ៍សង្គមមួយ ឬ ពីបុគ្គលដែលទទួលមុខដំណែងធំមួយនៅក្នុងសង្គម ដូចជា : ពួកគេធ្វើល្អ, ពួកគេធ្វើខុស, ឬ ពួកគេពុករលួយជាដើម។

៧.៣-ទស្សនៈឡប់ៗ :

ទស្សនៈឡប់ៗ ជាអត្ថបទមួយ ដែលអ្នកនិពន្ធសរសេររបៀបខ្លួនឯងជាមនុស្សមិនគ្រប់ទឹក ប៉ុន្តែមើលឃើញបញ្ហាអសកម្មនៅក្នុងសង្គមមានច្រើន រួចហើយក៏សរសេររិះគន់បុគ្គល, អំពើពុករលួយ សីលធម៌សង្គម។ល។ ដោយសរសេរកាច់កុង បញ្ឆិតបញ្ឆៀងពេបជ្រាយមិនចេញឈ្មោះអ្នកណាម្នាក់ ប៉ុន្តែក្នុងន័យកែលម្អអ្នកដែលប្រព្រឹត្តខុសនោះឱ្យដឹងខ្លួន ថាខ្លួនកំពុងតែអនុវត្តខុសធ្វើខុស ចេះកែប្រែមករកផ្លូវត្រូវ ផ្លូវល្អវិញ។

៧.៤-យោបល់អាចារ្យធំ :

យោបល់អាចារ្យធំ  អ្នកនិពន្ធសរសេររបៀបឱ្យជាយោបល់កែលម្អនូវអំពើអសកម្មទាំងឡាយដែលកើតមាននៅក្នុងសង្គម  របៀបខ្លួនឯងជាលោកអាចារ្យនិយាយស្តីប្រដៅកូនចៅកាលបើខ្លួនមើលឃើញចំណុចខ្វះខាត  ដោយនិយាយចំៗត្រង់ៗ ។

៧.៥-ទស្សនៈចៅតាខ្វែក :

តាមធម្មតាសត្វខ្វែករកស៊ីតែពេលយប់ ដូច្នេះអត្ថបទរបៀបនេះគេច្រើនសរសេរពីរឿង ពុករលួយ ពីរឿងមិនល្អទាំងឡាយដែលកើតមានឡើងនៅក្នុងសង្គម ដូចជារឿងអ្នកណាស្លូក ? អ្នកណាជាអ្នកស៊ីសំណូក ?។ គេសរសេរពីរឿងទាំងឡាយដែលមហាជនមិនបានដឹង មិនបានឮ ឆ្លៀតកកាយមកសរសេរឱ្យមហាជនបានដឹងពីអំពើពុករលួយ ពីរឿងអយុត្តិធម៌ទាំងឡាយ ដែលកើតមាននៅក្នុងសង្គមជាដើម ។

៧.៦-ទស្សនៈអាឡេវ :

ទស្សនៈអាឡេវ អ្នកនិពន្ធតាំងខ្លួនជាអាឡេវ ដែលមានលក្ខណៈចេះផងមិនគ្រប់ទឹកផងលើកយករឿងរ៉ាវអសកម្មក្នុងសង្គម ឬ បុគ្គលអសកម្មណាម្នាក់

ក្នុងសង្គម ដែលមានតួនាទីធ្វើការបម្រើជាតិ បម្រើរាស្ត្រ មកសរសេរក្នុងន័យរិះគន់ស្ថាបនា។ ប៉ុន្តែសរសេរធ្វើយ៉ាងណាឱ្យបានប្រយោជន៍បុគ្គល (បុគ្គលដែលប្រព្រឹត្តិខុសនោះលែងហ៊ានប្រព្រឹត្តិខុសតទៅទៀត) និង ផលប្រយោជន៍សង្គមក្នុងគោលដៅអប់រំកែប្រែ។ ឧទាហរណ៍ : អាឡេវឮដំណឹងថា លោកនេះលោកនោះមានគេហៅឱ្យឡានមួយគ្រឿងថ្មីសន្លាង តែលោកនោះមិនយកទេប្រសិនបើឱ្យអាឡេវវិញ អាឡេវយកមិនចាំថ្ងៃស្អែកទេ ខូចប្រយោជន៍អ្នកណាខូចទៅ បើក្រម្លឹង។ ខូចប្រយោជន៍ជាតិ ប្រយោជន៍រាស្ត្រប៉ុណ្ណាក៏អាឡេវស៊ីញ៉េយកដែរឱ្យតែបាន អាឡេវស្មោះ ! ។

### ៧.៧-អត្ថាធិប្បាយថ្ងៃនេះ :

អត្ថាធិប្បាយថ្ងៃនេះក៏មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹង "បរិយាយថ្ងៃនេះ" ដែរ ប៉ុន្តែបើសារព័ត៌មានមានច្រើនទំព័រ ឬ ព្រឹត្តិការណ៍នៅក្នុងសង្គមមានបញ្ហាច្រើន គេក៏សរសេរអត្ថាធិប្បាយមួយទៀត ឬក៏អាចបន្ថែម "**មតិមួយ**" មួយអត្ថបទទៀត។

សរសេររបៀបអត្ថាធិប្បាយ គឺសរសេរពីរបៀបអប់រំ, ណែនាំ, សិក្សាស្រាវជ្រាវ។ ឧទាហរណ៍ : បើអត្ថាធិប្បាយពីប្រភពនៃអំពើពុករលួយ អ្នក

អត្ថាធិប្បាយត្រូវសិក្សាស្រាវជ្រាវបញ្ហាពុករលួយតាំងពីឆ្នាំ១៩...?មានអំពើពុករលួយកម្រិតណា តាមរយៈស្ថិតិណា ឯកសារណា ? បើប្រៀបធៀបជាមួយនឹងការស្រាវជ្រាវរបស់អង្គការ...រកឃើញថាមានអំពើពុករលួយចំនួន...ភាគរយ ។ ការរីករាលដាលនៃអំពើពុករលួយបណ្តាលមកពី...? ហើយយើងជាអ្នកសរសេរថាគួរធ្វើដូចម្តេច ? ។

ដើម្បីសរសេរ "**អត្ថាធិប្បាយថ្ងៃនេះ**"ជាអត្ថបទស៊ីជម្រៅ មានជម្រៅល្អ គេកំណត់ក្រុមអ្នកនិពន្ធរបស់គេឱ្យសរសេរតាមទម្រង់របស់ខ្លួន គឺអ្នកសរសេរ "**បរិយាយថ្ងៃនេះ**" សរសេរតែ "**បរិយាយថ្ងៃនេះ**" តែប៉ុណ្ណោះ ។ រីឯអ្នកសរសេរ "**អត្ថាធិប្បាយ**" ឬ "**មតិមួយ**" គេឱ្យសរសេរតែអត្ថបទ "**អត្ថាធិប្បាយ**" ឬ "**មតិមួយ** " ពីព្រោះអត្ថបទនីមួយៗ វាមានរចនាបថដោយឡែកៗរបស់ខ្លួន ។ នៅក្នុងទសវត្សឆ្នាំ ១៩៦០ អ្នកចេញពីសាលាបាលីជាន់ខ្ពស់ច្រើនតែបានក្លាយទៅជាអ្នកសរសេរអត្ថបទ "**អត្ថាធិប្បាយថ្ងៃនេះ**" ឬ អត្ថបទ "**មតិមួយ**" ព្រោះគេបានសិក្សាច្រើនពីទស្សនៈពុទ្ធនិយម និងទស្សនៈរបស់អ្នកប្រាជ្ញដទៃទៀតយ៉ាងច្រើន ជាពិសេសគេបានសិក្សាអំពីជីវិត និងសង្គម ។ ចំពោះអត្ថបទ "**បរិយាយថ្ងៃនេះ**" ច្រើនតែកើតចេញពីអ្នកកាសែតដែលមានបទពិសោធន៍ពី៥ឆ្នាំទៅ១០ឆ្នាំ ក្នុង

របរជាអ្នកសរសេរអត្ថបទកាសែត ព្រោះគេយល់ច្រើនពីបញ្ហាសង្គមនិងនយោបាយ ។

K **ការបង្កើតទស្សនៈ** :

ការសរសេរ "**អត្ថបទស៊ីជម្រៅ**" ត្រូវធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ឱ្យបានច្រើនពីសកម្មភាពដឹកនាំ និងគោលនយោបាយដឹកនាំប្រទេសរបស់រដ្ឋាភិបាល ឬត្រូវសិក្សាស្វែងយល់ពីបក្សនីមួយៗ (ប្រសិនបើខ្លួនជាអ្នកកាសែតអព្យាក្រឹត្យក៏ដូចជាកាសែតប្រជាធិបតេយ្យ ឬជា អ្នកកាសែតរាជានិយមដែរ) ត្រូវធ្វើការសិក្សាស្វែងយល់ឱ្យបានច្រើនបំផុតពីសង្គមរបស់ខ្លួនដែលកំពុងរស់នៅ ដូចជា វប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ ចំណង់ចំណូលចិត្តប្រជាជន និងសង្គម កត្តាចិត្តសាស្ត្រ ចរិយាសាស្ត្រ សង្គមសាស្ត្រ ការអប់រំ ច្បាប់ ទស្សនៈវិជ្ជា ចិត្តវិទ្យា បច្ចេកវិទ្យា សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល ។ល។ ជាមួយនោះក៏ត្រូវសិក្សាស្វែងយល់ពីព្រឹត្តិការណ៍អន្តរជាតិ ស្គាល់ពីទំនាក់ទំនងជាអន្តរជាតិ ច្បាប់អន្តរជាតិឱ្យបានច្បាស់លាស់ និងទូលំទូលាយ ។ បើនៅក្នុងសង្គមរបស់ខ្លួនត្រូវស្វែងយល់ថា តើរដ្ឋាភិបាលនិងគណៈបក្សនយោបាយនីមួយៗ កំពុងតែធ្វើអ្វីខ្លះ ?, តើកំពុងតែមានជំងឺអ្វី ?, តើពួកគេ បម្រុងនឹងទៅណា ?,

តើរីកចម្រើន ឬ ចុះអន់ថយនៅពេលណា ?។ ក្រោយពីការស្រាវជ្រាវរកឃើញការពិតហើយ គេត្រូវប្រជុំជាក្រុម នេះហើយគឺជាការពង្រឹងគោលជំហរដែលត្រូវប្រកាន់យក។ ប៉ុន្តែការសរសេរកំណត់ឱ្យអ្នកនិពន្ធតែម្នាក់គត់ ដែលជាអ្នកសរសេរ ព្រោះវាជាបន្ទាត់នយោបាយរបស់កាសែតមួយ ជាអ្នកមានពាក្យសម្ដីឃ្លោងឃ្លា ឬ ឥរិយាបថរបស់នយោបាយមួយ។

K **អំពីគោលដៅ** :

អត្ថបទស៊ីជម្រៅ គេតែងតែធ្វើអត្ថាធិប្បាយលើបញ្ហាថ្មីមួយ ដែលមានសារៈប្រយោជន៍ចំពោះជាតិ ចំពោះប្រជាពលរដ្ឋ។

អត្ថបទស៊ីជម្រៅនីមួយៗមានគោលដៅដូចតទៅ :

-*លើកសរសើរ ឬ វាយប្រហារ* : គេអាចសរសើរអំពីស្ថាប័នមួយ ឬ អំពីការសម្រេចចិត្តដ៏ល្អមួយរបស់រដ្ឋាភិបាល តែគេក៏អាចសរសេរវាយប្រហារទៅលើការសម្រេចចិត្តខុសរបស់រដ្ឋាភិបាល ឬ ការធ្វើសេចក្ដីសម្រេចចិត្តខុសរបស់ស្ថាប័នមួយ។

-*ពន្យល់អំពីព្រឹត្តិការណ៍* : អត្ថបទស៊ីជម្រៅ ជាអត្ថបទពន្យល់អំពីហេតុការណ៍មួយដែលកើតឡើង។ តើហេតុការណ៍នេះបណ្ដាលឱ្យជាតិលិចលង់ ឬជាតិ

រីកចម្រើន?។ តើវាមានកត្តាអ្វីធ្វើឱ្យមានការផ្លាស់ប្តូរដល់របបនយោបាយរបស់រដ្ឋាភិបាលឬទេ ? បើមាន តើវាជះឥទ្ធិពលអ្វីខ្លះដល់សង្គម និងសេដ្ឋកិច្ចជាតិ ? ។

*-បញ្ចុះបញ្ចូល* : អត្ថបទស៊ីជម្រៅក៏អាចបញ្ចុះបញ្ចូល ឬ អូសទាញមតិសាធារណៈឱ្យរិះគិត ឱ្យចេះពិចារណា ឱ្យជឿតាមមាគ៌ានយោបាយរបស់ខ្លួន។ អត្ថបទរបៀបនេះលើកយកមកបង្ហាញនូវបញ្ហា ឬ ដំណោះស្រាយដែលអាចធ្វើឱ្យប្រទេសជាតិរីកចម្រើន និងប្រជាជនមានជីវភាពធូរធារ ។ល។ ហើយវាក៏ជាកត្តាធ្វើឱ្យប្រជារាស្ត្រជឿជាក់ទៅលើគណៈបក្សណាមួយបានដែរ ។

*-ការទស្សន៍ទាយទៅអនាគត* : អត្ថបទស៊ីជម្រៅវិភាគទៅលើព្រឹត្តិការណ៍បច្ចុប្បន្នភាព ឆ្លុះបញ្ចាំងទៅអនាគត និងអាចផ្តល់ការទស្សន៍ទាយថាតើទៅអនាគតប្រទេសជាតិយើងនឹងទៅជាយ៉ាងណា ? ប្រជាពលរដ្ឋយើងនឹងទៅជាយ៉ាងណា ? ។

*-អំពីប្រធានបទ* : អត្ថបទអ្វីក៏ដោយ សុទ្ធតែមានប្រធានបទរបស់វាទាំងអស់ ប្រធានបទបែប **អត្ថបទស៊ីជម្រៅ** គឺយកចេញពីគ្រប់មុំនៃបញ្ហាដែលមាននៅក្នុងសង្គម។ ឧទាហរណ៍ : ប៉ូលីសផាក, មន្ត្រីជីវិតយកប្រាក់, គិញគយជីវិតយកប្រាក់ ក៏ជាប្រធានបទមួយសម្រាប់ **អត្ថបទស៊ីជម្រៅ** ដែរ។ រាល់បញ្ហា

នេះគេត្រូវធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ ពិចារណាឱ្យបានល្អិតល្អន់មុននឹងលើកយកមកសរសេរ ទើបសំណេរយើងមានលក្ខណៈសមហេតុសមផល។ រឿងរ៉ាវខ្លះជារឿងរ៉ាវក្ដៅគគុកសម្រាប់ពេលបច្ចុប្បន្ន ឬ ជាការសម្ងាត់របស់ប្រទេសជាតិ បើកាលណាអ្នកលើកយកមកចុះក្នុងទំព័រសារព័ត៌មានរបស់អ្នក វាធ្វើឱ្យប៉ះពាល់ខូចខាតដល់ផលប្រយោជន៍របស់ប្រជាជន ប្រទេសជាតិ និងដល់របបគ្រប់គ្រងប្រទេសបាន។ ដូច្នេះ អ្នកត្រូវគិតពិចារណាឱ្យបានជ្រៅជ្រះល្អិតល្អន់ពិតប្រាកដចំពោះអត្ថបទនីមួយៗរបស់ខ្លួន ព្រោះអត្ថបទរបៀបនេះប្រៀបដូចជាយើងហុចដងដាវឱ្យចោរ ឬ សត្រូវរបស់ប្រទេសជាតិដូច្នោះដែរ។ អត្ថបទរបៀបនេះវាអាចធ្វើឱ្យរាស្ត្ររងទុក្ខ រដ្ឋាភិបាលមួយដួលរលំបាន។

K **គំនិតផ្ដួចផ្ដើមគម្រោងសរសេរ :**

មុននឹងសរសេរអត្ថបទស៊ីជម្រៅ យើងត្រូវធ្វើគម្រោងជាមុនសិន ថាតើយើងត្រូវសរសេរពីអ្វី ?, តើត្រូវប្រើសេចក្ដីផ្ដើមដូចម្ដេច ?, តើត្រូវប្រើអង្គសេចក្ដីពីអ្វីខ្លះ ?, ត្រូវស្វែងយល់ពីអ្វី ?, ស្រាវជ្រាវពីអ្វី?, តើត្រូវប្រើសេចក្ដីបញ្ចប់ដូចម្ដេច?, ...។

បើអ្នកធ្វើគម្រោងរួច អ្នកងាយស្រួលនឹងសរសេរ។ បើអ្នកធ្វើគម្រោង

លើក្រដាសប្រសើរជាងធ្វើគម្រោងនៅក្នុងខួរក្បាល។ អ្នកមានបទពិសោធន៍ដោយសារគេមានការងាររវល់ច្រើន គេសរសេរតាមតែគំនិតដែលគេគ្រោងទុកក្នុងខួរក្បាលតែប៉ុណ្ណោះ ប៉ុន្តែទោះបីជាយ៉ាងណា ក៏គេចមិនផុតពីការកត់ត្រាដែរ។ ឧទាហរណ៍ : នៅពេលអ្នកចូលហាងកុយទាវឮអ្នកផងគេជជែកគ្នាពីបញ្ហានយោបាយស្រុកទេសក្តី, នៅពេលអ្នកស្តាប់វិទ្យុ ឬ មើលទូរទស្សន៍ក្តី អ្នកតែងកត់ត្រានូវចំណុចណាមួយដែលត្រូវការដើម្បីកុំឱ្យភ្លេច។ លុះពេលធ្វើគម្រោងសរសេរ អ្នកអាចនឹកឃើញឡើងវិញនូវចំណុចដែលបានកត់ត្រានោះ និងមានគំនិតផ្សេងៗថែមទៀត។

K **ផ្ទៀងផ្ទាត់ឡើងវិញ :**

តាមធម្មតាអត្ថបទនីមួយៗ ត្រូវតែផ្ទៀងផ្ទាត់ឡើងវិញនៅពេលអ្នកតាក់តែងរួច។ នៅពេលអ្នកសរសេរអត្ថបទមួយចប់សព្វគ្រប់ អ្នកត្រូវទុកវាចោលមួយល្ងាច ឬ មួយយប់សិន លុះស្អែកឡើងទើបយកវាមកត្រួតពិនិត្យឡើង វិញ។ អ្នកធ្វើដូច្នេះ ដើម្បីបំភ្លេចរឿងដែលអ្នកសរសេរ ឬ ភ្លេចពាក្យពេចន៍ឃ្លោងឃ្លាដែលអ្នកបានសរសេរ នៅពេលអ្នកអានឡើងវិញអ្នកហាក់បីដូចជាដឹងថា មានខុស ឆ្គងឃ្លាត្រង់ណា ឬ គួរដកពាក្យមួយណា គួរតែកែខ្លឹមសារ

ត្រង់ណា បន្ថែមឃ្លាត្រង់ណា កាត់ចោលឃ្លាត្រង់ណា ?.។ល។ ប្រសិនអ្នកគ្មានពេលវេលាទុកចោលយូរ អ្នកអាចទុកចោលត្រឹម២ទៅ៣ម៉ោងក៏បាន សឹមយកអត្ថបទរបស់អ្នកមកពិនិត្យមើលឡើងវិញ។

ជាទូទៅការសរសេរក៏ត្រូវការពេលវេលាស្ងាត់ ពេលកែសម្រួលក៏ត្រូវការពេលវេលាស្ងាត់ដែរ ប៉ុន្តែការអានដើម្បីកែ ក៏ត្រូវតែអានឱ្យឮៗ ដើម្បីឱ្យអារម្មណ៍របស់យើងទទួលយក និងពិចារណាថា តើខ្លឹមសារនៃអត្ថបទនេះខ្លាំងពេកឬខ្សោយពេក តើអ្នកអានគេអាចយល់ដល់ការសរសេររបស់យើងដែរឬទេ ? តើអ្នកអានគេព្រមទទួលយកតាមគំនិតយើងឬទេ ?។

អត្ថបទស៊ីជម្រៅ (article de fond) គេត្រូវប្រុងប្រយ័ត្នជានិច្ចអំពីការភ្ជាប់ខ្លឹមសារពីប្រយោគមួយទៅប្រយោគមួយ ពីកថាខណ្ឌមួយទៅកថាខណ្ឌមួយ ជាពិសេសការប្រើប្រយោគដែលផ្តើមដោយពាក្យ "*ទោះជាយ៉ាងណាក៏ដោយ*", "*បើពុំនោះទេ*"," *បានសេចក្តីថា*", "*ម្យ៉ាងវិញទៀត*", "*ពោលគឺ*", ។ល។ ក្នុងករណីប្រើពាក្យទាំងនេះ យើងត្រូវត្រួតពិនិត្យម្តងហើយម្តងទៀត ដើម្បីឱ្យវាយោងន័យបានត្រឹមត្រូវ ងាយស្រួលឱ្យអ្នកអានគេយល់ន័យបានច្បាស់លាស់។

៨-សន្ទថា :

អ្វីទៅជាសង្កថា ?

សង្កថាគឺជា ពាក្យសន្ទនា, ការសន្ទនាគ្នា, ការថ្លែងសេចក្តីអ្វីៗ ដោយមាត់ទទេទៅរកគ្នាត្រង់ទៅត្រង់មកតែម្តង ។

៩-បាឋកថា :

អ្វីទៅជាបាឋកថា ?

នៅក្នុងវចនានុក្រមខ្មែរ បាឋកថា ន. (បា. សំ.)សម្តីថ្លែង សេចក្តី (មាត់ទទេ), កថាសម្តែងរឿងរ៉ាវ, កថាសូត្របាលី ។

ជាទូទៅកាលណាគេហៅអ្នកណាម្នាក់មកធ្វើបាឋកថា បាឋកថាជាសុន្ទរកថាថ្លែងដោយមាត់ទទេដោយឥតព្រាងទុក គឺជាការថ្លែងសេចក្តីដោយមាត់ទទេនូវរឿងរ៉ាវផ្សេងៗឬអាចជាបច្ចេកទេសអ្វីមួយ ដែលលោកអ្នកឡើងថ្លែង ជាអ្នកមានបទពិសោធន៍ ឬ ជាអ្នកជំនាញលើមុខការអ្វីមួយច្បាស់លាស់រួចហើយគាត់មកថ្លែងក្នុងលក្ខណៈជាពិធីសំណេះសំណាលផង បង្ហាញផងបង្រៀនផងឱ្យជាចំណេះដឹង ជាបទពិសោធន៍ដល់សិក្ខាកាមដែលចូលរួមស្តាប់ដើម្បីទុកជាមេរៀន ជាចំណេះចេះដឹង ឬ ជាបទពិសោធន៍រៀងខ្លួន ។

## ១០-ចំណាប់អារម្មណ៍ :

ចំណាប់អារម្មណ៍គឺជាការចាប់អារម្មណ៍ទៅលើព្រឹត្តិការណ៍ ឬ ពិធីនានាដែលយើងបានចូលរួម។ ប្រសិនបើយើងបានចូលរួមក្នុងពិធីប្រជុំ ឬ សន្និសីទណាមួយក្នុងនាមជាអធិបតី ឬ ជាភ្ញៀវកិត្តិយសនៃពិធីនោះ ហើយត្រូវគេអញ្ជើញយើងឱ្យឡើងធ្វើការចាប់អារម្មណ៍នៅពេលបញ្ចប់កម្មវិធី ជាដំបូងយើងត្រូវពោលពាក្យសរសើរដល់កម្មវិធី និងអ្នករៀបចំកម្មវិធីនេះ ដែលប្រកបទៅដោយអត្ថន័យ និងខ្លឹមសារយ៉ាងជ្រាលជ្រៅ។ បន្ទាប់មកទើបយើងចាប់ផ្ដើមនិយាយចាប់អារម្មណ៍ខ្លាំង ឬ និយាយសង្កត់ធ្ងន់ទៅលើអត្ថន័យនៃពិធីនោះ រៀបរាប់ពីផលប្រយោជន៍ដែលបានពីពិធីនោះ ថាវាបានផ្ដល់នូវមេរៀនបទពិសោធន៍ចំណេះដឹងថ្មីៗយ៉ាងណាខ្លះដល់អ្នកចូលរួម ដល់ប្រជាជន ដល់សង្គមជាតិទាំងមូល។ ហើយអ្នកយល់ថា គួរមានយោបល់អ្វីខ្លះ ដែលត្រូវបន្ថែមពីលើការរៀបចំពិធីនោះដែរឬទេ ?។ បើឃើញមាននូវចំណុចខ្វះខាតខ្លះ អ្នកគួរបន្ថែមដូចម្ដេចដែលគេស្ដាប់ទៅក្នុងន័យមិនមែនជារបៀបស្ដីបន្ទោស ប៉ុន្តែ ក្នុងន័យជាការបំពេញបន្ថែម ឬ ក្នុងនាមជាអ្នកមានបទពិសោធន៍ម្នាក់។ ចុងបញ្ចប់នៃចំណាប់អារម្មណ៍របស់អ្នក មិនត្រូវភ្លេចពោលពាក្យលើកសរសើរ ចំពោះអ្នករៀបចំ

កម្មវិធី ឬ គណៈកម្មការរៀបចំកម្មវិធីនោះ និងលើកសរសើរពីរបៀបរៀបចំនៃដំណើរការពិធីនោះ សាជាថ្មីម្តងទៀតដែរ ។

**១១- វិយោគកថា :**

វិយោគកថា គឺជាការថ្លែងតម្អូញរៀបរាប់នូវទុក្ខសោក ស្តាយស្រណោះដល់បុគ្គលដែលបានទទួលមរណភាពទៅ គឺគេថ្លែងពីជីវប្រវត្តិរបស់បុគ្គលដែលស្លាប់នោះដោយរៀបរាប់ពីស្រុកកំណើត ឈ្មោះឪពុក ម្តាយ បងប្អូន កូនចៅ ប្តីឬប្រពន្ធ និងរៀបរាប់ពីស្នាដៃល្អៗ ទាំងឡាយដែលបុគ្គលនោះបានបន្សល់ទុក ។

វិយោគកថា គេថ្លែងនៅពេលដែលសពបានដង្ហែទៅដល់ឈាបនដ្ឋាន ឬដល់កន្លែងបញ្ចុះ (កន្លែងកប់) ។ មុននឹងថ្លែង វិយោគកថា អ្នកថ្លែងត្រូវសម្តែងនូវការគោរព ថ្លែងពាក្យគោរពចំពោះភ្ញៀវ និងញាតិមិត្តដែលបានចូលរួមក្នុងពិធីនោះផងដែរ ។ នៅពេលថ្លែង វិយោគកថាចប់ អ្នកក៏មិនត្រូវភ្លេចថ្លែងនូវពាក្យអរគុណ និងជូនពរសព្ទសាធុការចំពោះភ្ញៀវ និងញាតិមិត្តឱ្យសោះ ។

## II- អំពីការនិពន្ធរឿង :

### ១- អ្វីទៅការនិពន្ធ ?

តាមវចនានុក្រមខ្មែរ *និពន្ធ* អាចជា :

*កិ.* (បា.) តែងឡើង, ចងក្រង, រៀបរៀង ។ ឧ. និពន្ធពង្សាវតារ, និពន្ធរឿងប្រលោមលោក ។

*គុ.* ដែលចងហើយ, ដែលតែងហើយ, ដែលសម្រេចឱ្យមានកម្រិតហើយ... ។ ឧ. រឿងនិពន្ធ... ។

*ន.* ចំណង (សេចក្ដី), សេចក្ដីតែង, ពំនោល ។ល ។ ឧ. ព្រះនិពន្ធ, ព្រះរាជនិពន្ធ ។

ជាទូទៅការនិពន្ធ គឺជាការសរសេររៀបរៀង ការតាក់តែង ការចងក្រងនូវព្រឹត្តិការណ៍ ហេតុការណ៍ សកម្មភាព ប្រវត្តិ រឿងរ៉ាវផ្សេងៗ ដែលកើតមាននៅក្នុងសង្គម ឬ ចំណេះដឹងទាំងឡាយតាមរយៈអ្នកសរសេរធ្លាប់បានឆ្លងកាត់ក្ដី ឬ តាមរយៈការសិក្សាស្រាវជ្រាវក្ដី ។ ចំពោះរឿងប្រលោមលោក ឬ រឿងផ្សេងៗទៀត ពេលខ្លះអ្នកនិពន្ធសរសេរតាមការស្រមៃរបស់ខ្លួន តាមការប្រឌិតរបស់ខ្លួន ឬ តាមរយៈនៃការឆ្លុះបញ្ចាំងតថភាពសង្គម ។

## ២-គោលបំណងអ្នកនិពន្ធ :

ការសរសេរចងក្រងនូវរឿងរ៉ាវពិតក្តី ពុំពិតក្តី ឬជា រឿងប្រឌិតក្តី អ្នកនិពន្ធមានបំណងបម្រើសេចក្តីត្រូវការផ្នែកអារម្មណ៍ និងផ្នែកស្មារតីរបស់អ្នកអាន ដើម្បីជាគ្រឿង ***កម្សាន្តសប្បាយ, ជាព័ត៌មាន និងជាការអប់រំ***។ អ្នកនិពន្ធចង់ផ្តល់នូវចំណេះដឹងទាំងឡាយដែលខ្លួនមាន ចែកចាយដល់មិត្តអ្នកអានបានចេះដឹងនូវអ្វីៗដែលគេមិនបានដឹងពីមុននោះឱ្យបានដឹង បានយល់ពីរឿងរ៉ាវទាំងឡាយដែលកើតមាននៅក្នុងសង្គម។ រាល់ការនិពន្ធ អ្នកនិពន្ធក៏មិនត្រូវភ្លេចពីកាតព្វកិច្ចរបស់ខ្លួន ដែលជាអ្នកបញ្ចូលនូវវិធីអប់រំដល់អ្នកអាន អ្នកទស្សនារបស់ខ្លួនពីតម្លៃរបស់មនុស្សជាតិ សិទ្ធិរបស់មនុស្សជាតិ (សិទ្ធិនៃការរស់រានមានជីវិត, សិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស, សិទ្ធិរបស់មនុស្សគ្រប់គ្នាក្នុងការគោរពច្បាប់រដ្ឋ...), សីលធម៌ វិន័យ វប្បធម៌ ប្រពៃណីរបស់ជាតិខ្លួននោះទេ។ តាមរយៈស្នាដៃអ្នកនិពន្ធ **កាប់ ឆិនកូ** ស្តីពីបុគ្គលិកលក្ខណៈរបស់អ្នកនិពន្ធ និងវិវត្តន៍នៃអក្សរសិល្ប៍បានសរសេរថា *"...វិវត្តន៍មនោគមវិជ្ជារបស់អ្នកនិពន្ធគឺជា ដំណើរការស្និតស្នេរផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងស្នាដៃរបស់គាត់ និងការអធិប្បាយរបស់គាត់ស្តីពីបញ្ហាទាំងឡាយដែលលេចចេញឡើងនៅក្នុងជីវភាព..."*, *"អ្នកនិពន្ធត្រូវបាន*

*ចាត់ទុកជាអ្នកផ្តល់ព័ត៌មានដ៏សកម្ម និងជាអ្នកដឹកនាំដំណើង យ៉ាងរហ័សរហួននូវព្រឹត្តិការណ៍ផ្សេងៗ, ការផ្លាស់ប្តូរនូវជីវភាពនៃទិដ្ឋភាពខុសៗគ្នា និងដោយឡែកៗ ..."* [៥] ។

ជារួម អ្នកនិពន្ធមុននឹងសរសេរនូវរឿងរ៉ាវអ្វីមួយ ត្រូវដឹងថា ខ្លួននិពន្ធរឿងមួយដើម្បីអ្វី ? ដើម្បីការកម្សាន្តសប្បាយ ឬ ដើម្បីផលប្រយោជន៍របស់ខ្លួន ? ឬក៏និពន្ធដើម្បីជាប្រយោជន៍របស់មនុស្សជាតិ ( ដូចជាការអប់រំទូន្មានប្រៀនប្រដៅ ឬ រិះគន់ដល់បុគ្គលទាំងឡាយដែលកំពុងប្រព្រឹត្តខុសឆ្គងចំពោះប្រជាជន និងប្រទេសជាតិ ឬ រិះគន់ពីបុគ្គលមួយចំនួនដែលកំពុងតែភ្លើតភ្លើននឹងសម្ភារៈនិយម ឬរិះគន់ពីសង្គមដែលកើតជំងឺពុករលួយ )? ។

## ៣-មធ្យោបាយដើម្បីក្លាយជាអ្នកនិពន្ធ :

ដើម្បីក្លាយខ្លួនជាអ្នកនិពន្ធមួយរូប មិនមែនជាការចៃដន្យ ឬ ជាការផ្សងព្រេងនោះឡើយ ។ ខាងក្រោមនេះជាវិធីខ្លះៗ ដើម្បីក្លាយទៅជាអ្នកនិពន្ធមួយរូប

[៥] សូមមើល ពៅ សាមី : "ទ្រឹស្តីអក្សរសិល្ប៍ លក្ខណៈទំនោរនៃអក្សរសិល្ប និងសិល្បៈ " ភាគ២ គ.ស.១៩៩៣ ទំព័រ១៦ ។

ដែលជាបទពិសោធន៍របស់រៀមច្បងយើងមួយចំនួន ដែលលោកធ្លាប់ឆ្លងកាត់ ៖

K  អ្នកត្រូវតែជាអ្នកពូកែចងចាំនូវរឿងរ៉ាវអ្វីៗ  ដែលអ្នកធ្លាប់បានជួបប្រទះតាំងតែពីអ្នកនៅពីវ័យក្មេងរហូតមក ។ ពេលខ្លះ អ្នកជួបវាតែម្តង អ្នកអាចចងចាំវាបានរហូត ។

K ការអានសៀវភៅច្រើន (សៀវភៅផ្សេងៗ, ឯកសារ, ទស្សនាវដ្តី, កាសែត, កីឡា, ភាពយន្ត, រឿងរ៉ាវប្រវត្តិសាស្ត្រ,ភូមិវិទ្យា, វប្បធម៌, ប្រពៃណី, ទំនៀមទំលាប់,   ព័ត៌មានពីបរទេស ។ល ។) អានហើយទាមទារការចងចាំបានល្អទៀត ។

K ចូលប្រឡូកក្នុងសង្គម ដូចជា ធ្វើការងារសង្គមផ្សេងៗ ជារួម ស្គាល់ឱ្យគ្រប់មជ្ឈដ្ឋានសង្គម    (តាំងពីអ្នកតូចតាចរហូតដល់អ្នកមានឋានៈខ្ពង់ខ្ពស់, ស្គាល់តាំងពីអ្នកក្រីក្ររហូតដល់អ្នកមាន ឬ សេដ្ឋី ជាដើម) ។

K ត្រូវយល់ពីរបៀបនៃការងារឱ្យបានច្រើនជំនាញ ។

K ត្រូវចេះស្តាប់នូវរឿងរ៉ាវអ្វីៗឱ្យបានជាក់ច្បាស់ ។

K ត្រូវចេះសង្កេតរឿងហេតុអ្វីមួយឱ្យបានគ្រប់ជ្រុងជ្រោយ   គឺត្រូវចេះតាមដានរឿងហេតុទាំងនោះឱ្យដល់ឫសគល់(ដឹងហេតុផល) ។

Kវិភាគ ពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយនូវរឿងរ៉ាវទាំងឡាយ ដែលអ្នកបានស្តាប់ បានសង្កេតមកហើយនោះ ។

Kត្រូវចេះកត់ត្រាទុកនូវរឿងរ៉ាវដែលបានវិភាគ ពិចារណា រួចហើយ ។

Kត្រូវចេះសិក្សាស្រាវជ្រាវ :

ស្រាវជ្រាវតាមរយៈឯកសារ (ការអាន, កត់ត្រា) ។

តាមការអនុវត្តផ្ទាល់ (ចូលប្រឡូកក្នុងសកម្មភាពសង្គម) ។

Kត្រូវចេះសេពគប់មនុស្សឱ្យបានគ្រប់វ័យ ដើម្បីស្វែងរក :

-បញ្ហាដែលកើតមានឡើងចំពោះអ្នកទាំងនោះ បើអ្នកចង់សរសេរពីអ្នកក្រីក្រ អ្នកត្រូវស្វែងរកមនុស្សក្រីក្រទាំងនោះ សេពគប់ជាមួយពួកគេ ដើម្បីបានព័ត៌មានច្បាស់លាស់ពីជីវិត ពិតប្រាកដរបស់ពួកគេ ។

បើអ្នកចង់សរសេរពីតុលាការ អ្នកត្រូវសេពគប់ជាមួយអ្នកជំនាញខាងតុលាការ ។ ពេលខ្លះត្រូវការអ្នកជំនាញ ដើម្បីស្វែងយល់ឱ្យស៊ីជម្រៅអំពីបញ្ហានានាដែលអ្នកចង់លើកឡើងនៅក្នុងរឿងរ៉ាវរបស់ខ្លួន ។

Kត្រូវមានចំណេះដឹងសង្គម វប្បធម៌ សីលធម៌ សុជីវធម៌ ប្រពៃណីទំនៀមទម្លាប់ ទស្សនៈវិជ្ជា សង្គមវិជ្ជា ចិត្តវិទ្យា... ។

## ៤-គំនិតខ្លះៗដើម្បីសរសេររឿង :

រាល់ការតាក់តែងរឿងមួយ អ្នកត្រូវមានចំណុចសំខាន់ៗដូចខាងក្រោម :

K **ឧត្តមគតិ** : ភាពត្រឹមត្រូវ, យុត្តិធម៌, ស្អាតស្អំ, ស្គាល់អត្តសញ្ញាណជាតិច្បាស់លាស់ ។

K **គោលដៅ** : នៅពេលចាប់ផ្តើមសរសេររឿងមួយ អ្នកត្រូវសួរខ្លួនឯងថា យើងចង់បានអ្វីពីស្នាដៃនេះ ?។ នៅពេលយើងដឹងពីអ្វីដែលយើងចង់បាន (ដូចជា អប់រំដល់យុវវ័យ, អប់រំពីសុខភាពផ្លូវភេទ, រិះគន់ពីអំពើពុករលួយ, ពីប្រព័ន្ធតុលាការឯករាជ្យ...) យើងចាប់ផ្តើមសរសេរអត្ថបទមិនឃ្លេងឃ្លោងប្រាសចាកប្រធានបទ អាចហៅថា **ការកំណត់ប្រធានបទ** ឱ្យបានច្បាស់លាស់ ។

K **គោលបំណង** : នៅពេលយើងដឹងច្បាស់ពីគោលដៅរបស់យើងថា យើងត្រូវសរសេរអំពីអ្វីហើយនោះ (កំណត់ប្រធានបទរួចហើយ) យើងនឹងដឹងថា យើងត្រូវតែបង្ហាញអ្វីដល់អ្នកអាន (ការបង្កើតសាច់រឿង) ។

K **ក្រុមគោលដៅ** : នៅពេលយើងបង្ហាញអ្វីៗ ជាគោលបំណងរបស់យើង យើងត្រូវដឹងពីក្រុមគោលដៅរបស់យើង ថាយើងសរសេរសម្រាប់អ្នកណា ? (សម្រាប់យុវវ័យ ?, សម្រាប់មនុស្សចាស់ ?, សម្រាប់តែស្ត្រី ?, ឬ

សម្រាប់តែអ្នកដឹកនាំ?) ។ល។ យើងកំណត់ក្រុមគោលដៅបានហើយ ពេលនោះយើងអាចចាប់ផ្តើមសរសេរសាច់រឿងទៅតាមនោះបានយ៉ាងល្អ។

K **លទ្ធផលរំពឹងទុក និងប្រសិទ្ធភាព** : នៅពេលយើងកំណត់ក្រុមគោលដៅបានហើយ លទ្ធផលរំពឹងទុក និងប្រសិទ្ធភាពដែលជាប្រយោជន៍ដល់អ្នកអាន ដល់ខ្លួនយើង និងដល់សង្គម ប្រាកដជាកើតមានជាក់ជាមិនខាន។

**៥-របៀបខ្លះៗនៅពេលតាក់តែងរឿង :**

K ត្រូវចេះរៀបគ្រោងឆ្អឹងរឿងជាមុនសិន។

K រិះរកចំណុចរួមនៃបញ្ហា

K ត្រូវមានអារម្មណ៍ល្អនៅពេលចាប់ផ្តើមសរសេរ ឬពេលមានអារម្មណ៍ល្អត្រូវចាប់ផ្តើមសរសេរភ្លាមមិនចាំបាច់ជ្រើសរើសពេលវេលា ឬទីកន្លែងសរសេរទេ ទីណាក៏បាន វេលាណាក៏កើត។

K ពេលមានឧបាយោជន៍ (នឹកឃើញភ្លាមៗដោយមិនបានគ្រោងទុក ឬមិនបានគិត) ត្រូវកត់ត្រាភ្លាមៗ (ទោះនៅទីណា វេលាណាក៏ដោយខ្លាចភ្លេចបាត់ទៅវិញព្រោះឧបាយោជន៍ងាយនឹងភ្លេចទៅវិញណាស់ ពេលខ្លះរកនឹកឡើងវិញមិនឃើញទេ)។

K ត្រូវមានគំនិតផ្តួចផ្តើម និងគំនិតថ្មីៗប្លែកៗរហូត ។

K ត្រូវតែក្លាហាន ព្យាយាម តស៊ូ និងមានអំណត់ ។

K ត្រូវមានពេលវេលាមួយត្រួតពិនិត្យឡើងវិញ នូវអត្ថបទដែលបានសរសេររួច (ទុកកាន់តែយូរ ពិនិត្យកាន់តែច្រើនដង កាន់តែល្អ) ។

## III-ការនិពន្ធរឿងប្រលោមលោក :

### ១-និយមន័យប្រលោមលោក :

ន័យតាមវចនានុក្រមខ្មែរ *ប្រលោមលោក ន.* រឿងប្រលោមចិត្តមនុស្សលោក គឺរឿងដែលអ្នកតែងប្រឌិតប្រដូចឡើងដោយឥតមានច្បាប់ដើមជាការណ៍ពិតប្រាកដជាគោលចារឹកឡើយ ។ ប្រលោមលោកនេះ ក្នុងសម័យពីដើម ហៅថាសាស្ត្រាល្បែង ឬ រឿងល្បែង, ខាងសម្រាយច្រើនតែតែងជាពាក្យកាព្យ ដូចជាសាស្ត្រាល្បែងផ្សេងៗមានច្រើនឈ្មោះ មានសាស្ត្រាស័ង្ខសិល្ប៍ជ័យ,លក្សណវង្ស, ហង្សយន្ត, ជិនវង្ស ជាដើម, ខាងបាលីច្រើនតែជា បកិណ្ណៈ ឬ វេយ្យាករណបាឋ គឺជាពាក្យបាលីរាយៗ ជួនមានគាថាបាលីបញ្ចូលមកខ្លះដោយអន្លើៗ ដូចបញ្ញាសជាតក ជាដើម, រឿងឬសាស្ត្រាទាំងនោះ ទោះជាកាព្យក្តី សម្រាយក្តី ជាបាលីក្តី ហៅថាសាស្ត្រាល្បែង ឬ រឿងល្បែងដូចគ្នា, ត្រូវគ្នានឹង រឿង ឬ សាស្ត្រា,

សៀវភៅប្រលោមលោកសម័យបច្ចុប្បន្ននេះ។ ប៉ុន្តែតាមការពិនិត្យឃើញថា ប្រលោមលោកសម័យឥឡូវនេះមាន ៣ប្រភេទគឺ ប្រលោមលោកស្នេហា, ប្រលោមលោកកសាងជីវភាពខ្លួន, ប្រលោមលោកប្រវត្តិសាស្ត្រ, ទាំង៣ប្រភេទនេះ សុទ្ធតែមានអត្ថន័យផ្សេងទីទៃពីគ្នា... (ម.ព. ជីវភាព, ប្រវត្តិ សាស្ត្រ "ក្នុងពាក្យ បវត្តិ ឬ ប្រវត្តិ" ស្នេហា ផង)។ សាស្ត្រាល្បើកក្នុងសម័យដើម ដូចជាល្បើកជូជក, ល្បើកមហារាជ ដែលគេបំផ្លើសក្នុងរឿងមហាជាតក៏ជាដើម ក៏រាប់ថាជាប្រលោមលោកបានដែរ ព្រោះតែតែងឡើងគ្រាន់នឹងប្រលោមឱ្យអ្នកអានអ្នកស្តាប់សើចសប្បាយ ...។ (ជ.ណ.ទំព័រ ៦៦៥-៦៦៦)។

ជាទូទៅប្រលោមលោក គឺជាប្រភេទរឿងអក្សរសិល្ប៍មួយផ្នែក ដែលអ្នកតែងប្រឌិតឡើងដោយប៉ុនប្រសប់ប្រកបដោយល្បិចកិច្ចកល។ គេតែងអំពីវិបត្តិទំនាស់របស់មនុស្សក្នុងសង្គម ដោយដំណើររឹករវ រំជើបរំជួល មានការផ្សងព្រេង ប្រយុទ្ធប្រឆាំងគ្នា ស៊ើបអង្កេត តាមដាន ចារកម្ម ការច្រណែននិន្ទាឈ្នានីស ។ល។ ដោយប្រើវិធីប្រលោមអ្នកអាន អ្នកស្តាប់ឱ្យអណ្តែតអណ្តូង មានអារម្មណ៍ភ័យ តក់ស្លុត ញាប់ញ័រ រំភើប ខឹង ស្អប់ ក្តាញ់ អាណិត អាសូរ ស្រឡាញ់ សប្បាយរីករាយខុសពីធម្មតា ហាក់បីដូចជាឋិតនៅក្នុងបរិយាកាស

មួយប្លែកពីធម្មតា។ ប្រលោមលោកអាចនិពន្ធវែងអន្លាយ មានច្រើនភាគច្រើនខ្សែ ឬ អាចនិពន្ធជារឿងខ្លីៗក៏បាន។

## ២-ទិដ្ឋភាពសំខាន់ដែលត្រូវមានក្នុងប្រលោមលោក :

ដើម្បីនិពន្ធរឿងប្រលោមលោកមួយល្អ អ្នកនិពន្ធត្រូវគិតទៅដល់ទិដ្ឋភាពសំខាន់ៗ៣យ៉ាងគឺ *អត្ថន័យ អត្ថរូប និងអត្ថរស* នៃរឿងនោះ ដែលប្រៀបបីដូចជាស្នូលរបស់រឿង។

### ២.១-អត្ថន័យ [៦] : (ទិដ្ឋភាពបញ្ហារឿង)

ការនិពន្ធរឿងនីមួយៗ អ្នកនិពន្ធមានគំនិតផ្តួចផ្តើមបង្កើតរឿងឱ្យមានលក្ខណៈបែបណាមួយនោះ គេត្រូវចេះដកស្រង់យកនូវដំណើររឿងរបស់មនុស្សដែលមានជាក់ស្តែងក្នុងសង្គម មានជាប់ទាក់ទងទៅនឹងជីវភាពរស់នៅរបស់មនុស្សជារឿងបន្តិចបន្តួចក្តី ឬ ជារឿងមួយដែលធ្លាប់ឮគេនិទានតំណាលតៗគ្នាក្តី មកចងក្រងប្រមូលផ្តុំបង្កើតឱ្យបានទៅជាដំណើររឿងដ៏វែងមួយ ដោយមានតួអង្គជាមនុស្សក្នុងសង្គមឋិតក្នុងសម័យកាលណាមួយ ដែលនោះគឺជាការបង្កើតឬ

[៦] សូមមើល លាង ហាប់អាន : សិក្សាអត្ថបទ (សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) គ.ស.១៩៦៦ ទំព័រ៧៣-៧៤។

ការកំណត់នូវប្រធានរឿងមួយ។ ការបង្កើតបានប្រធានរឿងរួចហើយ អ្នកនិពន្ធត្រូវចេះបង្កើតនូវបញ្ហារឿង តើយើងចង់ឱ្យដំណើររឿងរបស់យើងមានដំណើររឿងទៅយ៉ាងដូចម្ដេច ?។ យើងត្រូវបង្កើតបញ្ហាទំនាស់ ឬ វិបត្តិ ដូចជាទំនាស់រឿងស្នេហា ទំនាស់ប្រពៃណីទំនៀមទម្លាប់តឹងតែងចាស់គំរិល រឿងរ៉ាវប្ដីប្រពន្ធ ទំនាស់ពីរឿងច្រណែននិន្ទាឈ្នានីសគ្នា បំផ្លាញគ្នា សងសឹកគ្នារវាងបងប្អូន កូនចៅឯង ឬជាមួយអ្នកដទៃ ដែលកើតឡើងពីការលោភលន់អគតិ បង្កើតភាពអយុត្តិធមិ ព្យាបាទគ្នា។ល។ ឬយកទស្សនៈល្អៗអាចជាទស្សនៈផ្ទាល់ខ្លួន ជានិន្នាការរបស់ខ្លួនមកបញ្ចូលក្នុងផ្ទៃរឿងដើម្បីជាការអប់រំទូន្មាន ឬ ដើម្បីបង្កើតគំនិតដល់អ្នកអានឱ្យចេះធ្វើការពិចារណា រកហេតុ រកផលឱ្យគេយល់ដឹងនូវអំពើទាំងឡាយ អ្វីដែលគួរធ្វើ អ្វីដែលមិនគួរធ្វើ ជាដើម។ ការរៀបដំណើររឿងត្រូវចេះចោទ និងស្រាយបញ្ហានីមួយៗឱ្យបានសមស្របទៅតាមតថភាពនៃសម័យកាលសង្គម។ ការចោទបញ្ហា ឬស្រាយបញ្ហានីមួយៗ ត្រូវមានហេតុផល ឬក៏បង្ហាញហេតុផល និងបំណងឱ្យបានច្បាស់លាស់។

ដើម្បីដោះស្រាយហេតុផល ត្រូវមានវិធីឱ្យតួអង្គនីមួយៗ ប្រើវិធីអ្វីឱ្យសមស្របនឹងតថភាព ? ហើយត្រូវចេះបង្កើតសភាពការណ៍តឹងតែងខ្លាំងកម្រិត

ណា ឬធូរស្រាលកម្រិតណា ? ឱ្យជាផលយ៉ាងណា ? ផលវិបាកត្រូវឱ្យតួអង្គមួយណាទទួលលទ្ធផលយ៉ាងដូចម្ដេច ? ។ គឺត្រូវធ្វើឱ្យដំណើររឿងមានដំណាក់ដំណើរកាច់កុង កន្ទុកកន្ទ្បៀត លាក់សាច់រឿងត្រង់ណាខ្លះ ? ដើម្បីធ្វើឱ្យអ្នកអានចាប់អារម្មណ៍ចង់តាមដានរឿងជានិច្ច។ អ្នកនិពន្ធត្រូវគិតថា រឿងយើងនិពន្ធត្រូវបញ្ចូលគំនិតអប់រំនៅត្រង់ចំណុចណាខ្លះ ? ។

**២.២- អត្ថរូប :** (ទិដ្ឋភាពតំណែងនិពន្ធ)

កាលណាយើងមានគំនិតបង្កើតបញ្ហារឿង បញ្ហាទំនាស់ក្នុងសាច់រឿងរួចហើយ យើងត្រូវចេះរៀបពាក្យពេចន៍ ប្រយោគ ឃ្លាឃ្លោងក្នុងការនិយាយឆ្លងឆ្លើយពីតួអង្គមួយទៅតួអង្គមួយ។ ការព័ណ៌នាទេសភាពធម្មជាតិជាដើមពាក្យពេចន៍ត្រូវតែ ផ្អែមល្ហែម ល្អកល្អឺន រអាករអាយ លួងលោម បញ្ចោសអង្អែល ថ្នាក់ថ្នម ពេបជ្រាយ ឌឺដង ខ្ទក់ខ្ទាញ់ ...។ល។ ក្នុងការប្រើពាក្យពេចន៍ពីតួអង្គមួយទៅតួអង្គមួយ ត្រូវចេះប្រើទៅតាមវ័យ ភេទ និង ឋានៈ (ក្រមុំ, កំលោះ, មេម៉ាយ, ចាស់ ក្មេង, អ្នកបួស, អ្នកធំ, ស្ដេច...) គឺពាក្យសម្ដីត្រូវប្រើខុសៗគ្នា។

ការប្រើឃ្លាក្នុងប្រលោមលោកត្រូវឱ្យពីរោះ ហើយរលូន គឺ ឃ្លានីមួយៗ

មានលក្ខណៈឆ្លើយឆ្លងគ្នា ប្រើពាក្យកម្រងកែវឱ្យមានលក្ខណៈរណ្ដំប្រទាក់ប្រទង គ្នា។ គេច្រើនប្រើនូវរូបារម្មណ៍សម្រាប់ទាក់ចិត្តអ្នកអានឱ្យរំភើប ឱ្យសង្វេគ អនិច្ចា សប្បាយ ខ្សឹកខ្សួល ឬ ទុក្ខព្រួយជាដើម ដូចជាប្រើពាក្យសម្ដីរស់រវើក បង្កើតបាននូវជីវរូបារម្មណ៍, បង្កើតនូវឧបមានរូបបារម្មណ៍, ក្នុងការប្រៀបធៀប ប្រើនូវឥន្ទ្រិយរូបារម្មណ៍, ទាក់ទងទៅនឹងរូបរាងកាយ ចក្ខុ, សោត, និង ជិវ្ហិន្ទ្រិយ៍ ឬ ទាក់ទងទៅនឹងកាមតណ្ហាបង្កើតជាកាមរូបារម្មណ៍ ឬ បង្កើតជានិមិត្តរូបារម្មណ៍។ លក្ខណៈនៃការតាក់តែងនេះហើយ ដែលអ្នកនិពន្ធខិតខំរកពាក្យពេចន៍ឃ្លាឃ្លោង ចេះបង្កើតនូវព័ណ៌នាវិធី, វឌ្ឍមានវិធី (វិធីរុញច្រានដំណើររឿងឱ្យកាន់តែតឹងតែងឡើង១) ឧបមានវិធី, វិធីបញ្ច្រាសន័យ គឺចេះធ្វើយ៉ាងណាឱ្យមានហេតុតូចឱ្យផលធំ ហេតុធំឱ្យផលតូច...ឱ្យទៅជាគ្រឿងបំពេរអារម្មណ៍ ប្រលោមចិត្តគំនិតអ្នកអានឱ្យភ្លេចកង្វល់ ឱ្យកើតសន្ទុះចិត្តពុះពោរទៅតាមឧត្តមគតិរបស់អ្នកនិពន្ធ ដែលគេឱ្យឈ្មោះថា *ប្រលោមលោក* នេះឯង។

ក្នុងការបែងចែកសាច់រឿង ត្រូវចេះបែងចែកផ្ទៃរឿងឱ្យមានជាវគ្គ ជាសង្កាត់ ដើម្បីកុំឱ្យវែងពេកដែលបង្កឱ្យមានលក្ខណៈសាំញ៉ាំ។ ពីវគ្គមួយទៅវគ្គមួយត្រូវឱ្យមានលក្ខណៈបន្តគ្នា ដោយភ្ជាប់សាច់រឿងមួយទៅសាច់រឿងមួយ

ទៀត ធ្វើឱ្យអ្នកអានគេមានចិត្តចង់តាមដានដំណើររឿងតទៅមុខទៀត។

**២.៣ អត្ថរស :**[៧]

ប្រលោមលោកមានការពិតតិចណាស់។ ដូច្នេះតម្លៃជាមូលដ្ឋានឋិតនៅលើមនោគតិ ឋិតនៅលើការប្រលោមនេះឯងដែលហៅថា ប្រលោមរស។ ដើម្បីបង្កើតនូវប្រលោមរសនេះ អ្នកនិពន្ធត្រូវប្រើប្រលោមវិធីដោយយកការសង្កេតមកតុបតែងបង្កើតជារឿង ដើម្បីធ្វើយ៉ាងណាទាក់ទាញ មនោគតិ ចិត្តគំនិតអ្នកអានឱ្យញាប់ញ័រឱ្យប្លែកឡើងក្នុងវត្ថុបំណងឱ្យពួកគេបានទទួលនូវតម្លៃជាតិ តម្លៃអប់រំ និងតម្លៃរីកចម្រើន។

**៣-ការណែនាំខ្លះៗដើម្បីតែងរឿងប្រលោមលោក :**

នៅក្នុងទិដ្ឋភាពសំខាន់ៗដើម្បីសរសេរប្រលោមលោកខាងលើ យើងបានស្គាល់បានដឹងរួចមកហើយនូវវិធីតែងរឿង។ ជាបន្តទៅទៀតនេះ គឺជាចំណេះដឹងបន្ថែមដើម្បីការសរសេររឿងរបស់យើងឈានទៅរកសុក្រឹតភាព ឬ ជាពន្លឺមួយជួយក្នុងការតែងនិពន្ធ។

---

[៧] សូមមើល លាង ហាប់អាន : សិក្សាអត្ថបទ ( សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ ) គ.ស.១៩៦៦ ទំព័រ៧៧-៧៨។

## ៣.១-ការរំលេចផ្ទៃរឿងឱ្យមានសោភ័ណភាព ៖

K ត្រូវប្រើពាក្យសម្ដីផ្អែមល្ហែម លួងលោម បបោសអង្អែល ផ្ទាក់ផ្ទួម ល្អូកល្អឺន រអាក់រអាយ ស្អិតរមួត ពេបជ្រាយ ឌឹដង ខ្ទក់ខ្ទាញ់ ឡែបខាយ...។

K ការប្រើពាក្យពេចន៍ ត្រូវចេះប្រើទៅតាមវ័យ តាមឋានៈ តាមលំដាប់លំដោយខ្ពស់ទាប និងតាមកាលៈទេសៈនៃវគ្គ ឃ្លារបស់សាច់រឿង ឬអាចនិយាយថា ប្រើទៅតាមបរិយាការណ៍នៃសាច់រឿង។

K ការប្រើឃ្លាប្រយោគនៅក្នុងប្រលោមលោកត្រូវតែពីរោះ ហើយឱ្យរលូន (ឃ្លានីមួយៗឱ្យមានលក្ខណៈឆ្លើយឆ្លងគ្នា) ប្រើពាក្យកម្រងកែវជាដើម។

K អ្នកនិពន្ធសរសេរឆ្លុះបញ្ចាំងពីតថភាពសង្គមពិតៗផ្សារភ្ជាប់នឹងអត្ថន័យ ឧត្ដមគតិជឿនលឿន ចេះប្រើសិល្បវិធីបញ្ចូលនូវអ្វីដែលជាឧត្ដមគតិ ខ្លឹមសារ ពុទ្ធិ អប់រំនៅក្នុងស្នាដៃរបស់ខ្លួន។ ជាមួយនោះ ការធ្វើឱ្យសាច់រឿងពីរោះជាប់ចិត្តធ្វើឱ្យអ្នកអានមាន ចំណង់ ជំនក់ចិត្ត និងមានចម្ងាញ់ នោះហើយជាស្នាដៃដែលមានលក្ខណៈសោភ័ណ។

## ៣.២-ការលាក់សាច់រឿង ៖

នៅក្នុងការតែងរឿង អ្នកនិពន្ធត្រូវចេះរិះរកវិធីលាក់សាច់រឿង ដូចជា ៖

ក-ការលាក់១ជាន់, ២ជាន់, ៣ជាន់...។

ខ-ការលាក់សាច់រឿងដោយឱ្យតួអង្គក្នុងរឿងដឹង តែអ្នកអាន អ្នកទស្សនាមិនដឹង )។

គ-ការលាក់សាច់រឿងដោយឱ្យអ្នកអាន អ្នកទស្សនាដឹង តែតួអង្គក្នុងរឿងមិនដឹង។

ដើម្បីយល់អំពីការលាក់សាច់រឿងនេះ សូមមិត្តអ្នកអានពិនិត្យឈុតនៃរឿងប្រឌិតមួយដូចខាងក្រោម ៖

**ក-ឧទាហរណ៍១ *"ការលាក់១ជាន់, ២ជាន់, ៣ជាន់ "***

K "...ថៅកែហៅសានមកជិត ហើយប្រាប់ឱ្យយកកាំភ្លើងចេញទៅក្រៅ។ បន្តិចមក សានត្រឡប់មកវិញទាំងត្រហេបត្រហប ខ្សឹបដាក់ត្រចៀកថៅកែ ថៅកែឆ្ងល់បើកភ្នែកធំៗ។ ក្រោយមកប៉ូលីសចាប់អាសុខ ចោទអាសុខថាជាអ្នកសម្លាប់អាឃុន។ បន្តិចក្រោយមក ប៉ូលីសបានដោះលែងអាសុខវិញ ព្រោះរកភ័ស្តុតាងមិនឃើញ។ ក្រោយមកប៉ូលីសរកភ័ស្តុតាងឃើញក៏ទៅនាំខ្លួនអាផុនអាភឹម ដែលជាអ្នកសម្លាប់អាឃុន...។"

ខ-ឧទាហរណ៍២ : *"ការលាក់សាច់រឿងដោយឱ្យតួអង្គក្នុងរឿងដឹង តែអ្នកអាន អ្នកទស្សនាមិនដឹង "*

K "...ថៅកែហៅសាន មកខ្សិបប្រាប់រួចឱ្យលុយ និងឱ្យយកកាំភ្លើងចេញ ទៅក្រៅបាត់ទៅ...។"

គ-ឧទាហរណ៍៣ : *" ការលាក់សាច់រឿងដោយឱ្យអ្នកអាន អ្នកទស្សនាដឹង តែតួអង្គក្នុងរឿងមិនដឹង "*

K "...មានពួកចោរ៣នាក់កំពុងតែពិភាក្សាគ្នានៅក្រោមដើមឈើចុងភូមិ ដោយគូសវាសដីក្រវេមក្រវាមរកផ្លូវទៅផ្ទះថៅកែសេង ដើម្បីប្លន់នៅយប់នេះ។ ពួកវានិយាយថា យប់នេះម៉ោងប៉ុន្មានជួបគ្នា ? គ្នាវាថាជួបគ្នាម៉ោងប្រាំបួនកន្លះ ម៉ោង១០ ចូលប្លន់តែម្តង។ ស្រាប់តែម៉ោង១០យប់ ស្នូរកាំភ្លើងលាន់ឮចេញពីផ្ទះថៅកែសេង ហើយថៅកែសេងត្រូវចោរបាញ់ចំទ្រូងមួយគ្រាប់។ ឳពុកថៅកែ សេង និងប្រពន្ធថៅកែសេងថា មិនដឹងជាចោរមកពីណាទេ ចូលមកប្លន់ហើយ បាញ់ប្តីគាត់ទៀត។ ប៉ូលីសថា នឹងស្រាវជ្រាវរកចោរ...។"

**៣.៣-ការកំណត់ចរិតតួ :**

Kត្រូវកំណត់ឱ្យតួអង្គនីមួយៗ ( ជាពិសេសតួឯក) មានលក្ខណៈអ្វីមួយ

ប្រចាំខ្លួន។ ឧ. នៅពេលឱ្យតួអង្គឯកម្នាក់កាន់កាំភ្លើង គេច្រើនមានទម្លាប់ពាក់វ៉ែនតាខ្មៅរួចសម្លាប់ ឬ តែកាលណាតួអង្គឯកចេញសម្លាប់ ត្រូវតែពាក់វ៉ែនតាខ្មៅ សម្លាប់រួចហើយដាក់ផ្កា១ទង នៅលើសាកសព...ជាដើម។

K នៅក្នុងការកំណត់តួ វាអាស្រ័យទៅលើសាច់រឿង បែបបុរាណ បែបសម័យ...។

K ក្នុងការកំណត់ចរិតឱ្យតួអង្គនេះ អ្នកត្រូវចេះគិតដែរ នៅពេលតួអង្គជាបុរសវ័យក្មេង វ័យចំណាស់ វ័យចាស់ ស្ត្រីមានប្ដី ស្ត្រីមេម៉ាយ ឬជាស្រីក្រមុំ ឬជាតួអង្គឯក នៅទីជនបទ ទីក្រុង បញ្ញវន្ត ជនមិនចេះអក្សរ អ្នកលេង អ្នកមានពាណិជ្ជករ...។

### ៣.៤- ចង្វាក់ :

K ចង្វាក់ គឺជាការរៀបដំណើររឿងឱ្យតួអង្គមានសកម្មភាពឯកភាពនឹងកាយវិកា សំឡេង, សម្រែក (ភ័យ ស្លន់ស្លោ, ឈឺចុកចាប់, ត្រេកអរ, ទុក្ខព្រួយ...)ឱ្យស៊ីទៅនឹងចង្វាក់រឿង ឬ ឱ្យត្រូវទៅតាមសាច់រឿង ខ្លឹមសារនៃរឿង និងឱ្យត្រូវទៅនឹងតថភាពនៃសង្គមទៀតផង។ ឧទាហរណ៍ : ពេលម្ដាយបានទទួលដំណឹងថា កូនប្រុសមានគ្រោះថ្នាក់ភ្លាម ម្ដាយស្រែកដោយតក់ស្លុតថា " ពុទ្ធោ!

កូនប្រុសមាសម្ដាយ..."។ ឧបមាថាស្ត្រីវ័យក្មេងកំពុងងូតទឹកក្នុងបន្ទប់ទឹកហៀប នឹងចេញមកក្រៅ ពេលឮដំណឹងនេះភ្លាម នាងភ័យស្លន់ស្លោរត់មកទាំងកន្សែង ចោមពុងបណ្ដើរ ស្រែកសួរម្ដាយបណ្ដើរថា " សុធី កើតអីម៉ែ ?។ (សកម្មភាព របស់នាងត្រូវនឹងចង្វាក់រឿង)។ បើសកម្មភាពមិនត្រូវនឹងចង្វាក់រឿង : នាង (ស្ត្រីវ័យក្មេង)ឮហើយនៅតែជូតខ្លួន សិតសក់ ស្លៀកពាក់រួចរាល់សិន ទើបនាង ដើរមកសួរម្ដាយដោយគ្មានភ្ញាក់ផ្អើលសោះថា : " សុធី វាធ្វើស្អីម៉ែ ? " ។

(សកម្មភាពរបស់នាងមិនត្រូវនឹងចង្វាក់រឿងដែលគួរឱ្យភ្ញាក់ផ្អើលទេ)។

## ៣.៥-បរិយាការណ៍:

បរិយាការណ៍ គឺ ការណ៏ដែលនៅជុំវិញ, មជ្ឈដ្ឋានប្រកបដោយសម្ភារៈ មនុស្ស និងបញ្ញា។

Kនៅក្នុងឈុត ឬ វគ្គនីមួយៗរបស់រឿង ត្រូវបង្កើតឱ្យមានអង្គឯកភាព គ្នារវាងមនុស្ស(តួប្រុសស្រី ក្មេងចាស់)សម្ភារៈ(តាំងពីសម្លៀកបំពាក់ ឧបករណ៏ ដែលតួនីមួយៗប្រើ និងអ្វីៗឋិតនៅជុំវិញកន្លែងដែលកំពុងប្រព្រឹត្តទៅរបស់សាច់ រឿង...)ពេលវេលា ដែលដំណើររឿងកំពុងប្រព្រឹត្ត ការពោលពាក្យ...។

**Kបរិយាការណ៍មាន២ : ល្អ និងអាក្រក់**

ក-*បរិយាការណ៍ ល្អ* ៖ អ្វីៗបង្ហាញឱ្យឃើញថា ល្អ ស្រស់ គួរឱ្យរីករាយ។ ឧ. ចង់ឱ្យតួអង្គឯកប្រុស បានជួបជាមួយតួអង្គឯកស្រីបានដូចចិត្ត ត្រូវឱ្យតួអង្គបុរស នៅពេលចេញទៅបានជួបនឹងអ្វីៗដែលជាប្រផ្នូលល្អៗ ដូចជាបង្ហាញពីសម្លៀកបំពាក់ស្រស់ស្អាត ព័ណ៌ភ្លឺថ្លា. បង្ហាញពីផ្ការីករបាង់ មានកន្លង់ ឬឃ្មុំចោមរោមបុប្ផា ឬ រុក្ខជាតិមានផ្កា មានផ្លែ រយីងរយោង...។

ខ-*បរិយាការណ៍អាក្រក់* ៖ អ្វីៗបង្ហាញឱ្យឃើញថា មិនល្អ មិនស្រស់មានប្រផ្នូលអាក្រក់ៗ។ ឧទាហរណ៍ ៖ បើចង់ឱ្យតួអង្គត្រូវបែកបាក់គ្នា គឺឱ្យតួអង្គចេញមកស្លៀកពាក់ព័ណ៌ខ្មៅ ឬ ព័ណ៌ស្រអាប់ ឬ ពេលរៀបចេញដំណើរមានជ្រុះរបស់របរបែកបាក់ ដែលជាប្រផ្នូលអាក្រក់ៗ...។ នៅពេលជួបគ្នានិយាយលែងត្រូវគ្នា ឈ្លោះប្រកែកគ្នា...។

## ៤-ប្រភេទរឿងខ្លី ៖

### ៤.១-រឿងប្រលោមលោកមាន៣ខ្នាត ៖

#### ក-រឿងខ្លី ៖

រឿងខ្លី ជាប្រភេទរឿងសម្រាប់ចុះក្នុងទំព័រ ទស្សនាវដ្ដី ឬ សារព័ត៌មានជាដើម។ រឿងប្រភេទនេះគេច្រើនសរសេរត្រឹម២-៣ទំព័រ ទៅដល់៧-៨ទំព័រ។

ប្រសិនបើគេចង់បោះពុម្ពជាសៀវភៅ គេរៀបរៀងបញ្ចូលគ្នាពី៣ទៅ៥រឿងជាមួយក្បាលសៀវភៅ។

**ខ-រឿងខ្លាតខ្លី :**

រឿងខ្នាតខ្លី ជាប្រភេទរឿងខ្លីល្មមអាចបោះពុម្ពបាន មានកម្រាស់ពីត្រឹម១០០ ទំព័រ ចុះក្រោម ( អាចពី ៥០ទំព័រ ឬ ៤០ទំព័រ) ។

**គ- រឿងខ្នាតវែង :**

រឿងខ្នាតវែង ជាប្រភេទរឿងដែលអ្នកត្រូវសរសេរចាប់ពី១០០ទំព័រឡើង។ សម្រាប់ជនជាតិខ្មែរយើងអាចសរសេរត្រឹម១០០ទំព័រ ឬ ២០០ទំព័រ ឬ ៣០០ទំព័រ, សម្រាប់ជនបរទេសមានរហូតដល់ ៧០០ទំព័រ ឬ ៨០០ទំព័រក៏មាន។

**៤.២-វិធីសរសេររឿងខ្លី :**

រឿងខ្លីអាចសរសេរបានជា២ បែប :

**ក-សរសេរបែបបុរសទាំង៣ :**

សរសេរបែបបុរសទាំង៣ គឺសរសេរបែបប្រលោមលោកខ្នាតវែង ឬខ្នាតខ្លី។ បុរសទាំង៣ គឺអាចសរសេររៀបរាប់ពីទេសភាព ឬ ការដ្ឋានផ្សេងៗ ដោយនិយាយរៀបរាប់តែ១-៣បន្ទាត់យ៉ាងច្រើន។ គឺត្រូវតែរៀបរាប់ឱ្យខ្លីបំផុត។

អ្នកនិពន្ធរៀបរាប់ទេសភាព ឬ រៀបរាប់ចរិតតួ ឬ បង្ហាញតួ គេហៅថា បុរសទី១។ លុះតួម្នាក់និយាយ គេហៅថាបុរសទី២ ឯតួម្នាក់ផ្សេងទៀតនិយាយមកតួម្នាក់នេះ គេហៅថាបុរសទី៣។ បើទោះបីជាមានតួទី៤-៥-៦និយាយក៏គេហៅថាបុរសទី៣ដែរ។ ព្រោះតួមានតែ២ គឺតួមួយនិយាយទៅកាន់តួមួយទៀត។ តួដែលនិយាយគេហៅថា បុរសទី២ និងបុរសទី៣ ឯបុរសទី១ គឺវាចាអ្នកនិពន្ធ។

K **ឧទាហរណ៍ :** ព្រះអាទិត្យរះផុតពីចុងព្រឹក្សា ពូសុខ និងមីងសៅបានស្ពាយបាយសំណុំ និងបំពង់ទឹកយ៉ាងរលះរលាំងទៅស្រែ។ ការរៀបរាប់ព្រះអាទិត្យរបស់អ្នកនិពន្ធ គឺរៀបរាប់តែ១ឃ្លា ប៉ុណ្ណោះ។ គេអាចរៀបរាប់ដល់ទៅ ៣ ឬ ៤ឃ្លាក៏បាន។

K ឧទាហរណ៍ : ព្រះអាទិត្យបានរះផុតចុងព្រឹក្សា ពូសុខ និងមីងសៅកំពុង ធ្វើដំណើរយ៉ាងរលះរលាំងទៅស្រែ [៨]។

K ព្រះអរុណរើតភ័ក្ត្រមូលក្រឡង់ឯនាយជើងមេឃ ខំបញ្ចេញរស្មីរបស់ខ្លួនឱ្យកាន់តែច្បាស់ឡើងៗ ដើម្បីបំភ្លឺមនុស្សលោក និងបក្សាបក្សីព្រមទាំងម្រឹគ

[៨] ការរៀបរាប់ព្រះអាទិត្យរបស់អ្នកនិពន្ធនេះ រៀបរាប់តែ១ឃ្លាប៉ុណ្ណោះ។ គេអាចរៀបរាប់ដល់ទៅ៣ ឬ ៤ឃ្លាក៏បាន សូមមើលឃ្លាបន្ត។

ម្រឹគា [៩] ។ នុះន៎ ! ពូសុខមីងសៅ កំពុងធ្វើដំណើររលះរលាំងទៅស្រែ ។ ដើរយ៉ាងញាប់ជើងបណ្ដើរ មីងសៅនិយាយបណ្ដើរ :

-ពុកវា ! ឆ្នាំនេះកសិករស្រុកយើងពិបាកណាស់ ! ព្រោះស្រូវស្កកស្ទើរគ្រប់គ្នា ដោយសារភ្លៀងធ្លាក់មិនគ្រប់គ្រាន់ ( បុរសទី ២) ។

ពូសុខមិនបង្អង់ជើងខំនិយាយត :

-ហ៊ឺ ! ធ្វើម៉េច បើស្រុកយើងធ្វើស្រែប្រវាស់នឹងមេឃអ៊ីចឹង ចេះតែទ្រាំទៅ កាលណាអត់បាយចាំគិតទៀត ( បុរសទី៣) ។

**ខ- ការសរសេរបែបបុរសទី១ :**

ការសរសេរបែបបុរសទី១នេះ ទាមទារឱ្យអ្នកសរសេរប្រើពាក្យ "ខ្ញុំ" រហូត ។

Kឧទាហរណ៍ ក្នុងរឿងដដែលគឺ ពូសុខ និងមីងសៅធ្វើដំណើរទៅស្រែ ។ យើងចង់ឱ្យពូសុខ ធ្វើជាតួសំខាន់ក៏បាន ឱ្យមីងសៅ ធ្វើជាតួសំខាន់ក៏បាន ។

K ពូសុខ ជាតួសំខាន់ :

[៩] ការរៀបរាប់ព្រះអាទិត្យនេះ តែមួយប្រយោគទេ តែមានពាក្យ ។

ព្រះអាទិត្យបានរះផុតចុងព្រៃហើយ ខ្ញុំ និង ប្រពន្ធខ្ញុំនាំគ្នាដើររលះរលាំងទៅស្រែ។ យើងទាំងពីរដើរយ៉ាងញាប់ជើងបណ្តើរ ប្រពន្ធខ្ញុំនិយាយមកកាន់ខ្ញុំបណ្តើរ : " ពុកវា ! ឆ្នាំនេះកសិករស្រុកយើងមានការពិបាកណាស់ ព្រោះស្រូវស្កកស្ទើរគ្រប់គ្នា ដោយសារភ្លៀងធ្លាក់មិនគ្រប់គ្រាន់ "។ ខ្ញុំមិនបង្អង់ជើងខំនិយាយត : " ហ៊ឺ ! ធ្វើម៉េចបើស្រុកយើងធ្វើស្រែប្រវាស់នឹងមេឃអ៊ីចឹង យើងចេះតែទ្រាំទៅ កាលណាអត់បាយសឹមគិតទៀត "។

K ការសរសេរបែបបុរសទី១ គេមិនឱ្យអ្នកនិពន្ធនិយាយរួចចុះបន្ទាត់ដាក់វជ្ជសញ្ញា "-" រួចហើយឱ្យតួនិយាយទេ គឺគេឱ្យតួនិយាយរហូតមួយចប់សាច់រឿង។ តួសំខាន់និយាយតែម្នាក់ឯងគត់ គេនិយាយរៀបរាប់ទេសភាព ឬ រៀបរាប់តួ រួចគេប្រើសញ្ញាចុចពីរ (:) រួចបើកអភន្តរសញ្ញា " "។

## ៤.៣- ការកំណត់ប្រធានបទ :

ការកំណត់ប្រធានបទ គឺជាគំនិតរឿង ជាបំណងដែលយើងចង់សរសេរអំពីអ្វីមួយ។

K ឧទាហរណ៍ : យើងចង់សរសេរអំពីការឆ្លងមេរោគអេដស៍, ជនក្បត់

ជាតិ, ការដណ្ដើមកេរមរតកគ្នា, ស្នេហាក្បត់ចិត្ត, ការលោភលន់របស់មនុស្ស, កូនអកតញ្ញូ, ការរស់នៅរបស់មនុស្សសម័យថ្មី... ។ល ។

Kនៅក្នុងគំនិតរឿងនីមួយៗ អ្នកនិពន្ធត្រូវកំណត់ឱ្យច្បាស់ថា តើនរណាកើតអេដស៍ ?( ម្ដាយ ឪពុក ប្ដី ប្រពន្ធ ឬកូនកើតអេដស៍?) ឬ ជាគ្រូបង្រៀន ជាកុងស៊ីយ៍ ជាទាហាន ?... ។ ការផិតក្បត់ នរណាជាអ្នកផិតក្បត់ ? ប្ដី ផិតប្រពន្ធ ? ប្រពន្ធផិតប្ដី ? ។

K កាលណាអ្នកនិពន្ធកំណត់ប្រធានបទបានរួចច្បាស់លាស់ហើយ ទើបយកគំនិតនោះមកសរសេរ ។ ក្នុងការសរសេរ អ្នកនិពន្ធពុំគួរសរសេរឱ្យរីករាលដាលចូលទៅក្នុងប្រធានបទមួយផ្សេងទៀតទេ ។

K ឧទាហរណ៍ : កាលបើយើងសរសេរពីប្រធានបទអេដស៍ យើងអាចសរសេរពី យុវជន យុវនារី ឬ បុរស ស្ត្រីដែលមានដៃគូស្នេហាច្រើនមិនបានប្រើប្រាស់ស្រោមអនាម័យបណ្ដាលឱ្យកើតអេដស៍ ។ ប៉ុន្តែ ពុំគួរសរសេរពីជនពុករលួយ មានលុយចាយច្រើនដើរលេងស្រីនាំឱ្យកើតអេដស៍នោះទេ ។ ការពិតវាដូច្នេះមែនហើយ តែក្នុងប្រធានបទអេដស៍ កុំសរសេរថាជនពុករលួយ ពីព្រោះជនពុករលួយជាប្រធានបទមួយផ្សេងទៀត អំពីបញ្ហាពុករលួយ ។

Kរឿងខ្លីច្រើនសរសេរបែបបុរសទី១ ព្រោះរឿងខ្លីគេសរសេរបែបរឿងមនោសញ្ចេតនា។ រឿងខ្លីគេជម្រុះចម្រាញ់ ជម្រើសយកតែរឿងខ្លីម។មកសរសេរ ដូចជារឿង " ២0ឆ្នាំចាំស្នេហ៍ " របស់លោកយ៉ូបូ និងរឿង " ឱព្រហ្មចារីយ៍ " របស់អ្នកស្រី ពាន់ ភួងបុប្ផា ជាដើម។

## IV- អំពីការសរសេរសំបុត្រ និង លិខិតផ្សេងៗ :

### ១-របៀបសរសេរសំបុត្រផ្ទាល់ខ្លួន :

រាល់ការសរសេរសំបុត្រ អ្នកសរសេរមិនបាច់ប្រើបាវចនាជាតិទេ គឺនៅក្បាលលិខិតត្រូវចាប់ផ្តើមសរសេរពី ទីតាំង ឬ តំបន់ ខេត្ត ស្រុកទេសដែលយើងរស់នៅ បន្ទាប់មកថ្ងៃ ខែ ឆ្នាំ ដែលកំពុងសរសេរ។

ឧ. " រាជធានីភ្នំពេញ, ថ្ងៃទី...ខែ...ឆ្នាំ... "។

-បន្ទាប់មកចុះបន្ទាត់ នៅចំផ្នែកកណ្តាលនៃក្រដាសសរសេរអក្សរធំថា :

" **លិខិតរបស់...** " ឬ " **ខ្ញុំបាទសូម...** " ឬ " **មកដល់...** " តែម្តង។

-បន្ទាប់មកយើងត្រូវចុះបន្ទាត់ សរសេររៀបរាប់ សួរសុខទុក្ខ អ្នកម្ខាងទៀតនូវសេចក្ដីទាំងឡាយដែលអ្នកចង់ដឹង។

យើងក៏មិនភ្លេចសរសេរពីសុខទុក្ខរបស់យើងឱ្យអ្នកម្ខាងទៀតបានដឹង បានយល់អំពីជីវិតរបស់យើង ដែលរស់នៅឯនាយនេះបានសុខ ឬ ទុក្ខយ៉ាងណាៗ ស្រេចតែយើងរៀបរាប់។ បន្ទាប់ពីរៀបរាប់រួចរាល់ហើយ អ្នកសរសេរត្រូវចុះបន្ទាត់ ហើយសរសេរបញ្ចប់សេចក្ដីនៃលិខិត ក្នុងនោះយើងត្រូវមានពាក្យផ្ដាំផ្ញើ និងជូនពរ ឬ គោរពជូនពរតាមការដែលយើងចង់ រួចហើយទើបជម្រាបលាជាចុងក្រោយ។

**ឧទាហរណ៍ទី១ :** លិខិតសាមញ្ញរបស់មិត្តម្នាក់ផ្ញើទៅសំឡាញ់ ក្រោយពីបែកគ្នាយូរឆ្នាំ។

រាជធានីភ្នំពេញ, ថ្ងៃទី...ខែ...ឆ្នាំ...

មកដល់សម្លាញ់ ឬ មកដល់កល្យាណមិត្ត (ដោយក្ដីនឹករឮក)

ច្រើនឆ្នាំមកនេះ ខ្ញុំមិនដែលបានទទួលដំណឹងពីសម្លាញ់សោះ។ រីឯខ្ញុំឯណេះវិញក៏មិនដែលបានផ្ញើដំណឹងមកសម្លាញ់វិញដែរ ពីព្រោះមមាញឹកក្នុងការងារពេក។ ប៉ុន្តែទោះបីមមាញឹកយ៉ាងណាក្ដី ក៏ខ្ញុំនិងក្រុមគ្រួសារតែងតែនឹករឮកមកដល់សំឡាញ់

និងភិយាព្រមទាំងកូនៗមិត្តមិនដែលភ្លេចឡើយ។ តើមិត្ត និងក្រុមគ្រួសារមានសុខទុក្ខយ៉ាងណាដែរ ?..........................។

បើមានពេលទំនេរ (ឬ នៅក្នុងឱកាសឈប់សម្រាកខាងមុខនេះ) ចូរមិត្តមកលេងឯ...ម្តង ខ្ញុំនិងគ្រួសារ (ឬ យើងទាំងអស់គ្នា) នៅរង់ចាំទទួលដោយក្តីសោមនស្សបំផុត។

សូមសំឡាញ់និងក្រុមគ្រួសារប្រកបតែនឹងសេចក្តីសុខគ្រប់ប្រការ។

ដោយក្តីរឭកជានិច្ច

ពីខ្ញុំ............

**ឧទាហរណ៍ទី២**-លិខិតរបស់យុវសិស្សម្នាក់សរសេរផ្ញើទៅឪពុកម្តាយដែលនៅឆ្ងាយដើម្បីសួរសុខទុក្ខ និងជម្រាបពីសុខទុក្ខ ការសិក្សារបស់ខ្លួនវិញ។

**រាជធានីភ្នំពេញ, ថ្ងៃទី...ខែឧសភា ឆ្នាំ២០០៦**

កូនសូមក្រាបប្រណិប័តន៏ចំពោះអ្នកមានគុណទាំងទ្វេ ឬ

( កូនសូមក្រាបប្រណិប័តន៏ចូលមកលោកឪពុក និងអ្នកម្តាយ )

សូមទានជ្រាប។

អស់រយៈពេលជាច្រើនថ្ងៃហើយដែលរូបកូន.........................................

...........................................................................................................

..................................................................................................................................................

..................................................................................................................................................

..........។

ទីបញ្ចប់នៃសេចក្តីសំបុត្រនេះ កូនសូមបួងសួងដល់គុណព្រះរតនត្រ័យ សូមជួយបីបាច់ថែរក្សា ...។

ពីកូនសំឡាញ់របស់លោកអ្នកមានគុណ

ជ័យ សិទ្ធិ

**ឧទាហរណ៍ទី៣ - លិខិតឆ្លើយតបទៅកូនវិញ**

**កំពង់ចាម, ថ្ងៃទី....ខែ ឧសភា ឆ្នាំ២០០៦**

**មកដល់ សិទ្ធិ កូនសម្លាញ់**

**ជាដំណឹង។**

ពុក (ឬ ប៉ា) បានទទួលសំបុត្រកូនតាំងពីថ្ងៃទី...មកម្ល៉េះ ពុកម៉ែបានអានសំបុត្រកូនដឹងសុខទុក្ខកូនសព្វគ្រប់ហើយ តែពុករវល់មមាញឹកក្នុងរបរពុកពេក រកពេលតបសំបុត្រមកកូនពុំបាន។ ពុក ម៉ែ និងបងប្អូនឯងនៅឯនាយនេះបានសុខសប្បាយជាទេ ប៉ុន្តែគ្រប់គ្នាតែងតែនឹករឭកមករកកូនគ្រប់វេលា ព្រោះយល់ថា រូបកូននៅឆ្ងាយពីក្រុមគ្រួសារពិតជាជួបការលំបាកក្នុងការរស់នៅជាមិនខាន។

ពុកដឹងថាកូនមានការខ្វះខាតក្នុងជីវភាពហើយ ពីព្រោះការសិក្សាកាន់តែច្រើន ឈ្នួលផ្ទះ ទឹក ភ្លើង ម្ហូបម្ហាឡើងថ្លៃរាល់ថ្ងៃ ដើម្បីបំពេញការខ្វះខាតរបស់កូន ពុក និងម៉ែឯងផ្ញើប្រាក់ចំនួន...រៀលតាម (ប៉ុស្តិ៍ ឬ ញាតិមិត្ត...) ចូរកូនទៅយកពីគាត់ចុះ...។ ប៉ុន្តែ ពុកផ្តាំកូនថា កូនកុំដើរលេងយប់ កុំសេពគប់មិត្តមិនល្អ កុំចាយវាយខ្ជះខ្ជាយពេក កូនទិញដូរតែរបស់ណាដែលត្រូវការចាំបាច់បានហើយ ដ្បិតពុកនៅឯនេះ ផលរបរក៏មិនសូវបានដូចឆ្នាំមុនៗទេ។ កូនត្រូវខិតខំយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ កុំបីធ្វេសប្រហែសឱ្យសោះ, កូនត្រូវដឹងថា យើងជាអ្នកខ្សត់ខ្សោយខំកាត់ពីនាយធ្លាក់ដល់អាយ ដើម្បីក្រេបជញ្ជក់យកចំណេះវិជ្ជា សម្រាប់ថ្ងៃអនាគតភ្លឺស្វាង។

ពុក និងម៉ែ សូមជូនពរកូនពីចម្ងាយ ឱ្យកូនប្រកបតែសេចក្តីសុខ និងមានជោគជ័យក្នុងការសិក្សាជាដរាប។

ពីពុក

ជ័យ សុទ្ធ

(ឧទាហរណ៍ខាងលើនេះ ពុំមែនជាពុម្ពគំរូត្រូវតែធ្វើតាមនោះទេ វាគ្រាន់តែជាគំនិតមួយលើកមកបង្ហាញតែប៉ុណ្ណោះ អ្នកអាចមានគំនិតប្លែកពីនេះ និងចេះរៀបរាប់ប្រើពាក្យទន់ភ្លន់ ពីរោះជាងនេះទៅតាមឋានៈ និងពេលវេលានៃការសរសេររបស់ខ្លួន)។

## ២- សេចក្តីណែនាំខ្លះៗ :

យើងសរសេររៀបរាប់សួរសុខទុក្ខគាត់ឱ្យអស់សេចក្តីដែលយើងចង់ដឹង

បន្ទាប់មកទើបយើងសរសេររៀបរាប់ពីសុខទុក្ខរបស់យើងឱ្យគាត់បានដឹងវិញ អំពីការរកស៊ី ការសិក្សារៀនសូត្ររបស់យើងរីកចម្រើនបានដូចម្ដេចខ្លះ ? ជួបលំបាកអ្វីខ្លះ ? ចៀសវាងកុំសរសេរអ្វីដែលនាំឱ្យឪពុក ម្ដាយ បងប្អូនគាត់ពិបាកចិត្ត បើអាចចៀសវាងបាន។ យើងអាចប្រាប់ ឬ មិនប្រាប់ អាស្រ័យយើងយល់ថាគួរ ឬ មិនគួរ បើយល់ពីស្ថានភាពគ្រួសារច្បាស់ ប្រាប់ទៅគាត់អាចជួយដោះស្រាយបាន គួរប្រាប់ជាការប្រសើរ។ ប៉ុន្តែការលំបាកខ្លះដែលយល់ថា គាត់មិនអាចជួយយើងបាន មិនគួរប្រាប់ឡើយ ព្រោះនាំឱ្យគាត់ខ្វល់ខ្វាយឥតប្រយោជន៍ នេះក៏ជា សុជីវធម៌មួយដែរ។

ការសរសេរសំបុត្រ យើងអាចប្រើប្រាស់ពាក្យពេចន៍ឱ្យពីរោះពិសា ទន់ភ្លន់ ផ្អាក់ផ្អម លួងលោម សម្ដែងចេញនូវការគោរព ស្រឡាញ់រាប់អានដោយស្មោះអស់ពីដួងចិត្ត តែសរសេររបៀបសាមញ្ញបើក្នុងលក្ខណៈជាគ្រួសារ។ កុំប្រើពាក្យពេចន៍ ជាពាក្យវប្បធម៌ជ្រៅជ្រះដូចជា ភាសាបាលី សំស្ក្រឹត ឬ ពាក្យអាក្រក់ស្ដាប់ខ្លះ ដូចជា អញ, ហាង, អ៊ែ្ហង, អាអ្ហែង, ង៉ែង, មីនេះ, មីនោះ, ហាងអែង...ឱ្យសោះ។ លិខិតសរសេរទៅមកក្នុងលក្ខណៈគ្រួសារអ្នកគួរតែកុំសរសេររៀបរាប់ការសួរសុខទុក្ខវែងអន្លាយពេក គួរសរសេរខ្លីៗបានហើយ អ្នករៀប

រាប់តែកិច្ចការណា ដែលសំខាន់ៗ ។

**៣-លិខិតមានទម្រង់ផ្ទាល់ខ្លួនដែលបម្រើក្នុងអង្គភាពរដ្ឋបាល[១០] :**

លិខិតនេះជាលិខិតឯកជនដែរ ប៉ុន្តែជាបុគ្គលឋិតនៅក្នុងក្របខណ្ឌអង្គភាពរដ្ឋបាលណាមួយ ។ លិខិតរបៀបនេះ យើងសរសេរដើម្បីសុំច្បាប់ ឬ ធ្វើកិច្ចការអ្វីមួយ គឺត្រូវមានដាក់ក្បាល លិខិត ឬ បាវចនាជាតិ ។

K **អំពីក្បាលលិខិត :**

-យើងត្រូវសរសេរបាវចនាជាតិនៅផ្នែកខាងលើបង្អស់នៃលិខិត ហៅក្បាលលិខិត ។

K **ផ្នែកដើម :**

-ត្រូវចុះបន្ទាត់ រួចសរសេរចំណងជើងលិខិត " ពាក្យសុំច្បាប់ "ឬ "..." ជាអក្សរធំ ។

-បន្ទាប់មកចាប់ផ្ដើមបន្ទាត់សរសេររាយសេចក្ដីថា ខ្ញុំបាទឈ្មោះ...អ្វី

---

[១០] លិខិរដ្ឋបាលគេពុំចាត់ចូលទៅក្នុងការនិពន្ធទេ ពីព្រោះវាមានរបៀបជា គំរូ ឬ បែបបទត្រូវបំពេញតាម ។ ចំពោះការលើកយកមកបង្ហាញនៅពេលនេះ អ្នករៀបរៀងយល់ថា ថ្វីបើលិខិតដែលមានទម្រង់រដ្ឋបាលមានរបៀបរបស់វាក៏ពិតមែន ប៉ុន្តែការចេះនិយាយរៀបរាប់តែងឃ្លាប្រយោគឱ្យបានសមស្របត្រឹមត្រូវ តាមពេលវេលានោះក៏ជាវិធីមួយដែលយើងត្រូវតែចេះសរសេរដែរ ។

ធ្វើការនៅអង្គភាពណា ?ជាអក្សរធម្មតា ។

-ចុះបន្ទាត់សរសេរចំពាក់កណ្តាលបន្ទាត់ជាអក្សរធំថា" សូមគោរព " ។

-រួចចុះបន្ទាត់មួយទៀតសរសេរគោរមងារអ្នកជាប្រធានធំលើអង្គភាពរបស់យើងថា "ឯកឧត្តម... ឬ លោកប្រធាន..."( ដាក់គោរមងារជាតួនាទី ) ។

-បន្ទាប់មកចុះបន្ទាត់មួយទៀតចាប់ផ្តើមបន្ទាត់ សរសេរថា " តាមរយៈ : លោក..." ដែលជាអ្នកទទួលខុសត្រូវផ្ទាល់លើយើង ។

-បន្ទាប់មកចុះបន្ទាត់មួយទៀត ចាប់ផ្តើមបន្ទាត់ស្មើនឹង"តាមរយៈ"ដែរដោយសរសេរថា "កម្មវត្ថុ " ចុចពីរ (:) រួចសរសេរសេចក្តីយ៉ាងខ្លីច្បាស់លាស់ឱ្យគេងាយស្រួលចាប់បានពីចំណុចដែលយើងចង់បាន។ បើយើងសុំច្បាប់ឈប់ដាក់ថា ឈប់ចំនួន ប៉ុន្មានថ្ងៃ ? (សរសេរជា លេខ រួចបើកវង់ក្រចក សរសេរជាអក្សរផង )ពីថ្ងៃណាដល់ ថ្ងៃណា ? ។

K **ផ្នែកកណ្តាល :**

-បន្ទាប់មកចុះបន្ទាត់ ចាប់ផ្តើមបន្ទាត់សរសេរពី " មូលហេតុ "ហេតុអ្វីបានជាយើងត្រូវសុំច្បាប់ឈប់ ? ត្រង់នេះ គឺយើងត្រូវចេះតាក់តែងឃ្លាប្រយោគឱ្យគេស្តាប់បាន មិនត្រូវវែងអន្លាយទេ ឱ្យខ្លីល្មម ប៉ុន្តែមានន័យគ្រប់គ្រាន់ធ្វើឱ្យគេ

យល់បានពីមូលហេតុដែលបណ្ដាលឱ្យយើងសុំឈប់ ។ បន្ទាប់មក

-សរសេរថា "អាស្រ័យដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងមូលហេតុខាងលើ ឬដូចសេចក្ដីដែលបានជម្រាបជូនខាងលើនេះ ខ្ញុំបាទសូមលោក...មេត្តាអនុញ្ញាតឱ្យខ្ញុំបាទបានឈប់ដោយអនុគ្រោះ" ។

-យើងចុះបន្ទាត់មួយទៀតរួចសរសេរថា " សូមលោកប្រធាន...មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ " ។

K ផ្នែកបញ្ចប់ :

-នៅផ្នែកខាងស្ដាំដៃខាងក្រោម បន្ទាប់ពីសេចក្ដីលិខិត យើងដាក់ទីកន្លែង និងថ្ងៃខែឆ្នាំធ្វើលិខិត បន្ទាប់មកដាក់ហត្ថលេខារបស់យើង ដោយមិនបាច់សរសេរឈ្មោះ យើងទៀតទេ ។

-រីឯនៅផ្នែកខាងឆ្វេងដៃវិញដាក់ថា :

បានឃើញ និង បញ្ជូនមក

លោកប្រធាន...................

"ដើម្បីមេត្តាពិនិត្យសម្រេច"

ថ្ងៃទី..... ខែ.......ឆ្នាំ.......

គោរពមងារប្រធាន...

ហត្ថលេខា

ឈ្មោះ

សូមមើលគំរូខាងក្រោម :

**ឧទាហរណ៍ គំរូលិខិត :**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

→→

ពាក្យសុំច្បាប់

ខ្ញុំបាទឈ្មោះ.........បច្ចុប្បន្នធ្វើការនៅ..................ជា............................។

**សូមគោរព (ឬ សូមគោរពជូន)**

**ឯកឧត្តមប្រធាន**....................................

**តាមរយៈ** : លោកប្រធាន....................................... ...........................។

**កម្មវត្ថុ** : សំណើសុំច្បាប់ឈប់ចំនួន...(ចំនួន...) ដោយគិតពីថ្ងៃទី...ដល់ថ្ងៃទីខែឆ្នាំ...។

**មូលហេតុ** : ខ្ញុំបាទធ្វើដំណើរទៅកាន់....ដើម្បី........................ ...................។

អាស្រ័យដូចសេចក្ដីជម្រាបជូនខាងលើ ខ្ញុំបាទសូមឯកឧត្ដមប្រធានមេត្តាអនុញ្ញាត ឱ្យខ្ញុំបាទបានឈប់...ដោយក្ដីអនុគ្រោះ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី...ខែ...ឆ្នាំ...

បានឃើញ និង បញ្ជូនមក ហត្ថលេខា

ឯកឧត្តមប្រធាន...

"ដើម្បី ពិនិត្យសម្រេច"

ភ្នំពេញថ្ងៃទី ខែ... ឆ្នាំ.....

ប្រធាន...................

ហត្ថលេខា

នាមឈ្មោះ...

**៤-អំពីលិខិតរដ្ឋបាល** [១១] :

លិខិតរដ្ឋបាលគឺជ...ធ្យោបាយមួយ ដែលគេនិយមប្រើសម្រាប់ធ្វើការទាក់ទងគ្នាទាំងក្នុង និងក្រៅក្រសួង ឬ ស្ថាប័ន។ ម្យ៉ាងទៀត លិខិតទាំងនេះគឺជាលាយលក្ខណ៍អក្សរជាភស្តុតាងមួយស្ថិតស្ថេរនៅជាឯកសាររៀងរហូត ដោយមានលក្ខណៈជាផ្លូវច្បាប់ មិនដូចវាចាដែលអាចប្រែប្រួល និងផុតរលត់បាននោះទេ។

ទំនាក់ទំនងរវាងអង្គការរដ្ឋ ជាមួយនឹងអង្គការរដ្ឋ ឬជាមួយនឹងអង្គការនានា លិខិតដែលប្រើប្រាស់នោះគឺជា "លិខិតផ្លូវការ" ផ្ទុយទៅវិញ បើអង្គភាពរដ្ឋ

[១១] សូមមើល ឡេង លឹមតុង : " ការងារការិយាល័យ " ១៩៩៧ ទំព័រ១១។

មានទំនាក់ទំនងជាមួយប្រជារាស្ត្រ ឬ ជាមួយមន្ត្រីរាជការ បុគ្គលិក និយោជិត ស្ថិតនៅក្រោមឱវាទ លិខិតដែលគេនិយមប្រើប្រាស់នោះហៅថា " លិខិតមានទម្រង់ផ្ទាល់ខ្លួន ឬ ហៅ ថា លិខិតមានលក្ខណៈពាក់កណ្តាលផ្លូវការ "។

**ក-របៀបសរសេរលិខិត :**

លិខិតរដ្ឋបាលត្រូវសរសេរឱ្យខ្លី មានខ្លឹមសារច្បាស់លាស់ ដើម្បីឱ្យអ្នកអានងាយយល់ពីបំណងរបស់ខ្លួន (អ្នកសរសេរ) ចៀសវាងសរសេរវែងអន្លាយស្មុគស្មាញ។ លិខិតរដ្ឋបាលមានទម្រង់បែបបទខុសពីទម្រង់លិខិតផ្ទាល់ខ្លួន។

**ខ-ទម្រង់លិខិត :**

លិខិតរដ្ឋបាលតែងមាន "ក្បាលលិខិត" ដែលអង្គភាពបានបោះពុម្ពរួចហើយ មានដាក់ឈ្មោះប្រទេស បាវចនាជាតិ រូបសញ្ញា និង ឈ្មោះអង្គភាព អាស័យដ្ឋានអង្គភាពដែលផ្ញើចេញ។

K **ក្បាលលិខិត :**

-ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** នៅផ្នែកខាងលើគេ[១២] ចំពីក្រោមសរសេរបាវចនាជាតិ :

[១២] បើស្ថាប័នរាជរដ្ឋាភិបាលជាន់ខ្ពស់ សញ្ញាជាតិ ដាក់ពីលើ ព្រះរាជាណាចក្រកម្ពុជា ។

**- ជាតិ សាសនា ព្រះមហាក្សត្រ** ( ពីក្រោមត្រូវគូសបន្ទាត់ ឬ ប្រើក្បាច់រចនាផ្សេងៗ របៀបជាបន្ទាត់ ) ។

-នៅទន្ទឹមនឹងឈ្មោះប្រទេស ខាងឆ្វេងដៃមានរូបសញ្ញាអង្គភាព បើអង្គភាពជាន់ខ្ពស់ ក្រោមស្ថាប័នរដ្ឋាភិបាល, ( បើក្រសួង ឬ អង្គភាពនានាធម្មតា មិនចាំបាច់ប្រើរូបសញ្ញាអង្គភាពក៏បាន) ។

-នៅទន្ទឹមនឹងបាវចនាជាតិខាងឆ្វេងដៃដាក់ឈ្មោះអង្គភាព ឬស្ថាប័ន...។

K **ផ្នែកដើមលិខិត :**

-ផ្នែកដើមលិខិត ពីក្រោមបន្ទាប់ឈ្មោះអង្គភាពមានដាក់ "**លេខ :...**" សម្រាប់ចុះបញ្ជីរដ្ឋបាលចេញ។ នៅទន្ទឹមនឹង"**លេខ :...**" ផ្នែកខាងស្តាំដៃមានចុះឈ្មោះទីកន្លែង និងកាលបរិច្ឆេទនៃធ្វើលិខិត ។

-ចុះមួយបន្ទាត់ ឬ ពីរបន្ទាត់នៅផ្នែកកណ្តាលត្រូវសរសេរ ឈ្មោះអ្នកផ្ញើ បើរដ្ឋមន្ត្រីត្រូវដាក់ត្រឹមគោរមងារ "**រដ្ឋមន្ត្រីក្រសួង...**" បានហើយពុំចាំបាច់ដាក់ឈ្មោះគាត់ទេ សរសេរជាអក្សរធំៗ ។

-បន្ទាប់មកទៀតសរសេរថា "**សូមជម្រាបមក** " អ្នកធំទៅកាន់អ្នកតូចជាង, បើអ្នកតូចសរសេរទៅកាន់អ្នកមានឋានៈខ្ពង់ខ្ពស់ជាង ឬ ធំជាងត្រូវ "**សូមគោរពជូន ឬ គោរពជូន** "ជាអក្សរធំដែរ។

-បន្ទាប់មកសរសេរគោរមងារអ្នកទទួលចំកណ្តាល" **ឯកឧត្តម ឬ លោកប្រធាន...**"។

-ចាប់ផ្តើមបន្ទាត់ដាក់ថា "**កម្មវត្ថុ** " ចុចពីរ (:) ដកឃ្លាមួយសរសេរខ្លឹមសារលិខិតយ៉ាងខ្លីបំផុត តែមានន័យគ្រប់គ្រាន់ស្តាប់បាន។

-បន្ទាប់ពី "**កម្មវត្ថុ** " ត្រូវសរសេរ " **យោង** " ជាលិខិតដែលពាក់ព័ន្ធជាមូលដ្ឋាន។

K **ផ្នែកកណ្តាល** :

គឺផ្នែកអត្ថបទ ជាមូលហេតុនៃសេចក្តីក្នុងកម្មវត្ថុត្រូវនិយាយរៀបរាប់ឱ្យបានពិស្តារពីគោលបំណងសំខាន់ៗ ដែលយើងចង់បាន ត្រូវប្រាប់ហេតុផល មូលហេតុឱ្យគ្រប់ជ្រុងជ្រោយ ដើម្បីអ្នកទទួលលិខិតឆាប់យល់បាន និងសម្រេចចិត្តធ្វើការដោះស្រាយ។ ក្នុងផ្នែកនេះ អ្នកសរសេរគប្បីចាប់ផ្តើមថា "**ខ្ញុំមានកិត្តិយស សូមជម្រាបឯកឧត្តម**( មុខងារ) ថា...."។ ប្រសិនបើលិខិតយើងមានយោង

គប្បីសរសេរថា "**សេចក្តីដូចមានក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបឯកឧត្តម ( មុខងារ) ថា...**"។ បន្ទាប់មកត្រូវលើកសំណូមពរ សុំសេចក្តីសម្រេច ឬ មេត្តាជួយអន្តរាគមន៍ ឬ សុំជួយមានវិធាការដោះស្រាយ...។ ចុងបញ្ចប់នៃផ្នែកនេះ ត្រូវថ្លែងអំណរគុណ និងថ្លែងគោរព ដែលគេច្រើនតែប្រើថា :

-បើអ្នកតូចសរសេរទៅកាន់អ្នកមានឋានៈធំជាង " **សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ** ",

-បើអ្នកធំសរសេរ ទៅកាន់អ្នកមានឋានៈតូចជាង " **សូមលោក ឬ ឯកឧត្តមទទួលនូវការរាប់អាន ដ៏ស្មោះស្ម័គ្រ ( ឬ ទទួលនូវការស្រឡាញ់) អំពីខ្ញុំ** "។

K **ផ្នែកបញ្ចប់** :

បន្ទាប់ពីខ្លឹមសារអត្ថបទនៃលិខិតចប់ ត្រូវខណ្ឌចុះបន្ទាត់។ វាជាផ្នែកនៃការចុះហត្ថលេខា ម្ចាស់លិខិតត្រូវចុះហត្ថលេខាតែម្តង ប៉ុន្តែបើម្ចាស់លិខិត ( ម្ចាស់អង្គភាព ឬ ប្រធានអង្គភាព) អវត្តមានត្រូវមានអ្នកចុះហត្ថលេខាជំនួស ដែលមានគំរូ៣ របៀបដូចខាងក្រោម :

-**គំរូបែបទី១** : ក្នុងការដឹកនាំជារបបប្រធាន អ្នកជំនួសត្រូវសរសេរ ដូច្នេះ :

ជ.រដ្ឋមន្ត្រី

អនុរដ្ឋលេខា

ហត្ថលេខា

នាមឈ្មោះ និងត្រា

-គំរូបែបទី២:ក្នុងការដឹកនាំជារបបសមូហភាព អ្នកជំនួសត្រូវសរសេរដូច្នេះ :

ជ. គណៈកម្មាធិការ

ប្រធាន

ហត្ថលេខា

នាមឈ្មោះ និងត្រា

-គំរូបែបទី៣ : ក្នុងការដឹកនាំជារបបទទួលបន្ទុកការងាររួម អ្នកជំនួសត្រូវសរសេរដូច្នេះ :

ជ. អភិបាលស្រុក

អភិបាលរងស្រុកស្ដីទី (ឬអភិបាលរងស្រុក)

ហត្ថលេខា

នាមឈ្មោះ និងត្រា

K ការបោះត្រា :

ការបោះត្រាមិនត្រូវបោះឱ្យចំពីលើហត្ថលេខាពេកទេ នាំឱ្យពិបាកផ្ទៀងផ្ទាត់ហត្ថលេខាក្នុងការធ្វើកោសល្យវិច័យក្នុងករណីណាមួយ ។ គប្បីបោះត្រានៅផ្នែកខាងឆ្វេងនៃហត្ថលេខា ពីលើតែត្រឹមមួយភាគបី ( ១/៣) បានហើយ ។

**ឧទាហរណ៍ទី១ : ក្បាលលិខិត របស់ស្ថាប័នជាន់ខ្ពស់ :**

ក្បាលលិខិត

សញ្ញាជាតិ

ព្រះរាជាណាចក្រកម្ពុជា

ទីស្តីការគណៈរដ្ឋមន្ត្រី

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ :...( អក្សរកាត់រដ្ឋបាល)

រាជធានីភ្នំពេញ, ថ្ងៃទី....ខែ......ឆ្នាំ.....

ផ្នែកដើម

រដ្ឋមន្ត្រី...

សូមជម្រាបជូន

ឯកឧត្តមរដ្ឋមន្ត្រី...

កម្មវត្ថុ :.......................................................................................... ។

យោង :.......................................................................................... ។

ខ្ញុំមានកិត្តិយសសូមជម្រាបមក......................................................

....................................................................................................

ផ្នែកកណ្ដាល.......................................................................................... ។

................. ........................................................................។

ហត្ថលេខា
នាមឈ្មោះ និងត្រា

ផ្ញើកបញ្ចប់ ចម្លងជូន :

-..............

-.....................

-កាលប្បវត្តិ-ឯកសារ

**ឧទាហរណ៍ទី២ : លិខិតរបស់ស្ថាប័នជាន់ខ្ពស់ :**

សញ្ញាអង្គភាព
ព្រះរាជាណាចក្រកម្ពុជា
ទីស្តីការគណៈរដ្ឋមន្ត្រី
ជាតិ សាសនា ព្រះមហាក្សត្រ
ឈ្មោះអង្គភាព.........

លេខ :... (អក្សរកាត់រដ្ឋបាល)
រាជធានីភ្នំពេញ, ថ្ងៃទី....ខែ......ឆ្នាំ.....

**រដ្ឋមន្ត្រីក្រសួង........**
**សូមជម្រាបមក**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួង........**

កម្មវត្ថុ :...............................................................។
យោង :...................................................................។

សេចក្តីដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបឯកឧត្តម...ថា ............................................................................................................................................................។

សូមឯកឧត្តម (មុខងារ) ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ការតែងនិពន្ធ

---

ហត្ថលេខា
នាមឈ្មោះ និងត្រា

ចម្លងជូន ៖
- .........
- .............
- កាលប្បវត្តិ-ឯកសារ

**ឧទាហរណ៍ទី៣ ៖ លិខិតផ្លូវការរបស់ក្រសួង ឬ ស្ថាប័ននានា ៖**

(ក្បាលលិខិត)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
♬♬♬♬♬

ក្រសួង..................
ឈ្មោះអង្គភាព.........

---

លេខ ៖... (អក្សរកាត់រដ្ឋបាល) រាជធានីភ្នំពេញ, ថ្ងៃទី....ខែ......ឆ្នាំ.....

(ផ្នែកដើម)

រដ្ឋមន្ត្រីក្រសួង...........
សូមជម្រាបជូន
ឯកឧត្តមរដ្ឋមន្ត្រី....(ឬ ឯកឧត្តមប្រធាន...)

កម្មវត្ថុ៖.................................................................................. ។
យោង ៖............................................................................. ។

ខ្ញុំមានកិត្តិយសសូមជម្រាបមក...............................................................
....................................................................................................

(ផ្នែកកណ្ដាល)............................................................................... ។
.........................................................................................

(ផ្នែកបញ្ចប់)

ហត្ថលេខា

ចម្លងជូន : នាមឈ្មោះ និងត្រា

-...............

-....................

-កាលប្បវត្តិ-ឯកសារ

**៥-ដីកាបញ្ជូន [១៣] :**

គេអាចហៅថា ដីកាអមក៏បានដែរ គឺជាលិខិតអមមួយសម្រាប់បញ្ជូនសំណុំលិខិតឯកសារមួយចំនួនពីអង្គភាពថ្នាក់លើ ទៅអង្គភាពថ្នាក់ក្រោម ឬ ទៅអង្គភាពថ្នាក់ប្រហាក់ប្រហែលគ្នា។ បើអង្គភាពថ្នាក់ក្រោមចង់ធ្វើសំណុំលិខិតឡើងទៅថ្នាក់លើគួរគប្បីប្រើលិខិតអមជាជំនួសវិញ ដោយរៀបរាប់អំពីឈ្មោះលិខិតដែលត្រូវផ្ញើនោះ។ ការធ្វើលិខិតអមផ្ញើទៅអង្គភាពថ្នាក់លើរបៀបនេះ គឺដើម្បីជាការគួរសមប៉ុណ្ណោះ។

ដីកាបញ្ជូននេះ ចុះហត្ថលេខាត្រឹមអគ្គនាយក ឬ នាយខុទ្ទកាល័យក្រសួង ឬ ស្ថាប័នបានហើយ មិនចាំបាច់ដល់រដ្ឋមន្ត្រីទេ។

សូមមើលឧទាហរណ៍គំរូដីកាបញ្ជូន ខាងក្រោម :

**ឧទាហរណ៍គំរូ ដីកាបញ្ជូន :**

[១៣] សូមមើល ឡេង លីមតុង : " ការងារការិយាល័យ " ១៩៩៧ ទំព័រ៣៩-៤០។

ព្រះរាជាណាចក្រកម្ពុជា

ក្រសួង...... ជាតិ សាសនា ព្រះមហាក្សត្រ

លេខ....... .........

# ដីកាបញ្ជូន

សំណុំឯកសារជូនមក..........

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | ............................ | ០១ | ........................................ |
| ២ | ............................ | ០២ | ........... |

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី....ខែ...ឆ្នាំ.....

តប. រដ្ឋមន្ត្រី

នាយខុទ្ទកាល័យ

ហត្ថលេខា

នាមឈ្មោះ និងត្រា

បានទទួលគ្រប់ចំនួនច្បាប់

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

អ្នកទទួល( មុខងារ)

ហត្ថលេខា

នាមឈ្មោះ និងត្រា

ឧបសម្ព័ន្ធទី១

# សុន្ទរកថារបស់ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៃរាជរដ្ឋាភិបាលកម្ពុជា
# ក្នុងពិធីបើកសន្និសីទជាតិ
# ស្តីពី
# ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ នៅ
# រាជបណ្ឌិតសភាកម្ពុជាថ្ងៃទី ៧-៩ ខែ កញ្ញា ឆ្នាំ ២០០០

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យបរទេស សាស្ត្រាចារ្យជាតិ លោកស្រី អស់លោក និង ប្រិយមិត្តទាំងអស់**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងមានមោទនភាពយ៉ាងក្រៃលែង ដោយបានចូលរួមក្នុងសន្និសីទជាតិ ស្តីពី ការស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍភាសាខ្មែរ ។

យើងដឹងថា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានបង្ហាញអោយឃើញថា ចាប់តាំងពីសម័យនគរភ្នំប្រទេសកម្ពុជាបានស្ថាបនាគ្រឹះអរិយធម៌ ដោយបណ្តុះនូវធនធានមនុស្សអោយមានចំណេះដឹងជ្រៅជ្រះ ទាំងខាងទស្សនៈ សាសនា ជំនាញវិជ្ជាជីវៈ ជាពិសេសសិក្សាពីក្បួនខ្នាតនៃភាសា ដើម្បីឱ្យមានសមត្ថភាពពេញលេញ ក្នុងការអភិវឌ្ឍន៍ សង្គមជាតិខ្មែរយើង ឱ្យមានភាពរុងរឿង ដោយរក្សាអត្តសញ្ញាណជាតិ ដ៏ល្អប្រពៃ ។

នាពេលបច្ចុប្បន្ន ក្នុងវិស័យស្រាវជ្រាវជាន់ខ្ពស់ ប្រទេសកម្ពុជាមានរាជបណ្ឌិតសភាកម្ពុជាដែលក្នុងនោះ វិទ្យាស្ថានភាសាជាតិមានភារកិច្ចគ្រប់គ្រង និង សម្របសម្រួលនូវរាល់កិច្ចការ និង សកម្មភាព សំខាន់ដែលទាក់ទងនឹងភាសាខ្មែរ ។ យើងត្រូវទទួលស្គាល់ថា មាត្រា៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣បានកំណត់យកភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺ ភាសា និង អក្សរខ្មែរ ។

វិស័យអប់រំ និង សិក្សាធិការ ក៏បានប្រើប្រាស់ភាសាខ្មែរជាភាសាយាន ។ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្ម បានអនុម័តពាក្យបច្ចេកទេស ពាក្យវិទ្យាសាស្ត្រ សម្រាប់ជំរុញការអភិវឌ្ឍភាសាខ្មែរចាប់ពី ឆ្នាំ ១៩៦៧ រហូតដល់ ឆ្នាំ ១៩៧៥ ។ បន្ទាប់ពីសាលារៀនត្រូវបិទទ្វារនៅចន្លោះ ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ភាសាខ្មែរបានលូតលាស់ឡើងវិញ ដោយមានការប្រើប្រាស់យ៉ាងទូលំទូលាយនូវភាសាខ្មែរ ក្នុងផ្នែក

អប់រំរដ្ឋបាល និងបណ្ដាញផ្សព្វផ្សាយ ប៉ុន្តែពុំទាន់មានលក្ខណៈឯកភាពគ្នាទេ ។ ស្ថាប័នសិក្សាខ្មែរទាំងអស់បាន ប្រើ ភាសា ខ្មែរ ជាយានសិក្សា ដោយរៀបចំនិយាមបង្កើតពាក្យសម្រាប់ ប្រើប្រាស់ផ្ទាល់ខ្លួន ។

ដូចនេះ សេចក្ដីត្រូវការជាបន្ទាន់មួយ គឺកំណត់ស្ដង់ដារដែលអាចទទួលយក សម្រាប់ការអភិវឌ្ឍ និង ការប្រើប្រាស់ភាសាខ្មែរលើគ្រប់វិស័យ ជាពិសេសក្នុងមុខវិជ្ជាសិក្សា ដែលទាក់ទងនឹងវិទ្យាសាស្ត្រជាក់ស្ដែង និង បច្ចេកទេស ។ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា គប្បីសហការ និង បំពេញបេសកកម្មសម្រប សម្រួលយ៉ាងណា ធ្វើឱ្យមានការដោះស្រាយ សំណួមពររួមជាបន្ទាន់មួយ ទាក់ទងនឹងឯកភាពអក្ខរាវិរុទ្ធ និង ការបង្កើតពាក្យថ្មីសម្រាប់ប្រើប្រាស់ក្នុងភាសាខ្មែរ ។

ឆ្លៀតឱកាសដ៏មហោឡារិកនេះ ទូលបង្គំខ្ញុំ ខ្ញុំបាទសូមបញ្ជាក់ថា តួនាទីភាសាខ្មែរនៅក្នុងប្រព័ន្ធអប់រំ ជាតិចាប់តាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្ដមសិក្សា មានសារៈសំខាន់ណាស់ ។ ការរីកចំរើននៃ ការយល់ដឹង របស់មនុស្សជាតិដែលបានឈានទៅរកលក្ខណៈទំនើប តម្រូវឱ្យមានការអភិវឌ្ឍខាងផ្នែកភាសា ប្រកបដោយនិរន្តរភាព ។ តាមរយៈបទពិសោធន៍ ផ្នែកនយោបាយ និង សង្គមនៃប្រជាជនខ្មែរ កន្លងមកតួនាទី ភាសាខ្មែរត្រូវបានចាត់ទុកជាគន្លងរបស់ជាតិ ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លានៅក្នុងប្រព័ន្ធសិក្សាជាតិ ។ ការរីក លូតលាស់នាំឱ្យការប្រើភាសា មានលក្ខណៈសមស្រប ព្រមទាំងឆ្លើយត្រូវនឹងគោលបំណងស្ថាបនាជាតិ ដែល តម្រូវឱ្យរាជរដ្ឋាភិបាល យកចិត្តទុកដាក់ទៅលើការអភិវឌ្ឍភាសាជាតិ ដែលមានជាអាទិ៍ :

<u>ទីមួយ</u> : ការកំណត់អត្តសញ្ញាណកម្មជាមូលដ្ឋាននៃការប្រើភាសា ក្នុងទិសដៅអភិវឌ្ឍភាសាជាតិ ជា ពិសេស ទាក់ទងទៅនឹងការប្រើប្រាស់ ជាប្រព័ន្ធសិក្សាក្នុងវិស័យអប់រំ ។

<u>ទីពីរ</u> : ការផ្ដល់អាទិភាពដល់អ្នកជំនាញខាងភាសាជាតិសម្រាប់អភិវឌ្ឍភាសាខ្មែរ ដើម្បីរួមវិភាគទាន ជំរុញការរីកលូតលាស់នៃភាសាខ្មែរ ឱ្យមានលក្ខណៈជាប្រព័ន្ធមួយក្នុងវិស័យអប់រំកម្ពុជា ។

<u>ទីបី</u> : ការគួបផ្សំបទពិសោធន៍ របស់ប្រទេសនានាក្នុងការអភិវឌ្ឍភាសាជាតិរបស់ខ្លួន ដោយលើក អនុសាសន៍ ស្ដីពីការអភិវឌ្ឍបន្ថែមទៀតនៃភាសាខ្មែរ និងរក្សាទុកនូវអត្តសញ្ញាណដ៏ឧត្ដុង្គ ឧត្ដមនៃជាតិ ដើម្បីបង្កើតគោលនយោបាយ នៃការប្រើប្រាស់ភាសាជាតិ តាមនីតិកម្មដ៏ត្រឹម ត្រូវមួយ ។

ខ្ញុំសង្ឃឹមថា សន្និសីទដែលយើងរៀបចំឡើងនៅពេលនេះ នឹងដោះស្រាយសំណួមពររួមធ្វើឱ្យភាសា

ខ្មែរយើងមានស្តង់ដារភាសាសាស្ត្រ រីកចំរើនប្រកបដោយ ឯកភាវូបនីយកម្ម អក្ខរាវិរុទ្ធ ពាក្យបច្ចេកទេស និង វិទ្យាសាស្ត្រ សម្រាប់ការប្រើប្រាស់ជាយានសិក្សា នៅក្នុងគ្រប់កំរិតសិក្សា ក្នុងការប្រើប្រាស់ក្នុងស្ថាប័នសាធារណៈ និងក្នុងបណ្តាញផ្សព្វផ្សាយនានា ។

ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវវេយ្យាករណ៍ និរុត្តិវិទ្យានៃភាសាខ្មែរ វចនានុក្រមវិទ្យា និងការយកចិត្តទុកដាក់ទៅលើ ភាសាខ្មែរបុរាណតាមសិលាចារឹក សាស្ត្រាស្លឹករឹត ក្រាំង ព្រមទាំងការ សិក្សាភាសាអំបូរមន-ខ្មែរ ការប្រើប្រាស់ភាសាខ្មែរ ក្នុងកុំព្យូទ័រ ជាថាមពលកាយបញ្ញា និង ស្មារតីដ៏ថ្លៃថ្លា ឧត្តុង្គឧត្តមនៃអ្នកជំនាញជាតិ និង អន្តរជាតិ ផ្នែកភាសាខ្មែរ ដែលបានសហការគ្នាធ្វើការសិក្សាស្រាវជ្រាវ ដើម្បីជួយលើកស្ទួយឡើងវិញនូវ វប្បធម៌សន្តិភាព ការជំរុញក្នុងការអភិវឌ្ឍន៍ និង សមធម៌សង្គម ដើម្បីលើកស្ទួយឡើងវិញនូវព្រលឹងជាតិខ្មែរ ។

ក្នុងន័យនេះខ្ញុំសូមធ្វើការអំពាវនាវដល់គ្រប់ស្ថាប័នជាតិ អង្គការអន្តរជាតិ និង មតិសាធារណៈជាតិ អន្តរជាតិទាំងអស់ សូមជួយផ្តល់ ការជួយឧបត្ថម្ភគាំទ្រដល់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីឱ្យស្ថាប័ននេះអាចសំរេចជោគជ័យ ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ក្នុងការរួមចំណែកលើកតម្លៃភាសារបស់ជាតិ ដើម្បីបុព្វហេតុ នៃអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា ។

នៅក្នុងស្មារតីប្រកបដោយមោទនភាពដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមប្រកាសបើកសន្និសីទជាតិ ស្តីពីការស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍភាសាខ្មែរចាប់ពីពេលនេះតទៅ ។

ខ្ញុំសូមគោរពថ្វាយព្រះពរ និង ជូនពរ ព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សាស្ត្រាចារ្យជាតិ និងបរទេស លោក និង លោកស្រី ទាំងអស់ដែលបានចូលរួមក្នុងសន្និសីទជាតិនេះ សូមឱ្យប្រកបតែពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ សូមអរគុណ**

# សុន្ទរកថា
## ឯកឧត្តម ស ខេង នាយករដ្ឋមន្ត្រីស្តីទី
## ក្នុងឱកាសបិទសន្និសីទជាតិ ស្តីពីការស្រាវជ្រាវឯកភាព
## និង អភិវឌ្ឍភាសាខ្មែរ នៅរាជបណ្ឌិតសភាកម្ពុជា
## ( ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០០ )

**************

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុថេរគ្រប់ព្រះអង្គ !*

*សូមគោរព ឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោកស្រី អស់លោក និង មិត្តភក្តិ ទាំងអស់ ជាភ្ញៀវជាតិ និង អន្តរជាតិ !*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមកចូលរួមជាអធិបតីក្នុងពិធីបិទសន្និសិទជាតិ ស្តីពីការស្រាវជ្រាវឯកភាព និង អភិវឌ្ឍភាសាខ្មែរ ដែលបានប្រារព្ធធ្វើនៅរាជបណ្ឌិតសភាកម្ពុជាអស់រយៈពេល ៣ ថ្ងៃមកនេះ ។

ក្នុងនាមរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសម្តេច ហ៊ុន សែន ជាប្រមុខ និង ក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវសេចក្តីកោតសរសើរដ៏ស្មោះស្ម័គ្រអស់ពីដួងហឫទ័យ ចំពោះអង្គសន្និសិទទាំងមូល ដែលត្រូវបានអស់លោកជាវាគ្មិនជាតិ អន្តរជាតិ ជាពិសេសបណ្ឌិតអ្នកជំនាញឯកទេសខាងភាសាវិទ្យា វេយ្យាករណ៍ និរុត្តិវិទ្យា វចនានុក្រមវិទ្យា សិលាចារិកវិទ្យា សិក្សាភាសាអំបូរមន-ខ្មែរ ការប្រើប្រាស់ភាសាខ្មែរក្នុងកុំព្យូទ័រ ដោយបានផ្លោះប្តូរមតិយោបល់ គ្រើនរំលឹក សហការក្នុងកិច្ចការស្រាវជ្រាវ ក្នុងបំណងរុញច្រានឲ្យមានការអភិវឌ្ឍន៍ភាសាខ្មែរ ឲ្យភាសាខ្មែរចំរើនឡើងជាលំដាប់ប្រកបដោយឯកភាពជានិរន្តភាព និង រក្សាទុកឲ្យខាងតែបាននូវអត្តសញ្ញាណដ៏ថ្លៃថ្នូនៃជាតិកម្ពុជាយើង ។

*អង្គសន្និសិទ ជាទីគោរពស្នេហា !*

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអនុញ្ញាតថ្លែងជូនអង្គសន្និសិទ នូវគោលគំនិតសំខាន់ៗ របស់រាជរដ្ឋាភិបាលក្នុងការផ្តួចផ្តើមទ្រទ្រង់ឲ្យមានការឯកភាព និង អភិវឌ្ឍន៍ភាសា និង អក្សរខ្មែរយើង ដោយចាប់ផ្តើមពីការរំលឹកជូនអង្គសន្និសិទ និង ជនរួមជាតិទាំងអស់ថា ជំពូកទី១ មាត្រា៥ នៃរដ្ឋធម្មនុញ្ញរបស់

ព្រះរាជាណាចក្រកម្ពុជាយើងបានចែងច្បាស់ថា << ភាសា និង អក្សរដែលប្រើជាផ្លូវការគឺភាសា និង អក្សរខ្មែរ >> ។ ខ្ញុំសូមមិនពន្យល់ ឬ បកស្រាយជូនពីអត្ថន័យនៃពាក្យភាសាខ្មែរ អក្សរខ្មែរ ជូនអង្គសន្និសិទដែលប្រមូលផ្តុំទៅដោយអស់លោកជាបណ្ឌិតសាស្ត្រាចារ្យភាសា អក្សរសាស្ត្រដ៏ចំណានៗ នោះឡើយ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសូមឲ្យអង្គសន្និសិទយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការសិក្សាស្រាវជ្រាវស្តីពីភាសាខ្មែរ ក្រោយពេលដែលសន្និសិទបញ្ចប់ទៅ ។

តើត្រូវស្រាវជ្រាវអំពីអ្វី ? វិទ្យាស្ថានភាសា នៃរាជបណ្ឌិតសភាកម្ពុជា អាចជាទីកន្លែងដែលផ្តល់ចម្លើយដ៏ត្រឹមត្រូវបំផុតចំពោះសំណួរនេះ ។ ចំពោះខ្ញុំ ខ្ញុំគិតថាការស្រាវជ្រាវគឺនឹងនាំមកនូវអ្វីដែលថ្មី ហើយល្អជាងមុន ដូច្នេះការស្រាវជ្រាវភាសាអក្សរសាស្ត្រអាចនឹងនាំមកនូវអ្វីដែលថ្មី និង ល្អជាងមុនដែរ ។ ការសិក្សាស្រាវជ្រាវធ្វើឲ្យកើតឡើងជាការចងក្រងដំបូងក្នុង ឆ្នាំ ១៩១៥ នូវវចនានុក្រមខ្មែរ ។ ការវិវត្តន៍នៃភាសា និង អក្សរខ្មែរបានផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅជាក់ស្តែងពីជំនាន់មនុស្សមួយ ទៅជំនាន់មនុស្សមួយទៀត ។ ក្រៅពីនេះភាសា និង អក្សរខ្មែរយើងរុងរឿងត្រចះត្រចង់ ឬជួបនឹងភាពច្របូកច្របល់អាស្រ័យទៅតាមពេលវេលាសន្តិភាព ឬ សង្គ្រាមដែលកើតឡើងលើទឹកដីកម្ពុជាយើងនេះ ។

នៅមុនឆ្នាំ ១៩៧០ គឺមុនពេលដែលប្រទេសជាតិធ្លាក់ទៅក្នុងសង្គ្រាម យើងមានសៀវភៅជាច្រើនដែលបោះពុម្ពជាភាសាខ្មែរ ប្រជាពលរដ្ឋនិយមការសរសេរដោយហេតុថា មានពេលសរសេរ ចេះរបៀបសរសេរ ហើយរបៀបសរសេរនោះទៀតសោតសឹងតែមានការឯកភាពគ្នាក្នុងកិរិតគួរឲ្យកោតសរសើរ ដោយគេបានយកវចនានុក្រមខ្មែរ ដែលនិពន្ធ និង ចងក្រងដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ធ្វើជាគោលឯកភាព ។ ម្យ៉ាងវិញទៀតភាសានិយាយក្នុងសម័យកាលសន្តិភាពគឺជាភាសាដែលរមែងជាទីសណ្តាប់ នៃជនានុជនទូទៅផងដែរ ។

នៅក្នុងសម័យសង្គ្រាមប្រមាណជិត ៣ ទសវត្ស ក្រោយឆ្នាំ ១៩៧០ ភាសា និង អក្សរខ្មែរក៏ស្ថិតនៅក្នុងសភាពច្របូកច្របល់ អ្នកនិពន្ធខ្មែរគ្មានពេលសរសេរ លែងចង់សរសេរ សៀវភៅបោះពុម្ពជាអក្សរខ្មែរមានតិចតួច ដែលជាហេតុបណ្តាលឲ្យភាសាសរសេរអាប់ឱនថមថយរស្មីបន្តិចម្តងៗ គួរឲ្យបារម្ភ ។ នៅក្នុងសម័យសង្គ្រាមស៊ីវិលក៏មានការកកើតឡើងនូវភាសាថ្មីៗមួយចំនួន ដែលយើងពុំធ្លាប់បានឮ ឬក៏ឃើញនរណាសរសេរ ក៏ប៉ុន្តែភាសាថ្មីៗនោះហាក់ដូចជាមិនជាទីសណ្តាប់ ឬ គួរឲ្យចង់អាននោះទេ ឧទាហរណ៍ពាក្យថា ខ្លាំងងាប់ប៉ុណ្ណោះ

ក្បាល ប៉ុណ្ណោះក្បាល ដែលគ្រប់ភាគីខ្មែរបដិបក្ខក្នុងសង្គ្រាមស៊ីវិលបានប្រើដូចៗគ្នា ។

នេះជាពាក្យថ្មីកើតក្នុងសង្គ្រាម ពាក្យថ្មីដែលកើតចេញដោយគ្មានការស្រាវជ្រាវ កើតចេញពីភ្លើងផ្សែងសង្គ្រាមដ៏គួរឲ្យអាម៉ាស់ ហើយដែលលទ្ធផលរបស់វាពុំបានល្អប្រសើរជាងអ្វីដែលចាស់នោះទេ ។

*ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ប្រិយមិត្តទាំងអស់ !*

ខ្ញុំមានជំនឿមុតមាំថា ការបង្កើតគោលនយោបាយ នៃការប្រើប្រាស់ភាសាតាមនីតិវិធីដ៏ត្រឹមត្រូវ ការរៀបចំយន្តការ ស្វែងរកឯកភាពក្នុងភាសាជាតិដោយផ្អែកលើមូលដ្ឋាន និង វិធីសាស្ត្រ វិទ្យាសាស្ត្រជាក់ស្តែង ជាវិភាគទានដ៏ឧត្តុង្គឧត្តម សម្រាប់ការអភិវឌ្ឍន៍សង្គមកម្ពុជាឲ្យសំរេចបាននូវវប្បធម៌សន្តិភាពដោយរួមគ្នាដោះស្រាយបញ្ហាសំខាន់ៗ ក្នុងស្មារតីជំរុះនូវទស្សនៈ ឬ មតិឃ្លាតឆ្ងាយពីគ្នា មិនទុកចិត្តគ្នា ហើយលើកស្ទួយនូវគតិបណ្ឌិត ភាពស្មោះត្រង់ ដើម្បីលុបបំបាត់នូវភាពអសកម្មទាំងឡាយនៅក្នុងភាសាខ្មែរ ។ រាជរដ្ឋាភិបាលបានចាត់ទុកថាការឯកភាពភាសាជាតិ ព្រមជាមួយនឹងចំណេះដឹងភាសាបរទេសបន្ថែមជាគន្លឹះ និង ជាកត្តាសំខាន់បំផុត ដែលកំណត់ជោគជ័យក្នុងកិច្ចអភិវឌ្ឍន៍ធនធានមនុស្សចាំបាច់សំរាប់ការលើកស្ទួយសេដ្ឋកិច្ច និង សង្គមកម្ពុជានាពេលបច្ចុប្បន្ន និង អនាគត ។

ដើម្បីសំរេចបាននូវការឯកភាពភាសាជាតិខ្មែរយើង ពីលើវេទិកា នៃអង្គសន្និសិទនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវឲ្យជនរួមជាតិខ្មែរទាំងអស់ទាំងក្នុងប្រទេស ទាំងបងប្អូនជនរួមជាតិខ្មែរដែលកំពុងតែរស់នៅឯបរទេស នៅពេលសរសេរអក្សរខ្មែរត្រូវគោរពប្រតិបត្តិតាមក្បួនច្បាប់នៃការសរសេរ និង អក្ខរាវិរុទ្ធទាំងឡាយនៅក្នុងវចនានុក្រមខ្មែរនិពន្ធ និង ចងក្រងឡើងដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលជនរួមជាតិខ្មែរគ្រប់ៗ គ្នាទទួលស្គាល់ថាព្រះអង្គជាអ្នកប្រាជ្ញភាសា អក្សរសាស្ត្រខ្មែរនាសតវត្សទី២០ នេះ ។

ខ្ញុំគិតថា វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ជាច្បាប់ដែលយើងត្រូវប្រតិបត្តិតាមក្នុងការសរសេរអក្សរខ្មែរ ។ ការដែលត្រូវសរសេរតាមវចនានុក្រមនេះយើងទាំងអស់គ្នាត្រូវតែធ្វើឡើងដោយគោរពដល់វិន័យនៃការសរសេរ

អក្សរសាស្ត្រជាតិ ។ វិន័យនេះមានសារៈសំខាន់យ៉ាងក្រៃលែងដល់ការស្រាវជ្រាវឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ ។

សូមបងប្អូនជនរួមជាតិខ្មែរទាំងឡាយ ព្យាយាមសរសេរអក្សរខ្មែរឲ្យបានជារបៀបដូចគ្នាទាំងអស់ ទោះបីជាយើងមានគ្រាមភាសាដោយឡែកៗ ពីគ្នាតាមតំបន់ ខេត្ត ខ័ណ្ឌ ស្រុក ឃុំ ភូមិ ដែនដីនាទីកដីកម្ពុជាក៏ដោយ ហើយសូមឲ្យមានសេចក្ដីខ្មាស់អៀនក្នុងចិត្ត កាលណាបើសរសេរភ្លាត់ផ្លូតខុសពីពាក្យក្នុងវចនានុក្រម ត្បិតការសរសេរខុសដូច្នេះសំដែងឲ្យឃើញថាយើងខ្វះការសិក្សាដោយពិតប្រាកដ ។ ការសរសេរអក្សរសាស្ត្រជាតិឲ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍តាមវចនានុក្រម គឺជាកិត្តិយសមួយដ៏ខ្ពង់ខ្ពស់ ។ ក្រៅពីនេះការគោរពក្បួនខ្នាតនៃការនិយាយភាសាខ្មែរ និង សរសេរអក្សរខ្មែរ មានអត្ថន័យដ៏ពិតប្រាកដថា យើងបានគោរពបូជាដល់គុណូបការៈនៃបុព្វការីជនអ្នកប្រាជ្ញអក្សរសាស្ត្រអ្នកស្នេហាជាតិខ្មែរជាច្រើនជំនាន់ ដែលបានសុខចិត្តបូជាជីវិតដើម្បីបុព្វហេតុនៃការថែរក្សាភាសា អក្សរសាស្ត្រ និង ពូជសាសន៍ខ្មែរ ។ យើងមានមោទនៈភាពចំពោះភាសា និង អក្សរសាស្ត្រយើងដែលសំបូរបែប ។ តែពេលខ្លះយើងយកមកប្រើប្រាស់ខុសក្បួនខ្នាត ។ ឧទាហរណ៍ : ពាក្យថា << ញុំា >> ។ ពាក្យថាញុំានេះ គឺជាពាក្យយើនិយាយបានសំរាប់តែកូនក្មេងតូច ។ ខ្ញុំសង្កេតឃើញថាមានអ្នកខ្លះបាននាំគ្នានិយាយពាក្យនេះ ដោយពុំនឹកថាខ្លួនកំពុងមានវ័យចំណាស់ និង មានតួនាទីក្នុងសង្គមទេ ។

ខ្ញុំសូមថ្លែងជូននូវការកោតសរសើរដ៏ស្មោះ ចំពោះវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា និង គណៈកម្មការរៀបចំសន្និសីទ ដែលបានផ្ដួចផ្ដើមរៀបចំសន្និសីទស្ដីពី ភាសាជាតិជាលើកដំបូង ដើម្បីប្រមូលអ្នកជំនាញខាងភាសា និង អ្នកបច្ចេកទេស សិក្សាស្រាវជ្រាវបញ្ចូលភាសាខ្មែរក្នុងបណ្ដាញប្រព័ន្ធផ្សព្វផ្សាយ ដោយសហការគ្នាបំពេញបេសកកម្មលើកតម្លៃភាសាខ្មែរក្នុងបុព្វហេតុដ៏រុងរឿងរបស់ប្រទេសកម្ពុជា ។

ទន្ទឹមនឹងនេះតាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្នើឲ្យលោកបណ្ឌិតលោកសាស្ត្រាចារ្យ និង អ្នកស្រាវជ្រាវខាងភាសាវិទ្យា ជួយពន្យល់ណែនាំជនរួមជាតិឲ្យនិយាយ និង សរសេរភាសាខ្មែរតាមក្បួនខ្នាតវេយ្យាករណ៍ត្រឹមត្រូវបង្កើតពាក្យបច្ចេកទេសវិទ្យាសាស្ត្រ ចាំបាច់សំរាប់ការអភិវឌ្ឍន៍ផ្នែកអប់រំគ្រប់ភូមិសិក្សា ជាពិសេសចងក្រងភាសាជាតិយើងជាវចនានុក្រមគ្រប់បែប ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍របស់ស្ថាប័នសាធារណៈ និង ឯកជននានា ។

ចំពោះប្រព័ន្ធផ្សព្វផ្សាយនានាដូចជា វិទ្យុ ទូរទស្សន៍ សារពត៌មាន ទស្សនាវដ្ដី ដែលមានតួនាទីផ្ដល់ពត៌មានទាក់ទងនឹងចំណេះដឹងខាងផ្នែកវប្បធម៌ អក្សរសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកទេស សូមឲ្យរួមសហការប្រើភាសាខ្មែរ ដែលគណៈកម្មាធិការជាតិ បានលើកជាក្បួនខ្នាតត្រឹមត្រូវសម្រាប់អភិវឌ្ឍន៍ភាសាខ្មែរ ។

ជាមួយនេះខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណ និង កោតសរសើរចំពោះគណៈកម្មការរៀបចំសន្និសីទស្ដីពី ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ និង សូមកោតសរសើរចំពោះសំណើបង្កើតឡើងនូវគណៈកម្មាធិការភាសាជាតិ សម្រាប់ជាយន្តការធានាដល់ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ ដែលជាលទ្ធផលគួរជាទីមោទនៈ ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង ជូនពរ ឯកឧត្ដម លោកជំទាវ លោកស្រី អស់លោក ជាភ្ញៀវ លោក លោកស្រី បណ្ឌិតសាស្ត្រាចារ្យ និង អង្គសន្និសីទទាំងមូល សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

សូមអរព្រះគុណ សូមអរគុណ !

# សុន្ទរកថាស្វាគមន៍
# របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុំ ច័ន អនុប្រធានវិទ្យាស្ថានភាសាជាតិ ថ្លែងក្នុងពិធីបើកសន្និសីទជាតិ ស្តីពី ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥**

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !
- សូមគោរពឯកឧត្តម ស៊ិន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យបណ្ឌិត លោក លោកស្រី និងអង្គសន្និសីទទាំងមូល

នៅថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសោមនស្សយ៉ាងក្រៃលែង ដោយបានឃើញវត្តមានដ៏ថាំបាច់របស់ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក និងលោកស្រី បណ្ឌិត-សាស្ត្រាចារ្យ មន្ត្រីតំណាងក្រសួងស្ថាប័ននានា អ្នកស្រាវជ្រាវ និងនិស្សិតទាំងអស់ នៅក្នុងសន្និសីទជាតិ ស្តីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២* នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ នេះ។ ឆ្លៀតឱកាសនេះ សូមអនុញ្ញាតធ្វើការសង្ខេបពីការងារដែលវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានខិតខំពុះពារបំពេញ និងធ្វើឱ្យសម្រេចជាផ្លែផ្កានូវអនុសាសន៍នៃអង្គសន្និសីទជាតិ ស្តីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី១* ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៧-៩ ខែកញ្ញា ឆ្នាំ២០០០ កន្លងទៅ។ រាជបណ្ឌិតសភាកម្ពុជា បានខិតខំប្រមូលអ្នកឯកទេស ដែលមានបទពិសោធន៍ ឱ្យជួយបណ្តុះបណ្តាលក្រុមខណ្ឌអ្នកស្រាវជ្រាវបានបួនជំនាន់ ដែលនៅក្នុងនោះមានអ្នកសិក្សាភាសាខ្មែរចំនួន២៤នាក់។ មន្ត្រីនៃវិទ្យាស្ថានភាសាជាតិទាំងនេះ រួមជាមួយសាស្ត្រាចារ្យបណ្ឌិតជំនាញខាងភាសាវិទ្យា បានចូលរួមស្រាវជ្រាវស្នាដៃ អ្នកប្រាជ្ញខាងភាសាវិទ្យាជំនាន់មុន ហើយប្រមូលក្បួនខ្នាតវេយ្យាករណ៍ ព្រមទាំងពាក្យបច្ចេកស័ព្ទដែលស្ថាប័នរដ្ឋ និងសាកលវិទ្យាល័យនានាបានបង្កើត និងចងក្រងជាសទ្ទានុក្រម ហើយដាក់ស្នើជូនគណៈកម្មការអក្ខរាវិរុទ្ធនៃរាជបណ្ឌិតសភាកម្ពុជាពិនិត្យ។ ក្រុមអ្នកស្រាវជ្រាវផ្នែកភាសានៃវិទ្យាស្ថានភាសាជាតិ បានប្រមូលមេពាក្យថ្មី និងពាក្យសមាសនៃពាក្យបច្ចេកស័ព្ទថ្មី

ដែលគោរពតាមនិយាមវេយ្យាករណ៍ខ្មែរ និងបានទទួលការប្រើប្រាស់ជាសាធារណៈហើយ មកបញ្ចូលបន្ថែមទៅលើមេពាក្យដែលមានក្នុងវចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ដើម្បីចងក្រងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរជាជំហានទី១ ដើម្បីទុកជាឯកសារពិគ្រោះសម្រាប់សរសេរអក្សរខ្មែរឱ្យបានត្រឹមត្រូវ។ ការខិតខំយ៉ាងសកម្មក្នុងការរៀបចំវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរនេះ ជាស្ពានសម្រាប់ឈានទៅរៀបចំវចនានុក្រមនៃភាសាខ្មែរ បន្តស្នាដៃរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។

ក្នុងការអភិវឌ្ឍភាសាខ្មែរឱ្យបានកាន់តែសម្បូរបែប ក្រុមការងារឯកទេសផ្នែកភាសានៃវិទ្យាស្ថានភាសាជាតិ បានចងក្រង និងផ្សព្វផ្សាយនូវទស្សនៈ និងនិទ្ទាការផ្សេងៗក្នុងការអភិវឌ្ឍភាសា តាមរយៈទស្សនាវដ្តីចាប់ពីលេខ១ ដល់ លេខ៤, បទសម្ភាសន៍សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមអត្ថាធិប្បាយសទិសសព្ទពហុន័យសព្ទ, វចនានុក្រមខ្មែរបុរាណសម័យមុនអង្គរ, វចនានុក្រមខ្មែរបុរាណសម័យអង្គរ, សៀវភៅទំនាក់ទំនងភាសាមន-ខ្មែរ, វចនានុក្រមស្ថាននាមវិទ្យាសម័យអង្គរ, វចនានុក្រមនរនាមវិទ្យាសម័យអង្គរ និង ចុះផ្ទៀងផ្ទាត់និងបកប្រែសិលាចារឹកនៅខេត្តបាត់ដំបង តាមរយៈគម្រោងរបស់មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិតសភាកម្ពុជា។

វិទ្យាស្ថានភាសាជាតិ បានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រគរុកោសល្យនិងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និង កីឡា ក្នុងការអភិវឌ្ឍភាសាមន-ខ្មែរ នៅខេត្តរតនគិរី, មណ្ឌលគិរី និង ព្រះវិហារ ដោយជំរុញឱ្យយកសញ្ញាអក្សរខ្មែរ សម្រាប់កត់សូរភាសា ទំពួន គ្រឹង ភ្នង ព្រៅ និង កួយ សម្រាប់រៀនភាសា និង លើកតម្កើងវប្បធម៌ប្រពៃណីខ្លួន និង អាចសិក្សាភាសាខ្មែរ ដើម្បីបង្កើនចំណេះដឹងនិងពង្រឹងសមត្ថភាព ក្នុងការរួមចំណែកស្ថាបនាប្រទេសកម្ពុជា។

## *អង្គសន្និសីទជាទីគោរព*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា ស្របតាមអនុសាសន៍នៃអង្គសន្និសីទលើកទី១ និងដើម្បីអភិវឌ្ឍន៍ភាសាជាតិ វិទ្យាស្ថានភាសាជាតិបានសហការជាមួយគណៈកម្មាធិការរៀបចំស្តង់ដារអក្ខរក្រមខ្មែរក្នុងកុំព្យូទ័រ ដើម្បីបញ្ចូលពាក្យខ្មែរក្នុងប្រព័ន្ធកុំព្យូទ័រ សម្រាប់សម្រួលដល់ការសរសេរភាសាខ្មែរឱ្យបានឯកភាពគ្នា តាមរយៈការបញ្ជាក់ដោយគូសក្រហមពីក្រោមពាក្យដែលសរសេរខុសអក្ខរាវិរុទ្ធ និង គូសខៀវបញ្ជាក់ពីការសរសេរខុសរបៀបប្រើប្រាស់វណ្ណយុត្តិ

និង ឃ្លាប្រយោគនៃភាសាខ្មែរ។ ខ្ញុំមានជំនឿថា ភាសាខ្មែរយើងនឹងរុងរឿង ហើយអាចឆ្លើយតបនឹងតម្រូវការប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍ ដូចភាសាអន្តរជាតិដទៃទៀតដែរ។

ម្យ៉ាងវិញទៀត ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់មូលនិធិកូរ៉េសម្រាប់ការសិក្សាស្រាវជ្រាវ ចំពោះការឧបត្ថម្ភថវិកា តាមរយៈមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីរៀបចំសន្និសីទ ស្ដីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២* នៅរាជបណ្ឌិតសភាកម្ពុជា។

## *អង្គសន្និសីទជាទីគោរព*

នៅក្នុងឱកាសជួបជុំគ្នានេះ មានវាគ្មិនជាតិ និង អន្តរជាតិ ដែលស្គាល់តម្លៃ និង ស្រឡាញ់ចូលចិត្តភាសាខ្មែរ បានបញ្ចេញទស្សនៈ ទ្រឹស្ដីភាសាវិទ្យា និង បង្ហាញពីសារសំខាន់នៃភាសាខ្មែរ ដើម្បីស្រាវជ្រាវរករូបមន្ត ធ្វើឱ្យមានឯកភាពក្នុងការអភិវឌ្ឍភាសាខ្មែរ ឱ្យឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាផ្លូវការ ក៏ដូចជាការប្រើប្រាស់ភាសាខ្មែរជាយានសិក្សាសម្រាប់គ្រប់ភូមិសិក្សា តាំងពីបឋមសិក្សា, មធ្យមសិក្សារហូតដល់ឧត្តមសិក្សា។

ខ្ញុំសង្ឃឹមថា សន្និសីទជាតិនឹងឈានដល់ការឯកភាពក្នុងអភិវឌ្ឍន៍ភាសាជាតិ ដែលជាអត្តសញ្ញាណដ៏ឧត្តុង្គឧត្តមរបស់ជាតិខ្មែរយើង។

សូមអរព្រះគុណ និង អគុណ!

## សុន្ទរកថា

## ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា

## នៅក្នុងឱកាសបើកសន្និសីទជាតិ ស្ដីពីការសិក្សាស្រាវជ្រាវ ឯកភាព

## និងអភិវឌ្ឍន៍ភាសាខ្មែរ

## លើកទី២ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !

ឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោកស្រី អស់លោក ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងប្អូនៗនិស្សិតទាំងអស់ជាទីមេត្រី !

ខ្ញុំព្រះករុណាខ្ញុំ មានកិត្តិយស និងសេចក្ដីសោមនស្សរីករាយ ដោយបានចូលរួមក្នុងពិធីបើកសន្និសីទជាតិ ស្ដីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២* នៅពេលនេះ។ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក បានជ្រាបហើយថា កាលពីខែកញ្ញា ឆ្នាំ២០០០ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានរៀបចំសន្និសីទជាតិ ស្ដីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី១* ដើម្បីផ្ដល់ឱកាសជូនអ្នកជំនាញខាងភាសាជាតិ ឱ្យធ្វើការបង្ហាញ និងពិភាក្សាអំពីលទ្ធផលនៃការស្រាវជ្រាវថ្មីៗស្ដីពីភាសាខ្មែរ ព្រមទាំងផ្ដល់ជាមតិយោបល់ ប្រកបដោយវិចារណញ្ញាណ ឈានទៅរកការឯកភាពខាងភាសាឡើងវិញ ដើម្បីមានលទ្ធភាពក្នុងការអភិវឌ្ឍភាសារបស់យើង។ អត្ថបទអន្តរាគមន៍មួយចំនួនត្រូវបានចងក្រងជាសៀវភៅ និងបានធ្វើការផ្សព្វផ្សាយ។ សន្និសីទជាតិនោះ បានផ្ដល់អនុសាសន៍ចំនួន ២២ចំណុច ដើម្បី ឈានទៅសម្រេចនូវការឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ។ ព្រមជាមួយនេះ ឯកឧត្តម **សខេង** ជាឧបនាយករដ្ឋមន្ត្រី និងជានាយករដ្ឋមន្ត្រីស្ដីទី ដែលបានអញ្ជើញមកជាអធិបតី ក្នុងពិធីបិទសន្និសីទនៅថ្ងៃទី៩ កញ្ញា ២០០០ នោះ បានកំណត់ឱ្យយកវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពគ្រាទី៥ ជាគោលក្នុងការសរសេរ និងប្រើប្រាស់ភាសាខ្មែរជាផ្លូវការទូទាំងប្រទេស។

*ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ! អង្គសន្និសីទជាតជានីមេត្រី !*

បន្ទាប់ពីសន្និសីទជាតិកាលពីឆ្នាំ២០០០ នោះ យើងសង្កេតឃើញថា ក្នុងរយៈពេល៥ឆ្នាំ នេះ ក្រសួង ស្ថានប័នជាតិ អន្តរជាតិនានាទូទាំងប្រទេស ជាពិសេសគណៈកម្មាធិការរៀបចំស្តង់ដារអក្ខរក្រមខ្មែរក្នុងកុំព្យូទ័រ បានអនុវត្តតាមការកំណត់ខាងលើនេះ ក្នុងការបញ្ចូលភាសាខ្មែរក្នុងប្រព័ន្ធ UNICODE ។

ខ្ញុំសូមឯកភាព នឹងខ្លឹមសារនៃសុន្ទរកថាស្វាគមន៍ ដែលថ្លែងដោយសាស្ត្រាចារ្យបណ្ឌិត អ៊ុំ ច័ន ជាអនុប្រធានវិទ្យាស្ថានភាសាជាតិ ដែលបានបង្ហាញថា រយៈពេល ៥ឆ្នាំ បន្ទាប់ពីសន្និសីទលើកទី១ ក្នុងចំណោមអនុសាសន៍ទាំង២២ នោះ យើងអនុវត្តបាននូវអនុសាសន៍មួយចំនួនហើយ ប៉ុន្តែការងារដែលយើងត្រូវធ្វើក្នុងផ្នែកភាសាជាតិនេះ មានទំហំធំធេងណាស់ ដែលតម្រូវឱ្យមាននូវធនធានមនុស្សកម្រិតខ្ពស់ច្រើននាក់ និងមធ្យោបាយហិរញ្ញវត្ថុសមស្រប។ ទោះជាយ៉ាងនេះក្តី ក៏វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានខិតខំចងក្រងវចនានុក្រមអក្ខរាវិរុទ្ធភាសាខ្មែរ និងបានបោះពុម្ពផ្សាយរួចហើយ។ ទន្ទឹមនឹងនេះ វិទ្យាស្ថានភាសាជាតិបានចូលរួមជាមួយគណៈកម្មាធិការរៀបចំស្តង់ដារអក្ខរក្រមខ្មែរក្នុងកុំព្យូទ័រ ដើម្បីបញ្ចូលភាសាខ្មែរក្នុងប្រព័ន្ធ UNICODE និងបានចូលរួមក្នុងគណៈកម្មការបណ្ឌិតសភាអនុម័តិពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី។ លើសពីនេះទៅទៀត វិទ្យាស្ថាននេះ បានចងក្រងនូវសៀវភៅដែលជាក្បួនខ្នាតមួយចំនួនបម្រុងនឹងបោះពុម្ពដូចជា ៖ សៀវភៅវេយ្យាករណ៍ របស់សាស្ត្រាចារ្យ *ពុំ ម៉ល់*, សៀវភៅរបស់សាស្ត្រាចារ្យបណ្ឌិត *ឡុង សៀម* មានដូចជា ទំនាក់ទំនង និងវាក្យសព្ទមូលដ្ឋាននៃ ភាសាមន-ខ្មែរ ទៅនឹងអំបូរដទៃនៃភាសាអូស្ត្រូអាស៊ីយ៉ាទិក, វចនានុក្រមខ្មែរបុរាណសម័យអង្គរ ស.វ.ទី៩-១៥, វចនានុក្រមនរនាមសម័យអង្គរស.វ.ទី៩-១៥ និង វចនានុក្រមស្ថាននាមវិទ្យាសម័យ អង្គរស.វ.ទី៩-១៥, និង វចនានុក្រមអត្ថាធិប្បាយសទិសសព្ទ ពហុន័យសព្ទ របស់លោក *ជួរ គារី* ។ ចំពោះសៀវភៅវេយ្យាករណ៍ខ្មែរ ដែលដឹកនាំរៀបចំដោយសាស្ត្រាចារ្យបណ្ឌិត *ឃីន សុខ* ក្នុងក្របខណ្ឌ នៃរាជបណ្ឌិតសភាកម្ពុជាក៏បម្រុងនឹងបោះពុម្ពដែរ ពីព្រោះបានទទួលការអនុញ្ញាតពីសម្តេចនាយក រដ្ឋមន្ត្រី ហ៊ុន សែន រួចហើយ។

*អង្គសន្និសីទជាតជានីមេត្រី !*

ថ្ងៃនេះ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានប្រារព្ធសន្និសីទជាតិ ស្តីពីការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២ នេះឡើង ដើម្បីផ្តល់ឱកាសជាថ្មីម្តងទៀត

ដល់វាគ្មិនជាតិ និងអន្តរជាតិ ដែលខិតខំស្រាវជ្រាវអស់រយៈពេល៥ឆ្នាំកន្លងមកនេះ ឱ្យធ្វើការបង្ហាញអំពីលទ្ធផលស្រាវជ្រាវថ្មីៗ ព្រមទាំងមតិយោបល់ឈានទៅរកការឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរដោយជោគជ័យ។ មកដល់ថ្ងៃនេះ ការឯកភាពភាសាជាតិនៅជាបញ្ហាស្មុគស្មាញនៅឡើយ។ ខ្ញុំមានសេចក្តីសង្ឃឹមថា បទអន្តរាគមន៍ទាំងឡាយ ស្តីពីការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ នឹងលើកយកនូវបទពិសោធន៍ពីអតីតកាលមកធ្វើជាទុន សម្រាប់ពិចារណាក្នុងពេលបច្ចុប្បន្ន ព្រមទាំង លើកយកនូវមតិយោបល់ ផ្អែកលើមូលដ្ឋានវិចារណញ្ញាណ និងប្រាកដនិយម ដើម្បីសម្រេចនូវគោលបំណងចម្បងរបស់យើង *គឺឯកភាពសម្រាប់អភិវឌ្ឍន៍* ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះវិទ្យាស្ថានភាសាជាតិ ដែលបានជួយជំរុញការសិក្សាស្រាវជ្រាវ ចងក្រងនូវអ្វីៗដែលជាក្បួនខ្នាតខាងអក្សរសាស្ត្រ និងភាសាខ្មែរ។ ខ្ញុំក៏សូមអបអរសាទរ ចំពោះការចូលរួមនៃអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិទាំងឡាយ ក្នុងសន្និសីទនេះ ក្នុងគោលដៅឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ ដើម្បីរួមចំណែកក្នុងការកសាង និងអភិវឌ្ឍន៍ជាតិយើងឱ្យរីកចម្រើនតរៀងទៅ។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរសព្ទសាធុការចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរចំពោះឯកឧត្តម លោកជំទាវ លោកស្រី អស់លោកជាភ្ញៀវ ជាវាគ្មិនជាតិ និងអន្តរជាតិ ព្រមទាំងប្អូនៗនិស្សិតទាំងអស់នៃអង្គសន្និសីទនេះ ប្រកបដោយព្រះពុទ្ធពរទាំង៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកអង្គសន្និសីទជាតិ ស្តីពីការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២ ចាប់ពីពេលនេះតទៅ។

សូមអរព្រះគុណ សូមអរគុណ !

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ:

# សុ ន្ទ រ ក ថា

◆◆◆+◆◆◆

**របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ក្នុងឱកាសបិទសន្និសីទជាតិលើកទី ២ ស្តីពីការស្រាវជ្រាវ ឯកភាព**
**និងអភិវឌ្ឍន៍ភាសាខ្មែរ នៅរាជបណ្ឌិតសភាកម្ពុជា**
**ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៥**

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ*
*ឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី*
*ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីរាប់អាន*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានកិត្តិយសដោយបានមកចូលរួមជាអធិបតីក្នុងពិធីបិទសន្និសីទជាតិលើកទី២ ស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ ដែលបានប្រារព្ធនៅរាជបណ្ឌិតសភាកម្ពុជា។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលមានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រមុខ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីកោតសរសើរដ៏ស្មោះស្ម័គ្រ ចំពោះអង្គសន្និសីទទាំងមូល ដែលមានអស់លោកជាវាគ្មិនជាតិ អន្តរជាតិ ជាពិសេសឯកឧត្តម អស់លោកជាអ្នកជំនាញមានឯកទេសខាងភាសាវិទ្យា វេយ្យាករណ៍ និរុត្តិវិទ្យា វចនានុក្រមវិទ្យា សិលាចារឹកវិទ្យា សិក្សាអំបូរមន-ខ្មែរ ការប្រើប្រាស់ភាសាខ្មែរក្នុងកុំព្យូទ័រ ។ល។ បានលើកឡើងនូវបញ្ហា និងក្បួនខ្នាតក្នុងភាសាជាតិយើងមកផ្តោះប្តូរមតិយោបល់យ៉ាងផុលផុសអស់រយៈពេញមួយថ្ងៃមកនេះ។ ការលើកឡើងនេះសំដៅស្វែងរកភាពរីកចម្រើននៃភាសាជាតិរបស់យើង ដើម្បីឱ្យភាសាជាតិយើងមានក្បួនខ្នាតរឹងមាំ រក្សាបាននូវអត្ត-សញ្ញាណជាតិពិតប្រាកដ និងដើម្បីឈានទៅរកការអភិវឌ្ឍភាសាជាតិរបស់យើង ក៏ដូចជាការអភិវឌ្ឍវិស័យផ្សេងៗទៀតដែរ ដើម្បីចូលរួមចំណែកក្នុងការកសាងប្រទេសជាតិ។

*អង្គសន្និសីទជាទីគោរព !*

ខ្ញុំសូមអនុញ្ញាតថ្លែងជូនអង្គសន្និសីទ នូវគំនិតសំខាន់ៗរបស់រាជរដ្ឋាភិបាល នាឱកាសសន្និសីទជាតិស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរលើកទី១ នៅថ្ងៃទី ៧-៩ ខែកញ្ញា ឆ្នាំ ២០០០ កន្លងទៅ យើងបានឯកភាពគ្នាលើអនុសាសន៍ ២២ ចំណុច និងសម្រេចឱ្យយកវចនានុក្រមខ្មែរភាគ ១ និងភាគ ២ បោះពុម្ពគ្រាទី ៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ ធ្វើជាគោលក្នុងការសរសេរ និងប្រើប្រាស់ជាផ្លូវការទូទាំងប្រទេស ដរាបណាពុំទាន់មានវចនានុក្រមខ្មែរឯណាមួយមកជំនួសទេ។ ឥឡូវនេះយើងមានវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដែលរៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា យើងត្រូវតែអនុវត្តតាមវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរនេះ ឱ្យដូចយើងអនុវត្តតាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ដែរ។

វចនានុក្រមអក្ខរាវិរុទ្ធនេះ ជាសមិទ្ធផលថ្មីមួយដែលបន្តពីស្នាដៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ថ្វីបើពុំទាន់មានការពន្យល់ក៏ដោយ ក៏អាចឱ្យយើងយកជាគំរូក្នុងការសរសេរឱ្យបានឯកភាពគ្នាជាធ្លុងមួយ។ ដើម្បីឱ្យស្របតាម កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលយើងនាពេលបច្ចុប្បន្ន គណៈកម្មការបណ្ឌិតសភាបានពិនិត្យ និងអនុម័តពាក្យច្បាប់ដែលកំពុងប្រើប្រាស់ ពាក្យច្បាប់ថ្មី និងពាក្យច្បាប់ដែលបកប្រែពីភាសាបរទេស។

ខ្ញុំសង្ឃឹមថា វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា នឹងប្រមូលពាក្យច្បាប់ថ្មីទាំងនេះ ព្រមទាំងពាក្យបច្ចេកសព្ទ ដែលក្រសួងអប់រំ សាកលវិទ្យាល័យ និងក្រសួងទាំងឡាយមានជាអាទិ៍ ក្រសួងសេដ្ឋកិច្ច សុខាភិបាល និងវប្បធម៌ និង វិចិត្រសិល្បៈ កសិកម្ម ជាដើម បានបង្កើត និងប្រើប្រាស់រួចហើយ យកមកសិក្សានិងពិនិត្យធ្វើឱ្យមានឯកភាពគ្នា ទើបរៀបរៀងចងក្រងទុកជាវចនានុក្រមសម្រាប់ប្រើប្រាស់ទូទៅឱ្យបានទូលំទូលាយ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលបាននឹងកំពុងខិតខំលើកតម្កើង ភាសាអំបូរមន-ខ្មែររបស់ជនជាតិ ដោយក្រសួងអប់រំរួមជាមួយរាជបណ្ឌិតសភាកម្ពុជា ជួយសម្រួលឱ្យជនរួមជាតិយើងនៅខេត្តរតនគិរី មណ្ឌលគិរី ឧត្តរមានជ័យជាដើម ប្រើសញ្ញាអក្សរខ្មែរសម្រាប់កត់ត្រាភាសារបស់ខ្លួន ដើម្បីអភិវឌ្ឍ និងអភិរក្សវប្បធម៌ប្រពៃណីរបស់ខ្លួនផង និងជាស្ពានសម្រាប់ឱ្យពួកគាត់អាចបន្តការសិក្សាភាសាខ្មែរបានងាយស្រួលផង។ សព្វថ្ងៃនេះ ប្រទេសកម្ពុជាយើងផ្សារភ្ជាប់នឹងចរន្តសកលភាវូបនីយកម្មខាងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស ដូចនេះ ឯកភាពក្នុងការសរសេរភាសាខ្មែរជាយន្តការដ៏ប្រពៃសម្រាប់អ្នកជំនាញ

ខាងប្រព័ន្ធសារគមន៍បញ្ចូលអក្សរខ្មែរក្នុងយូនីកូដ ដើម្បីបញ្ជូនព័ត៌មានជាអក្សរខ្មែរលើពិភពលោកតាមលក្ខណៈអន្តរជាតិ ដូចភាសាអង់គ្លេស ភាសាបារាំង និងភាសាអន្តរជាតិដទៃទៀតដែរ ។

សូមបងប្អូនជនរួមជាតិ មេត្តាព្យាយាមសរសេរអក្សរខ្មែរឱ្យបានឯកភាពគ្នា ឱ្យមានរបៀបដូចគ្នាជាក្បួនខ្នាតតែមួយ ថ្វីបើប្រជាជនខ្មែរយើងសំបូរភាសាផ្ទាល់ខ្លួនដែលជាគ្រាមភាសាក្តី ប៉ុន្តែយើងជាជនជាតិខ្មែរតែមួយ រដ្ឋធម្មនុញ្ញរបស់យើងបានកំណត់ច្បាស់ថា " ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺ ភាសា និងអក្សរខ្មែរ "។ ដូច្នេះ ការសរសេរអក្សរសាស្ត្រជាតិ ដោយគោរពតាមក្បួនខ្នាតវេយ្យាករណ៍ គឺជាកិត្តិយសមួយដល់ខ្លួនឯងជាម្ចាស់សំណេរផង ហើយវាក៏ជាកិត្តិយសមួយដ៏ខ្ពង់ខ្ពស់សម្រាប់ជាតិខ្មែរយើងផងដែរ ដែលមានពលរដ្ឋមានចំណេះដឹងជ្រៅជ្រះខាងភាសា និងអក្សរសាស្ត្រជាតិរបស់ខ្លួន ហើយបង្ហាញឱ្យឃើញនូវការគោរព និងស្រឡាញ់អក្សរសាស្ត្រជាតិយ៉ាងពិតប្រាកដរបស់ពលរដ្ឋយើង ។

ខ្ញុំសូមសម្តែងនូវទឹកចិត្តសរសើរដ៏ស្មោះ ចំពោះរាជបណ្ឌិតសភាកម្ពុជា ជាពិសេស វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ព្រមទាំងគណៈកម្មការរៀបចំសន្និសីទជាតិផងដែរ ដែលខិតខំប្រឹងប្រែងរៀបចំសន្និសីទជាតិស្តីពី ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរនេះឡើង ដើម្បីស្វែងរកផ្លូវរីកចម្រើនខាងភាសា និងអក្សរសាស្ត្រជាតិ។ ឥឡូវនេះ យើងមានគោលឯកភាពគ្នាដ៏រឹងមាំហើយ ជាពិសេស ស្ថាប័នរាជបណ្ឌិតសភាកម្ពុជា ដែលមានវិទ្យាស្ថានភាសាជាតិ ជាជំហដ៏រឹងមាំដើម្បីបំពេញបេសកកម្មដ៏ថ្លៃថ្លានេះបន្តទៅទៀត ។

មុននឹងបញ្ចប់ តាងនាមនៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមគាំទ្រដល់ការបង្កើតគណៈកម្មាធិការជាតិផ្នែកភាសាខ្មែរដើម្បីឈានទៅរកឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរឱ្យបានគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ហើយខ្ញុំសូមបន្តការគាំទ្រដល់ការរៀបចំវចនានុក្រមពន្យល់ជាភាសាខ្មែរដោយផ្អែកលើវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែររបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ធ្វើជាមូលដ្ឋានបន្តស្នាព្រះហស្ថរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរឯកឧត្តម លោកជំទាវ លោកស្រី អស់លោកជាវាគ្មិន លោក លោកស្រី បណ្ឌិត សាស្ត្រាចារ្យ និងអង្គសន្និសីទជាតិទាំងមូល សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទអង្គសន្និសីទជាតិ ស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ លើកទី២ ចាប់ពីពេលនេះទៅ ។

*សូមអរព្រះគុណ សូមអរគុណ !*

# សុន្ទរកថា

## ថ្លែងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ក្នុងសន្និសីទស្តីអំពី "ព្រះពុទ្ធសាសនា និងសន្តិភាពនៅអាស៊ី"

ព្រះថេរានុត្ថេរៈជាទីសក្ការៈ

ឯកឧត្តម អស់លោក ប្រតិភូជាទីគោរព

ឯកឧត្តម អ្នកស្រីជំទាវ ជាទីគោរព

ឯកឧត្តម អ្នកស្រី អស់លោក អ្នកសង្កេតការណ៍ជាទីគោរព

ក្នុងនាមរដ្ឋាភិបាលកម្ពុជា ក្នុងនាមក្រសួងធម្មការនិងសាសនា និងក្នុងនាមទូលព្រះបង្គំខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ ខ្ញុំព្រះករុណា ខ្ញុំបាទមានក្តីរីករាយ និងដឹងគុណយ៉ាងជ្រាលជ្រៅក្រៃលែងចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ចំពោះឯកឧត្តម អស់លោកប្រតិភូ ចំពោះឯកឧត្តម អ្នកស្រីជំទាវ ដែលបាននិមន្ត និងអញ្ជើញមកចូលរួមក្នុងសន្និសីទអំពី "ព្រះពុទ្ធសាសនា និង សន្តិភាពនៅអាស៊ី" នាទីក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា នាឱកាសនេះ ។

ក្នុងពិធីដ៏មហោឡារិកនេះ ទូលព្រះបង្គំខ្ញុំ ព្រះករុណាខ្ញុំបាទមានក្តីសុខក្នុងកាយនិងចិត្ត ដោយយល់ថា ក្នុងបណ្តាប្រទេសអាស៊ីទាំង ៤៨ ប្រទេស មានប្រទេស ២៨ បានបញ្ជូនគណៈប្រតិភូមកចូលរួម ។ ក្រៅពីនេះសុទ្ធតែបានផ្ញើសារលិខិតមកចូលរួមក្នុងសន្និសីទនេះ ដែលជាសន្និសីទមួយធ្វើអោយ

ជីវិតសត្វលោក ព្រមទាំងជីវិតធម្មជាតិនៅលើភពផែនដីនេះបានសេចក្ដីសុខ ចៀសផុតពីភ័យន្តរាយដោយសារសង្គ្រាមផ្លូវចិត្ត និងសង្គ្រាមសំភារៈ ។

ចលនាដ៏ឧត្តម ដែលជាសញ្ញានៃការអនុវត្តន៍ ព្រះធម៌នៃព្រះបរមគ្រូរបស់យើង ជាទីសង្ឃឹមយ៉ាងមុតសំរាប់ពុទ្ធបរិស័ទទាំងឡាយនៅក្នុងពិភពលោកនេះ ដែលប្រាថ្នាចង់បានពន្លឺសច្ចធម៌តែមួយដូចគ្នា បំភ្លឺសតិសម្បជញ្ញៈនៃមនុស្សដែលសង្វាតស្វែងរកនូវសច្ចធម៌នោះ គឺផ្លូវត្រូវ ផ្លូវល្អ ដើម្បីមនុស្សលោកអាចរស់បាននៅក្នុងសន្តិភាព ។ ទាំងនេះជាកម្លាំងខាងផ្លូវចិត្តដ៏មហាស្ចារ្យធ្វើឱ្យពិភពលោកប្រកបដោយវឌ្ឍនភាពមួយដែលគ្មានសង្គ្រាម ។ កម្លាំងទាំងនេះត្រូវតែជាមធ្យោបាយ ដើម្បីស្ថាបនាឯកភាពនៃសកម្មភាពរបស់យើងព្រមទាំងថាមពលរបស់យើង ក្នុងករណីយកិច្ចដែលយើងត្រូវបំពេញ ក្នុងឋានៈជាអ្នកនាំសាររបស់ព្រះសម្ពុទ្ធដែលមានព្រះទ័យអាណិត មេត្តាដល់មនុស្សលោក ជួយរំដោះសកលលោកដែលសព្វថ្ងៃនេះស្ថិតនៅក្នុងអសន្តិភាព និងសភាពច្របូកច្របល់ក្រហល់ក្រហាយវឹកវរ ។

ម្យ៉ាងទៀតការរីកចំរើនខាងវិទ្យាសាស្ត្រ នាបច្ចុប្បន្នកាលនេះ បានដាក់ឱ្យមនុស្សលោកប្រឈមនឹងស្ថានការណ៍រីករាលដាលខាងសង្គ្រាមកាន់តែធំឡើងៗ ។ អាវុធប្រល័យលោកសុទ្ធតែរុញច្រានសកលលោកឆ្ពោះទៅរកមហន្តរាយឥតទីបញ្ចប់ ។ គេប្រើប្រាស់អាវុធវិទ្យាសាស្ត្រដើម្បី "អំណាច-អំណាច" ទាំងនេះត្រូវនឹងពុទ្ធឱវាទថា "មនុស្សលោកមានតែការស្អប់គ្នា ច្រណែនគ្នា ឈ្នានីសគ្នា គុំគួនគ្នា សងសឹកគ្នា ពុំចេះចប់ពុំចេះហើយ ។ គេប្រព្រឹត្តបែបនេះពីព្រោះគេមានតែមោហៈ ទោសៈ លោភៈនៅក្នុងខ្លួន ជាប្រការមួយធ្វើឱ្យមហិច្ឆិតាលោភលន់របស់គេកាន់តែស្រួចស្រាល់ខ្លាំងក្លាឡើង ម្ល៉ោះហើយដៃគូរបស់គេ ក្រុមប្រឆាំងរបស់គេក៏ខិតខំរៀនសូត្រស្រាវជ្រាវ រកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីទប់ទល់នឹងគូបដិបក្ខ បង្កឱ្យតែកើតសង្គ្រាមពុំចេះចប់ ធ្វើឱ្យតែមនុស្សលោកជួបប្រទះតែការភ័យរន្ធត់ញាប់ញ័រ ជួបប្រទះតែសប្បដិភ័យ ជួបប្រទះតែការកាប់សម្លាប់គ្នា ការប្រល័យជីវិតមនុស្សលោក បំផ្លាញលោកពុំចេះចប់ពុំចេះហើយ ។

អាស្រ័យហេតុនេះ ការជួបជុំគ្នានាឱកាសនេះ គឺជាការប្រមូលផ្តុំគ្នា ការចុះសម្រុងគ្នា ការត្រូវចិត្តគំនិតគ្នា រវាងបណ្តាប្រទេសអាស៊ី និងរវាងបណ្តាប្រទេសនានាក្នុងសកលលោក ដើម្បីពិភាក្សា ដោះស្រាយនូវវិបត្តិដែលកំពុងមាននៅលើសកលលោកស្ទើរគ្រប់ទិសទី ។ ដំណោះស្រាយនេះមានតែមួយ គឺសត្វលោកទាំងអស់ដែលរស់នៅលើភពផែនដី គួរតែគោរពតាមឱវាទព្រះពុទ្ធ ព្រះបរមគ្រូនៃយើង ។ យើងត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសម្ភារៈ ដើរតាមទស្សនវិជ្ជារបស់ព្រះពុទ្ធ ដែលជាមហាទស្សនវិទូមួយអង្គនៅក្នុងសកលលោក ព្រះធម៌របស់ព្រះអង្គមាន ៨៤០០០ ព្រះធម្មក្ខន្ធ ។ ក្នុងនោះព្រះវិន័យមាន ២១០០០ព្រះធម្មក្ខន្ធ ដែលបង្រៀនយើងកុំឱ្យធ្វើអំពើអាក្រក់ ។ ឯព្រះសូត្រមាន ២១០០០ព្រះធម្មក្ខន្ធ បង្រៀនយើងឱ្យធ្វើតែអំពើល្អ ។ ចំពោះព្រះអភិធម្មមាន ៤២០០០ព្រះធម្មក្ខន្ធ បង្រៀនឱ្យយើងធ្វើខ្លួនរបស់

យើងឱ្យបរិសុទ្ធ ។ ក្នុង ៨៤000ព្រះធម្មក្ខន្ធនេះ និយាយរួមព្រះពុទ្ធបង្រៀនយើងតែមួយគត់ គឺឱ្យ "ស្គាល់ទុក្ខ និងដោះទុក្ខ" (Le Buddha n'enseigne qu'une chose: la souffrance et la délivrance de la souffrance) ។

ព្រោះហេតុនេះ ទើបឱកាសនេះ យើងបានជ្រើសរើសព្រះធម៌ នៃព្រះបរមសព្វញ្ញុពុទ្ធ ដើម្បីជាមូលដ្ឋាន នៃការស្ថាបនាបច្ចុប្បន្ន និងអនាគតរបស់យើងឱ្យប្រកបតែនឹងសន្តិភាព មេត្តាធម៌ និងយុត្តិធម៌ ។ ចៀសផុតពីការបែកបាក់ប្រេះឆា ជាប្រជាជាតិ ដែលស្គាល់តែអមិត្តភាព ស្អប់-និន្ទា ច្រណែនឈ្នានីស រង់ចាំតែឱកាសបំផ្លាញគ្នាទៅវិញទៅមកឱ្យសាបសូន្យ ។ យើងទាំងឡាយដែលមានឱកាសជួបជុំគ្នាទៅទីនេះ សុទ្ធតែបានខិតខំប្រឹងប្រែង តំកល់ចិត្តស្ថិតនៅក្នុងពុទ្ធឱវាទដែលមានន័យថា: "អ្នកឈ្នះតែងតែរងពៀរសងសឹក អ្នកចាញ់តែងតែដេកកើតទុក្ខ អ្នកស្ងប់រំងាប់លះចោលនូវការឈ្នះ និងចាញ់ ទើបដេកជាសុខ" ។ ព្រះពុទ្ធទ្រង់សំដែងថា "នត្ថិ សន្តិ បរំ សុខំ" មានន័យថា "ពុំមានសុខអ្វីស្មើនឹងសេចក្តីស្ងប់ឡើយ" ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកហត្ថប្រណម ចំពោះព្រះសម្ពុទ្ធ ព្រះបរមគ្រូនៃយើង សូមព្រះពុទ្ធ ទ្រង់ព្រះរាជទានដល់យើងនូវមធ្យោបាយគ្រប់គ្រាន់ ដើម្បីយកជ័យជំនះ លើកងទ័ពនៃបាបអកុសល នៃហឹង្សា នៃការព្យាបាទ-ឫស្យា ។ សូមប្រជាជាតិក្នុងសកលលោក បានសេចក្តីសុខក្នុងក្តីស្ងប់តរៀងទៅ ។

ព្រមជាមួយនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមបួងសួងដល់គុណព្រះរតនត្រ័យ សូមព្រះអង្គជួយប្រសិទ្ធពរជ័យដល់អង្គសន្និសីទរបស់យើងឱ្យបានជោគជ័យ បានសំរេចតាមព្រះពុទ្ធវចនៈទាំងអស់ ដើម្បីសត្វលោកបានចៀសផុតពីការវិនាសសាបសូន្យ ដោយមោហៈ ទោសៈ លោភៈ និងសូមឱ្យមានសន្និសីទស្តីអំពីព្រះពុទ្ធសាសនា និងសន្តិភាពនៅអាស៊ីនេះ ចេះតែប្រព្រឹត្តទៅតាមពេលកំណត់នៅរាល់ប្រទេសនីមួយៗតរៀងទៅកុំបីឈប់ឈរឡើយ។

( អត្ថបទនេះ ជាអត្ថបទនិពន្ធដោយលោក យូ បូ ដើម្បីបង្រៀនដល់និស្សិត )

# និទាន

## INTRODUCTION

## សម្រាប់បោះពុម្ពគ្រាទី ៥

វចនានុក្រមខ្មែរ នេះបានចាប់កំណើតឡើងដោយមានព្រះរាជប្រកាសលេខ ៦៧ ចុះថ្ងៃទី ៤ ខែធ្នូ គ.ស. ១៩១៥ (ព.ស. ២៤៥៩) តាំងគណៈកម្មការមួយក្រុមធំឲ្យរៀបចំ ដូចមានព្រះនាមនិងនាមក្នុងអារម្ភកថាបោះពុម្ពគ្រាមុនៗនោះស្រាប់ ។ មុននឹងផ្ដើមការរៀបរៀង, គណៈកម្មការបានប្រឹក្សាយ៉ាងយូរ ក៏មូលមតិគ្នាជាឯកច្ឆន្ទដូចរាយរាប់ខាងក្រោមនេះ ៖

១១– ស្រៈពេញតួ ឱ ដែលពីដើមយកសញ្ញា (~) នេះ ហៅថា សក់-ក ដាក់ពីលើជាជំនួសតួ ក ប្រកបជា ឱក ប្រើការសរសេរជា ឱញ៉ា, ឯកឱ យើងមិនប្រើក្នុងវចនានុក្រមដែលត្រូវបង្កើតនេះទេ ព្រោះលែងប្រើយូរឆ្នាំហើយ ត្រូវប្រើ ឧកញ៉ា, ឯកឧក នេះវិញ ។

១២– ស្រៈ ឪ ដែលយកអក្សរ វ ដាក់ពីលើ ឱ ជាតួប្រកបឲ្យមានសំឡេងជា ឪ (អ៊ៅ ឬ អ្វៅ) ត្រូវរក្សាទុកឲ្យនៅដូចដើម សម្រាប់ប្រើពាក្យ ឪ, ឪពុក, ឪជំ, ឪជ្រើង, ឪទីន, ឪណុល, ឪម៉ាល់, ឪឡ, ឪឡឹក, ឪឡោក ជាដើម ។

១៣– ស្រៈ ឱ ត្រូវទុកឲ្យនៅដូចដើម, ប៉ុន្តែត្រង់ពាក្យ ឱ្យ មួយម៉ាត់នេះ ត្រូវប្រើជើង យ ភ្ជាប់ជាតួប្រកបដូចពីដើម រាប់ថាជា អញ្ញត្រសព្ទ ចុះ កុំប្រើជា ឱយ ឬ អោយ ព្រោះសព្ទខ្មែរយើងមាន អញ្ញត្រ-សព្ទ ក៏ច្រើនដែរ ។ ក្រៅពីពាក្យ ឱ្យ មួយម៉ាត់នេះ ត្រូវប្រើតួអក្សរជាតួប្រកបទាំងអស់ លែងប្រើជើងអក្សរជាតួប្រកប ។

១៤– ស្រៈ ឯ និង ឮ នេះក៏ត្រូវទុកដែរ, ប៉ុន្តែ ឮ នេះទុកសម្រាប់ប្រើបន្តិចបន្តួច ចំពោះតែពាក្យដែលប្រើ អឺ ជាជំនួសពុំបានប៉ុណ្ណោះ ដូច ឮង់, ឮយា, ឮឯ ជាដើម ។

១៥– ស្រៈ ឪ ដែលយកអក្សរ ៖ ដាក់ភ្ជាប់នឹង ឱ ឲ្យមានសំឡេងជា អៅ ឬ អៅ នេះក៏ត្រូវទុកដែរ សម្រាប់ប្រើខ្លះបន្តិចបន្តួចតាមដោយត្រូវការ ច្រើនតែធៀបពាក្យសំស្រ្កឹតជាដើម ។

១៦– អញ (អាញ់), អ្នក (នាក់), នេះ (និះ), នោះ (នុះ), ហោង (អួន) ពិនិត្យសិលាចារឹកឃើញប្រើយូរណាស់ហើយ តាំងពីសម័យ យសោធរបុរៈ (មហានគរ) របស់ប្រទេសកម្ពុជាយើង, ត្រូវទុកឲ្យនៅដូចដើម ព្រោះប្រើជាប់ជកបមកពុំដែលកែប្រែទេ, កប់ថាជា អញ្ញត្រសព្ទ ទៅចុះ ព្រោះមានសំឡេងផ្សេងពីសរសេរ ។

១៧– ពាក្យដែលមានប្រកពដើមជាបាលីប្រើតួ ឋ ត្រូវលែងប្រើតួ ឋ នេះជាដំនួស ដូចជា ឋាន, ឋានៈ, ឋានន្តរ, ឋិត ជាដើម កុំប្រើជា ឋាន, ឋានៈ, ឋានន្តរ, ឋិត; ពាក្យបាលីដែលមានប្រកពជា ថ លែងប្រើជា ឋ ដូចជា ថាមពល, ថាវរកម្ម, មហាថេរ ជាដើម កុំប្រើជា ឋាមពល, ឋាវរកម្ម, មហា-ឋេរ ។

១៨– អក្សរឃោសៈនៅពីខាងដើម ហ កុំបាច់ប្រើត្រីសព្ទ (៊) ឲ្យជា ហ៊ ដូចជា ជំហាម, ជំហរ, ទាហាន ជាដើម កុំប្រើជា ជំហ៊ាម, ជំហ៊រ, ទាហ៊ាន ។

១៩– អក្សរអឃោសៈនៅពីខាងដើមឬពីខាងលើអក្សរដែលត្រូវសម្ងាប់ ទើបមានសំឡេងតូចគឺ ង, ញ, ន, ម, យ, រ, ល, វ មិនត្រូវសម្ងាប់ដោយមូសិកទន្ត (៉) នោះទេ ដូចជា កិរិយា, ចរិយា, សម្ងាច, សម្លេង, ខ្នាត, ក្មេង, សន្យា, ស្រែក, ស្លា, ស្វាយ ជាដើម ។ ប៉ុន្តែ សម៉, ម៉ង្គ ជាដើម ត្រូវសរសេរយ៉ាងនេះឯង ។

២០– ពាក្យពេលជាស្រៈ អ ដែលឥត តួ រ ប្រកបហៅថា ពាក្យកំព្រា ដូចជា ក (កមនុស្សសត្វ), ង (ងស្ងៀត), ល (លមើល), ស (សម្បុរស) ជាដើមនេះ គណៈកម្មការជំបូងបានបង្កើតសញ្ញាថ្មីមួយហៅថា អឌ្ឍចន្ទ មានសណ្ឋានស្រដៀងនឹងចំណិតសាច់ដូង ប៉ុន្តែផ្កាប់ (⌒) នេះប្រើដាក់ពីលើ ដូចជា

ឈឹក, លើកដាក់លើក, ទូកង, ថាលិមើល, លើបលិ, កុកសិក, ដឹសិ កុំឲ្យច្រឡំក្នុងការអាន ។

១១– កិរិយាសព្ទឬគុណសព្ទពោល គឺមានអក្សរមិនតម្រួតឬមិនគ្រក់ មិនជើងជើង ដល់ចេញមកជានាមសព្ទត្រូវច្រើកយ ត្ត ដូចជា កត់ កិ. > កំណត់ ន.; កាត់ កិ. > កំណាត់ ន.; ដឹង កិ. > ដំណឹង ន.; ដើរ កិ. > ដំណើរ ន.; តួច គុ. > តំណួច ន.; ទាប គុ. > ទំនាប ន.; ធំ គុ. > ទំហំ ន. ។ល។

១២– កិរិយាសព្ទឬគុណសព្ទដែលមានអក្សរតម្រួតឬជើងជើង គ្រក់ ដល់ចេញមកជានាមសព្ទត្រូវតម្រួតដូចជា ក្រង កិ. > កម្រង ន.; ក្រាស់ គុ. > កម្រាស់ ន.; ស្តី កិ. > សម្តី ន. ។ល។ កិរិយាសព្ទជាកត្តុវាចក (សម្រេចអំពើខ្លួនឯង) ចេញទៅជាកិរិយាសព្ទជាហេតុកត្តុវាចក (ញុំាងអ្នកដទៃឲ្យសម្រេចអំពើ)ក៏មាន ដូចជា ខ្ចាត់ កិ. (កត្តុ.) > កម្ចាត់ កិ. (ហេតុ.); ខ្ចាយ កិ.(កត្តុ.) > កម្ចាយ កិ.(ហេតុ.) ។ល។ ប៉ុន្តែសព្ទខ្លះ ដែលតម្រួតពុំកើតក៏មាន ដូចជា ភ្លឺ កិ. (កត្តុ.) > បំភ្លឺ កិ. (ហេតុ.); ផ្លើស កិ. (កត្តុ.) > បំផ្លើស កិ. (ហេតុ.); ឃ្លាត កិ. (កត្តុ.) > បង្ឃ្លាត កិ. (ហេតុ.) ។ល។

គ្រង់ ១០ គណៈកម្មការជំនុំបានបង្កើត អឌ្ឍចន្ទ ប្រើក្នុងការសរសេរខ្លះបណ្តើរៗទៅហើយ ប៉ុន្តែបែរជាវិនាសទៅវិញ ព្រោះមានអ្នកតវ៉ាជំទាស់ ៗ គួរឲ្យនឹកស្តាយណាស់ ៗ សព្វថ្ងៃនេះកាលបើប្រទះលើពាក្យកំព្រាម្តងៗ ក៏ទៅជាសរសេរដោយប្រើតំនូស ( - ) នេះរាំងជា កុកស-ក, ទូក-ង, លើបរ-លេ ដើម្បីកុំឲ្យច្រឡំជា កុក-សក, ទូ-កង, លើប-លេ ។ល។ គណៈកម្មការមានសង្ឃឹមថា តទៅក្នុងអនាគតកាល, គង់តែអស់លោកអ្នកអក្សរសាស្ត្រខ្មែរនឹងបង្កើតសញ្ញាបែបណាមួយឲ្យជាជំនួសអឌ្ឍចន្ទនោះពុំខាន ទោះដែលកត្តីសញ្ញានោះឲ្យមានទ្រង់ទ្រាយយ៉ាងណាក៏ដោយ ដ្បិតមានលំអានក្នុងសិលាចារឹកខ្មែរក្នុងសម័យបុរាណជាគំរូស្រាប់ហើយ គ្រាន់តែកែទ្រង់ទ្រាយឲ្យគួរដល់ការប្រើប៉ុណ្ណោះ ។

គ្រង់ ១១ និង ១២ គណៈកម្មការជំនុំបង្អស់គ្រាន់តែមានយោបល់យល់ឃើញ ប៉ុន្តែពុំអាចហាមសម្រេចដោយដាច់ខាតទេ, ព្រោះក្រែងជួយនឹងទម្លាប់ដែលប្រើតាមតែបានមកយូរហើយ, ដូចជាអស់លោកអ្នកខ្លះសរសេរ ដំរាប់, ខ្លះ ដម្រាប់, ខ្លះ តំរាប់, ខ្លះ តម្រាប់ ជាដើម គឺទម្លាប់ដៃយ៉ាងណា ក៏ប្រើ

យ៉ាងនោះទៅ តាមតែបាន ។ លុះគណៈកម្មការយល់ឃើញខាងក្រោយយ៉ាងនេះហើយ ក៏សម្រេចចិត្ត ថា ត្រូវទុកឲ្យនៅតាមទម្លាប់នោះខ្លះទៅសិនចុះ ។ល។

ខ្ញុំថ្លែងសេចក្ដីអំពីប្រវត្តិនៃវចនានុក្រមនេះជាសង្ខេប មិនសព្វគ្រប់តាមដំណើរការណ៍ដែលកន្លងទៅ ហើយនោះទេ, ខ្ញុំថ្លែងដោយឥឡូវខ្លះគ្រាន់តែឲ្យអស់លោកបានជ្រាប សោះតែមានប៉ុណ្ណោះ ហើយ អស់លោកនឹងបានជួយឧបត្ថម្ភវចនានុក្រមនេះឲ្យមានការល្អលាស់ចម្រើនទៅតាមសម័យនិយម តាម-តាមកាល ។ វចនានុក្រមខ្មែរទាំង ២ ភាគនេះជាសម្បត្តិរបស់ពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ ពីដើម របស់រាជរដ្ឋាភិបាលតាំងពីចាប់ផ្ដើមបោះពុម្ពគ្រាទី ១ មក ពុំមែនជាសម្បត្តិរបស់ឯកជនទេ ។ ក្រមរាជ-ប្រកាសលេខ ៦៧ ចុះថ្ងៃទី ៤ ធ្នូ ១៩១៨ ឲ្យឈ្មោះថា វចនានុក្រមខ្មែររបស់រាជការ ប៉ុន្តែកាលដែល បោះពុម្ពគ្រាទី ១ ជាដំបូងបង្អស់នោះ អស់លោកកុងស៊ីយ៍សេនាបតីក្នុងសម័យនោះ សុំថាឲ្យដាក់ឈ្មោះ ត្រឹមតែថា វចនានុក្រមខ្មែរភាគទី១ ភាគទី២ (DICTIONNAIRE CAMBODGIEN Tome I Tome II) កុំដាក់ពាក្យថា របស់រាជការ ព្រោះបើដាក់ឈ្មោះថា របស់រាជការ ក៏ទៅជាបង្ខំឲ្យគេប្រើតាមទាំងអស់គ្នា ដោយដាច់ខាត, ដោយហេតុនេះ ត្រូវទុកឱកាសឲ្យគេទៅសិនចុះ បើអ្នកណាគេមិនត្រូវការប្រើតាម ក៏ឥតបើមានកំហុសអ្វីឡើយ, យូរៗទៅគង់តែនឹងប្រើតាមទាំងអស់គ្នាឯងទៅទេ ។

ដល់មកកាលជាខាងចុង គ.ស. ១៩៦៧ លោកនាយកនៃពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ បាន ចាត់ការបោះពុម្ពវចនានុក្រមខ្មែរនេះជាគ្រាទី ៥ ថែមឡើងទៀត ក៏បានតាំងគណៈកម្មការ ៤ រូបគឺ ១– ព្រះសាសនមុនី គិម - ទូ (ចន្ទមង្គលោ), ២– ព្រះបិដកធម្ម អ៊ុម - ស៊ុម (សង្ឃរក្ខិតោ) ទាំង ២ រូប នេះជាសមាជិកនៃគណៈកម្មការប្រែព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ; ៣– លោក ញូង - សឿង នាយលេខាធិការដ្ឋាននៃសមាគមអ្នកនិពន្ធខ្មែរក្រុងភ្នំពេញ (អតីតអគ្គលេខាធិការរងនៃពុទ្ធ-សាសនបណ្ឌិត្យ), ៤– លោក ប៉ោង - សំអ៊ី អ្នកនិពន្ធនៃផ្នែកសេចក្ដីនៅពុទ្ធសាសនបណ្ឌិត្យ; គណៈកម្ម-ការទាំង ៤ រូបនេះជាអ្នកស្ទាត់ជំនាញខាងអក្សរសាស្ត្រខ្មែរ, ឲ្យជាអ្នកពិនិត្យផ្ទៀងផ្ទាត់វចនានុក្រមខ្មែរ

ដែលបានបោះពុម្ពគ្រាទី ៤ នោះជាថ្មីម្តងទៀត ឲ្យបានហ្មត់ចត់គ្រាន់បើមន្តិចឡើងជាងមុន ដ្បិតវចនានុក្រមក្នុងពុទ្ធសាសនបណ្ឌិត្យអស់ទៅហើយ ឥតមានសល់សម្រាប់អស់លោកអ្នកត្រូវការទេ, សុំឲ្យគណៈកម្មការទាំង ៤ រូបនេះឆ្លៀតពេលធ្វើការឲ្យបានសម្រេចឆាប់បន្តិច ឲ្យបានទាន់ពេលនៃអស់លោកអ្នកត្រូវការ ។

លោក លាង - ហ៍បអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ បានមកសូមឲ្យខ្ញុំជួយឧបត្ថម្ភក្នុងការបោះពុម្ពគ្រាទី ៥ នេះ— បានតម្រូវតាមការងាយស្រួល ឲ្យគណៈកម្មការទាំង ៤ រូបរៀបចំការិយាល័យមួយក្នុងវត្តឧណ្ណាលោម ដើម្បីឲ្យបាននៅជិតខ្ញុំជាអ្នកជួយឧបត្ថម្ភ ។ ខ្ញុំក៏បានទទួលភារៈជួយ ដោយតាំងចិត្តថា ស៊ូទ្រាំឡើយចំពោះវចនានុក្រមនេះជាថ្មីម្តងទៀតចុះ, ទោះបីខ្ញុំមានវ័យចាស់ចូលក្នុងជន្មាយុគម្រប់ ៨៤ ឆ្នាំហើយ ព្រមទាំងមានកិច្ចការផ្ទាល់ខ្លួនច្រើនស្មុគស្មាញស្ទើរតែរើខ្លួនពុំរួចផងក៏ដោយ, ព្រោះវចនានុក្រមខ្មែរនេះជាការស្នាដៃថ្មីគំនិតចាស់របស់ខ្ញុំ, ខ្ញុំមិនសូវក្តេចយូរប៉ុន្មានចំពោះវចនានុក្រមនេះទេ, កាលបើសរសេរការស្មើ ខ្ញុំតែងតែនឹកដល់វចនានុក្រមខ្មែរទាំង ២ ភាគនេះជាដរាប, ដោយហេតុនេះឯង បានជាខ្ញុំមិនប្រកែក ។ ក្នុងគ្រានេះ, ខ្ញុំលៃពេលម៉ោងឆ្លៀតជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួលឲ្យបានគ្រាន់បើជាងពីមុនខ្លះដោយអន្លើ, ខ្ញុំខំប្រឹងឆ្លៀតជ្រើសរើសយកមេពាក្យដែលខ្វះ ព្រមទាំងអត្ថន័យផង សរសេរខ្លួនឯងចុះបន្ថែមឲ្យមានមេពាក្យក្រៃលែងជាងពីមុន, បានដកស្រង់យកកាព្យជាព្រះរាជនិពន្ធនៃព្រះករុណា ព្រះបាទសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី (ព្រះបរមកោដ្ឋ) ខ្លះ, កាព្យសាស្ត្រច្បាប់កេរកេរ្តិ៍ជាព្រះនិពន្ធនៃ ព្រះរាជសម្ភារ ខ្លះ, កាព្យសាស្ត្រច្បាប់ក្រៅពីនោះខ្លះ, ល្បើកថៅក្រម ដែលកើតមានក្នុងរជ្ជកាលនៃ ព្រះបាទសម្តេចព្រះជ័យចេស្តា ខ្លះ ចំពោះត្រង់អត្ថន័យនៃពាក្យ មន្ទលេន សេនបទ មណ្ឌុកផង សីហលោ, សុភាសិតនិងភាសិតបុរាណខ្លះ, និងកាព្យរបស់ខ្ញុំខ្លះ តម្រូវឲ្យសមតាមអត្ថន័យរបស់មេពាក្យនោះៗដោយអន្លើ, ក៏ឃើញថា វចនានុក្រមខ្មែរទាំង២ ភាគដែលបោះពុម្ពគ្រាទី ៥ នេះទូលំទូលាយគ្រាន់បើមន្តិចជាងមុន, ប៉ុន្តែបើធៀបប្រៀបទៅនឹងផ្លូវ ក៏មានឋានៈត្រឹមតែប្រហែលនឹងថ្នល់លំដែលបានចាក់

កយក្រសួបាយក្រៀមស្ងើងៗប៉ុណ្ណោះ ពុំទាន់មានឋានៈស្មើនឹងថ្នល់ដែលចាក់ជ័រយ៉ាងក្រាស់រលើបរលោងនៅឡើយទេ; ក្នុងអនាគតកាលមិនយូរឆ្នាំប៉ុន្មាន ទើបអាចនឹងឡើងឋានៈស្មើនឹងថ្នល់ចាក់ជ័ររលោងរលើបពុំខានឡើយ, គួរឱ្យខ្ញុំនឹកស្តាយណាស់ ដោយមិនបានឃើញឋានៈខ្ពង់ខ្ពស់របស់វចនានុក្រមខ្មែរនេះ !

ការពិនិត្យក្រោយនេះ, ខ្ញុំបានថ្លែងការណ៍យ៉ាងពិស្តារ ឱ្យគណៈកម្មការទាំង ៤ រូបបានដឹងអំពីយោបល់នៃគណៈកម្មការមុនដំបូងដែលខ្ញុំបានពោលហើយខាងលើ, គណៈកម្មការទាំង ៤ រូបក៏មានយោបល់ព្រមគ្នាជាឯកច្ឆន្ទថា ត្រូវយើងយកយោបល់របស់គណៈកម្មការដំបូងនោះមកអនុវត្ត កុំទុកវចនានុក្រមនេះឱ្យនៅសេមសោមច្រើនពេក នាំឱ្យពិបាកប្រើ ពិបាកដោះស្រាយណាស់, ប៉ុន្តែត្រង់សញ្ញាដែលហៅថា អឌ្ឍបន្ទ នោះត្រូវលើកទុកទៅចុះ ព្រោះវិនាសបាត់រូបបាត់ឈ្មោះទៅហើយ បើទុកជាយើងបង្កើតក្នុងសម័យនេះឱ្យមានរូបសណ្ឋានផ្សេងជាជំនួស សម្រាប់ប្រើដាក់លើ ពាក្យកំព្រា ទាំងប៉ុន្មាននោះក៏ពុំកើតដែរ ។ ឯយោបល់ក្រៅពីនោះ យើងត្រូវអនុវត្តតាមខ្លះ ដើម្បីបើកផ្លូវឱ្យមានឱកាសប្រហាទូលំទូលាយ ឱ្យអស់លោកអ្នកអក្សរសាស្ត្រខ្មែរនាអនាគតតាយដើរ ផ្សិតក្នុងសម័យសង្គមរាស្ត្រនិយម ដែលមាន សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ជាព្រះបិតាអក្សរសាស្ត្រជាតិ ព្រះអង្គសព្វព្រះរាជហឫទ័យឱ្យអក្សរសាស្ត្រខ្មែរយើងលូតលាស់ចម្រើននេះ ផ្ទុយគ្នាស្រឡះពីសម័យមុន ឆ្ងាយពីគ្នាដាច់ស្រយាលទៅហើយ, យើងគួរសម្រេចតាមយោបល់របស់គណៈកម្មការដំបូងបង្អស់នោះបានខ្លះហើយ ព្រោះមិនដូចសម័យ គ.ស. ១៩១៥ នោះទេ ។ ខ្ញុំនិងគណៈកម្មការទាំង ៤ រូបក៏បានព្រមព្រៀងគ្នាជាឯកច្ឆន្ទ តាមយោបល់របស់គណៈកម្មការដំបូងបង្អស់នោះ, មិនទាំងអស់ទេ គ្រាន់តែអនុវត្តតាមខ្លះ ទុកឱ្យត្រង់តាមទម្លាប់ខ្លះ ដើម្បីគោរពអធ្យាស្រ័យនៃអស់លោកអ្នកធ្លាប់សរសេរតគំនិតតៗដែរទៅហើយ ។

ត្រង់ ១១– ដែលបានពោលហើយ, យើងសម្រេចថា កត់ កិ. > កំណត់ ន.; កប់ កិ. > កំណប់ ន.; កល់ កិ. > កំណល់ ន.; កាត់ កិ. > កំណាត់ ន.; កែន កិ. > កំណែន ន.; គុំ កិ. > គំនុំ ,ន.; ចង់ កិ. > បំណង់ ន. ; ជិះ កិ. > ជំនិះ ន., ឈាន កិ. > ជំហាន ន.; ដឹង កិ.> ដំណឹង ន.; ដើរ កិ.>

ដំណើរ ន.; ខុស គុ. > កំហុស ន.; តូច គុ. > តំណូច ន.; ទាប គុ. > ទំនាប ន.; ធំ គុ. > ទំហំ ន.;... (មិនត្រូវជា កម្ចត់, កម្ចប់, កម្ចល់, កម្ចាត់, កម្ចែន, គម្ចុំ, ចម្ចង់, ជម្ចិះ, ជម្ហាន, ដម្ចឹង, ដម្ចើរ; កម្ហុះ, តម្ចូច, ទម្ចាប, ទម្ហំ ទេ...) ។ល។

ត្រង់ ខ ១២– ដែលបានពោលហើយដែរ, យើងសម្រេចថា ក្រាល កិ. > កម្រាល ន.; ក្រាស់ គុ. > កម្រាស់ ន.; ខ្ចាត់ កិ. (កត្តុវាចក គឺខ្ចាត់ឯង) > កម្ចាត់ កិ. (ហេតុកត្តុវាចក គឺញាំងអ្វីៗ ឲ្យខ្ចាត់); ខ្ចាយ កិ. (កត្តុ.) > កម្ចាយ កិ. (ហេតុ.); ខ្ចិល គុ. > កម្ចិល ន.; គ្រប កិ. > គម្រប ន.; ឃ្លាន កិ. > គម្លាន ន.; ប្រួត កិ. > បម្រួត ន.; ជ្រក កិ. > ជម្រក ន.; ជ្រាប កិ. (កត្តុ.) > ជម្រាប កិ. (ហេតុ.), ជម្រាប ន. (ទីដែលទឹកជ្រាប); ជ្រៅ គុ. > ជម្រៅ ន.; ត្រាស់ កិ. > តម្រាស់ ន.; ត្រិះ កិ. > តម្រិះ ន.; ត្រេក កិ. > តម្រេក ន.; ស្រេក កិ. > សម្រេក ន.; ស្រេច កិ. (កត្តុ.) > សម្រេច កិ. (ហេតុ.) ឬ គុ.; ស្រោច កិ. > សម្រោច ន.;...(មិនប្រើយកតួជា កំរាល, កំរាស់, កំចាត់, កំចាយ, កំជិល, គំរប, គំលាន, បំរួត, ជំរក, ជំរាប, ជំរៅ, តំរាស់, តំរិះ, តំរេក, សំរេក, សំរោច ...ទេ; ប៉ុន្តែមេពាក្យទាំងអស់នេះជាដើម ដែលធ្លាប់តែសរសេរយកតួដឹកដៃមកយូរហើយ យើងក៏ពុំទាន់ហ៊ានសម្រេចតាមយោបល់នោះដោយដាច់ខាតដែរទេ, បើត្រូវការសរសេរយកតួជា កំរាល, កំរាស់ ។ល។ តាមទម្លាប់នោះសិនទៅក៏បាន ទោះបីក្នុងវចនានុក្រមនេះ យើងបានសម្រេចជាមេពាក្យតម្រួតហើយក៏ដោយ ។ មានពាក្យខ្លះទៀត ដែលមានលក្ខណៈដូចគ្នានឹងពាក្យខាងលើនេះ យើងច្រើនតែរៀងមេពាក្យថា ឬ នេះជាដកថ ដូចជា សម្គម ឬ សំគម, សម្ដី ឬ សំដី ជាដើម ទុកឱកាសឲ្យប្រើតាមទម្លាប់ដែលសរសេរធ្លាក់ដៃទៅហើយនោះខ្លះទៅសិនចុះ ។ល។

ថ្ងៃទី ១០ ធ្នូ ១៩៦៧ (ព.ស. ២៥១១)

សម្ដេចព្រះសង្ឃរាជ,

គណៈមហានិកាយ

ជ. ណ. ជោតញ្ញាណោ

# និវេទនកថា

សៀវភៅវចនានុក្រមខ្មែរភាគទី ១ នេះ នៅខ្វះមេពាក្យច្រើន ទាំងសេចក្ដីអធិប្បាយនិងរបៀបរៀបរៀងមេពាក្យ ក៏មានភ្លាំងភ្លាត់ខ្លះ ៗ តាំងពីចាប់ផ្ដើមបោះពុម្ពគ្រាទី ១ រហូតដល់គ្រាទី ៣ ក៏មិនទាន់បានថែមមេពាក្យដែលខ្វះ ទាំងមិនទាន់បានកែសម្រួលសេចក្ដីដែលភ្លាំងភ្លាត់ទាំងនោះផងសោះនៅឡើយ ។

ក្នុងការបោះពុម្ពគ្រាទី ៤ នេះ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំឲ្យអាត្មាជួយរៀបចំបន្ថែមមេពាក្យដែលខ្វះ ព្រមទាំងសុំឲ្យជួយកែសម្រួលសេចក្ដីដែលធ្គាំធ្គងទាំងនោះខ្លះផង ដោយយល់ឃើញថាអាត្មាជាសមាជិក ១ រូប នៃក្រុមជំនុំវចនានុក្រមខ្មែរ ដែលបានកាន់កាប់មុខការនេះតាំងពីគ្រាដំបូងមក ។ អាត្មាក៏មានយោបល់ស្រប ដោយសេចក្ដីរីករាយ ប៉ុន្តែនឹងទទួលការកិច្ចនេះឲ្យពេញបន្ទុកដូចកាលពីក្នុងគ្រាដំបូងនោះពុំកើត ព្រោះអាត្មាមានសុខភាពមិនបរិបូណ៌ផង មានកង្វល់ចំពោះកិច្ចការក្រសួងព្រះសង្ឃនាយកផង, ក៏គ្រាន់តែជួយបានខ្លះៗនៅពេលដែលអាត្មាអាចទៀតបាន ។ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី គិម-ទូរ (ចន្ទមគ្គោ) សមាជិកក្រុមជំនុំព្រះត្រៃបិដក និងលោក ញ៉ុង-សឿង លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ ឲ្យទទួលបំពេញមុខការនេះ ដោយមកពិគ្រោះជាមួយនឹងអាត្មាម្ដងៗ ។ ឯមេពាក្យបន្ថែមក្នុងការបោះពុម្ពគ្រាទី ៤ នេះ ក៏មិនទាន់សព្វគ្រប់នៅឡើយដែរទេ គង់នៅខ្វះជាច្រើនទៀត ព្រោះមានវេលាខ្លីពេកមិនអាចនឹងស្រាវជ្រាវរកពាក្យឲ្យសព្វគ្រប់បាន ដោយពុទ្ធសាសនបណ្ឌិត្យប្រញាប់លៃលកបោះពុម្ពឲ្យទាន់ក្នុង គ.ស. ១៩៦៦ នេះ តាមសេចក្ដីត្រូវការជាការចាំបាច់របស់ប្រជាពលរដ្ឋផង មួយទៀត ព្រោះសម័យសព្វថ្ងៃ ពាក្យវប្បធម៌ខ្មែរយើង រឹតតែរីកចម្រើនកើនឡើងជាលំដាប់ផង ៗ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ សៀវភៅវចនានុក្រមខ្មែរភាគទី ១ ដែលបោះពុម្ពគ្រាទី៤នេះ គង់សម្បូរមេពាក្យក្រៃលែងគ្រាន់បើជាងមុនដែរ ។ ពុទ្ធសាសនបណ្ឌិត្យ មានបំណងថា លុះដល់វេលាបោះពុម្ពឡើងវិញក្នុងគ្រាក្រោយៗ នឹងលៃលកបន្ថែមមេពាក្យ

ខ្លះទាំងនោះតទៅទៀត ដើម្បីឲ្យមានគ្រប់គ្រាន់ឡើង ។ ក្នុងគ្រាទី ៤ នេះ មានការកែពាក្យខ្លះ ដូចមានសេចក្ដីពន្យល់ក្នុងទំព័រមួយទៀតបន្ទាប់ពីនេះ ។

ម្យ៉ាងទៀត ក្នុងសៀវភៅភាគទី ១ នេះ កាលដែលបោះពុម្ពគ្រាទី ១-២-៣ មិនបានដាក់នាមអស់លោកសមាជិកគណៈកម្មការនៃវចនានុក្រមនេះទេ មានដាក់តែខាងសៀវភៅភាគទី ២ ឥឡូវនេះបានស្រង់យកនាមអស់លោកទាំងនោះមកដាក់ខាងដើមសៀវភៅភាគទី ១ នេះវិញ, ឯក្នុងភាគទី ២ ពុំបាច់ដាក់ទៀតឡើយ ។

សម្ដេចព្រះមហាសុមេធាធិបតី

ជោតញ្ញាណោ

សង្ឃនាយក គណៈមហានិកាយ

៨. ណាត

# ចំណាប់អារម្មណ៍

សន្និសីទជាតិស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ មាន អនុសាសន៍សំខាន់ៗចំនួន២២ ដែលបានផ្តោតការចាប់អារម្មណ៍ជាពិសេសទៅ លើបញ្ហាអក្ខរាវិរុទ្ធ ក្នុងស្មារតីជម្រុះនូវទស្សនៈ ឬមតិឃ្លាតឆ្ងាយពីគ្នាដែលបាន បង្កើតជាបញ្ហាស្មុគស្មាញដល់ការអភិវឌ្ឍភាសាខ្មែរយើង ដែលជាភាសាផ្លូវការ និងភាសាយានសម្រាប់វិស័យអប់រំ ចាប់ពីកម្រិតបឋមសិក្សារហូតដល់ ឧត្តមសិក្សា។ សំណូមពរ ដ៏សំខាន់ៗទាក់ទងនឹងបញ្ហាអក្ខរាវិរុទ្ធមាន ៖

១- គប្បីរក្សាទុកព្យញ្ជនៈខ្មែរទាំង៣៣តួ ពិសេសអក្សរ៥តួ ក្នុងវគ្គ " ដ " ស្រៈពេញតួ និង វណ្ណយុត្តិទាំងអស់

២- គប្បីបង្កើតក្បួនវេយ្យាករណ៍ត្រឹមត្រូវមួយ

៣- គប្បីគោរព រក្សាពាក្យ និងប្រើប្រាស់ពាក្យ ដែលមានក្នុងវចនានុក្រម ខ្មែររបស់សម្តេច ព្រះសង្ឃរាជ ជួន ណាត

៤- គប្បីរៀបចំវចនានុក្រម សទ្ទានុក្រម ដោយផ្អែកលើមូលដ្ឋានឯកភាព

៥- គប្បីឱ្យអ្នកបច្ចេកទេសកុំព្យូទ័រជួយរៀបចំអក្ខរាវិរុទ្ធខ្មែរឱ្យបានល្អ និង ឱ្យមានសញ្ញាប្រាប់កំហុសផង។

វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដែលត្រូវបានរៀបរៀងដោយ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជាអស់រយៈពេលយ៉ាងយូរនោះ ជាស្នាដៃដែលធ្វើតាមអនុសាសន៍ខាងលើនេះ។ វចនានុក្រមនេះ ជាវិភាគទាន មួយដែលជួយដោះស្រាយដល់ការសរសេរអក្សរខ្មែរឱ្យបានឯកភាពគ្នា ដោយ គោរព និងរក្សាក្បួនខ្នាតនៃការសរសេររបស់បុព្វការីជាអ្នកប្រាជ្ញខាងភាសា

និងអក្សរសាស្ត្រខ្មែរជាច្រើនជំនាន់មកហើយ ជាពិសេសដោយយកវចនានុក្រមខ្មែររបស់សម្តេច ព្រះសង្ឃរាជ ជួន ណាត ជាគោល។

សព្វថ្ងៃ មតិសាធារណៈរង់ចាំនូវក្បួនខ្នាតនៃការសរសេរដ៏ត្រឹមត្រូវបែបនេះ ដើម្បីលើកស្ទួយភាសាជាតិ តាមគតិបណ្ឌិត ដោយផ្អែកលើមូលដ្ឋាននិងវិធីសាស្ត្រជាក់ស្តែងសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ក្នុងស្មារតីឯកភាពជាតិ។

វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ បានរៀបចំតាមលំដាប់អក្សរ និងសម្រួលចំណាត់ថ្នាក់នៃអក្ខរក្រម ដែលអ្នកបច្ចេកទេសខាងយូនីកូដអាចរៀបបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីជួយសម្រួលប្រាប់ពាក្យខុសតាមក្បួនខ្នាតអក្ខរាវិរុទ្ធ ដែលជាមូលដ្ឋានដ៏ចាំបាច់ និងសំខាន់បំផុតក្នុងការប្រើប្រាស់ភាសាខ្មែរឱ្យបានត្រឹមត្រូវ។

វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរនេះ ជាគុណប្រយោជន៍ដល់អ្នកប្រើប្រាស់អក្សរខ្មែរ និងជាជំនួយនាំឱ្យអក្សរសាស្ត្រខ្មែរមានការរីកចម្រើនប្រកបដោយនិរន្តរភាព ដែលជាកត្តាសំខាន់បំផុតសម្រាប់លើកស្ទួយសង្គមកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០៥

**ប្រធានរាជបណ្ឌិតសភាកម្ពុជា**

**បណ្ឌិត ស៊ន សំណាង**

# អារម្ភកថា

អក្ខរាវិរុទ្ធ គឺជាមុខវិជ្ជាមួយដ៏បួងដ៏សំខាន់នៃភាសាវិទ្យា ជាពិសេសនៅក្នុងវេយ្យាករណ៍នៃភាសានីមួយៗ ទោះបីភាសានោះជាភាសាមានវត្តមានវិភត្ត ឬអវត្តមានវិភត្តក្តី។ ភាសាខ្មែរ ជាភាសាគ្មានវិភត្តមែន ក៏ប៉ុន្តែមានអក្ខរាវិរុទ្ធប្រកបដោយ និរុត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ ដោយហេតុថាភាសាខ្មែរបានក្លាយទៅជាភាសាសរសេរ ឬភាសាមានលាយលក្ខណ៍តាមការទទួលឥទ្ធិពលភាសាសំស្ក្រឹតតាំងពីសតវត្សទី២ ឬ ទី៣នៃគ.ស. (តាមឯកសារសិលាចារឹកវ៉ូកាញ់ជា ភាសាសំស្ក្រឹតដែលបានត្រូវប្រើជាភាសារដ្ឋតាមរយៈរាជខុទ្ទកាល័យនៃព្រះមហាក្សត្រនគរភ្នំ)។ នៅក្នុងលក្ខខណ្ឌនៃការចាប់ផ្តើមប្រើប្រាស់អក្សរដើម្បីកត់ត្រាភាសានេះហើយ ដែលអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្របានចាប់ផ្តើមកំណត់នៅសម័យកាលប្រវត្តិសាស្ត្រនៃប្រជាជននីមួយៗ ហើយនៅសតវត្សទី៥ ទី៦ នៃគ.ស. តាមឯកសារសិលាចារឹកនានាដែលទើបនឹងរកឃើញថ្មី ជាពិសេសតាមឯកសារសិលាចារឹកអង្គរបុរី K៦00 ជាភាសាខ្មែរនាឆ្នាំ៥៣៣នៃមហាសករាជ គេអាចឃើញថា មានអក្ខរាវិរុទ្ធនៃពាក្យខ្លះត្រូវបានរក្សាទុកនៅ រហូតដល់បច្ចុប្បន្នកាល ដូចជាពាក្យ *ឆា នៅ អ្នក អញ ឯ ឮ ឱ្យ* និង ពាក្យដទៃទៀតជាដើម។

ពាក្យទាំងអស់នេះ ជាភស្តុតាងបញ្ជាក់ឱ្យយើងទាំងអស់គ្នាមានយោបល់ថា ភាសាខ្មែរ យើងជាភាសាមានប្រវត្តិសាស្ត្រដ៏យូរលង់មួយនៅភូមិភាគអាស៊ីអាគ្នេយ៍បានដក់នូវលក្ខណៈអភិរក្សនិយមជាវិជ្ជមានទៀតផង។ មិនតែប៉ុណ្ណោះសោតលក្ខណៈអភិរក្សខាងអក្ខរាវិរុទ្ធដែលជាមូលដ្ឋានរឹងមាំឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ បានត្រូវរក្សាទុកយ៉ាងខ្ជាប់ខ្ជួនផងដែរនៅក្នុងអក្ខរាវិរុទ្ធនៃភាសាសៀមបច្ចុប្បន្ននេះ ដោយហេតុថា ភាសាសៀម ឬថៃបានទទួលឥទ្ធិពលយ៉ាងសម្បើមខាងវាក្យសព្ទខ្មែរនៅចុងសម័យកាលនៃចក្រភពអង្គរ។

នៅសម័យមុនមហាសង្គ្រាមលោកលើកទីពីរ ពួកអាណានិគមបារាំងបានសាកល្បងកែប្រែអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដោយការបង្ខិតបង្ខំឱ្យប្រើអក្សរឡាតាំង ឬ អក្សរកុកងឺវិញ ហើយនៅពេលជាបន្តបន្ទាប់មក ការសាកល្បងនេះក៏បានទទួលបរាជ័យយ៉ាងជូរចត់។ មួយវិញទៀត គួរជ្រាបផងដែរថា ជនជាតិបារាំងបានខិតខំថែរក្សាអក្ខរាវិរុទ្ធនៃភាសារបស់ខ្លួនយ៉ាងផ្ចិតផ្ចង់ ទោះបីជាអក្ខរាវិរុទ្ធនៃភាសាបារាំង លំបាកលំបិនជាង

អក្ខរាវិរុទ្ធនៃភាសាខ្មែរជាច្រើនផងយ៉ាងណាក៏ដោយ ព្រោះថាពួកបារាំងបានប្រមើលមើលឃើញថា ផលវិបាកខាងភាសានឹងអាចកើតមានឡើងចំពោះប្រទេសដទៃទៀតណាដែលប្រើប្រាស់ភាសាបារាំង។

សព្វថ្ងៃជារៀងរាល់ឆ្នាំ នៅប្រទេសបារាំងក្តី នៅប្រទេសរុស្ស៊ីក្តី ការបោះពុម្ពផ្សាយសៀវភៅ និងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសារបស់គេ បានក្លាយទៅជាភារកិច្ចដ៏ចាំបាច់របស់វិទ្យាស្ថានខាងភាសានៃបណ្ឌិតសភាវិទ្យាសាស្ត្រ។ បញ្ហាអក្ខរាវិរុទ្ធបានត្រូវសិក្សា និងដោះស្រាយនៅលើកម្រិតខ្ពស់បំផុត ដោយបណ្ឌិតសភាអក្សរសាស្ត្រ ដោយខុទ្ទកាល័យរដ្ឋាភិបាល ឬប្រធានាធិបតី ហើយបុគ្គលម្នាក់ៗពុំអាចមានលទ្ធភាពនឹងប្រគល់ឱ្យប្រើប្រាស់នូវអក្ខរាវិរុទ្ធតាមបែបបទណាមួយតាមតែខ្លួនឡើយ។ អភិរក្សនិយមខាងអក្ខរាវិរុទ្ធក៏អាចបង្កើតនូវកម្រិតនៃការអភិវឌ្ឍន៍ភាសាឱ្យកាន់តែខ្ពស់ ពីព្រោះឯកភាវូបនីយកម្មនៃការប្រើប្រាស់អក្ខរាវិរុទ្ធបានទៅជាមូលដ្ឋាននៃឯកភាពប្រជាជាតិ ហើយបានចូលទៅក្នុងប្រព័ន្ធដ៏ស្មុគស្មាញនៃព័ត៌មានវិទ្យា មានការប្រើប្រាស់កុំព្យូទ័រជាអាទិ៍។

ចំពោះពាក្យថា អក្ខរាវិរុទ្ធ តាមនិយមន័យគឺបានសេចក្តីថា មិនមែនគ្រាន់តែជាកម្រងនៃក្បួនខ្នាត និងច្បាប់ទម្លាប់នៃការសរសេរដ៏ត្រឹមត្រូវតាមវេយ្យាករណ៍ ប៉ុណ្ណោះទេ ក៏ប៉ុន្តែជាក្បួនខ្នាតទូន្មានឱ្យសរសេរត្រឹមត្រូវតាមតួអក្សរ តាមចំណាត់ថ្នាក់នៃអក្ខរក្រមទៀតផង។ សរសេរខុសច្បាប់ទម្លាប់ពីមុនអាចប៉ះទង្គិចដល់ទំនៀមទម្លាប់ និងចិត្តសាស្ត្រនៃអ្នកប្រើប្រាស់ភាសាខ្មែរនៅក្នុងស្រុក អាចធ្វើឱ្យសហគមន៍ខ្មែរនៅក្រៅស្រុកដើរតាមយើងមិនទាន់ ដូចជាជនជាតិខ្មែរសុរិន្ទ ឬខ្មែរក្រោមជាដើម។

ដោយយោងទៅលើមូលដ្ឋានទាំងឡាយ ដូចបានត្រូវរៀបរាប់ត្រួសៗមកហើយ យើងខ្ញុំដែលជាអ្នករៀបរៀងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ បានសម្រេចចិត្តជាបឋមធ្វើដំណើរដោយឥតល្អៀងតាមលំអាននៃវចនានុក្រមខ្មែរ និពន្ធដោយសម្តេចព្រះសង្ឃរាជជួន ណាត ដែលជាការបោះពុម្ពផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០៥

**ប្រធានវិទ្យាស្ថានភាសាជាតិ**

**ឡុង សៀម**

# បុព្វកថា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សៀវភៅវចនានុក្រមអក្ខរាវិរុទ្ធនេះ ចាំបាច់សម្រាប់ប្រើប្រាស់ដើម្បីរក្សានូវសំណេរដ៏ត្រឹមត្រូវក្នុងអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដោយហេតុថា អក្ខរាវិរុទ្ធបង្ហាញឱ្យឃើញនូវកិច្ចសហការខំប្រឹងប្រែង រក្សាឯកភាពជាតិនៅក្នុងការអភិរក្ស និងអភិវឌ្ឍភាសាខ្មែរយើង។

ការបោះពុម្ពផ្សាយវចនានុក្រមអក្ខរាវិរុទ្ធ ដែលបានរៀបចំឡើងដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ជាព្រឹត្តិការណ៍មួយល្អប្រសើរសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងតែយកចិត្តទុកដាក់ដល់ការអភិវឌ្ឍភាសាជាតិ ដើម្បីឱ្យមានវចនសព្ទថ្មីៗប្រកបដោយសម្បូរភាព សម្រាប់សេចក្តីត្រូវការនៅក្នុងការប្រើប្រាស់បច្ចេកពាក្យទៅតាមវិស័យផ្សេងៗនៃស្ថាប័នរបស់រដ្ឋ ជាពិសេសក្នុងផ្នែកអប់រំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ០៨ ឆ្នាំ២០០៥

**សុខ អាន**

កោះសន្តិភាព •លេខ 5752 ថ្ងៃ

ឧស្សនមតិ.

បរិយាយថ្ងៃនេះ

# ខែរបស់កុមារ

ដោយ : សាងម.ឧត្តម

តើគេអាចចាត់ទុកបានទេថា ខែមិថុនាគឺជាខែសំរាប់កុមារពិភពលោក ខណៈដែលប្រតិទិនបង្ហាញថា ថ្ងៃ១ មិថុនា គឺជាទិវាកុមារអន្តរជាតិ ហើយថ្ងៃ១២ មិថុនា គឺជាទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារនោះ ? នេះមិននិយាយដល់ថ្ងៃទី២៥ មិថុនា ដែលជាទិវាប្រឆាំងគ្រឿងញៀន ហើយដែលក្នុងមួយឆ្នាំៗស្រទាប់យុវវ័យក្នុងនោះក៏មានកុមាររាប់លាននាក់បានក្លាយជាជនរងគ្រោះដោយឥទ្ធិពលនៃគ្រឿងញៀនគ្រប់ប្រភេទផង ។ ក្នុងន័យនេះ តើគេអាចកំណត់បានទេថា ខែមិថុនា គឺខែរបស់កុមារនោះ ? ចំពោះកម្ពុជា តើយើងបានធ្វើអ្វីខ្លះឱ្យប្រសើរសំរាប់កុមារដែលជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ ខណៈដែលក្រុមបងតូច បងធំ គឺជាក្រុមក្មេងអន្ធពាលកើតឡើងព្រោងព្រាត ចំណែកការបង្ក្រាបហាក់មានសន្ទុះមិនទៅមុខនោះ ? ម្យ៉ាងវិញទៀតការដែលសង្គមបើកទូលាយឱ្យមានបនល្បែង កាស៊ីណូ មណ្ឌលកំសាន្តហ្គេមគ្រប់ប្រភេទរួមទាំងល្បែងភ្នាល់ ដូចជាបាល់ កន្ទុយលេខ រួមជាមួយការនាំចូលនិងចរាចរគ្រឿងញៀន ក៏ដូចជាការរីករាលដាលនូវវប្បធម៌ពាលាអាវ៉ាសែ អាសអាភាស តើទាំងអស់នេះវាអាចប៉ះពាល់ដល់កុមារខ្មែរ ដែរឬទេ ? នេះមិននិយាយដល់ភាពក្រីក្ររបស់ប្រជាពលរដ្ឋមួយចំនួនដែលមិនមានលទ្ធភាពឱ្យកូនចូលសាលា ហើយករណីខ្លះឈានដល់នាំកូនធ្វើចំណាកស្រុកទៅប្រកបរបរសុំទានគេនៅស្រុកថៃ និងវៀតណាមរាប់សែននាក់ផង ។ តើឯណាទៅការយកចិត្តទុកដាក់របស់រដ្ឋចំពោះកុមារនោះ ?

ជាការពិតណាស់ ក្រៅអំពីកាលបរិច្ឆេទដែលពិភពលោកទទួលស្គាល់ថា ខែមិថុនាជាខែរបស់កុមារនោះ ក្នុងមាត្រា៤៧នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "មាតាបិតាមានកាតព្វកិច្ចថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ" ។ ចំណែកមាត្រា៤៨ចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋការពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ" ។ តាមរយៈមាត្រាទាំងពីរនៃច្បាប់កំពូលរបស់ជាតិនេះសួរថា តើរដ្ឋាភិបាលបានធ្វើអ្វីខ្លះឱ្យប្រាកដប្រជាចំពោះកុមារ ពិសេសកុមារក្រីក្រតាមជនបទ ដែលមិនមានលទ្ធភាពបានចូលរៀនសាលាដោយស្ថានភាពជីវភាពក្រីក្រតោកយ៉ាករបស់គ្រួសារនោះ ? ហើយដោយការឆកល្វែងរបស់គ្រួសាររួមជាមួយការពង្រឹងសន្តិសុខមិនបានជិតដល់ ដែលជាហេតុផលធ្វើឱ្យរីករាលដាលនៃក្រុមក្មេងអន្ធពាលនោះជាបឋមគេគួរបន្ទោសអ្នកណា ? អ្នកអនុវត្តច្បាប់ ឬអាណាព្យាបាលដែលរកអង្គរច្រកឆ្នាំងស្ទើរមិនបាននោះ ? នេះមិននិយាយពីក្រុមបងតូច បងធំដែលជាក្រុមក្មេងអន្ធពាល ហើយមានប្រភពចេញពីគ្រួសារអ្នកមានលុយ មានអំណាចមួយចំនួនណានោះផង ។

វាច្បាស់ណាស់ថា ប្រសិនបើប្រធានបទកុមារនិងការយកចិត្តទុកដាក់របស់រដ្ឋ និងសង្គមរួមជាមួយការរំលោភលើពលកម្មកុមារត្រូវបានយកមកបរិយាយនោះ វាគឺជាប្រធានបទមួយដ៏ទូលំទូលាយ និងជាក្ដីបារម្ភមួយរបស់ជាតិទាំងមូលទៅថ្ងៃអនាគតទៀតផង ។ និន្នាការកុមារកម្ពុជាបច្ចុប្បន្ននេះត្រូវបានគេមើលឃើញថា បានញែកជាបីដាច់ស្រឡះពីគ្នារវាងកូនអ្នកមានអំណាច មានលុយ កូនអ្នកមានទ្រព្យសម្បត្តិមធ្យម ដែលអាចមានលទ្ធភាពឱ្យកូនរៀនឱ្យចប់ចុងចប់ដើម និងកូនអ្នកក្រីក្រ ដែលមិនអាចមានលទ្ធភាពឱ្យកូនរៀនឬរៀនដែរតែបានត្រឹមតែចេះអានអក្សរខ្មែរប៉ុណ្ណោះ ទីបំផុតគឺជួយធ្វើកិច្ចការគ្រួសារ ហើយបើគ្រួសារនោះគ្មានកិច្ចការឱ្យធ្វើដោយគ្មានដីធ្វើស្រែចំការនោះ គឺត្រូវធ្វើចំណាកស្រុកដើររកការងារផ្សេងៗ រហូតក្លាយខ្លួនជាអ្នកសុំទាននៅប្រទេសថៃទាំងគ្រួសារតែម្ដងក៏មាន ។ តើទិដ្ឋភាពទាំងនេះ មានអ្នកណាម្នាក់ដែលហ៊ានបដិសេធថាវាមិនជាការពិតក្នុងសង្គមខ្មែរនោះ ? នេះមិននិយាយពីឥទ្ធិពលនៃអំពើពុករលួយ ការិយាធិបតេយ្យដែលកូនអ្នកមានលុយ មានអំណាចបានចេញទៅរៀននៅបរទេស ហើយត្រឡប់មកវិញមានស្ថាប័នមួយផ្ដែកណានោះជាបក្សពួករបស់ខ្លួនរង់ចាំបើកទ្វារចំហទទួលទៀតផង ។ ឯណាទៅសមធម៌នៃក្មេងជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សីនោះ ? ឯណាទៅការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលសំរាប់កុមារក្រីក្រគោកយ៉ាកនោះ ?

ជាការពិតណាស់ ការអះអាងបែបនេះមិនមែនមានចេតនាបដិសេធនូវរាល់ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលរួមជាមួយសប្បុរសជនទាំងក្នុងនិងក្រៅប្រទេស ដែលបានជួយយកចិត្តទុកដាក់ដល់បញ្ហាកុមារនោះទេ ក៏ប៉ុន្តែទំហំនៃការងារនោះ គឺមិនទាន់អាចឆ្លើយតបបានទាំងស្រុងនូវតម្រូវការរបស់កុមារដែលទាមទារឱ្យរដ្ឋយកចិត្តទុកដាក់ទ្វេថែមទៀតនោះ ពិសេសគឺចលនាជាតិ និងសង្គមទាំងមូលសំរាប់កុមារនេះឯង ។ បើមិនដូច្នេះទេ គម្លាតរវាងកូនអ្នកមាននិងកូនអ្នកក្រ រវាងកូនអ្នករៀនបានចប់ចុងចប់ដើម និងកូនអ្នកក្រីក្របំផុតរហូតមិនចេះអក្សរនោះ នឹងក្លាយជាស្នូរជួងមួយដែលបញ្ចេញសម្លេងដោយភាពគ្រោះថ្នាក់ និងបារម្ភបំផុតរបស់សង្គមទាំងមូលសំរាប់ថ្ងៃអនាគត ។

នេះមិននិយាយពីយុវវ័យជំនាន់ក្រោយមួយចំនួនដែលបញ្ចប់ការសិក្សាហើយ ទោះនៅថ្នាក់ក្រោយឧត្តមសិក្សាឬមធ្យមសិក្សាដែលមិនមានលទ្ធភាពរកការងារបានធ្វើនោះផង ។ ទីបំផុត យុវជនឬកុមារដែលអត់ការងារធ្វើទាំងនោះ តើអនាគតរបស់ពួកគេនឹងទៅជាយ៉ាងណា ? មកទល់បច្ចុប្បន្ននេះគេមិនដឹងឱ្យប្រាកដនិយមថា តើកុមារកម្ពុជាប៉ុន្មាននាក់ដែលមិនបានចូលសាលា ហើយប៉ុន្មាននាក់ដែលទៅប្រកបរបរសុំទាន និងប៉ុន្មាននាក់ទៀតដែលបំរើការងារតាមផ្ទះ ឬតំបន់ផ្សេងៗនោះ ? ពិសេសតើចំនួនកុមារដែលរងគ្រោះដោយការជួញដូរផ្លូវភេទ និងរងគ្រោះដោយឥទ្ធិពលគ្រឿងញៀននោះមានចំនួនប៉ុន្មាននាក់ ? តើទាំងនេះមិនមែនជាបន្ទុកឬជាកាដូរបស់កុមារសំរាប់រាជរដ្ឋាភិបាលដោះស្រាយក្នុងអ្វីដែលហៅថា ខែមិថុនា គឺជាខែរបស់កុមារកម្ពុជាទេឬ ? ក្នុងន័យដដែលនេះ ប្រសិនបើគិតនៃការដោះស្រាយរបៀបហៃអើទេនោះ គឺវាច្បាស់ណាស់ថា ខែមិថុនា ដែលជាខែរបស់កុមារវាក៏គ្រាន់តែជាខែហៃអើដែរ ៕

បរិយាយថ្ងៃនេះ

# សត្រូវនីតិរដ្ឋ

ដោយ : សាឯម_ឥណ្ឌុន

ក្រោយការបោះឆ្នោតអាណត្តិទីមួយនៃរាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ១៩៩៣មកទល់បច្ចុប្បន្ននេះ ពាក្យថានីតិរដ្ឋត្រូវបានអ្នកនយោបាយខ្មែរមួយចំនួនយកមកនិយាយកោក១ជាមួយប្រជាពលរដ្ឋ បើទោះប្រជាពលរដ្ឋនៅតាមជនបទមួយចំនួនធំមិនយល់ពីអ្វីដែលហៅថា នីតិរដ្ឋក៏ដោយ ។ ទីបំផុតទោះយល់ឬមិនយល់ក៏នីតិរដ្ឋនៅតែជាពាក្យពេញនិយមយកមកប្រើប្រាស់ដដែលជាដដែល ។ សំរាប់ប្រជាពលរដ្ឋខ្មែរ ពិសេសកសិករខ្មែរនៅស្រុកស្រែចំការក្នុងរយៈពេលជាង១០ឆ្នាំមកនេះធ្លាប់បានឮកោក១នូវពាក្យដែលមិនសូវធ្លាប់ឮពីមុនមកដូចយ៉ាង"រាស្ត្រមានមុនរដ្ឋ ភូមិមួយកសិផលមួយ រដ្ឋាភិបាលសេដ្ឋកិច្ច រដ្ឋាភិបាលផ្លូវថ្នល់ រដ្ឋាភិបាលធារាសាស្ត្រ វិមជ្ឈការនិងសហវិមជ្ឈការ ។ល។" ដែលពាក្យទាំងនេះគឺជាពាក្យថ្មីសន្លាងសំរាប់ប្រជារាស្ត្រខ្មែរ ។ ប៉ុន្តែអ្វីដែលយើងលើកយកមកធ្វើប្រធានបទនៅទីនេះគឺ "សត្រូវរបស់នីតិរដ្ឋ" ។

ជាការពិតណាស់ នីតិរដ្ឋ គឺជារដ្ឋមួយដែលចាត់ទុកឬតម្កល់ច្បាប់ថាមានអំណាចខ្ពស់ជាងគេមិនមែនអំណាចស្ថិតនៅក្នុងដៃមនុស្សម្នាក់ឬក្រុមមនុស្សឬបក្សពួកណាមួយឡើយ ។ ដោយហេតុថារដ្ឋនីមួយ១មិនដូចគ្នាទាំងបញ្ហាវប្បធម៌ សង្គមកិច្ច សេដ្ឋកិច្ច និងប្រជាពលរដ្ឋនោះ ទើបការកំណត់ស្តង់ដាអំពីនីតិរដ្ឋគេមិនអាចកំណត់ឱ្យដូចគ្នាដោយប្រាកដប្រជាបានឡើយ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺរដ្ឋនោះត្រូវមានអង្គការកំពូលឯករាជ្យមួយសំរាប់ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយ ។ អង្គការកំពូលនោះ ប្រទេសខ្លះហៅថា ក្រុមប្រឹក្សាធម្មនុញ្ញ ខ្លះហៅថាតុលាការធម្មនុញ្ញ និងខ្លះទៀតហៅតុលាការកំពូលជាអ្នកត្រួតពិនិត្យច្បាប់ ។

ដោយឡែកចំពោះសត្រូវនីតិរដ្ឋ គឺបញ្ហានិទណ្ឌភាព ពោលគឺការ បណ្តែតបណ្តោយឱ្យអ្នកប្រព្រឹត្តបទល្មើសរួចពីសំណាញ់ច្បាប់ ។ និទណ្ឌភាពគឺអាចកើតឡើងពីហេតុផលជាច្រើនក្នុងនោះអំពើពុករលួយ និងការផ្តាច់ការ គឺជាហេតុផលសំខាន់ពីរដែលជំរុញឱ្យមានបញ្ហានិទណ្ឌភាព ដែលក្នុងន័យនេះសំរាប់កម្ពុជាខណៈដែលសម្តេចហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលធ្លាប់បានប្រកាសជារឿយ១ដោយទទួលស្គាល់ថា កម្ពុជាមួយផ្នែកណានោះគឺអំពើពុកកំពុងបង្កប់ខ្លួនគ្រប់ច្រកល្ហក ដែលជាប្រការមិនត្រូវអត់អោននោះទេ នៅពេលមានភស្តុតាងសំរាប់ដាក់បន្ទុកឬចោទប្រកាន់នោះ ។ ក្នុងន័យនេះសួរថា បើកម្ពុជាមានអំពើពុករលួយ ហើយការប្រើសិទ្ធិ តួនាទីផ្តាច់ការតាំងពីថ្នាក់តូចទាបរួមផ្សំជាមួយអ្វីដែលហៅថា ការិយាធិបតេយ្យ ឬសន្តិវង្សនោះ តើនីតិរដ្ឋរបស់កម្ពុជាស្ថិតនៅជើងមេឃ ជើងមុងឯណា ? ដូច្នេះសួរថា នីតិរដ្ឋនៅទីនេះគឺជាការបោកប្រាស់ឬជាសិល្បៈនៃសំនួនវោហារសាស្ត្រដែលគេគ្រាន់តែយកមកនិយាយឱ្យរួចពីមាត់នោះ ?

គេនៅចាំបានថា ផ្អែកទៅលើរបាយការណ៍បារ៉ូម៉ែតអំពើពុករលួយសម្លេងពលរដ្ឋឆ្នាំ២០០៥នៅកម្ពុជាដែលរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានបង្ហាញថា ស្ថាប័ននៃប្រព័ន្ធច្បាប់ និងតុលាការជាស្ថាប័នដែលពុករលួយបំផុត ដែលបន្ទាប់មកមានប៉ូលិសនិងគយ ។ ក្រៅពីនោះស្ថាប័នដទៃទៀតក៏ជាកន្លែងដែលមើលឃើញថា មិនគួរជាទីទុកចិត្តរបស់ប្រជាពលរដ្ឋឡើយ ដោយរួមទាំងគណបក្សនយោបាយផង ដែលក្នុងន័យនេះសួរថា បើអំពើពុករលួយវាមាននៅចំកន្លែងកៅអីនៃអ្នកអនុវត្តច្បាប់ទៅហើយនោះ តើបញ្ហានិទណ្ឌភាពវាមានដែរឬអត់ ? រួចចុះបើបញ្ហានិទណ្ឌភាពវាពិតជាមានដោយអំពើពុករលួយទៅហើយនោះ តើគេអាចចាត់ទុកថា អំពើពុករលួយជាសត្រូវរបស់នីតិរដ្ឋដែរឬទេ ? ចុះបើរដ្ឋជួបបញ្ហានិទណ្ឌភាពរួមជាមួយអំពើពុករលួយរីកគ្រប់ច្រកល្ហក តើយុត្តិធម៌សំរាប់ប្រជាពលរដ្ឋស្ថិតនៅឯណា ? អ្វីទៅដែលហៅថា សិទ្ធិស្មើគ្នាចំពោះមុខច្បាប់របស់ប្រជាពលរដ្ឋខ្មែរនោះ ?

វាច្បាស់ណាស់ថា ប្រសិនបើបញ្ហានីតិរដ្ឋត្រូវបានលើកយកមកនិយាយ ហើយសត្រូវនីតិរដ្ឋគឺបញ្ហាពុករលួយនោះ គេប្រាកដជានឹកទៅដល់អំពីអ្វីដែលហៅថា ច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា ដែលត្រូវដេកផ្លូវជាង១២ឆ្នាំទៅហើយនៅតែមិនទាន់ចេញ រួចបើទោះរាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តធ្វើឱ្យចេញរួចក្នុងអំឡុងឆ្នាំ២០០៥ក្នុងកម្មវិធីនយោបាយរបស់ខ្លួនក៏ដោយ ។ តែទោះជាយ៉ាងនេះក្ដីមកទល់ពេលនេះ ច្បាប់ប្រឆាំងអំពើពុករលួយគឺស្ថិតនៅក្នុងដៃនៃក្រុមអ្នកច្បាប់របស់រាជរដ្ឋាភិបាលដដែល ខណៈដែលគំរោងធំៗត្រូវបានចោទប្រកាន់អំពីបញ្ហាពុករលួយ និងភាពមិនប្រក្រតីពីធនាគារពិភពលោកនិងទាមទារឱ្យមានសំណងពីរាជរដ្ឋាភិបាលវិញក៏ដោយ ។ ជាមួយការចោទប្រកាន់នេះ សម្ដេចហ៊ុន សែន ក្នុងឋានៈជាប្រមុខរាជរដ្ឋាភិបាលក៏ធ្លាប់មានប្រសាសន៍ម្ដងហើយម្ដងទៀតសុំឱ្យធនាគារពិភពលោកបង្ហាញនូវភ័ស្ដុតាងឱ្យប្រាកដប្រជាអំពីបញ្ហានេះ ដោយសម្ដេចប្រដូចថា "គ្រូពេទ្យម្នាក់គេមិនអាចធ្វើការវះកាត់បានដោយភ្លាមៗខណៈដែលមិនទាន់រកឃើញនូវការវិនិច្ឆ័យថា អ្នកជម្ងឺឈឺអ្វី ហើយឈឺនៅកន្លែងណានោះ ?" ទីបំផុតការឆ្លើយឆ្លងរវាងធនាគារពិភពលោកធ្វើឱ្យយន្តការនៃការសាងសង់មួយចំនួនត្រូវគាំងដំណើរ ហើយដែលបញ្ហានេះត្រូវបានមតិសាធារណៈរិះគន់ដោយត្រង់ៗថា អ្នកខាតបង់ផលប្រយោជន៍ពិតប្រាកដក្នុងរឿងនេះ គឺប្រជាពលរដ្ឋនិងប្រទេសជាតិនេះឯង ។ ហេតុអ្វីក៏អ្នកផ្ដល់លុយនិងអ្នកទទួលលុយម៉េចមិនអង្គុយនិយាយលើតុជាមួយគ្នាដើម្បីរកចំណុចជួយប្រជាពលរដ្ឋខ្មែរ ?

ដូច្នេះសរុបសេចក្ដីមក អំពើពុករលួយនិងទង្វើផ្ដាច់ការ ឬអារកាត់ដោយអត្តនោម័តមួយផ្នែកណានោះ គឺជាដើមចមនៃបញ្ហានិទណ្ឌភាព ហើយបញ្ហានិទណ្ឌភាពគឺជាសត្រូវនីតិរដ្ឋ រួចចុះបើរដ្ឋមួយមិនមានការគោរពច្បាប់ ឬចាត់ទុកច្បាប់ជាធំទេនោះ តើយុត្តិធម៌របស់ប្រទេសនោះ ពិសេសសំរាប់ប្រជាពលរដ្ឋក្រីក្រនឹងទៅជាយ៉ាងណា ? អ្វីដែលសំខាន់នោះ តើគេគួរនិយាយពីពាក្យថា នីតិរដ្ឋដោយរបៀបណា ? រួចចុះបើនីតិរដ្ឋវាឃ្លាតឆ្ងាយពីប្រជាពលរដ្ឋទៅហើយ តើពាក្យថាប្រជាធិបតេយ្យដែលសំដៅអំណាចរបស់ប្រជារាស្ដ្រជាធំនោះ ? គេមិនត្រូវច្រលំដោយឆ្កាំឆ្កងថា ប្រទេសមួយឬរដ្ឋមួយនៅពេលដែលរដ្ឋាភិបាលនោះកើតចេញពីការបោះឆ្នោតចាត់ទុកថាជាប្រជាធិបតេយ្យ១០០ភាគរយនោះទេ ក៏ប៉ុន្តែប្រជាធិបតេយ្យពិតប្រាកដ គឺអំណាចប្រជារាស្ដ្រដែលជាម្ចាស់ឆ្នោតគឺជាធំ ដែលក្នុងន័យនេះច្បាប់ទាំងឡាយសំរាប់បំរើឱ្យប្រជាពលរដ្ឋនោះត្រូវចាត់ទុកជាធំ ដោយគ្មានបញ្ហានិទណ្ឌភាពនិងអំពើពុករលួយឡើយ ។ បើមិនដូច្នេះទេ ពាក្យថានីតិរដ្ឋគឺជាពាក្យហាស្លាក់ ខ្វាក់ស្លែងនៅពេលដែលបញ្ហានិទណ្ឌភាពនៅច្រឡំបល់គ្នានោះ ៕

បរិយាយថ្ងៃនេះ

# អ្នកណាជាវីរជន ?

ដោយ : សាឯម-ឥណ្ឌូន

"វីរ"ក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជជួន ណាត បើជាគុណនាមប្រែថា ដែលខ្ជាប់ខ្ជួន រឹងប៉ឹង អង់អាចក្លាហាន ក្សៀវក្លា មោះមុត ខ្លាំងពូកែ ដែលបានព្យាយាមខ្ជាប់ខ្ជួន ។ តែបើជានាមវិញប្រែថា អ្នកអង់អាច ក្សៀវក្លា អ្នកចំបាំង អ្នកប្រាជ្ញ វីរជនអង់អាច ភាពដែលអង់អាច ដំណើរអង់អាច ។ ផ្អែកតាមនិយមន័យនិងអត្ថន័យនៃពាក្យវីរជននេះសួរថា តើកម្ពុជាមកទល់បច្ចុប្បន្ននេះមានវីរជនប៉ុន្មាននាក់ ? ក្នុងន័យនេះដដែលសួរថា តើមានមនុស្សខ្មែរប៉ុន្មាននាក់ដែលបានបូជាជីវិត ទាំងសាច់ស្រស់ ឈាមស្រស់ មនោសញ្ចេតនាគ្រួសារ ទាំងយុវវ័យរបស់ខ្លួនស្ម័គ្រលីអាវុធទាំងនៅវ័យក្មេង ដើម្បីអ្វីដែលហៅថាការពារជាតិ បានបាត់បង់ជីវិតទាំងមិនដឹងថាតើគេជាអ្វីផងនោះ ? ផ្ទុយទៅវិញអ្នកដែលមានសំណាងបានរស់នៅដោយគ្រាន់តែរងរបួសនិងធ្លាក់ខ្លួនពិការ តើគេជាជនស្នេហាជាតិឬយ៉ាងណា ខណៈដែលស្ថានភាពគ្រួសារមួយផ្នែកបានធ្លាក់ក្នុងភាពតោកយ៉ាកទៅហើយនោះ ។ នេះមិននិយាយដល់មន្ត្រីរាជការ សិល្បៈករនិងប្រជាពលរដ្ឋខ្មែរទូទៅដែលអ្នកខ្លះបានបូជាជីវិតដើម្បីការងាររបស់ខ្លួននិងអាជីពរបស់ខ្លួនរហូតដល់ថ្ងៃត្រឡប់ទៅវិញជាភាទៀតផងនោះ ។

ជាការពិតណាស់ សំរាប់អ្វីដែលហៅថាអ្នកណាជាវីរជនហើយអ្នកណាជាជនក្បត់ជាតិក្នុងសង្គមកម្ពុជានោះ វាបានក្លាយជារឿងច្របូកច្របល់និងជាសោកនាដកម្មលាបពណ៌ឱ្យគ្នាទៅវិញទៅមកយ៉ាងអគតិបំផុត ដែលសារជាតិទាំងនេះផ្តើមចេញពីអ្នកនយោបាយដឹកនាំជាតិនេះឯង ។ ទីបំផុតកម្ពុជាក្រោយការដួលរលំនៃសម័យអង្គរ ពោលគឺក្រោយសម័យដ៏រុងរឿងនៃមហាអាណាចក្រខ្មែរក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី៧មក ស្ទើរតែរកវីរជនអ្នកស្នេហាជាតិ និងអ្នកប្រាជ្ញមិនបាន ដែលហេតុផលនៃបច្ច័យអាក្រក់បែបនេះគឺផ្តើមចេញពីការលាបពណ៌ឱ្យគ្នាទៅវិញទៅមកជាមួយចរិកច្រណែនទិន្នា ឈ្នានីស ដែលធ្លាប់តែមានតាំងពីមុនមក ហើយមិនដឹងថាពេលណាទើបគំនិតអគតិបែបនេះត្រូវជម្រុះចោល ។

លទ្ធផលចុងក្រោយដោយគំនិតអាត្មានិយមនៃអ្នកដឹកនាំដែលគិតថា "ក្រៅពីអញ គឺអញ អស់ពីអញ គឺគ្មានអ្នកស្នេហាជាតិនិងគ្មានអ្នកណាធំជាងអញ" ផ្តើមចេញពីគំនិតបែបនេះហើយទើបអ្វីៗចេះវិវត្តន៍ទៅរកភាពអវិជ្ជមានបែបនេះទៅ ។ វាគឺជារឿងដែលគួរឱ្យសង្វេគស្រណោះស្រណោក សោកស្តាយនិងគួរឱ្យមានវិប្បដិសារីខ្លាំងណាស់ ខណៈដែលរបបមួយដួលរលំទៅអ្នកបំរើការងារក្នុងរបបនោះមួយផ្នែកត្រូវបានចាត់ទុកថា គឺជាជនក្បត់ជាតិ ពិសេសអ្នកកាន់អាវុធនេះឯង ហើយរបបថ្មីមកក្រោយក៏តាំងខ្លួនជាអ្នកស្រោចស្រង់ជាតិ ស្នេហាជាតិ ពោលគឺជាក្រុមវីរជន ។ បន្តបន្ទាប់មកទៀត របបនោះក៏ដួលរលំទៅ ហើយត្រូវជំនួសដោយរបបថ្មីមួយផ្សេងទៀត ដែលគ្រានោះប្រពៃណីលាបពណ៌ក៏នៅតែបន្តទៅទៀត គឺអ្នកដែលចាញ់ទាំងនោះត្រូវក្លាយជាជនក្បត់ជាតិវិញម្តង ។ ក្នុងន័យនេះសួរថា តើសច្ចភាពប្រាកដនិយមអំពីវីរជនក្នុងសង្គមខ្មែរស្ថិតនៅក្នុងតម្លៃបែបណា? នេះមិននិយាយដល់ការច្រឡំបល់នៃប្រវត្តិសាស្ត្រសំរាប់មនុស្សជំនាន់ក្រោយផង ។

គេនៅចាំនិងទទួលស្គាល់ថា ព្រោះតែការលាបពណ៌នៃអ្នកនយោបាយជាមួយភាពអគតិ ការច្រណែន ឈ្នានីសនេះហើយទើបវីរជនខ្មែរមួយចំនួនក្រោយសម័យអង្គរបានក្លាយជាអ្នកតា ជាវត្ថុអរូបិយ រហូតក្មេងជំនាន់ក្រោយមួយចំនួននាពេលបច្ចុប្បន្ននេះពុំស្គាល់វីរជនខ្មែរផង ដូចយ៉ាងអ្នកតាដំបងក្រញូង តាក្រហម.ក តាខ្មៅ យាយម៉ៅ ឬជំទាវម៉ៅ ពិសេសអ្នកតាឃ្លាំងមឿង និងជំទាវខាន់ ខៀវ...ដែលបានលះបង់ជីវិតទាំងគ្រួសារ ដើម្បីការពារជាតិ សាសនា ព្រះមហាក្សត្រខ្មែរ ដែលក្នុងន័យនេះសួរថា ហេតុអ្វីមនុស្សជំនាន់ក្រោយមិនរៀបចំនិងទទួលស្គាល់ប្រកាសដោយចំហប្រាប់មនុស្សទាំងអស់ថា អ្នកទាំងនោះមិនមែនជាអ្នកតាទេ តែគឺជាមនុស្សខ្មែរ ហើយដែលជាវីរជនស៊ូស្លាប់ដើម្បីការពារជាតិខ្មែរឱ្យគង់វង្សរហូតដល់សព្វថ្ងៃនេះ ។ តើសម័យបច្ចុប្បន្ននេះមានមនុស្សក្លាហានប៉ុន្មាននាក់ដែលហ៊ានលះបង់ជីវិតធ្វើដូចឧកញ៉ាឃ្លាំង មឿង ដែលព្រោះតែចាញ់សង្គ្រាមជាមួយទ័ពសៀមសុខចិត្តបញ្ជាឱ្យគេជីករណ្ដៅបួនម៉ែត្របួនជ្រុង និងជម្រៅបួនម៉ែត្រ ហើយឱ្យគេដាក់សស្ត្រាវុធក្នុងរណ្ដៅ និងធ្វើពិធីបួងសួងរយៈពេលបីយប់បីថ្ងៃដើម្បីកៀងគរព្រលឹងខ្មោច ហើយក៏សំរេចលោតធ្វើអត្តឃាតដោយមានកូនប្រុសពីរនាក់រួមទាំងជំទាវខាន់ ខៀវ ដោយផ្ដាំអ្នកនៅរស់ថា រយៈពេល៧ថ្ងៃក្រោយពេលស្លាប់គាត់ (ឃ្លាំង មឿង) រួមជាមួយគ្រួសារនឹងប្រមែប្រមូលទ័ពខ្មោចទាំងអស់ប្រយុទ្ធតទល់ជាមួយទ័ពសៀម ដែលទីបំផុតទ័ពសៀមក៏បរាជ័យក្នុងសង្គ្រាមនាអំឡុងសតវត្សទី១៥ ដោយសារភាពអង់អាច ក្លាហានហ៊ានបូជាជីវិតរបស់ឧកញ៉ាឃ្លាំង មឿង ដែលជាវីរជនយ៉ាងពិតប្រាកដ ?

ខាងលើនេះគឺជាប្រវត្តិសាស្ត្រពិតរបស់កម្ពុជា ហើយដែលតាមរយៈនៃមហាពលិកម្មដ៏អស្ចារ្យនេះសួរថា មហាបុរសឃ្លាំង មឿង រួមជាមួយជំទាវខាន់ ខៀវ និងកូនប្រុសទាំងពីរគួរមានឈ្មោះជាវីរជន ឬមានឈ្មោះជាអ្នកតា ? ហើយបើអ្វីៗនៅ តែបែបនេះ តើមនុស្សជំនាន់ក្រោយគេយល់យ៉ាងណា ចំពោះបុព្វបុរស និងមហាវីរបុរសរបស់គេ ? ពិសេសតើមជ្ឈដ្ឋានបរទេសមើលមកខ្មែរ តើគេយល់យ៉ាងណា ខណៈដែលខ្មែរមិនផ្ដល់តម្លៃដល់អ្នកដែលលះបង់ជីវិតដើម្បីជាតិ ទឹកដី សាសនា ព្រះមហាក្សត្ររបស់ខ្លួននោះ ?

វាច្បាស់ណាស់ថា អំពីអ្វីដែលហៅថា វីរជនខ្មែរ វាមិនត្រឹមតែស្ថិតក្នុងភាពច្របូកច្របល់ និងជាភាពអាម៉ាស់សំរាប់ខ្មែរប៉ុណ្ណោះទេ ដែលសូម្បីថ្មីៗនេះខ្មោចតាម៉ុកដែលជាឃាតកដៃប្រឡាក់ឈាមខ្មែររាប់ម៉ឺននាក់ក៏ត្រូវគេយកទង់ជាតិគ្របពីលើមឈូសដូចជាអ្នកស្នេហាជាតិ ឬវីរជនសំរាប់ខ្មែរ ដែលតាមរយៈនេះបើប្រៀបធៀបជាមួយអ្នកតាឃ្លាំង មឿង ឃើញថា តាម៉ុកអស្ចារ្យណាស់ បើទោះគាត់ជាឃាតកក៏ដោយ ហើយអ្វីដែលអស្ចារ្យហួសនិយាយទៀតនោះ គឺតាម៉ុកមានឈ្មោះថាម៉ុកវីរជនខ្មែរក្រហមអន្លង់វែង ខុសពីអ្នកតាឃ្លាំង មឿង ដែលមកទល់ពេលនេះគេនៅតែហៅថា អ្នកតា ហើយកូនប្រុសទាំងពីរនាក់របស់មហាបុរសនេះមិនមានឯកសារណាបញ្ជាក់ឱ្យប្រាកដប្រជាថា ឈ្មោះអ្វីទៀតផង ។ តើទិដ្ឋភាពបែបនេះអាចទទួលយកបានទេសំរាប់សង្គមខ្មែរដែលពោរពេញដោយសន្តិភាពពេញលេញនាពេលបច្ចុប្បន្ននេះ ? ដូច្នេះសរុបឱ្យខ្លីមកវីរជនខ្មែរត្រូវតែលើកតម្កើង ហើយអ្នកនយោបាយខ្មែរមិនត្រូវកាឡៃប្រវត្តិសាស្ត្រជាតិខ្លួនឯងនោះទេ ៕

ឧបសម្ព័ន្ធ ទី ៤

# ២០ឆ្នាំចាំស្នេហ៍

ដោយៈ យូ ចូ

យើងទាំងពីរនាក់ប្តីប្រពន្ធ និងកូនប្រុសមួយអាយុ៧ឆ្នាំ បានដើរលេងនៅលើខ្នងទំនប់ធារាសាស្ត្រដ៏ធំមួយនៅខេត្តកំពុងស្ពឺ ។ ទំនប់ធារាសាស្ត្រនេះបាននាំទឹកមកស្រោចស្រប់ដីស្រែរបស់ប្រជាកសិកររាប់ពាន់ហិចតា ។

ពេលថាវីងាកមកខ្ញុំ សម្លឹងមុខខ្ញុំដោយក្តីញញឹមបង្កប់នូវមន្តស្នេហ៍ ដ៏អាថ៌កំបាំងមួយ ធ្វើអោយដួងចិត្តខ្ញុំរំភើប រំភើបនឹងស្នាមស្នេហ៍នៃជីវិតដ៏កំសត់របស់ខ្ញុំ គឺជីវិតដ៏កំសត់នេះហើយដែលជាលទ្ធផលចេញជាទំនប់ធារាសាស្ត្រដែលយើងកំពុងដើរកំសាន្តនេះ ។

កាលណោះ

ខ្ញុំទើបនឹងរៀនចប់បរិញ្ញាប័ត្រអក្សរសាស្ត្រ ខ្ញុំបានចូលទៅធ្វើការនៅក្នុងអង្គការក្រៅរដ្ឋាភិបាលមួយក្នុងនាមជាអ្នកនិពន្ធទស្សនាវដ្តីនៃអង្គការនោះ និងជាគ្រូបង្រៀនសិទ្ធិមនុស្សនិងគ្រូបង្រៀនលទ្ធិប្រជាធិបតេយ្យ ប្រចាំអង្គការនោះ ។

ថ្ងៃមួយខ្ញុំបានណាត់ជួបជាមួយថាវីដើម្បីបញ្ជាក់អំពីបេះដូងរបស់ខ្ញុំដែលកំពុងរីករហង់រង់ចាំបេះដូងថាវីតែ....តែក្តីសង្ឃឹមត្រូវរលាយសូន្យ ។ ពេលថាវីជួបខ្ញុំ នាងឈរ...ឈរអោនមុខចុះ មានទឹកភ្នែករលីងរលោង ។ នៅពេលងើបមុខឡើងស្រាប់តែថាវី យំ ឱបខ្ញុំ... នាងឱប...ឱបយំអណ្តឹតអណ្តក និយាយពុំច្បាស់ ពុំដឹងជានាងនិយាយថាម៉េច មួយសន្ទុះទើបនាងដកដង្ហើមបានស្រួល នាងមានការអៀនខ្មាសម្ទីម្នាដកដៃចេញពីខ្លួនខ្ញុំ ។ ខ្ញុំប្រញាប់សួរនាងដោយក្តី ស្រពាប់ស្រពោនក្នុងដួងចិត្តៈ " ថាវី! ថាវីអូន!ម៉ាក់អូនបដិសេធមែនទេ!..." ។ថាវីក្តោបបបូរមាត់លេបទឹកមាត់អួលអាក់រួចអោបខ្ញុំម្តងទៀត ។ នាងហាមាត់និយាយ តែនិយាយពុំចេញ ។ ខ្ញុំលើកមុខនាងថ្នមៗឡើង រួចស្រាប់តែឱនថើបនាងដោយពុំដឹងខ្លួន ។

ថាវីបង្ហើបបបូរមាត់ញ័រៗបែបខឹង និយាយមកកាន់ខ្ញុំៈ " បង! ម៉ាក់មិនត្រឹមតែបដិសេធទេ តែគាត់ថែមទាំងជេរអូនជេរលអូន ហ៊ឹក! ហ៊ឹក! ហ៊ឹកៗ!! " ។ ស្រាប់តែខ្ញុំលិឍទឹកភ្នែកនាង លេបទឹកភ្នែកនាង លេបទាល់តែអស់ស្រក់ប៉ុណ្ណាលេបប៉ុននោះ ។ មួយសន្ទុះធំ ទើបទឹកភ្នែកនាងឈប់ហូរ ទើបខ្ញុំដឹងខ្លួនឈប់លិឍទឹកភ្នែកនាង ។ ឱ! ស្នេហាខ្ញុំ ម្តេចក៏អភ័ព្វម្ល៉េះ? ស្រលាញ់គ្នាដោយស្មោះ ស្រលាញ់គ្នាបួនឆ្នាំមកហើយ ។ ទើបតែឆ្នាំនេះ ដែលខ្ញុំមានការងារធ្វើ មានលំនឹងក្នុងជីវភាព ខ្ញុំក៏ធ្វើតាមដួងស្នេហ៍ដ៏កន្ទោកកន្ទោលរបស់ថាវី និងខ្ញុំ ។ បេះដូងយើងទាំងពីរបានវេញត្របាញ់ចូលគ្នាចំនួនបួនឆ្នាំ កន្លងមកមែន តែយើងពុំដែលប្រាសចាក ប្រពៃណីម្តងឡើយ ។ ទើបតែពេលនេះ...ពេលនេះដែលថាវីលាក់ទុក្ខព្រួយពុំបាន នាងក៏ឱបខ្ញុំដោយពុំដឹងខ្លួន...ហើយខ្ញុំ! ខ្ញុំ ទប់សន្ទុះចិត្តពុំបាន ក៏ហ៊ានលិឍទឹកភ្នែកនាង លេបអោយអស់នូវទឹកភ្នែកនាង លេប

អោយអស់នូវនិមិត្តរូបនៃទុក្ខកង្វល់ លេបអោយអស់នូវគំនិតចាស់គំរិលរបស់ម្តាយនាង...គំនិតចាស់គំរិល ដែលពោរពេញដោយលុយកាក់ បុណ្យស័ក្តិ ។ ក្របែបខ្ញុំ គាត់ពុំព្រមអោយថាវីស្រលាញ់ខ្ញុំទេ... គាត់ថាយ៉ាងហោចណាស់ ក៏ត្រឹមថ្នាក់ចៅហ្វាយស្រុកឬប្រធាននាយកដ្ឋានទើបគាត់អោយថាវីស្រលាញ់ ។ បើបានដល់ថ្នាក់អនុរដ្ឋលេខាធិការទើបប្រសើរ ។ ឱ!នៅលើលោកនេះ តើមានម្តាយបែបនេះប៉ុន្មាននាក់ទៀត ?

ខ្ញុំសម្លឹងមុខនាង ដើម្បីសុំអោយនាងបញ្ជាក់អោយច្បាស់ពីបំណងល្អរបស់យើងទាំងពីរ គឺម្តាយខ្ញុំបានពឹងអោយអ្នកមានមុខមានមាត់ចូលទៅស្តីដណ្តឹងនាងឱ្យខ្ញុំ តែគាត់ពុំព្រមឱ្យចូលស្តីដណ្តឹងទេ គាត់បានទាំងជេរទៀតថាៈ " បុណ្យស័ក្តិប៉ុណ្ណឹង ត្រឹមអាអ្នកនិពន្ធម្រៀល១ អាគ្រូបង្រៀនម្រៀល១ ហ៊ានចូលមកដណ្តឹងកូនអញផង! " ។ រឿងចូលដណ្តឹងនេះកន្លងទៅបីខែហើយ ។ តែបេះដូងយើងពុំអាចកាត់ផ្តាច់ចេញពីគ្នាបាន ទើបយើងសំរេចចិត្តថាអោយថាវីទៅអង្វរម្តាយនាងថែមទៀត ...អង្វរសុំក្តីមេត្តា អាណិតស្រលាញ់ពីម្តាយ តែម្តាយនាងពុំដឹងពោលពាក្យបែបណាទើបនាងដាច់ចិត្តមកឱបខ្ញុំយំ.... យំយ៉ាងយូរ...។

ឥឡូវយើងទាំងពីរស្វាងអារម្មណ៍ហើយ ។ ថាវីមានទឹកមុខស្រពាប់ស្រពោនពោលថា :" បង! ម្តាយអូនជាមនុស្សគ្មានបេះដូង...អូនសាកល្បងអង្វរគាត់...អង្វរទាំងទឹកភ្នែក...អង្វរឱ្យគាត់អាណិតស្រលាញ់អូន និងសុំអោយគាត់អាណិតដល់ចិត្តពុកផង ចិត្តពុកដែលអាណិតស្រលាញ់កូន បានអនុញ្ញាតឱ្យគេចូលស្តីដណ្តឹងកូន តែម៉ាក់មិនព្រម ម៉ាក់បានទាំងជេរជៀលពុកថែមទៀត...ហ៊ឺ! បងអើយ! អូនអាណិតពុកណាស់ ពុកជាមនុស្សអត់ធ្មត់បំផុត គាត់សុខចិត្តលេបគ្រួស លេបថ្មគាត់ សុខចិត្តលេបពាក្យសំដីគ្រោតគ្រាតរបស់ម៉ាក់...។ បង! អូនគិតអ្វីលែងយល់ហើយ! អូនសំរេចចិត្តថា អូនលែងនៅជាមួយម៉ាក់ហើយ...អូនទៅនៅជាមួយម៉ាក់មីងដែលជាប្អូនបង្កើតរបស់ម៉ាក់...អូនជឿថាបើអូនទៅនៅជាមួយម៉ាក់មីង ម៉ាក់នឹងមិនចោទប្រកាន់ថា អូនរត់តាមប្រុសទេ ហើយក៏គ្មាននរណានិន្ទាកេរអូនដែរ..." ។

ឮសំដីថាវី ខ្ញុំបានត្រឹមតែរំជួល...រំជួលចិត្តឥតអ្វីមកសាងសង់ស្នេហ៍យើងអោយបានសំរេច...ស្នេហ៍យើងបានត្រឹមតែទ្រេតទ្រោតនៅក្នុងលំហអាកាស...ឱ ! ស្នេហ៍កម្ម ឬស្នេហ៍ជ័យ ! ។ ស្នេហ៍កម្មឬស្នេហ៍ជ័យស្ថិតនៅចិត្តគំនិតរបស់ម្តាយនាង។ ខ្ញុំសំរេចចិត្តបង្វែបបបួរមាត់ថា :" ថាវីអូន ! បងយល់តាមគំនិតអូន ! ព្រោះបងជឿអូន ! បងជឿថាអូនធ្វើនេះ គឺដើម្បីស្នេហ៍យើង! បងសុំពោលពាក្យដដែលថា បងរង់ចាំអូនជានិច្ច! រង់ចាំរហូតសក់ស្កូវក៏បងព្រមដែរ "។

ថាវីបែកចេញពីខ្ញុំទៅ ខ្លួនខ្ញុំស្រាលខ្ញើក ខ្ញុំញញឹមដោយពុំដឹងខ្លួន សើចដោយពុំដឹងខ្លួន ហើយខ្ញុំពុំដឹងថាជើងរបស់ខ្ញុំនាំខ្ញុំទៅណាផង!។

មិនអីទេ ជីវិតខ្ញុំនៅល្អនៅឡើយ...ខ្ញុំឈ្ងោកមុខ ខ្ញុំដេកឱប ខ្ញុំដេកកើយអ្នកប្រាជ្ញអស់ រយៈពេល៧ថ្ងៃ៧យប់ ។ អីយ៉ា ! ពេញមួយអាទិត្យនេះ អ្នកប្រាជ្ញណាក៏ស្រលាញ់រាប់អានខ្ញុំដែរ អ្នកប្រាជ្ញណាក៏មានចិត្តអត់ធ្មត់ មិនចេះខឹងសម្បារទោះបីខ្ញុំដេកកើយគាត់ ឬលើកគាត់បោះទៅលើក្តារក្រាល ឬរីគាត់បោះចេញពីទូ ក៏គាត់នៅតែញញឹមដាក់ខ្ញុំ ហៅខ្ញុំអោយចូលទៅជិតគាត់ទៀត ។ ថ្ងៃមួយខ្ញុំរអ៊ូស្រែកអោយគាត់ថា :" អ្នកប្រាជ្ញអស់នេះ គ្មានមួយណាជួយដោះទុក្ខស្នេហ៍របស់ខ្ញុំសោះ ...ហ៊ឺ! ខ្ញុំត្រូវតែរស់នៅជាមួយអស់លោកទៀត....ចាំមើល៍ តើអស់លោកណាមួយអាចជួយរំដោះស្នេហ៍ខ្ញុំឱ្យបានជោគជ័យ!...គ្មាន! គ្មានសោះ ។ ៧ថ្ងៃនៃការរុករក គឺសូន្យឈឹង ។ ហាក់ស្វាងអារម្មណ៍បន្តិច ខ្ញុំយល់ថា យី! ៧ថ្ងៃនេះម៉េចក៏គ្មាន

នរណាទូរស័ព្ទមករកខ្ញុំសោះអញ្ចឹង ។ ខ្ញុំហាក់នឹកឃើញអ្វីមួយ ខ្ញុំក៏ម្នីម្នាទៅយកទូរស័ព្ទមកមើល គឺខ្ញុំបានចុចបិទទូរស័ព្ទ ហើយទូរស័ព្ទក៏អស់ថ្មដែរ ខ្ញុំយកវាដាក់បញ្ចូលភ្លើង។ មួយស្របក់ស្រាប់តែឮរោទិ៍ ។ និពន្ធនាយកទស្សនាវដ្ដីបានសួរខ្ញុំថា : " អាឡូ! លោកនៅឯណា ? លោកឈឺឬក៏ជាប់រវល់អ្វី ? គេរាល់គ្នា បារម្ភពីសុខភាពលោកណាស់ណាំ! ម៉េចក៏លោកមិនឱ្យគេដឹងអ្វីសោះអញ្ចឹង ? " ។ ខ្ញុំម្នីម្នាឆ្លើយថា: " អូ!សូស្ដី សុំទោស! សុំ ទោស! ដោយសារខ្ញុំរវល់ជួបនឹងអ្នកប្រាជ្ញច្រើនពេក ទើបខ្ញុំភ្លេចទូរស័ព្ទទៅប្រាប់..." ។ ខ្ញុំឮសំលេងគេនិយាយគ្នាតិចៗថា : " យី! យើងរាប់ទៅរកគាត់មើល៍...គាត់មានបញ្ហាអ្វីធ្ងន់ធ្ងរទេដឹង? "។ខ្ញុំឮសំឡេងអ្នកនិយាយទូរស័ព្ទជាមួយខ្ញុំសួរបញ្ជាក់ខ្ញុំថា : " អាឡូ ឥឡូវលោកនៅឯណា ? ខ្ញុំមានការចង់ជួបលោកបន្តិច ? " ។ ខ្ញុំឆ្លើយទៅវិញថា: " ខ្ញុំនៅឯផ្ទះខ្ញុំ..." ។ សម្លេងពីចុងម្ខាងឆ្លើយកាត់ : " បាទ! បាទ! ខ្ញុំទៅរកលោកឥឡូវហើយ! សុំលា " ។

15 នាទីក្រោយមក មនុស្ស 4នាក់ចុះពីលើម៉ូតូពីរគ្រឿងរត់ចូលមកក្នុងផ្ទះខ្ញុំហាក់ដូចជាមនុស្សចំឡែករត់រកវត្ថុអ្វីមួយ។ និពន្ធនាយកទស្សនាវដ្ដីឃើញខ្ញុំភ្លាម ក៏ស្រែកថា : " យី! លោកមិនមានរឿងអ្វីទេឬ?តើអ្នកប្រាជ្ញដែលជួបលោកជានរណាខ្លះទៅ ? " ។ ខ្ញុំលើកដៃចង្អុលបង្ហាញថា : " គឺអស់លោកទាំងនេះណា ទោះបីខ្ញុំដាក់គាត់ ឱ្យដេក ឱ្យឈរ ឱ្យអង្គុយត្រមាត់ត្រមូវ ក៏គាត់មិនប្រកាន់ខ្ញុំដែរ..." ។ មិត្តម្នាក់ឧទានឡើង: " អឺ! អឺ! ឯងនេះចំជាចំឡែកមែន! ខ្ញុំទើបនឹងដឹងថា ឯងជាប់រវល់ជាមួយសៀវភៅទាំងនេះតើ! " ។ និពន្ធនាយកតឿន :" ល្ហើយ! ខ្ញុំជឿលោកហើយ! តោះទៅសំអាតខ្លួនទៅ! យើងទៅញ៉ាំបាយជុំគ្នា " ។ មិត្តម្នាក់ឆ្លើយថា :" ទៅ! ទៅ! ឯងស្គមជាងមុនច្រើនណាស់ណាំ! ទៅញ៉ាំបាយជុំគ្នាឱ្យសប្បាយចិត្តទៅ " ។ ដើម្បីមិត្តភាព ខ្ញុំក៏សំរេចចិត្តទៅបាយជុំគ្នា ។

ស្អែកឡើង មិត្តភ័ក្តិជាច្រើនទូរស័ព្ទមកសួរខ្ញុំ : " ឯងនៅឯណាហ្នឹង ? ម៉េចឯងមិនមកធ្វើការ ? " ។ ខ្ញុំឆ្លើយទៅវិញថា :" អូ! អូ! សុំទោស! ខ្ញុំមានកំហុសភ្លេចប្រាប់និពន្ធនាយក ខ្ញុំពុំបាននៅផ្ទះឯភ្នំពេញទេ ខ្ញុំរើប្រដាប់ប្រដារទៅនៅខែត្រហើយ ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំកាត់ផ្ដាច់ទូរស័ព្ទរបស់ខ្ញុំទៀត ។ ខ្ញុំក្លាយខ្លួនទៅជាកសិករនៅខែត្រកំពង់ស្ពឺ ។ ខ្ញុំចាប់ផ្ដើមសួរអ្នកប្រាជ្ញដែលខ្ញុំដឹកជញ្ជូនគាត់យកមកទុកនៅផ្ទះថ្មីមផ្ទះ និងសៀតតាមសរសៈជញ្ជាំងផ្ទះ ។

បីខែ! បីខែដែលខ្ញុំបំភ្លេចថាវី ទើបតែថ្ងៃនេះខ្ញុំទូរស័ព្ទទៅរកនាង :" អាឡូ! សួស្ដីថាវី! ថាវីមែនទេ? " ។ សំលេងឆ្លើយពីចុងខ្សែយំ ហ៊ុះ!ហ៊ុះ! :" បង! បងនៅទីណា?ម៉េចក៏បងផ្ដាច់ទូរស័ព្ទ ?តើបងខឹងអូនឬ ? តើអូនខុសអី ? ហ៊ុះ!ហ៊ុះ! តើអូនខុសអី ?...បងស្អប់អូនហើយមែនទេ ?..." ។ ខ្ញុំឆ្លើយទៅនាងជាបន្ទាន់ថា : "ទេ! ទេ! មិនមែនអញ្ចឹងទេអូន! គឺបងនៅតែស្រលាញ់អូនជានិច្ចហើយស្រលាញ់តែអូនម្នាក់ប៉ុណ្ណោះ! " ។ ខ្ញុំដកដង្ហើមសំរួលអារម្មណ៍ទើបបន្តថា :" ថាវីអូន!បងបានស្ងប់អារម្មណ៍ហើយ គឺបងបានក្លាយទៅជាកសិករគំរូម្នាក់ បងបានដឹកនាំកសិករ ឱ្យចេះធ្វើស្រែតាមប្រព័ន្ធថ្មី... ឱ្យប្រជាកសិករ ធ្វើស្រែដោយចេះប្រើជីធម្មជាតិ និងជីវគីមី កសិករចេះធ្វើស្រែប្រាំងដោយចេះជីកប្រឡាយ និងបាចទឹកបញ្ចូលស្រែ ។ឥឡូវ កសិករចេះទាំងបណ្ដុះផ្សាំដាំកូនដំណាំផ្សេងៗគ្រប់ប្រភេទ អាចនាំយកទៅលក់នៅទីផ្សារ មានថវិកាចំណូលបន្តិចបន្តួច... តែ!...តែបងមិនឱ្យថាវីមកធ្វើកសិករទេណាំ ! ថាវីត្រូវរៀនបន្ត រៀនយកអនុបណ្ឌិត និងបណ្ឌិតឱ្យបាន ...បងធានាចិញ្ចឹមអូន ដោយអង្ករក្រអូប និងផ្លែឈើបន្តិចបន្តួចជាប្រចាំ... តែអ្វីដែលអូនត្រូវចុះកិច្ចសន្យាជាមួយបងនោះ គឺបង

មិនឱ្យអូនស្គាល់កន្លែងអភិវឌ្ឍរបស់បងទេ!...ម៉េច ? ព្រមទេអូន ?" ។ ថាវីឆ្លើយទាំងគក់ក្រហល់ :" ទេ! ទេ! អូនមិនព្រមទេ មិនព្រមចុះកិច្ចសន្យាបែបនោះទេ ! " ។ ខ្ញុំឆ្លើយកំបុតកំបុយទៅនាងវិញថា :" ល្មើយ! ទេមិនទេគង់តែដឹងទេ!..." ។

តាំងពីថ្ងៃនោះមក ខ្ញុំកាត់ផ្តាច់ទូរស័ព្ទពីនាងទៀត ។ តែជារៀងរាល់ខែ ខ្ញុំតែងផ្តល់ឱ្យនាងជាអាថ៌កំបាំងនូវអង្ករក្រអូបមួយតៅ និងដូងមួយឡូ-ស្វាយទុំ ឬផ្លែឈើ ផ្សេងៗជាប្រចាំ ។ ប៉ុន្តែខ្ញុំមិនឆ្លើយឆ្លងតាមទូរស័ព្ទ ឬសូម្បីតែកូនលិខិតតូចមួយក៏ខ្ញុំមិនដែលដាក់តាមអង្ករក្រអូបផង ។

ខ្ញុំដឹង ! ខ្ញុំដឹងថា ថាវីច្រួលច្របល់......ច្រួលច្របល់ដោយរកខ្ញុំពុំឃើញ ។ខ្ញុំតែងស្រមៃឃើញជារឿយៗថា ថាវីដើររកខ្ញុំ....ថាវីទៅកន្លែងអង្គការដែលខ្ញុំធ្វើការ......ថាវីដើរសួរមិត្តភ័ក្តិខ្ញុំគ្រប់ច្រកល្ហក...។

អំពីការងាររបស់ខ្ញុំនៅឯអង្គការក្រៅរដ្ឋាភិបាល ខ្ញុំនៅតែសរសេរអត្ថបទជាប្រចាំដដែល តែខ្ញុំដាក់ឈ្មោះផ្សេងជាក់ខែត្រផ្សេងដើម្បីកុំអោយគេទៅរកខ្ញុំឃើញ ។ ជាពិសេសអត្ថបទរបស់ខ្ញុំ ខ្ញុំពឹងគេឱ្យចម្លងដើម្បីកុំអោយមិត្តភក្តិខ្ញុំស្គាល់អក្សរខ្ញុំ ។

បីឆ្នាំកន្លងផុតទៅ ថាវីប្រលងជាប់បរិញ្ញាប័ត្រទស្សនវិជ្ជា ។ នៅថ្ងៃទទួលបរិញ្ញាប័ត្រ មានខ្ញុំទៅចូលរួមដែរ តែខ្ញុំលាក់មុខមិនអោយនាងឃើញ ។ នៅពេលចប់ពិធី ខ្ញុំក៏បានទូរស័ព្ទសុំជួបនាង ។ យើងទាំងពីរបានធ្វើដំណើរសាសងគ្នាតាមម៉ូតូ រួចទៅសំរាកសំណេះសំណាលអំពីទិសដៅស្នេហានាអនាគតនៅក្រោមដើមឈើកណ្តាលស្រែខាងលិចពោធិ៍ចិនតុង ។ ហ៊ឺ!..ពិបាកវ៉ាយវ៉ាប់ណាស់ បើស្នេហ៍យើងមានតែទឹកភ្នែក..មានតែក្តីរំជើបរំជួលនៅលើទឹកមុខនិងនៅក្នុងគ្រាប់ភ្នែក.. ។

ពុទ្ធោអើយ! ស្នេហ៍បរាជ័យរបស់យើង ពីរឆ្នាំក្រោយទើបជួបគ្នាបានម្តងទៀត គឺជួបគ្នានៅពេលថាវីទទួលសញ្ញាប័ត្រអនុបណ្ឌិត ។ ពេលនេះក៏ដូចជាពីមុនដែរ គឺយើងរង់ចាំស្នេហ៍ជារៀងរហូត ទោះបីដល់ចាស់ជរា ក៏ស្នេហ៍យើងស្ថិតនៅលើវិថីតែមួយ.....វិថីស្នេហ៍ដ៏រឹងមាំ ឥតមានរង្គោះរង្គើឡើយ ទោះបីមេឃរលំ ភ្នំរលាយ ផែនដីក្លាយជាសមុទ្រ ក៏ស្នេហ៍យើងនៅតែមានស្ថេរភាពជានិច្ច ។ ពិតមែនតែការរង់ចាំស្នេហ៍ប្រើពេលយូរ អាយុរបស់យើងហាក់ដូចជាចាស់បន្តិច ប៉ុន្តែព្រលឹងស្នេហ៍របស់យើងនៅខ្ចី ហើយមានសម្រស់ជានិច្ច...។ គិតមកដល់ថ្ងៃនេះ ស្នេហ៍យើងកសាងគ្រឹះបាន៨ឆ្នាំមកហើយជាគ្រឹះមួយដ៏រឹងមាំដែលព្យុះព្យោមាររបស់ម្តាយនាងបក់មកក៏ពុំប្រេះស្រាំដែរ ។ ជារៀងរាល់ឆ្នាំ ម្តាយថាវីតែងតែនាំ ឯកឧត្តមនេះ ឯកឧត្តមនោះមកស្តីដណ្តឹងនាង មកនាំនាងទៅធ្វើទេសចរណ៍នៅបណ្តាប្រទេសនានា លើសកលលោកទៀតផង ។ តែជាលទ្ធផល គឺឯកឧត្តមទាំងនោះ បានត្រឹមតែបាក់មុខបាក់មាត់ ឆ្លើយនឹងសំនួររបស់នាងមិនរួច....ព្រោះនាងមិនត្រូវការលុយកាក់របស់អស់លោក មិនត្រូវការ មុខមាត់បុណ្យសក្តិរបស់អស់លោក មិនត្រូវការកាយវិការជាអភិជនភាពរបស់អស់លោក......។

ពីរឆ្នាំកន្លងផុតទៀត ក្រៅពីជំនាញខាងកសិកម្ម ខ្ញុំបានទទួលជំនាញខាងបកប្រែភាសាអង់គ្លេសនិងជំនាញសរសេរភាសាអង់គ្លេស ។ ខ្ញុំបានធ្វើទំនាក់ទំនងជាមួយស្ថានទូតជាង ១០ នៅក្រុងភ្នំពេញអំពីបញ្ហាកសិកម្មស្រុកខ្មែរ ជាពិសេសខ្ញុំហាក់មានអំណោយទានជាមួយជប៉ុនអំពីការធ្វើធារាសាស្ត្រនៅខេត្តកំពង់ស្ពឺ ។ ខ្ញុំបានសុំឱ្យខាងជប៉ុនធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតធារាសាស្ត្រនៅខេត្តកំពង់ស្ពឺ ។ ក្រោយការសិក្សាអស់រយៈពេលពីរឆ្នាំជប៉ុនក៏ឱ្យខ្ញុំទៅធ្វើកម្មសិក្សា២ឆ្នាំ

នៅប្រទេសជប៉ុនទៀត អំពីបញ្ហាសាងសង់ធារាសាស្ត្រនេះ ។ គិតទៅនៅឆ្នាំទី៥ ទើបជប៉ុនបានលើកជាផែនការ៨ឆ្នាំក្នុងការសាងសង់ធារាសាស្ត្រនៅខែត្រកំពង់ស្ពឺ ដោយមានខ្ញុំជាប្រធានខាងខ្មែរសហការណ៍ ជាមួយប្រធានខាងជប៉ុន។

ក្នុងការជួយឧបត្ថម្ភ ជាជំនួយឥតចំណង ជប៉ុនបានចំណាយថវិកា៨ឆ្នាំ សំរាប់ជួយកសិករនៅខែត្រកំពង់ស្ពឺ និងខែត្រ តាកែវ គឺនៅក្រោយពេលកសិករច្រូតកាត់រួច ប្រជាកសិករត្រូវចំណាយកម្លាំងពលកម្ម វាយបំបែកថ្មជាដុំតូចៗនៅក្រោយពេលដែលគ្រឿងយន្តរាប់សិបគ្រឿងបុកទំលុះគាស់កកាយជើងភ្នំឱរ៉ាល់អស់មួយចំហៀងភ្នំដើម្បីធ្វើទំនប់ទប់ទឹក ។ អាងទឹកដ៏ធំសម្បើមនេះត្រូវចំណាយពេលអស់៨ឆ្នាំ ។ ថវិកាដែលជាអំណោយសប្បុរសរបស់ប្រជាជនជប៉ុនបានផ្តល់ជាអង្ករ ត្រី សាច់ បន្លែ ផ្លែឈើ និងគ្រឿងប្រើប្រាស់ដទៃទៀតជាច្រើនមុខ ។

សម័យនេះជាសម័យវិទ្យាសាស្ត្រ ដូច្នេះការធ្វើអាងទឹកបែបនេះ គេចំណាយពេលតែមួយឆ្នាំក៏គ្រប់គ្រាន់ណាស់ទៅហើយ ។ តែនេះកើតចេញពីទឹកចិត្តរបស់ប្រជាកសិករខែត្រកំពង់ស្ពឺ និងខែត្រតាកែវដោយមានរូបខ្ញុំជាអ្នកសំរបសំរួលបាន ពាំនាំយកគំនិតរបស់ប្រជាកសិករខ្មែរ ទៅជួបពិភាក្សាជាមួយប្រជាកសិករជប៉ុន ធ្វើគំរោងស្នើសុំពីទឹកចិត្តសប្បុរសរបស់ប្រជាកសិករជប៉ុន ពុំមែនជាថវិការបស់រាជរដ្ឋាភិបាលជប៉ុនឡើយ ។

៨ឆ្នាំ! ៨ឆ្នាំពោរពេញដោយការព្យាយាម ការអត់ធ្មត់របស់ប្រជាកសិករខ្មែរ ។ ៨ឆ្នាំពោរពេញដោយមោទនៈដែលកើតចេញពី "បាតដៃស្អាបនា" បានធ្វើឱ្យអាងទឹកដ៏ធំនៅជើងភ្នំឱរ៉ាល់កើតជារូបរាងឡើង ។

ឆ្នាំនេះជាឆ្នាំទី៩ នៅគ្រប់ភូមិដ្ឋាន និងនៅគ្រប់ស្រែទាំងឡាយដែលបានទទួលផលពីអាងទឹកភ្នំឱរ៉ាល់ គេឃើញប្រជាកសិករមានទឹកមុខញញឹមស្រស់ស្រាយទាំងក្មេងទាំងចាស់ ព្រោះជីវិតគេបានរួចចាកផុតពីគិរិតជីវភាពនៃ "បន្ទាត់ក្រីក្រ" ។ ដោយមានការជួយសហការណ៍ពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ក្នុងការកាត់បន្ថយភាពក្រីក្រ តាមផែនការរបស់រាជរដ្ឋាភិបាល ។ ថ្ងៃនេះប្រមុខរាជរដ្ឋាភិបាលបានចូលរួមធ្វើជាប្រធានគណៈអធិបតី ក្នុងការសម្ពោធជាផ្លូវការ ឱ្យប្រើប្រាស់អាងទឹកភ្នំឱរ៉ាល់ ។ នៅក្នុងពិធីដ៏មហោឡារិកនេះ គេសង្កេតឃើញមានស្ថានទូតជាង ១០ នៅប្រទេសកម្ពុជាបានអញ្ជើញចូលរួម ។

ដោយឡែកម្តាយឪពុកថាវី និងថាវីក៏បានអញ្ជើញចូលរួមក្នុងពិធីនេះដែរ ។ ខ្ញុំចេះតែឆ្ងល់ថាហេតុអ្វីបានជាគ្រួសារថាវី អញ្ជើញមកចូលរួមក្នុងពិធីសម្ពោធអាងទឹកភ្នំឱរ៉ាល់នេះ ។

នៅពេលឃើញថាវី បេះដូងខ្ញុំសែនរំជួល...។ ដោយសារការងារច្រើនពេក ខ្ញុំគ្មានពេលសួរនាំនាងឡើយ ហើយខ្ញុំក៏ពុំទាន់បើកទូរស័ព្ទខ្ញុំនៅឡើយដែរ ។ ខ្ញុំជឿថានៅពេលថាវី ឮបទសុន្ទរកថារបស់ប្រមុខរាជរដ្ឋាភិបាល លើកសរសើរ អំពីទឹកចិត្តជាកសិកររបស់ខ្ញុំ ដែលចំណាយពេល១២ឆ្នាំដើម្បីចូលរួមក្នុងការ[illegible]ធ្វើឱ្យសំរេចនូវទំនប់ទឹកដ៏ធំនេះបេះដូងនាងប្រាកដជារំជើបរំជួលជាងខ្ញុំទៅទៀត ។ ខ្ញុំបានតាមដាននាង ឃើញភ្នែកនាងតែងងាកតាមមើលខ្ញុំជាប់ជានិច្ច..ឯម្តាយឪពុកនាងក៏មានទឹកមុខស្រស់ស្រាយជាប់ជានិច្ចដែរ ។

ក្រោយពិធីត្រូវរំសាយ ខ្ញុំក៏ទូរស័ព្ទទៅរកនាង...សំឡេងតក់ក្រហល់...សំឡេងដង្ហក់ដង្ហោយហៅរបស់នាង បានអង្រួនដួងចិត្តខ្ញុំឱ្យដង្ហក់ដង្ហោយហៅនាងវិញដែរ !.. តែ ! តែអ្វីដែលនៅអល់ឯកនោះគឺខ្ញុំហាក់ពុំទាន់ចង់ទៅជួប ម្តាយថាវី ព្រោះខ្ញុំនៅពុំទាន់ជឿថា ម្តាយនាងព្រមឱ្យយើងទាំងពីររៀបការឡើយ...។ ខ្ញុំគេចមុខទៅបាំងនឹងដើមឈើធំៗ លបលួច

មើលថាវីនិងឃើញទាំងម្ដាយឪពុកនាងទៀតផង ។សំលេងពីចុងទូរស័ព្ទម្ខាងស្រែកអង្វរញាប់រន្ថើនៈ "បង!អាណិតអូនផង! អូនប្រេះទ្រូងស្លាប់ឥឡូវហើយ! អូនឃើញបងតាំងពីព្រឹក អូនចង់តែជួបបង...អូនចង់ប្រាប់បងថា ស្នេហ៍យើងបានជោគជ័យហើយ ម្ដេចឡើយពេលនេះបងនៅតែគេចមុខអូន ! បង ! មេត្តាអូនផង !...តើបងដាច់ចិត្តឱ្យអូនស្លាប់ដោយមិនបានរៀបការឬ?... បងឆ្លើយមក! ឆ្លើយមក! បងនៅទីណា?...បង្ហាញមុខភ្លាមមក!..." ។

ទ្រូងសែនរំភើប! សែនសប្បាយ! សែនរីករាយ! ខ្ញុំដើរចេញពីទីកំបាំងបណ្ដើរឆ្លើយទៅរកនាងបណ្ដើរៈ " ថាវីអូន! បងនៅទីនេះ! បងយល់ហើយ! បងជឿហើយ! បងយល់តាំងពីព្រឹកមិញដែលឃើញម៉ាក់អូនមានទឹកមុខញញឹម...បងជឿ! បងដឹង ! បងដឹងថាទឹកចិត្តគាត់ត្រូវស្រុតចុះដោយទឹកចិត្តរបស់យើងទាំងពីរដែលព្យាយាមអត់ធ្មត់ជារៀងរហូត..." ។ខ្ញុំនិយាយពុំទាន់ចប់ស្រួលបួលផង ស្រាប់តែឃើញថាវីរត់យ៉ាងលឿនតំរង់មករកខ្ញុំ ខ្ញុំម្នីម្នារត់ត្របាញ់ជើងទៅរកនាងដោយខ្លាចនាងរត់លឿនពេកបណ្ដាលឱ្យដួល...។ ពេលថាវីមកដល់ស្រាប់តែនាងឱបខ្ញុំ តែពេលនេះនាងពុំមានទឹកភ្នែកទេ ខ្ញុំក៏ឱបនាងវិញ។ នាងងើបមុខមើលខ្ញុំដោយកែវភ្នែកស្រទន់ភ្លឺថ្លាពោរពេញដោយទឹកដមស្នេហ៍...។

ខ្ញុំងាកទៅម្ខាងស្រែកប្រាប់ថាវី :" នោះប៉ាម៉ាក់មកហើយ...អូស ! សុំទោស អ្នកមីងនិងលោកពូមកហើយ ! " ។

ខ្ញុំដើរតម្រង់ទៅរកគាត់ទាំងពីរ រួចលើកដៃសំពះ " សុំជំរាបសួរអ្នកមីង លោកពូ!...អឺ!អឺ!..." ខ្ញុំអៀនពេកក៏នៅស្ងៀមព្រោះចិត្តខ្ញុំហាក់នៅតែគិតថា តើកសិករដូចរូបខ្ញុំនេះ គាត់ព្រមឱ្យខ្ញុំហៅគាត់ថាម៉ាក់ដែរឬ ?.." ។

ព្រម! ពិតជាព្រម! ព្រោះតែព្រមហើយទើបគាត់មកចូលរួមក្នុងពិធីសម្ពោធអាងទឹកដ៏ធំនេះ...។ ហើយព្រោះតែព្រមនេះដែរ ទើបខ្ញុំមានកូនអាយុ 7ឆ្នាំដើរកំសាន្តនៅលើទំនប់ទឹកនេះ!...។

**ចប់**

# រឿងខ្លី និពន្ធដោយអ្នកស្រី ពាន់ ត្នួងបុប្ផា

(ចម្លងឡើងវិញជាឧបសម្ព័ន្ធទី៤ក្នុងសៀវភៅនេះ)

## ឱព្រហ្មចារីយ៍

តាំងពីថ្ងៃដែលខ្ញុំបានជួបគេលើកដំបូង ខ្សែភ្នែកដ៏មុតមានស្នេហ៍របស់គេបានធ្វើអោយចិត្តខ្ញុំជ្រួលច្របល់ញាប់ញ័រខុសពីធម្មតា។ គេមានមាឌធំបង្គួរសម្បុរសដូចកូនកាត់តែភ្នែកគេមានត្របកពីរជាន់យ៉ាងច្បាស់ហើយវែងបញ្ជាក់ថា គេមានឈាមជ័រជាខ្មែរ រួមទាំងទម្រង់មុខថ្កាមខ្លា មានរិទ្ធិរបស់គេ។ គេជាមនុស្សមិនសូវនិយាយស្ដី មានបុក មានអំណាច ដែលសូម្បីតែមនុស្សនៅជុំវិញគេជាមនុស្សចាស់ជាងក្ដី ក៏គោរពហៅគេបងសឹងគ្រប់គ្នាដែរ។ គេមានឈ្មោះថា រ៉ា ស៊ី បងស្រីម្នាក់ដែលជិតដិតនឹងខ្ញុំបានលួចខ្សឹបប្រាប់ខ្ញុំថា គេជាអ្នកមានថ្មី វ័យក្មេងម្នាក់នៅទីក្រុងភ្នំពេញនេះ គេមានទាំងប្រាក់ មានទាំងអំណាចហើយបរិវារនៅជុំវិញខ្លួនគេ ជានិច្ចជាកាលមិនតិចជាង ៥ នាក់ឡើយនេះមិនគិតពីអង្គរក្សអ្នកតាមការពារសន្តិសុខអោយគេផង។

អាលីន ពួកម៉ាកជិតដិតរបស់ខ្ញុំបានប្រាប់ខ្ញុំថា គេចាប់អារម្មណ៍ចំពោះខ្ញុំ តាំងពីថ្ងៃដែលខ្ញុំទៅជប់លៀងឡើងផ្ទះរបស់វាម្ល៉េះ។ វាថា ពេលនោះខ្ញុំមិនចាប់ភ្លឹកពីគេទេព្រោះគេមិនចុះពីលើឡាន គ្រាន់តែអោយបរិវារគេចុះយកកាដូអោយអាលីន ដែលឈរទទួលភ្ញៀវនៅមុខផ្ទះ ហើយខ្ញុំពេលនោះក៏ឈរនៅក្បែរអាលីនដែរ បានជាគេឃើញខ្ញុំ និងសួរពីខ្ញុំតាមរយៈអាលីន។ ថ្ងៃនេះខ្ញុំ

បានជួបផ្ទាល់ជាមួយគេ ដោយសារការរៀបចំរបស់អាលីន និងបងវណ្ណា ត្បិតបងវណ្ណាគាត់មានសង្សារជាបរិវារម្នាក់របស់ លោក រ៉ា ស៊ី ដ៏សង្ហារនោះ។

ពីមុនខ្ញុំមិនជឿគេនិយាយទេ ថាលោក រ៉ាស៊ី មានសច្ចភាពជាមនុស្សនឹងធឹងចាស់ទុំកាលីបលើ ថ្ងៃនេះខ្ញុំឃើញថា ពិតជាមិនខុសមែន ព្រោះនៅជុំវិញខ្លួនគេសុទ្ធជាវ័យកណ្តាល និងចំណាស់ មានតែគេម្នាក់គត់ដែលមានអាយុ ២៨ ឆ្នាំ តែឫកពារសំដីសំដៅហាក់ខ្ពស់ដាច់ពីគេ។

គេមិនដែលផឹកស្រាអ្វីក្រៅពី Hennessy ឬ Johny ទេ ហើយជុំវិញខ្លួនគេក៏មានមនុស្សជិតដិតមិនតិចជាង១០ នាក់ដែរ គេចាយមួយយប់រាប់រយដុល្លារទៅដល់ទីណាបានការកោតញញើតដល់នោះ។ ភាពទាំងអស់នោះហើយបានស្រូបទាញរូបខ្ញុំអោយធ្លាក់ក្នុងសភាពមួយរកថាមិនត្រូវ ព្រោះសំដីរបស់អាលីន បងវណ្ណា ពិសេសស្នាមញញឹមរបស់គេ កែវភ្នែកមុតស្រួចហាក់ទម្លុះដួងចិត្តខ្ញុំអោយធ្លុះទាំងដុំៗ។ ខ្ញុំជឿហើយថារូបរាងមុខមាត់ភាពខ្ពង់ខ្ពស់របស់គេហាក់មានអំណាចគ្របដណ្តប់លើរូបខ្ញុំយ៉ាងពិតប្រាកដ។ យប់នោះខ្ញុំគេងមិនលក់សោះព្រោះរង្វង់មុខគេហាក់នៅក្បែរខ្ញុំបង្អើយ ភាពសោះអង្អើយរបស់គេកាន់តែធ្វើអោយចិត្តខ្ញុំកាន់តែគិតពីគេចង់នៅក្បែរគេ ចង់និយាយរកគេ និងចង់សួរគេថា តើពេលគេកំពុងគិតអ្វី នេះក៏ដោយសារតែភាពអាថ៌កំបាំងរបស់គេនោះ។ បងវណ្ណានិយាយថា គេកម្រនឹងចាប់អារម្មណ៍ចំពោះនារីណាណាស់បើដើរលេងយប់វិញ គេមិនដែលត្រូវការស្រីបារ ឬ ស្រីខារ៉ាអូខេអង្គុយកំដរ

គេទាល់តែសោះ គេចូលចិត្តតែអង្គុយសញ្ជប់សញ្ជឹង ឡើងរាំតែជាមួយអ្នកថ្លៃថ្នូររួមដំណើរម្តងម្កាល ឬច្រៀងខារ៉ាអូខេមួយបទពីរបទលេងអីចឹងទៅ។

លុះត្រាតែនារីស្រស់ស្អាតថ្លៃថ្នូរ ឬមានកេរ្តិ៍ឈ្មោះក្នុងសង្គមទើបអាចអង្រួនបេះដូងគេអោយរញ្ជួយបាន ដូចជាពេលដែលគេបានជួបខ្ញុំនេះជាឧទាហរណ៍ បងវណ្ណា នៅនិយាយច្រើនទៀតអំពីភាពមានបានរបស់ក្រុមគ្រួសារគេ ហើយនេះចំណុចមួយទៀតដែលបងវណ្ណាតែងនិយាយ ច្រំដែលៗថា គេមានចិត្តទូលាយណាស់ បើខ្ញុំចង់បានអ្វីអោយសុំគេទៅគេមិនកំណាញ់ទេសព្វបើសំពត់អាវក្នុងហាងថ្លៃៗ នាឡិការ៉ាដូកាត់កញ្ចក់ ឬអ្វីៗប្រហាក់ប្រហែលនេះ។ តែពុទ្ធោអើយ ខ្ញុំឯណាទៅគិតពីរឿងទ្រព្យរបស់យ៉ាងដូច្នេះនោះពោះគ្រួសារខ្ញុំជាអ្នកលក់ដូរបង្គួរដែរ ឪពុកម្តាយខ្ញុំគាត់តែងតែទំយើ និងតំរូវចិត្តមិនហ៊ានឱ្យទាស់។ ក្រោយពីខ្ញុំប្រឡងជាប់ឌីប្លូម ធ្លាក់កៅអី ពុកខ្ញុំមិនហ៊ានអោយខ្ញុំទៅរៀនបំពេញវិជ្ជាយប់ទេ ព្រោះខ្លាចថ្លោះធ្លោយ គាត់បានទិញតូបសំពត់អាវមួយអោយខ្ញុំលក់នៅក្នុងផ្សារថ្មី។ នៅទីនោះហើយដែលខ្ញុំបានស្គាល់ អា លីន និងបងវណ្ណា ព្រោះយើងលក់តូបនៅជិតគ្នា។

ពេលអាលីនឈប់លក់ទៅធ្វើការអោយក្រុមហ៊ុន ឯកជនមួយនោះ វាក៏បបួលខ្ញុំ ហើយខ្ញុំក៏រំអុកពុកម៉ែខ្ញុំ ថាចង់ធ្វើការវិញ វាជឿនលឿនជាង បានរៀនគួរអង់គ្លេសអីខ្លះផង។ ពុកម៉ែខ្ញុំក៏តាមខ្ញុំដោយសេងតូបនោះអោយម្តាយមីងខ្ញុំលក់វិញទៅ។

ប៉ុន្មានអាទិត្យនេះ អា លីន និងបងវណ្ណា ឧស្សាហ៍បបួលខ្ញុំដើរលេង ណាស់ ហើយនៅអាទិត្យចុងក្រោយនេះដែលខ្ញុំបានជួបនឹងគេ។ និយាយតាម ត្រង់ ថ្វីបើខ្ញុំមានកំពស់ រាងអន់បន្តិចមែន (១, ៥៨ ម.) តែខ្ញុំមានសាច់ស ម៉ដ្ឋរលោង និងរង្វង់មុខពងក្រពើ ក្រហមព្រឿងរបស់ខ្ញុំតែងទាក់ទាញអោយ បុរស១ជាច្រើនសម្លឹងមើលមិនដាក់ភ្នែក ខ្លះទៀតសុំស្នេហ៍តាមផ្លូវ ខ្លះចូលដល់ ឪពុកម្តាយតែខ្ញុំមើលមិនចូលភ្នែកទេ។

ដោយឡែកចំពោះរូបគេ លោក វ៉ា ស៊ី វាផ្សេងចាប់ពីថ្ងៃដែលបានជួប គ្នាម្តងនោះ ថ្វីបើគេមិនបាននិយាយស្តីអ្វីច្រើនជាមួយខ្ញុំ ក្រៅពីសួរគួរសមពីរបី ម៉ាត់ក៏ដោយ តែក្រសែភ្នែករបស់គេធ្វើអោយខ្ញុំមានអារម្មណ៍ថា ខ្ញុំស្គាល់គេ តាំងពីយូរយ៉ាងជិតស្និទ្ធទៀតផង។

ចាប់ពីថ្ងៃនោះមក អា លីន ឧស្សាហ៍មករកខ្ញុំណាស់ ហើយជួបម្តង១ វាតែងតែនិយាយពីគេថាគេសរសើរខ្ញុំអីចេះអីចុះ បងវណ្ណាក៏អីចឹងដែរអោយ អារម្មណ៍ខ្ញុំជ្រួលជ្រើមរាល់ថ្ងៃរហូតដល់ពេលមួយនោះខ្ញុំដូចជាមានអារម្មណ៍ ថានឹកគេ...។ ទេ !មិនកើតទេ ខ្ញុំជាស្រី ហេតុអីក៏ចិត្តងាយយ៉ាងដូច្នោះ ខ្ញុំប្រឹង តាំងចិត្តអោយរឹងប៉ឹងហើយប្តេជ្ញាថា ឈប់គិតពីគេ។

ស្រាប់តែថ្ងៃមួយថ្ងៃបន្ទាប់ និងថ្ងៃក្រោយ១មកទៀត រាល់ពេលខ្ញុំ ចេញពីធ្វើការ ខ្ញុំសង្កេតឃើញរថយន្តមួយបិទកញ្ចក់ខ្មៅ គឺរថយន្តមែសីដែស ពណ៌ប្រផេះរបស់គេចតនៅស្ងៀម ឯជ្រុងផ្លូវម្ខាង។ បេះដូងខ្ញុំលោតឌឹប១

គ្រាន់តែឃើញរថយន្តរបស់គេ ព្រោះខ្ញុំទទួលអារម្មណ៍ថាគេនៅអង្គុយក្នុងនោះ ហើយកំពុងសម្លឹងមក។

ជង្គង់ខ្ញុំទាំងពីរដូចជារលុងខ្មៅ ដំណើរខ្ញុំស្រាលដូចចង់ហោះ ទំរាំតែដើរផុតបត់ទៅម្ខាង បេះដូងខ្ញុំលោតរន្ថើនចង់រកកល់នឹងតាំងពេលនោះខ្ញុំហាក់ធូរក្នុងខ្លួនខ្សាកតែក៏ដូចជាល្ហល្ហេវក្នុងចិត្តដោយបាត់បង់អ្វីម្យ៉ាង។

មិនយូរប៉ុន្មាន អាលីនបាននិយាយអោយដឹងថា គេស្រឡាញ់ខ្ញុំ គេនឹកខ្ញុំ គេលួចមើលខ្ញុំរាល់ថ្ងៃ ស្តាប់ឮដូច្នោះព្រលឹងខ្ញុំស្រាលស្ទើរ ហោះហើរទៅកាន់លំហរដ៏ធំធេងលែងម្ចាស់ការលើខ្លួនឯងបាន មាត់ខ្ញុំប្រកែកថា អីចេះអីចុះ តែក្នុងចិត្តអាណិតគេឡើងផ្សារក្នុងទ្រូង...អាលីននិយាយទៀតថា បានៈប៉ុនគេមិនងាយចុះចាញ់ស្រីដោយងាយរហូតដល់វង្វេងបាយវង្វេងទឹកដូច្នោះទេ គឺទើបតែរូបខ្ញុំនេះឯងដែលធ្វើអោយគេក្លាយជាមនុស្សផ្សេងខុសពីមុន។

ក្រោយមកយើងជួបគ្នាប៉ុន្មានដងទៀត តែពេលណាក៏មានអ្នករួមដំណើរច្រើនគ្នាដែលមិនតិចជាង១០នាក់ឡើយ ដូច្នោះយើងគ្មានពេលសាសងគ្នាដូចដែលខ្ញុំប៉ងប្រាថ្នាចង់នៅក្បែរគេស្តាប់សំដីគេតែពីរនាក់ស្ងាត់ៗនោះទេ។ ខ្ញុំចង់ស្តាប់សំដីគេដោយផ្ទាល់ តើគេយល់យ៉ាងណាចំពោះខ្ញុំ ខ្ញុំមានបញ្ហាជាច្រើនចង់សួរគេ តែបរិវារគេវាច្រើនលើសលុបរហូតដល់យើងបានត្រឹមតែសម្លឹងគ្នាហើយនិយាយរកគ្នានូវសំដីធម្មតាៗប៉ុណ្ណោះ។

ចរិតនឹងធឹងខ្ពស់ខ្ពស់របស់គេ សភាពបុរសរបស់គេ បានធ្វើអោយខ្ញុំ

គិតថា បើទៅថ្ងៃអនាគតខ្ញុំជាភរិយារបស់គេនោះ គឺជាសំណាងមួយដ៏ធំព្រោះថា គេមិនធ្វើឫកម្រៀលៗដូចប្រុសខ្លះឃើញស្រីៗដូចឆ្មាឃើញសាច់ជ្រូកយ៉ាងដូច្នោះ តែនេះគេអោយតំលៃខ្ញុំណាស់ គេអោយ អាលីន និងបងវណ្ណាមើលសួរចិត្តខ្ញុំចង់ញ៉ាំអី គេអនុញ្ញាតអោយទាំងអស់។

ត្រូវនឹងអាលីន ព្រមទាំងបងវណ្ណាចេះតែសរសើរសំណាងខ្ញុំញឹកញាប់ធ្វើអោយចិត្តខ្ញុំបាក់ផ្តោតទៅលើគេទាំងស្រុង ទាំងយើងមិនទាន់បាននិយាយអ្វីចំពោះគ្នាបន្តិចសោះ។

...រួចថ្ងៃនោះក៏មកដល់ អាលីន បានប្រាប់ថា លោក រ៉ា ស៊ីបបួលវាបងវណ្ណា សង្សារគាត់ព្រមទាំងមនុស្សជាច្រើនទៀតទៅលេងអង្គរវត្ត វាថាលោករ៉ាស៊ីបបួលខ្ញុំដែរ បើព្រមទៅគេច្បាស់ជាសប្បាយចិត្តខ្លាំងណាស់។ អាលីន វាបន្ថែមទៀតថា " តាមពិតគេចង់បបួលឯងផ្ទាល់ តែគេមិនហ៊ានខ្លាចឯងប្រកែកគេខ្មាស់ស្លាប់ហើយ ម្យ៉ាងទៀតបើទៅឆ្ងាយទៅគ្នាតិចស្ងាត់ៗក៏គេមិនអាចព្រោះកុំអោយថាគេមើលងាយ ឬ មានបំណងអាក្រក់..." ចិត្តខ្ញុំចង់ទៅណាស់ គេពិតជាសុភាពបុរសដ៏អស្ចារ្យនាទសវត្សនេះ គេចេះយល់ដឹងពីហេតុការណ៍ សមមិនសមគ្រប់យ៉ាង...តែខ្ញុំមិនអាចទៅបានដោយសារតែខ្ញុំមិនអាចទៅឆ្ងាយដោយគ្មានការអនុញ្ញាតពីឪពុកម្តាយពិសេសទៅរបៀបនោះច្បាស់ជាពុកម៉ែខ្ញុំគាត់មិនអោយទៅទេ។

ខ្ញុំនិយាយប្រាប់អាលីន ពីការគិតរបស់ខ្ញុំ អាលីនឆ្លើយឡើងមិនបញ្ចោ

ទេ ចាំវាទៅសួរយោបល់លោកវ៉ាស៊ី តើអាចជួយដោះស្រាយយ៉ាងណា។ មិនបានមួយម៉ោងផងក៏លទ្ធផលឆ្លើយតបបានមកដល់ ដោយអាលីនប្រាប់ថាកុំព្រួយ វាមានមធ្យោបាយហើយអោយតែខ្ញុំចាំឆ្លើយសំរបទៅបានហើយ។

លុះចនោះលោកម្នាក់ដែលជាបរិវាររបស់លោកវ៉ាស៊ី ក្នុងសំលៀកបំពាក់យ៉ាងស្អាតចងក្រវ៉ាត់ក បានដើរតួជាប្រធានក្រុមហ៊ុនរបស់ខ្ញុំ ទៅដល់ផ្ទះខ្ញុំជាមួយអាលីន សុំជួបឪពុកម្តាយខ្ញុំដោយសុំការអនុញ្ញាតអោយខ្ញុំបានទៅលេងអង្គរតាមការរៀបចំរបស់ក្រុមហ៊ុន ដែលផ្តល់ការលើកទឹកចិត្តអោយបុគ្គលិក ទាំងអស់ទៅសំរាកនៅខេត្តសៀមរាបចំនួនបីថ្ងៃ។ អាលីនបានបញ្ជាក់ថាវាព្រមទាំងបុគ្គលិកនារីជាច្រើននាក់ទៀតក៏រួមដំណើរ។

ឃើញរឹរយរបស់លោកសារ៉ាយ ព្រមទាំងស្តាប់សំដីសំដៅយ៉ាងត្រឹមត្រូវ មានការចេះដឹង ពុកម៉ែខ្ញុំក៏ជឿភ្លាមដោយបានហៅខ្ញុំមកប្រាប់ ពីបំណងល្អរបស់លោកប្រធានក្រុមហ៊ុន។ ពុកម៉ែខ្ញុំនិយាយថា ខ្ញុំសំណាងហើយបានដើរលេងសៀមរាប ដោយមិនបាច់អស់សោហ៊ុយ ធ្វើដំណើរស៊ីចាយ។ ខ្ញុំបានសន្យាថាខ្ញុំនឹងយកប្រាក់ខែខ្ញុំនៅបំណាច់ឆ្នាំជូនពួកគាត់ជាសោហ៊ុយទៅលេងសៀមរាបមើលអង្គរម្តង។

ទៅដល់សៀមរាបយើងនាំគ្នាស្នាក់នៅសណ្ឋាគារមួយយ៉ាងធំល្បីឈ្មោះមានការរៀបចំបំរើ យ៉ាងម៉ត់ចត់។ ខ្ញុំមិនបានជួបមុខលោកវ៉ាស៊ីទេ ព្រោះយើងជិះយន្តហោះមកដើងខុសគ្នា។ មកដល់សណ្ឋាគារខ្ញុំក៏មិនបានជួប

គាត់ដែរ បងវណ្ណាប្រាប់ថា លោករ៉ាស៊ីមានការច្រើនអំពីរឿងដីធ្លីដែលគាត់បានទិញទុកនៅសៀមរាប ហើយឮថាជើងនេះគាត់មកទិញបន្ថែមម្ដែសាមសិបហិកតាទៀត។ ខ្ញុំដើរលេងនៅអង្គរតូចសម្លឹងមើលក្បាច់រចនារបស់អង្គរយ៉ាងល្អប្រណិត ដែលពីមុនខ្ញុំធ្លាប់តែឃើញក្នុងរូបថត ឬទូរទស្សន៍។ ទោះយ៉ាងនេះក្ដី ក៏ភ្នែកខ្ញុំនៅតែរេរករូបគេហើយចេះតែគិតថា បើគេបានមកមើលជាមួយរៀបរាប់ពីសារតានៃរូបចម្លាក់នានា លើជញ្ជាំងថ្មនេះ មិនដឹងជាមានអត្ថន័យយ៉ាងណាទេ។ ចិត្តអន្ទះអន្ទែងរបស់ខ្ញុំធ្វើអោយខ្ញុំហាត់គយួររួចដកដង្ហើមធំដោយមិនដឹងខ្លួន។

ពេលល្ងាចនោះទៀតខ្ញុំនៅតែមិនឃើញស្រមោលរបស់គេទៀត ទោះបីបរិវាររបស់គេមិនមានបាត់មុខម្នាក់ក៏ដោយ។ ខ្ញុំគិតថាគេពិតជា ចំតួអង្គជាប្រុសក្នុងរឿងព្រេងនិទាន គេស្រឡាញ់ខ្ញុំតែគេមិនមកក្រឡឹងក្រវែលខ្ញុំដូចប្រុសដទៃទេ នោះហើយដែលធ្វើអោយខ្ញុំមានចិត្តគោរពនឹងលើកតំកើងគេយ៉ាងខ្ពស់ក្នុងដួងចិត្ត។

ម៉ោងប្រាំពីរយប់នោះទើបគេបង្ហាញមុខក្នុងសំលៀកបំពាក់សាមញ្ញថ្លៃថ្នូរតែបើតាមអាលីនខ្សឹបប្រាប់ខ្ញុំថាមួយកំប្លេនេះមិនតិចជាង២០០ដុល្លារទេ។ មែនសាច់ក្រណាត់ថ្លៃពិតជាស្អាតមែន សមនឹងរង្វង់មុខស្រស់ស្រាយញញឹមញញៀមទៀត ខ្ញុំបានលេបត្របាក់យករូបគេទៅទុកក្នុងប្រអប់បេះដូងដោយក្ដីរំភើបឥតឧបមា។ គេសើចញញឹមរកខ្ញុំ ហើយរៀបឱ្យខ្ញុំអង្គុយជិតគេ គេសួរ

នាំពីដំណើរទស្សនកិច្ចរបស់យើង និងជាញឹកញាប់គេចាប់ម្ហូបដាក់ក្នុងចានរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំជាទេពធីតាក្នុងរាត្រីនោះ ។

ក្រោយពេលបាយ យើងនាំគ្នាអង្គុយស្តាប់ភ្លេងនៅជាន់ក្រោមសណ្ឋាគារ គេសួរនាំខ្សឹបៗដាក់ត្រចៀកខ្ញុំ សួរពីអារម្មណ៍ខ្ញុំ និងមិនភ្លេចលើកកែវស្រាហ៊ិនណេស៊ីជល់កែវយ៉ាងខ្សៀវខ្សាជាមួយអ្នករួមដំណើរ ។

នោះជាលើកទីមួយដែលខ្ញុំញ៉ាំស្រាយ៉ាងច្រើនដោយសារគួរសមផងដោយក្តីរំភើបសប្បាយចិត្ត ព្រោះគេទាំងឡាយបានទុករូបខ្ញុំជាតួឯកស្រី ជាមួយ នឹងលោក វ៉ាស៊ី ជាតួឯកប្រុស ។ ម្នាក់ៗយកចិត្តថ្លើមខ្ញុំជល់កែវជាមួយខ្ញុំរហូតដល់ខ្ញុំធឹងធោងរកកល់ដួលគេបានហៅអាលីន អោយគ្រាហ៍ខ្ញុំចូលបន្ទប់ខ្ញុំប្រកែកចង់នៅទៀត តែគេលួងលោមខ្ញុំ អោយទៅសំរាកទៅ ក្រែងហត់នឿយក្នុងការធ្វើដំណើរពីល្ងាច ។

នៅក្នុងបន្ទប់អ្វូតែលក្រោមពន្លឺភ្លើងស្រទន់ព្រាលៗ ខ្ញុំមានអារម្មណ៍លិចអណ្តែតៗមួយសន្ទុះខ្ញុំឃើញគេដើរចូលមករកខ្ញុំស្ទាបថ្ងាសសួរសុខទុក្ខខ្ញុំ... ខ្ញុំខំប្រឹងឆ្លើយតបជាមួយគេ ក្លិនដ៏ក្រអូបនៃទឹកអប់ដ៏ថ្លៃរបស់គេ បានធ្វើអោយខ្ញុំហាក់លង់ទៅឋានសុបិន្តមួយ...។ ពេលដៃរបស់គេមកត្រកងខ្ញុំ ស្បែកខ្ញុំស្រៀវស្រើប អារម្មណ៍ខ្ញុំមានភាពកក់ក្តៅរហូតដល់ដៃទាំងពីរក្រសោបខ្លួនដ៏មាំរបស់គេដោយម្ចាស់ការលែងបាន...។ ពេលនោះខ្ញុំភ្លេចអ្វីៗទាំងអស់ ខ្ញុំគ្រាន់តែដឹងថា អ្វីដែលខ្ញុំត្រូវការបានគេឆ្លើយតបយ៉ាងស្រទន់...។

ព្រះអាទិត្យនៃថ្ងៃថ្មីបានរះឡើង ខ្ញុំដឹងខ្លួនភ្ញាក់ក្រញោង ខ្លួនទទេស្អាត របស់ខ្ញុំនៅគ្រលំក្នុងភួយ ខ្ញុំនឹកឡើងវិញនូវអ្វីៗដែលកើតឡើងពីយប់មិញ... មិនមែនជាការយល់សប្តិទេ ពីយប់មិញបងរ៉ាស៊ីពិតជានៅជាមួយខ្ញុំ... ក្លិនគេហាក់នៅជាប់នឹងនាសាថ្មីៗនៅឡើយ ខ្ញុំចង់យំបន្តិច សើចបន្តិច ខ្ញុំយំព្រោះខ្ញុំស្តាយព្រហ្មចារីយ៍ដែលខ្ញុំខំថែរក្សាមកជិត២០ឆ្នាំ នេះដោយប្រុងប្រយ័ត្ន និងអោយតំលៃជាទីបំផុត... ខ្ញុំលួចញញឹមព្រោះគេបានក្លាយជារបស់ខ្ញុំហើយ ពីថ្ងៃនេះទៅ ខ្ញុំជារបស់គេហើយគេជារបស់ខ្ញុំ ។

ខ្ញុំហាក់ស្រមៃឃើញកែវភ្នែករាប់សិបគូសម្លឹងមករកខ្ញុំពេលដែលយើងទាំងពីរបណ្តើរដោយក្តីច្រណែន និងនិន្ទា មិនអោយរំជើបរំជួលចិត្តម៉េចបានបើទីតាំងនេះកន្លងមកមាននារីជាច្រើនប៉ងប្រាថ្នារាប់ទាំងតារាភាពយន្តល្បីៗឈ្មោះផងនោះ...

ស្នូរគោះទ្វារបន្ទប់... ខ្ញុំគិតច្បាស់ថាជារូបគេ គេនឹងចូលមកគេនឹងលួងលោមចិត្តខ្ញុំកុំអោយគិត កុំអោយព្រួយ គេនឹងអរគុណខ្ញុំ ដែលបានរក្សាភាពក្រមុំទុកអោយគេ... ខ្ញុំលួចញញឹម ទាញរូបដេកមកពាក់រួចស្រែកខ្សាវៗ ...ចូលមក !

ខ្ញុំធ្វើជាគេងបិទភ្នែកទឹកមុខស្លេកស្រពោន ដៃគេដាក់លើស្មាខ្ញុំ បេះដូងខ្ញុំ ចាប់លោតកញ្ជ្រោលមួយសារទៀត តើខ្ញុំត្រូវធ្វើអ្វីហើយនិយាយស្អីអោយសមទៅនំ ...

ក្រោកឡើងភ្លឺហើយនៅគេងដល់ណា ?

ខ្ញុំធ្លាក់ថ្លើមក្តុក ព្រោះនេះជាសម្លេងបងវណ្ណាទេតើ ខ្ញុំស្ទុះក្រោកអង្គុយ បងវណ្ណាសម្លឹងខ្ញុំ ក្នុងខ្សែភ្នែកចម្លែក...ខ្ញុំអៀនខ្លួនយកដៃខ្ទប់ទ្រូង

-សំបុត្រយន្តហោះ ឥវ៉ាន់ សាច់ងៀត សាច់ក្រកអីខ្ញុំទិញរួចអស់ហើយ ថ្ងៃរសៀលយើងឡើងទៅភ្នំពេញវិញ។

-ចុះលោកវ៉ាស៊ី ...

-

គេចេញទៅតាំងពីស្រាង៧ម៉ោងតាមវ៉ុលពិសេស...នេះអោយទុកលុយអោយឯង ៣.០០០ $ឯងយកទៅប្រើការចុះ ចំណែកសំបុត្រយន្តហោះ និងបញ្ញើអ្នកភ្នំពេញ គាត់អោយសង្សារបងចាត់ចែងអោយអស់ហើយកុំខ្វល់...ឥឡូវយើងដើរលេងក្រុងបន្តិចសិនទៅ រង់ចាំបាយថ្ងៃត្រង់ហើយអាលឡើងយន្តហោះ...

ខ្ញុំស្តាប់អ្វីលែងឮទៀតហើយ ព្រោះត្រចៀកខ្ញុំហ៊ឹងអស់ ...ទឹកមុខស្ងប់ស្ងៀមដូចទឹកស្ទឹងគ្មានខ្យល់បក់ ធ្វើអោយខ្ញុំអាចយល់បានពីអ្វី១គ្រប់បែបយ៉ាង ។ប្រៀបដូចជាគេយកទឹកត្រជាក់មកជះកណ្តាលមុខ ខ្ញុំហាក់ក្រោកចេញពីកន្លែងអ័ព្ទដែលរុំខ្លួនខ្ញុំជុំជិត ហាក់រួចពីក្តីស្រមៃដែលខ្ញុំបានលង់លក់មួយរយៈនេះ។

ខ្ញុំគិតរឿងរ៉ាវទាំងអស់ឡើងវិញ .......ការពិតទាំងអស់នោះជាអន្ទាក់ដែលគេបានរៀបចំយ៉ាងស្ទាត់ជំនាញ ខ្ញុំបានចូលស៊ងអន្ទាក់របស់គេដោយខ្លួន

ឯង ។ ប៉ុនប្រសប់មែនបានធ្វើអោយខ្ញុំលក់ក្នុងក្តីស្នេហ៍ដែលគេបានប្រឌិតឡើង ដោយមនុស្សមួយក្រុមនេះឬជាល្បិចព្រានកាលីបលើ ខ្ញុំធ្លាប់គិតថាខ្ញុំជានារីខ្លាំងម្នាក់ តាមពិតគេខ្លាំងជាងខ្ញុំ ព្រោះការចេះដឹងតិចតួចរបស់ខ្ញុំមិនអាចឈ្នះកំលាំងប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់របស់គេបាន ពិសេសល្បិចថ្មីនេះ គេកម្រជួបប្រទះណាស់ ។

តើខ្ញុំត្រូវបន្ទោសអ្នកណា........ពុទ្ធោឱព្រហ្មចារីយ៍ខ្ញុំ ! ( ចប់ )

# កូនក្រក

និពន្ធដោយលោកនូ ហាច
ឆ្នាំ១៩៥៣
កុំព្យូទ័រដោយ ខូ តារាប្ញទ្ធិ

សំលេងមួយនិយាយថា អ្នកជំទប់ឯងប្រាកដជាអាភឿកវាចូលមកមែន?
មែនហើយ អ្នកស្រុកដែលប្រទះនឹងវានិយាយថា ស្គាល់មុខវាជាក់លាក់ណាស់។

សំដីលើកក្រោយ បានចេញពីមាត់ជនម្នាក់ ដែលដើរស្ទុងៗនាំផ្លូវគេ ក៏សាបសូន្យទៅក្នុងផ្ទៃរាត្រី។ គេឮតែសូរជើងគ្រៀបគ្រូបលើស្លឹកឈើងាប់ ហើយយូរៗម្តងមានមាត់ទីទុយ ឬមៀមយំ ធ្វើអោយអ្នកដើរព្រឺឆ្អឹងខ្នង។

ព្រៃអង្គរដែលមានឈើទាលធំ ត្រសុំត្រសាយ ហើយដែលនៅតាមប្រឡោះស្លឹករុក្ខជាតិ មានពន្លឺព្រះចន្ទ្រភ្លឺភ្លែតៗនោះ ក្នុងខណៈនោះ ពួកមនុស្សដេកស្ងាត់ជ្រងំ។

ជនទាំងបីនាក់ ដែលត្រាច់ក្នុងព្រៃទាំងយប់នេះ គឺជាជំទប់មេនាទី និងពួកទាហានក្រុមរក្សាជាតិពីរនាក់ ដើម្បីស្វែងរកចាប់អាភឿកមេចោរ។

អាភឿកនេះកាលពីដើមមានទីលំនៅ នៅអង្គរក្រៅ ដែលជាកូនភូមិតូចមួយ នៅក្បែរពពួកប្រាសាទអង្គរធំ លុះក្រោយដែលមានព្រំប្រទល់ ដែលឧប្បត្តិឡើងដោយកំលាំងគំរាមនៃអនុសញ្ញាក្រុងតូក្យូមក. អាភឿកក៏ភៀសខ្លួននៅពីម្ខាងដែនប្រទេសកម្ពុជាវិញ។ ដោយនៅតំបន់មានតែព្រៃឈើធំស្រោងស្រាង ដែលជាហេតុងាយនឹងគេចបំបាត់ខ្លួនជាបំផុត. អាភឿកក៏តាំងខ្លួនជាចោរ ហើយតែងនាំគូកនវាចូលមកលួចប្លន់សត្វពាហនៈ នៃកូនស្រុក ឃុំនគរធំជាញឹកញយ។ ដូច្នោះហើយនៅសាលាឃុំ សាលាស្រុក មានដីការបង្គាប់អោយនាំខ្លួន និងអោយចាប់ខ្លួនឈ្មោះអាភឿក ក៏ចេះតែគរច្រើនឡើងៗ។

មេឃុំ, ជំទប់, ប៉ូលិស, ទាហាន នាំគ្នាប្រឹងប្រែងស្កាត់ផ្លូវរកចាប់មេចោរនេះ គ្មានឈប់ឈរឡើយ តែមនុស្សទុច្ចរិតនេះ ហាក់ដូចជាទិព្វសោត ដឹងថាមានគេស្កាត់ផ្លូវ ហើយហាក់ដូចជាចេះថ្នឹនភ្នែក គេចខ្លួនបានជានិច្ច។ ម្លោះហើយស្នាដៃអាគៀកក៏សឹងតែពុំរន្ទឺទូទៅទាំងខេត្ត។ ហេតុនេះហើយបានជាកាលដែលអ្នកស្រុកម្នាក់ចូលទៅប្តឹងថា គេបានឃើញអាគៀកចូលមកដេក នៅខ្ទមមួយក្បែរមាត់ព្រៃអង្គរ, អ្នកជំទប់ក៏ស្ទុះហៅទាហាន២នាក់ ដែលគេចាត់មកអោយល្បាតក្នុងនាទីឃុំនគរធំ ម្ដីម្នាទៅរកខ្លួនមេចោនោះភ្លាម។

ភ្នាក់ងារទាំងបីនាក់ ដើរបន្តើដើងក្នុងព្រៃស្រងាត់ ម្រាមដៃរៀងខ្លួនប្រុងចាំតែនៅលើកកាំភ្លើង។ លុះបានដល់ជាយព្រៃហើយ គេក៏ឃើញខ្ទមអ្នកយកជ័រឈើមួយ ដែលមានដំបូលសស្លុង នៅក្រោមពន្លឺព្រះចន្ទ័។ ភ្នាក់ងារទាំងបីនាក់ក៏វារទៅជិតខ្ទមនោះ ទើបឮសូរមនុស្សស្រមុកឃ្លូរគរៗ។ ដូច្នេះហើយជនទាំងបីនាក់ក៏ពង្រាយគ្នាស្កាត់ច្រកផ្លូវ កុំអោយចោរវារត់រួចទៅបាន។

ស្រេចហើយ ទើបជំទប់ស្រែកហៅថា អាគៀក! ចុះមក អញមកដល់ហើយ កុំរឹងទទឹងអីកុំអោយគេធ្វើបាប។

មនុស្សដែលដេកលើកូនខ្ទមភ្ញាក់ស្ទុះអង្គុយឡើង· ហើយសំលឹងទៅត្រង់កន្លែងដែលឮមាត់មនុស្សហៅខ្លួន ក៏ឃើញបំពង់កាំភ្លើងដែលឆ្លុះ ភ្លឺ សៗ ដោយរស្មីលោកខែ។ អាគៀកទាញយកផ្គាក់ដែលនៅជិតខ្លួន វាក្រោកឈរហើយស្រែកថា អាកូនជួយឪផង រួចហើយក៏លោតព្រឹះទៅដី ដៃកាន់សាស្ត្រាងង៖ ប្រុងបៀតបៀនសត្រូវ។

លុះឃើញដូច្នេះហើយ ជំទប់ក៏គាស់កៃកាំភ្លើងស្ទាសង់កាទ័រពុប៉ិកៗ តែមិនឃើញឆេះ។ នៅតែពីរជំហានទៀត អាគៀកមកដល់ខ្លួនហើយ។ ជំទប់ស្ទួនស្ទាំងស្មារតីញ័រខ្លួនចំប្រប់ រកពេលនឹងដកខ្លួនថយក៏ពុំទាន់ ស្រាប់តែនៅវេលាដែលអាគៀកវាលើក

ផ្កាក់នឹងកាប់ ក៏ស្រាប់តែឮសូរកាំភ្លើងពីរបាញ់ស្រុះគ្នា ហើយឃើញខ្លួនអាគៀក ដួលងាប់ខ្យល់មួយរំពេច។

នៅក្នុងចំណោមវត្ថុតាងដែលគេចាប់បាននៅជាមួយសពនោះ គេឃើញមានរបស់ មួយធំរៃក ទំហំប៉ុនមេដៃ ដងខ្លួនរុំដោយសំឡីស នៅសល់តែក្បាល ដែលមានច្រមុះ មុខ មាត់ ភ្នែកដូចមនុស្សសុទ្ធវិស័យ។ នេះហើយដែលគេហៅថាកូនក្រក ដែលពួក មនុស្សសាហាវចូលចិត្តរាប់អានថាខ្លាំងពូកែ ថាឆុតឆាប់បំផុត។

សម្រែកចោរដែលហៅកូនអោយជួយនោះ គឺនិយាយទៅរកកូនក្រកនោះឯង។

លុះឃើញនាងម៉ៅជាប្រពន្ធរបស់ខ្លួនមានផ្ទៃគម្រប់ងខែហើយ អាគៀកចេះតែទទូច និយាយនឹងស្រីនោះថា ឯងអោយកូនមកអញមក។

ស្រីនោះឆ្លើយថា កូនរបស់យើងទាំងអស់គ្នាចាំសុំធ្វើអីទៀត។

ឮដូច្នោះអាគៀកក៏នៅស្ងៀមទៅ។ លុះពីរបីថ្ងៃក្រោយមក អាគៀកក៏សុំដូចខាងលើ នេះទៀត។ នាងម៉ៅជិនត្រចៀកពេក ក៏ឆ្លើយសើចទៅវិញថា យកក៏យកទៅចុះ កូន ផងបងឯងស្រាប់ហើយ។

សំដីនេះធ្វើអោយអាគៀកត្រេកអរឥតឧបមា។ វាក៏លួចទៅសំលៀងកាំបិតចុងស្រួច មួយ ហើយយកមកលាក់នៅត្រង់ដំណេក មិនអោយនាងម៉ៅដឹងខ្លួនប្រាណឡើយ។

មានយប់មួយនៅវេលាដែលស្រីនេះកំពុងតែនិទ្រាដោយសុខសំរាន្ត អាគៀកងោះ ឡើង យកកាំបិតចុងស្រួចចាក់ពោះនាងម៉ៅទាញយកទារក។

លុះព្រឹកឡើង អ្នកជិតខាងឃើញផ្ទះនោះស្ងាត់ពេក ក៏ដើរទៅមើល ឃើញសពនាងម៉ៅស្លាប់ ដោយមានឈាមដេរដាសពាសពេញខ្លួន ហើយនៅជើងគ្រានមានភ្លើងឆេះហុយៗ ព្រមទាំងមានចង្កើរមួយនៅពីលើផង។

ឯរូបអាភឿកវិញ បាត់ឈ្មោះបាត់សម្លេងតាំងពីនោះមក។

អាភឿកមេចោរ អាភឿកដើរសម្លាប់ប្រពន្ធឯង យកទារកក្នុងពោះធ្វើជាកូនក្រក, អាភឿកដែលដេលេគេរកខ្លួនមកជាយូរណាស់ហើយ ឥឡូវអាភឿក ដេកស្លាប់ដូចខ្មោចឆ្កែក្នុងព្រៃធំ ក្នុងរាត្រីស្រងាត់ មានដើមទ្រូងនឹងពោះធ្លុះដោយគ្រាប់កាំភ្លើង មុស្គីតុងទាហាន។ ភ្នែកវិលស្លើតសម្លឹងព្រះចន្ទ ដែលក្នុងមេឃាថ្លាត្រចះ៕

## ឧបសម្ព័ន្ធទី៥ :

### -ការសិក្សាអត្ថបទអក្សរសិល្ប៍ [១] :

១-ផិដ្ឋភាពប្រវត្តិ :

ក-អត្ថបទ :

ក.១-ប្រភព
- -ចំណងជើងរឿង
- -ឯកសារបោះពុម្ពឆ្នាំណា ?
- -ជាតិ ឬ បរទេស

ក.២-ប្រភេទ
- -ជាអក្សរសិល្ប៍ប្រជាប្រិយ
- -ជាអក្សរសិល្ប៍ បុរាណ
- -ជាអក្សរសិល្ប៍ ទំនើប

[១] ការលើកយក គម្រោងសិក្សាអត្ថបទអក្សរសិល្ប៍មកនេះដើម្បីជាពន្លឺខ្លះៗ ដល់មិត្តអ្នកអានឱ្យងាយស្រួលយល់នៅក្នុងការតាក់តែងអក្សរសិល្ប៍ ឬរឿងប្រលោមលោកផ្សេងៗ។ គម្រោងសិក្សាអត្ថបទអក្សរសិល្ប៍នេះ ជាគម្រោងអត្ថបទអក្សរសិល្ប៍ដែលខ្ញុំធ្លាប់បានសិក្សានៅក្នុងឆ្នាំ១៩៨៧ ដូច្នេះអាចនៅមានខ្វះចន្លោះជាក់ជាមិនខាន។ សូមមិត្តអ្នកអានមេត្តាអធ្យាស្រ័យស្រាវជ្រាវបន្ថែមផងចុះ។

-មានលំនាំជា ៖

-រឿងព្រេង

-រឿងប្រឌិត

-រឿងប្រលោមលោក

-ផ្នែកមនោសញ្ចេតនា ៖

-កាប់ដាវ, -ស៊ើបអង្កេត...។

-សរសេរជា ពាក្យ កម្រងកែវ

-ពាក្យកាព្យ បុរាណ, សម័យ

-ពាក្យរាយ

៣-ចលនា និងឥទ្ធិពល ៖

ក-ចលនា និងឥទ្ធិពល ៖

ក.១-ព្រាហ្មនិយម, ពុទ្ធនិយម, ខ្មែរនិយម។

ក.២- សក្តិភូមិ, មូលធន, សង្គមនិយម។

ខ- អ្នកនិពន្ធ ៖

-ឈ្មោះ, -ជីវប្រវត្តិ, -ស្នាដៃ។

គ-កាលកំណត់តែង ៖ ថ្ងៃ, ខែ, ឆ្នាំ និពន្ធរឿង។

ឃ-សង្គមបរិយាកាស ៖

ឃ.១- សង្គមប្រវត្តិ : -របបគ្រប់គ្រង
-វណ្ណៈសង្គម
-វីរជន

ឃ.១- ព្រឹត្តិការណ៍សំខាន់ៗ :

-រឿងរ៉ាវទាក់ទងទៅនឹងបញ្ហាស្រុកទេស និងបញ្ហាសង្គម ។

២-ឱដ្ឋភាពធំនាក់ធំនងរឿង :

ក- សេចក្ដីសង្ខេបរឿង :

បង្រួមបង្រួមអត្ថបទដោយច្បិចយកតែចំណុចណាសំខាន់ៗ ចាំបាច់ ។

ខ- តួអង្គ :

-ប្រាប់ឈ្មោះ, -មុខងារ ។

គ-កាលអាកាស :

គ.១-ទីកន្លែង :ប្រព្រឹត្តិទៅតាមចលនានៃរឿងនីមួយៗ ។ ដោយឡែកចលនាខ្មែរនិយម ទីកន្លែងក្នុងសង្គមមនុស្ស ជាឈ្មោះភូមិស្រុករបស់ខ្មែរ ។

គ.២-ពេលវេលា : ទៅតាមចលនានៃរឿងនីមួយៗដែរ តែចំពោះខ្មែរ និយមមិនកំណត់ទេ ។

## ៣-ផិដ្ឋភាពបញ្ហារឿង : (អត្ថន័យ)

### ក-ប្រធានរឿង :

ប្រធានរឿងគឺជាផ្នែកមួយនៃចិត្តសាស្ត្រសង្គម ដែលឆ្លុះបញ្ចាំងនៅក្នុង ស្នាដៃអក្សរសិល្ប៍។ ឧទាហរណ៍ : រឿងធនញ្ជ័យ ប្រធានរឿងគេនិយាយអំពី បញ្ញា។

### ខ-មូលបញ្ហារឿង :

មូលបញ្ហារឿងគឺជាលទ្ធផលរបស់ប្រធានរឿង។ ឧទាហរណ៍: មូលបញ្ហារឿងនៅក្នុងរឿងធនញ្ជ័យ គឺអ្នកតូចតាចអាចយកជ័យជំនះលើអ្នកធំបាន ឱ្យតែមានបញ្ញា។

### គ-បញ្ហាទំនាស់វិបត្តិ :

គ.១ ទំនាស់វិបត្តិ :

-តួទំនាស់ : ចោទ ក ↔ ខ ស្រាយ

-ទីកន្លែងទំនាស់

ក-ចោទ ←តួទំនាស់→ ខ-ស្រាយ

ហេតុ ↔ ហេតុ

បំណង បំណង

វិធី : សន្តិវិធី, យុត្តិវិធី, ល្បិច, វិធី

សភាពលក្ខណៈ តឹងតែង សភាពលក្ខណៈ

ធូរស្រាល

លទ្ធផល : ចាញ់, ឈ្នះ, លទ្ធផល : ឈ្នះ, ចាញ់

ផលវិបាក : លទ្ធផល បញ្ចប់ទំនាស់។

សំណួរភ្ជាប់ទៅនឹងវិបត្តិទី២ :

យោបល់រួម : ការបញ្ចេញយោបល់របស់យើង ឬ ឧត្តមគតិរឿង ទាញយកពីសុភាសិត ឬ ទាញចេញជាទ្រឹស្តី។ ត្រូវបញ្ចេញយោលបល់រួមមួយ ដែលជាយោបល់ផ្ទាល់ខ្លួន ជាឧត្តមគតិរឿងជាពាក្យស្លោក, ជាសុភាសិត, ជាទស្សនៈដែលស្របទៅនឹងអត្ថបទនៃរឿង។

**ឃ-បញ្ហាវិភាគតួអង្គ** ឱ្យតម្លៃទៅលើតួអង្គនីមួយៗ ដូចជា

ឃ.១-គុណសម្បត្តិ :

ឃ.២-គុណវិត្តិ :

ឃ.៣-វណ្ណៈភាព :

ង- បញ្ហាសង្គម :

ង.១- វប្បធមិ :

-ជំនឿ,-ទំនៀមទំលាប់,-ប្រពៃណី,-សាសនា,-អប់រំសិល្បៈ។

**ខ.២-សេដ្ឋកិច្ច** :

-កសិកម្ម, -ឧស្សាហកម្ម, -ពាណិជ្ជកម្ម, -គមនាគមន៍។

ខ.៣-សង្គមកិច្ច :

-ជីវភាព, -ការងារ, -សុខាភិបាល, -សន្តិសុខ...។

ខ.៤-នយោបាយ :

-ក្នុងប្រទេស, -ក្រៅប្រទេស...។

៣-ទិដ្ឋភាពតំណែងនិពន្ធ : (អត្ថរូប)

ក-បច្ចេករូប :

ក.១- ភេទរូប :

-ជាអក្សរសិល្ប៍បុរាណ ?, ប្រជាប្រិយ ?, ទំនើប ?។

-សរសេរជាពាក្យ រាយ ឬ ពាក្យកាព្យ ?

ក.២- វចនៈរូប :

-មានប្រើពាក្យអ្វីខ្លះ ? បាលី ? សំស្ក្រឹត ? បរទេស ?។

ក.៣- រចនារូប :

របៀបប្រើឃ្លា ពិបាកស្តាប់ ឬ ងាយស្រួលស្តាប់ ?

ខ-និពន្ធរូប :

ខ.១-ផ្តើមរឿង :

ការផ្តើមរឿងទៅតាមចលនានីមួយៗ :

-ចលនាព្រាហ្មនិយម :

គេផ្ដើមសេចក្ដីដោយប្រកាសរំឭកគុណអាទិទេព ដែលជាអ្នកមានគុណជាអ្នកបង្កើតលោក ។

**-ចលនាពុទ្ធនិយម :**

គេផ្ដើមដោយធ្វើបទនមស្សការនឹង គុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ រំឭកគុណគ្រូ គុណមាតាបិតារួចប្រាប់ប្រភពរឿង ។

**-ចលនាខ្មែរនិយម :**

ផ្ដើមដោយពុំឯកភាពគ្នាទេ ពោលគឺគេផ្ដើមទៅតាមចំណង់ចំណូលចិត្ត និងវិធីសាស្ត្រផ្ទាល់របស់អ្នកនិពន្ធម្នាក់ៗ ។

**១.២-តួរឿង :**

-ដំណើររឿងមានបែបផែនប្លែកៗគ្នាទៅតាមល្បិចផ្ទាល់របស់អ្នកនិពន្ធ ដើម្បីទាក់ទាញទឹកចិត្តអ្នកអានអ្នកស្ដាប់ឱ្យចូលចិត្តអ្នកនិពន្ធបានប្រើវិធីផ្សេងៗ មានដូចតទៅ :

-ពិព័ណ៌នាវិធី ជាវិធីដែលអ្នកនិពន្ធបានលើកយកតួអង្គ ឬទេសភាពមក ពិព័ណ៌នារៀបរាប់ឱ្យអ្នកអានឃើញច្បាស់នឹងភ្នែក ។

-វឌ្ឍនមានវិធី ជាវិធីដែលអ្នកនិពន្ធប្រើប្រាស់សម្រាប់រុញច្រានដំណើររឿងឱ្យមានលក្ខណៈកាន់តែតឹងតែងឡើងៗជាលំដាប់រហូតដល់កំពូល ។

-សំវាទវិធី គឺជាការជជែកឆ្លើយឆ្លងគ្នារវាងតួអង្គ២ នាក់។

-ឯកវាទវិធី គឺជាការនិយាយតែម្នាក់ឯងនៃតួអង្គ។

-សន្ទេហវិធី ជាវិធីមួយសម្រាប់ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ ឆ្ងល់ចង់ដឹងនិងតាមដានសកម្មភាពដំណើររឿង។

-ឧបមាណវិធី ជាវិធីប្រៀបប្រដូចពីរបស់មួយទៅរបស់មួយទៀត ឬ រវាងវត្ថុ២ផ្ទឹមគ្នា។

-វិធីបញ្ច្រាស(បដិវិធី)គឺជាវិធីបញ្ច្រាសហេតុទៅនឹងផល។

ហេតុតូចឱ្យផលធំ, ហេតុធំឱ្យផលតូច។

សេចក្ដីបញ្ចប់រឿង :

អ្នកនិពន្ធបញ្ចប់រឿងនីមួយៗ ទៅតាមចលនារបស់រឿង។

ចលនាព្រាហ្មនិយម គេបញ្ចប់ដោយឱ្យ :

តួអង្គឯកដែលជា តំណាងសភាវៈល្អ ឈ្នះតួអង្គតំណាងសភាវៈអាក្រក់។

ចលនាពុទ្ធនិយម អ្នកនិពន្ធបញ្ចប់ដោយឱ្យ :

-តួអង្គឯកបានសម្រេចនូវការកសាងបារមី។

-តួអង្គឯកទាំងពីរជួបជុំគ្នា។

-ការសរជាតិនៃតួអង្គ។

ចលនាខ្មែរនិយម អ្នកនិពន្ធបញ្ចប់ដោយ :

-មានសង្ឃឹមតួអង្គជួបជុំគ្នា ទទួលជ័យជំនះ មានសុភមង្គល

-អស់សង្ឃឹម តួអង្គព្រាត់ប្រាស បែកបាក់ បរាជ័យ ស្លាប់ ។

**៤-ទិដ្ឋភាពតម្លៃ :** (អត្ថរស)

**ក-បច្ចេករស** ជាតម្លៃដែលលេចចេញមកពីបច្ចេកទេសនៃការតែងនិពន្ធស្របទៅតាមប្រភេទអក្សរសិល្ប៍នីមួយៗ ។ បច្ចេករសមាន : កាព្យរស, ប្រលោមរស, ឧបទេសរស ។

**ក.១-កាព្យរស** ជាតម្លៃដែលកវីបានរចនាស្នាដៃរបស់ខ្លួនជាពាក្យកាព្យប្រកបដោយសម្រស់ទឹកដម មានចំណាប់ចុងចួនរណ្តំគ្នា ។

**ក.២-ប្រលោមរស** ជាតម្លៃដែលតែងរឿងប្រលោមលោកបង្កើត ឡើងនូវសេកម្មភាពផ្សេងព្រេង ស្នេហា សញ្ចេតនា សប្បាយ ទុក្ខ...របស់តួអង្គ ។

**ក.៣-ឧបទេសរស** គឺជាតម្លៃអប់រំទូន្មានរិះគន់ទៅលើស្នាដៃអក្សរ សិល្ប៍ ។ ឧទាហរណ៍ ល្បើកកេរ្តិ៍កាលថ្មីរបស់កវី ក្រមង៉ុយ ។

**ខ-វិហារសរស** ជាតម្លៃពិសេសដែលអ្នកនិពន្ធបានបង្កើតឡើងដោយសារការប៉ិនប្រសប់ក្នុងស្នាដៃអក្សរសិល្ប៍ ។ វិហារសរសចែកចេញជា :

-សោភ័ណ, -វិសិដ្ឋរស, -អាក្រក់, -វីរៈរស, -នាដ្យរស, -ទារុណរស, -សម្បើម, -ទស្សនីយរស, -ហាសរស ។

ខ.១-សោភ័ណ ជាតម្លៃល្អគ្មានសល់ធ្វើឱ្យគេកោតសរសើរ មាននៅក្នុងការរៀបរាប់អំពីសម្រស់របស់តួអង្គ, ទីកន្លែង, សភាពធម្មជាតិ ។ល។

ខ.២-អាក្រក់ គឺតម្លៃនេះចេញមកពីការពិព័ណ៌នារូបរាងអាក្រក់របស់តួអង្គ ។

ខ.៣-ទស្សនីយភាព ជាតម្លៃដែលលេចចេញមកពីការរៀបរាប់ទេសភាពធម្មជាតិ ប្រកបដោយអារម្មណ៍ល្អ ។

ខ.៤-វិសិដ្ឋរស ជាតម្លៃដែលលេចចេញមកពីការបំពេញពលិកម្មបណ្ដាច់អស្ចារ្យ ដែលមនុស្សធម្មតាមិនអាចធ្វើបាន ។ ឧទាហរណ៍ការបំពេញទានរបស់ព្រះវេស្សន្តរ ។

ខ.៥-សម្បើមជា តម្លៃដែលលេចចេញមកអំពីការរៀបរាប់រូបរាងមហិទ្ធិឫទ្ធិ សភាពអស្ចារ្យរបស់តួអង្គ ។

ខ.៦-វីរៈរស ជាតម្លៃដែលលេចចេញមកអំពីសភាពអង់អាចក្លាហានរបស់តួអង្គក្នុងការធ្វើពលិកម្មតស៊ូប្រឆាំងនឹងខ្មាំងសត្រូវ ដើម្បីបុព្វហេតុជាតិមាតុភូមិ ប្រយោជន៍សមូហភាព និងមនុស្សជាតិ... ។

ខ.៧-ទារុណរស ជាតម្លៃដែលលេចចេញមកអំពីការកំសត់ព្រាត់ប្រាស់ស្លាប់របស់តួអង្គល្អ ពីសំណាក់តួអង្គអាក្រក់។ ឧទាហរណ៍ ទារុណរស នៅក្នុងរឿងទុំទាវ។

ខ.៨-ហាសរស ជាតម្លៃដែលលេចចេញមកអំពីការរៀបរាប់រាល់សកម្មភាពតួអង្គរូបសត្វ រូបរាងរបស់តួអង្គធ្វើឱ្យអ្នកអាន អ្នកស្ដាប់អស់សំណើចទប់សំណើចមិនបាន។

ខ.៩-នាដ្យរស ជាតម្លៃដែលលេចចេញមកពីការលើកយកបញ្ហាទំនាស់វិបត្តិរបស់តួអង្គ មានកម្លាំងប្រហាក់ប្រហែលគ្នា បរិយាកាសនៃរឿងមាន តឹងតែង ធូរស្រាល មានចាញ់ មានឈ្នះ។

**គ-សព្វរស** ជាតម្លៃទូទៅនៃរឿងដែលកវីនិពន្ធតែងលើកយកមក ប្រើប្រាស់ក្នុងស្នាដៃរបស់ខ្លួន។ សព្វរសចែកចេញជា ៈ

-សង្គមរស, -តថរស, -អច្ឆរិយរស, -អច្ឆរិយផ្សំនឹងលោកកិយសច្ចៈ, -កុសលរស។

គ.១-សង្គមរស ជាតម្លៃលេចចេញមកអំពីការលើកយកបញ្ហាទំនាស់វិបត្តិក្នុងសង្គមមកចោទ និងដោះស្រាយ ហើយដែលជាប់ទាក់ទងទៅនឹងវប្បធម៌ និងសង្គមធម៌។

គ.២ - តថរស ជាតម្លៃដែលបានបង្ហាញអំពីតួអង្គជាក់ស្ដែង

ជាមនុស្សគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈ បង្ហាញសកម្មភាពមនុស្ស បញ្ហាមនុស្សដែលតែងតែមានទំនាស់វិបត្តិ ក្នុងជីវភាពប្រចាំថ្ងៃ ទំនៀមទម្លាប់ ប្រពៃណី សាសនា ចំណង់ចំណូលចិត្តរបស់មនុស្សទីកន្លែងក្នុងលោកិយសច្ចៈ។

គ.៣-អច្ឆរិយរស ជាតម្លៃដែលអ្នកនិពន្ធលើកយកសកម្មភាពអស្ចារ្យរបស់តួអង្គមកបង្ហាញ។ ច្រើនមាននៅក្នុងអក្សរសិល្ប៍ព្រាហ្មនិយម និងអក្សរសិល្ប៍ពុទ្ធនិយម។

គ.៤-អច្ឆរិយផ្សំនឹងលោកិយសច្ចៈ ជាតម្លៃដែលអ្នកនិពន្ធលើកយកភាពអស្ចារ្យផងនិងភាពធម្មតាផង ឬរឿងពិតផង និងរឿងមិនពិតផងមកបង្ហាញ បង្កើតបានជាសោភ័ណភាពមួយនៃរឿង។

គ.៥-កុសលរស ជាតម្លៃដែលឋិតនៅលើការអប់រំទូន្មានប្រៀនប្រដៅមនុស្សឱ្យដើរតាមគន្លងសីលធម៌ល្អ ចេះគោរពសិទ្ធិមនុស្ស ចេះគោរពតាមច្បាប់ពុទ្ធចក្រ និងអាណាចក្រ។

**៥-សន្និដ្ឋានទូទៅ :**

-ប្រៀបធៀបរឿងមួយទៅនឹងស្នាដៃដ៏ទៃទៀតនៃអក្សរសិល្ប៍

-វាយតម្លៃ (រិះគន់, លើកសរសើរ)។

៙៙៚៙៙

ឧបសម្ព័ន្ធទី៦:

៧៤

ក្រុងបាត់ដំបង ថ្ងៃ ៥ ។ ៦ ២ ៣ ស. ២៤៧៦

" ជូនដំណឹងដល់គូជីវិត ,

" ខ្ញុំមានចិត្តមមៃគិតមកបងមិនមានដាច់មួយវេលាឡើយ ។
" ខ្ញុំដេលនៅឯនាយ តែងនឹកថា ពេលថ្មើរនេះសមបងចូល
" រៀន ពេលថ្មើរនោះសមបងនិយាយកំសាន្ត នឹងពួកម៉ាក
" ព្រោះទុក្ខចំបែង ចេះតែងំក្នុងដើមទ្រូង មិនដឹងទៅនិយាយ
" ប្រាប់នរណាឡើយ ។ ពីដើមខ្ញុំមានរំពឹងជាច្រើនទៅលើ
" សៀវភៅ ដែលអាចបន្ធូបន្ថយកង្វល់បានខ្លះ ។ ឥឡូវនេះ
" ចេះតែសបសៅ អានសៀវភៅក៏មិនបានល្ហែក្នុងចិត្តដែរ ។
" ដូច្នេះ ខ្ញុំខំបន់ស្រន់ អស់ទាំងទេវតាឱ្យលោកជួយជ្រោម
" ជ្រែង ឱ្យបងរៀនសូត្របាន ប្រកបដូចសេចក្ដីប្រាថ្នា
" ដោយខ្ញុំសព្វថ្ងៃនៅមានរំពឹងតែលើបងមួយប៉ុណ្ណោះ ។

៧៥

" បង , ខ្ញុំដឹងចិត្តបងថាមានសេចក្ដីស្នេហាដល់អូនជា
" ទីបំផុត ។ ហេតុនេះខ្ញុំសូម កុំឱ្យបងមានតក់ស្លុតនឹងដំណឹង
" ដែលពណ៌នាខាងក្រោមនេះឱ្យសោះ , ឱ្យបងខំប្រុងស្មារតី
" តែខាងរៀនសូត្រទៅចុះ ។ ជនដទៃ មានចេះភ្លេច
" ពាក្យសន្យាខ្លះ ចំណែកខ្ញុំមិនដូច្នោះទេ , ខ្ញុំមានតែពាក្យ
" មួយប៉ុណ្ណោះ មិនចេះប្រែប្រួលឡើយ ។

" បង , ជាច្រើនថ្ងៃមកហើយ ខ្ញុំបានសង្កេតឃើញ
" កិរិយាម្ដាយខ្ញុំប្លែកពីសព្វមួយដង ។ ទឹកមុខគាត់ចេះតែ
" ញញឹមញញែម ហើយថែមទាំងមានវាចាមកកាន់ខ្ញុំថា :
" កូនឯងនេះចំជាមានវាសនាហើយ ! ។ គាត់និយាយតែ
" ប៉ុណ្ណោះ , ខ្ញុំដេញដោល សួរគាត់យ៉ាងណា , គាត់នៅតែ
" ស្ងៀមធ្វើព្រងើយ ។

" ឯយាយដៃរិញ, ដូចបងជ្រាបស្រាប់ហើយ គាត់មាន
" សេចក្ដីស្រឡាញ់បងឯង នឹងខ្ញុំដូចជាបុត្រចេញពីផ្ទៃគាត់
" មិនដឹងថាហេតុដូចម្ដេចឡើយបានជាមុខគាត់ចេះតែស្រពោន

៧៦

" មិនសប្បាយ ។

" កិរិយានឹងទឹកមុខខុសពីគ្នា នៃជនទាំងពីរនាក់ដែល
" មានចិត្តស្រឡាញ់ខ្ញុំដូចគ្នានេះ នាំខ្ញុំគិតអើយសែនគិត !
" ខ្វល់អើយសែនខ្វល់ !
" ស្រាប់តែម្សិលមិញនេះ ឱបងអើយ ! ខ្ញុំទើបនឹង
" ភ្ញាក់ខ្លួន ។

" បងគង់ស្គាល់ថៅកែណៃស៊ានដែលជាអ្នកមានធំមួយ
" នៅក្រុងបាត់ដំបង ។ ប្រពន្ធ ណៃស៊ាននេះឈ្មោះ ថូ ។
" អ្នកទាំងពីរនោះមានកូនកំឡោះមួយ ឈ្មោះណៃស៊ត
" មនុស្សកំឡោះនេះហើយ ដែលម៉ែផែបានប្រាប់ខ្ញុំថាជាអ្នក
" ដែលដេញតាមមើលខ្ញុំ ហើយធ្វើឫកងងុលជ្រើមមកលើខ្ញុំ
" នៅឱកាសដែលខ្ញុំទៅមើលបុណ្យ ព្រះសពលោកគ្រូចៅ
" អធិការ វត្តដំរីសជាមួយនឹងបងប្អូនជិតខាង ។ ឱសែន
" ក្នាញ់ពេក !

" ពីម្សិលមិញនេះ មីងថូគេបរឡានមកបញ្ឈប់នៅមុខ

៧៧

" ផ្ទះ ហើយមានចាស់ទុំ ជាច្រើននាក់លើកផ្លែឈើ , ចំណី
" ចំណុក , សំពត់ , ព្រៃ , ផាមួង , ហួល , ចរបាប់ នឹង
" ខៀនបីក្រឡី ដង្ហែគ្នាឡើងមកលើផ្ទះ ។
" វត្ថុទាំងនេះជាជំនូន យកមកភ្ជាប់ពាក្យដណ្តឹងខ្ញុំ ។ តាមដែល
" ម៉ែផៃគាត់ប្រាប់ខ្ញុំនោះ ម៉ែខ្ញុំនឹងខាងប្រុសបានដាច់ស្រេច
" ថាផ្សំផ្គុំខ្ញុំឱ្យទៅណែស៊ត នៅខែពិសាខខាងមុខនេះហើយ ។

" ឱម៉ែ ! ម៉ែចឃើញតែ ទ្រព្យសម្បត្តិ , ម៉ែចមិន
" មើលលក្ខណៈមនុស្ស, ម៉ែចក៏មិនស្នើចិត្តកូនផង ? បើបាន
" ទុក្ខឬសុខយ៉ាងណា ក៏នៅលើរូបកូនទាំងអស់ទេតើ !

" ណ្ហើយបង ខំរៀនសូត្រចុះ , កុំព្រួយរន្ធត់អ្វី ។
" ទោះយ៉ាងណាក៏ដោយ មុខជាចៅណែស៊តមិនបានជួប
" ប្រសប់នឹងអូនទេក្នុងជាតិនេះ ។

" នៅទីបំផុតនេះ ខ្ញុំសូមឱ្យបងទទួលសេចក្តីរលឹក
" យ៉ាងធ្ងន់របស់ខ្ញុំ ។

" វិធារី "

៧៨

ក្រុងភ្នំពេញ ថ្ងៃ ១៥ យ៉ាំងវិយេរ ១៩៣៣

" តបដំណឹងដល់អូន ,

" អូន , សេចក្ដីស្រឡាញ់របស់បង បណ្ដាលឱ្យ
" បង មិនចង់ឱ្យអូន នាងមានសេចក្ដីព្រួយ ដោយសារបង
" សោះឡើយ ។ បងធ្លាក់ក្រហើយ ។ លុះបងចេញធ្វើការ
" ទៅក៏មិនសង្ឃឹមបានប្រាក់ខែប៉ុន្មានដែរ ។ ហេតុនេះនាង
" កុំមានប្រទូសរាយ ទទឹងចិត្តម្ដាយនាងដូច្នេះឱ្យសោះ
" គាត់ជាមនុស្សចាស់បើគិតធ្វើការអ្វីនិមួយ ៗ សឹងតែមើល
" ដំណើរការនោះបានធ្លុះវែងឆ្ងាយ ។ ចូរនាងព្រមទទួល
" យកគូស្រករ ដែលគាត់ទុកដាក់ឱ្យ កុំប្រកែកឡើយ ។

៧៩

" ណែសិតដល់គេចាស់ដៃ , ចាស់ជើងទៅ មុខជាបានជា
" ពាណិជ្ជមួយ យ៉ាងធំនៅប្រទេសកម្ពុជា ។ ចំណេះគេក៏
" មាន សម្បត្តិគេក៏មាន ដែលជាលក្ខណៈមួយ អាចនាំឱ្យ
" អូនបានសុខសំរាន្តទៅថ្ងៃក្រោយ ។

"កុំអូនប្រកាន់ខឹងនឹងកិរិយាមិនគប្បីនៃកំឡោះនេះ
" ខុសម្តង ឆ្គងម្តង , គួរបំភ្លេចចោលទៅ ។

" ចំណែកបងវិញ បងនៅជាប់ស្រឡាញ់អូនពេញ
" ដូចពីដើម ។ តែសុំឱ្យនាងទុកបងដូចជាបងបង្កើតទៅចុះ ,
" បងក៏ទទួលព្រមដែរ " ។

១៥៤

" បងសំឡាញ់ "

នៅ "ពេលដែលបងបានអានសំបុត្រនេះ ខ្ញុំនឹងចូល
" មរណភាពបាត់រូបទៅហើយ ។

" ឱបងអើយ, ខ្ញុំចាំទន្ទឹងមើលផ្លូវបងពីថ្ងៃមួយទៅថ្ងៃ
" មួយ ។ មុននឹងស្លាប់ មិនបានអ្វីគ្រាន់តែជួបបងមួយភ្លែត
" ក៏សុខចិត្តដែរ ។ តែឥឡូវ, យូរថ្ងៃណាស់ទៅហើយបាត់
" ដំណឹងបងសូន្យឈឹងតែម្ដង ។ ឯរោគសោតក៏ធ្វើឱ្យខ្ញុំ
" ឈឺសព្វអស់អង្គកាយ មិនបានស្រយាលឡើយ ។ ហេតុ
" នេះហើយបានជាខ្ញុំស៊ូព្យាយាម ត្រដរសរសេរ ម្ដងបន្តិច ៗ
" តែងជាសំបុត្រនេះទុកជាសេចក្ដីលារបស់ខ្ញុំ ។ បងអើយ
" អូនលាហើយ ! ធ្វើម្ដេចជាតិនេះកម្មក្រាស់ឈ្នានីសមិនឱ្យ
" ខ្ញុំនឹងបងបានជួបគ្នា ។ តែខ្ញុំសូមចិត្តបងកុំឱ្យកើតទុក្ខនឹងខ្ញុំ
" ច្រើនហួសប្រមាណ ។

១៥៥

" ជំពូកមួយទៀត ខ្ញុំសូមចិត្តបងកុំនឹកប្រកាន់ខឹងនឹង
" អ្នកម្ដាយអូនខ្លាំងពេក ។ ធ្វើម៉េចគាត់ជាមនុស្សចាស់ ,
" គាត់តែងកាន់គំនិតចាស់ ។ គាត់មិនមែនចង់ធ្វើបាបយើង
" ទេ , គាត់គ្រាន់យល់ខុសប៉ុណ្ណឹងតើ ។

" បង,បើបងស្រឡាញ់អូនដោយស្មោះត្រង់ ចូរបង
" ធ្វើតាមបណ្ដាំខ្ញុំនេះកុំខាន ។ ចូរបងត្រឡប់ទៅកាន់វិទ្យា-
" ល័យវិញ ហើយខំរៀនសូត្រឱ្យបានចំណេះខ្ពង់ខ្ពស់ ។
"រួចហើយបងសំឡឹងមើលនារីណាមួយ ដែលអាចនាំសេចក្ដី
" ក្សេមក្សាន្តជូនបងបាន សូមបងដណ្ដឹងយកធ្វើជាភរិយា
" ទៅ ។ ឯចិញ្ចៀនត្បូងទទឹមដែលជាវត្ថុមួយគាប់ចិត្តរបស់
" ខ្ញុំលើសលុបជាងវត្ថុឯទៀត , ខ្ញុំសូមឱ្យបងទុកដាក់ដៃជាទី
" រលឹកផង ខ្ញុំជូនយុវតីនោះតទៅ ...

"បងអើយ, កុំទុក្ខពេក ។ ធ្វើម៉េចវាសនារបស់មនុស្ស
" តែងតែប្រកបដោយសេចក្ដីមិនទៀង ,មិនឋិតថេរដូច្នេះ ។
" អូនសូមលាហើយបង "

( អត្ថបទដកស្រង់ចេញពីរឿង " ផ្កាស្រពោន "របស់អ្នកនិពន្ធ នូ ហាច )

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

Royal Academy of Cambodia

Institute of Humanities and Social Sciences

**លេខ:** *ពិសេស វមវស/លអជ*

**គណៈកម្មការរៀបចំសន្និសីទជាតិ**

**សូមគោរពជូន**

**លោក ជូរ គារី ប្រធានផ្នែក នៃវិទ្យាស្ថានភាសាជាតិ**
**រាជបណ្ឌិត្យសភាកម្ពុជា**

**កម្មវត្ថុ:** គោរពអញ្ជើញចូលរួមក្នុងសន្និសីទជាតិ នាថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០០៦ នៅរាជបណ្ឌិត្យសភាកម្ពុជា។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **លោក** មេត្តាជ្រាបថា វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា នឹងរៀបចំសន្និសីទជាតិស្តីពី ***"កម្ពុជាឆ្ពោះទៅកាន់ទសវត្សរ៍នៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ២០០៥-២០១៤"*** ដោយសហការជាមួយ អង្គការយូណេស្កូ នាថ្ងៃទី **២៦-២៧ ខែកក្កដា ឆ្នាំ២០០៦** នៅរាជបណ្ឌិត្យសភាកម្ពុជា។

អាស្រ័យហេតុនេះ សូម **លោក** មេត្តាចូលរួមក្នុងសន្និសីទជាតិនេះ ដោយសេចក្តីអនុគ្រោះ។

សូម **លោក** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

<u>សូមភ្ជាប់</u> : កម្មវិធីសន្និសីទជាតិ...............១ច្បាប់។

*រាជធានីភ្នំពេញ ថ្ងៃទី២៨..ខែកក្កដា ឆ្នាំ២០០៦*

**ប.គណៈកម្មការរៀបចំសន្និសីទជាតិ**

**ប្រធាន**

បណ្ឌិត.រស់_ចន្ត្រាបុត្រ

<u>សំគាល់</u> : សូមមេត្តាឆ្លើយតបតាមរយៈទូរស័ព្ទ

*០១២ ៩៨៦ ៩៩៦-០១៦ ៨០០ ៥៥៨*

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្សី (ជាប់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល ២ ពោធិចិនតុង) ភ្នំពេញ កម្ពុជា
Russian Federation Blvd, near by Royal Phnom Penh University, Campus II, Pochin Tong, Phnom Penh. Cambodia.
Tel(855)12-364-383, 16-789-309,16-886-610 / Fax (855)23-890-180 / E-mail: ihss_rac@everyday.com.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជបណ្ឌិតសភាកម្ពុជា
វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

Royal Academy of Cambodia
Institute of Humanities and Social Sciences

*លេខ: ពិសេស វ.ម.វ.ស.*

## លិខិតអញ្ជើញ

**សូមគោរពអញ្ជើញ**

**លោក ជួរ គារី**

**ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច អដ្ឋស័ក ពុទ្ធសករាជ ២៥៥០ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃ សៅរ៍ ទី០៨ ខែមេសា ឆ្នាំ ២០០៦ នៅរាជបណ្ឌិតសភាកម្ពុជា ៖**

ដើម្បីប្រារព្ធទិវាចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលនឹងមកដល់នៅពេលខាងមុខនេះ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិតសភាកម្ពុជា បានរៀបចំពិធីអបអរសាទរមួយ ដែលមានកម្មវិធីដូចខាងក្រោម:

- *កម្មវិធីចាប់ផ្តើម:* ម៉ោង៣.០០ រសៀល : សូត្រមន្តនៅវិទ្យាស្ថាន
  ម៉ោង៤.០០ រសៀល : កម្មវិធីល្បែងប្រជាប្រិយ
  ម៉ោង៥.៣០ រសៀល : អាហារសាមគ្គី និងតន្ត្រីកម្សាន្ត
- *កម្មវិធីបញ្ចប់:* ម៉ោង១០.០០ យប់។

អាស្រ័យហេតុនេះ សូមលោកអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសដោយមេត្រីកុំបីអាក់ខានឡើយ ។

សូមលោកទទួលនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

*ភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦*

អនុប្រធាន

បណ្ឌិត **សោម សុមុនី**

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី ពោធិ៍ចិនតុង ភ្នំពេញ. កម្ពុជា
Tel: (855)-12-364-383, 12-856-127, 16-886-610/ Fax: (855)-23-890-180 / E-mail: ihss_rac@everyday.com.kh

" វាចាតែងផុតរលត់ទៅ សំណេរតែងសល់នៅ "

" les paroles s'envolent, les écrits restent"

(សុភាសិតបារាំង)

## ឯកសារពិគ្រោះ

១-នូ ហាច ផ្កាស្រពោន (បោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ នៅ ប៉ារីស, ១៩៨០)។

២-ពៅ សាមី ទ្រឹស្តីអក្សរសិល្ប៍ ជំពូក១-២-៣ ភ្នំពេញ១៩៨៧-១៩៩២- ១៩៩៣។

៣-ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១-២ ភ្នំពេញ ១៩៦៧-១៩៦៨ ។

៤-លាង ហាប់អាន សិក្សាអត្ថបទ(សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) ភ្នំពេញ ១៩៦៦។

៥-លាង ហាប់អាន ព្រះរាជសម្ភារអ្នកនិពន្ធខ្មែរ ភ្នំពេញ១៩៦៦។

៦-វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា វចនានុក្រមអក្ខរាវិរុទ្ធនៃ ភាសាខ្មែរ ភ្នំពេញ ២០០៥ ។

៧-ស្រី ប៊ុនដន (អ្នកបោះពុម្ពឡើងវិញ២០០៦)សារលិខិតគំរូលិខិតគ្រប់បែបយ៉ាង ភ្នំពេញ ១៩៥៧។

៨-ឡេង លីមតុង ការងារការិយាល័យ ភ្នំពេញ ១៩៩៧។

៩-ផ្នែកឧបសម្ព័ន្ធ ៖

-ឧបសម្ព័ន្ធទី១ ៖

- សុន្ទរកថារបស់ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីបើកសន្និសីទជាតិ ស្តីពី ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ នៅរាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី ៧-៩ ខែ កញ្ញា ឆ្នាំ២០០០

- សុន្ទរកថារបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ស្តីទីក្នុងឱកាសបិទសន្និសីទជាតិ ស្តីពី ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍភាសាខ្មែរ នៅរាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី (៩ ខែ កញ្ញា ឆ្នាំ២០០០)

- សុន្ទរកថាស្វាគមន៍របស់សាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន្ទ អនុប្រធានវិទ្យាស្ថានភាសាជាតិ ថ្លែងក្នុងពិធីបើកសន្និសីទជាតិ ស្តីពី ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរលើកទី២ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៥

- សុន្ទរកថា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា នៅក្នុងឱកាសបើកសន្និសីទជាតិ ស្តីពី ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរលើកទី២ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៥

-ឧបសម្ព័ន្ធទី ៥ :

-សិក្សាអត្ថបទអក្សរសិល្ប៍

-ឧបសម្ព័ន្ធទី ៦:

-អត្ថបទដកស្រង់ចេញពីរឿង"ផ្កាស្រពោន"របស់អ្នកនិពន្ធនូហាច

-លិខិតផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ... ប្រឹក្សា...

ខ្ទង់ថ្វាយ គោរពជូន

ឯកឧត្តម ជួរ គារី
ប្រធានវិទ្យាស្ថានភាសាជាតិ

| រាជបណ្ឌិត្យសភាកម្ពុជា | |
| --- | --- |
| ចូល | មកដល់ថ្ងៃទី ៣០/០៥/០៦<br>លេខ ៥០/០៦ មសក<br>ម៉ោង ៨.៣០ |

រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

គណៈកម្មការរៀបចំសន្និសីទជាតិ
លេខ ពិសេស ម.ម.ឧ.ស/២០០៩

# សូមគោរពអញ្ជើញ

លោក ជួរ គារី
ប្រធានផ្នែក នៃវិទ្យាស្ថានភាសាជាតិ

# ប្រលោមលោករបស់អ្នកនិពន្ធ ល្បីៗខាងក្រោមនេះមានចេញផ្សាយហើយពី













ផ្ទះលេខ 143Eo ផ្លូវខេមរភូមិន្ទ ភ្នំពេញ

ISBN: 99950-59-35-5

បណ្ណាគារ អង្គរ